PESTECH




Energising Growth Sustainably

ANNUAL REPORT 2021




# ការបង្កើនថាមពល ប្រកបដោយនិរន្តរភាព

ក្នុងនាមជាក្រុមហ៊ុនឈានមុខគេនៃវិស័យឧស្សាហកម្មនេះ ការផ្តោតសំខាន់លើមនុស្សគឺជាអាទិភាពចម្បងរបស់ក្រុមហ៊ុន។

កំណត់ត្រាជោគជ័យនៃដំណើរការរបស់ក្រុមហ៊ុន គឺដោយសារបុគ្គលិករបស់យើងក៏ដូចជាការផ្តល់ជូននូវសេវាសុវត្ថិភាពសន្តិសុខ ទំនុកចិត្ត និងប្រសិទ្ធភាព ព្រមទាំងការផ្តល់នូវដំណោះស្រាយថាមពលដ៏ឆ្លាតវៃប៉ុន្តែប្រសព្វប្រកបដោយបរិស្ថានបៃតង និងសេដ្ឋកិច្ចស្ថិតស្ថេរ។ ក្រុមហ៊ុនផ្តោតលើឱកាសរីកចម្រើន និងការអនុវត្តដែលជាចាំបាច់មិនភ្លេចនូវការរក្សាការប្តេជ្ញាចិត្តឆ្ពោះទៅរកយុទ្ធសាស្រ្តអភិវឌ្ឍន៍ប្រកបដោយចីរភាព។

ការប្តេជ្ញាចិត្តក្នុងការបម្រើផលប្រយោជន៍សហគមន៍ និងជំនឿជឿជាក់លើចក្ខុវិស័យរបស់ក្រុមហ៊ុន គឺបានទ្រទ្រង់ក្រុមហ៊ុនឱ្យឈរជើងនៅក្នុងទីផ្សារនេះបាន។ ក្រុមហ៊ុនបានយកចិត្តទុកដាក់លើផលប៉ះពាល់នៃការងាររបស់យើងចំពោះបរិស្ថាន និងតុល្យភាពរវាងតម្រូវការអតិថិជន សហគមន៍ដែលក្រុមហ៊ុនកំពុងបម្រើ វិនិយោគិន និងសហការីអាជីវកម្មរបស់ក្រុមហ៊ុន ជាមួយនឹងតម្រូវការក្នុងការផ្តល់ហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីប្រកបដោយនិរន្តរភាព។

www.pestech.com.kh

# មាតិកា





## ០១

### មាតិកា


០៣ ទស្សនវិស័យ និង បេសកកម្ម
០៤ ព័ត៌មានហិរញ្ញវត្ថុសង្ខេប
០៥ ក្រាហ្វិកអំពីព័ត៌មាន ហិរញ្ញវត្ថុសង្ខេប
០៦ សមាសភាពក្រុមប្រឹក្សាភិបាល
០៧ សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាលប្រតិបត្តិ
០៩ សេចក្តីថ្លែងរបស់នាយកប្រតិបត្តិ


## ០២

### ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីលក់មូលបត្រ


១១ អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ
១២ ព្រឹត្តិការណ៍សំខាន់ៗប្រចាំឆ្នាំ
១៦ ស្ថានភាពទីផ្សារ
១៧ ស្ថានភាពប្រកួតប្រជែង
១៧ ផែនការអនាគត
១៨ កត្តាហានិភ័យ


## ០៣

### ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច


២៥ លទ្ធផលនៃប្រតិបត្តិការអាជីវកម្មតាមផ្នែក
២៥ រចនាសម្ព័ន្ធចំណូល


## ០៤

### ព័ត៌មានអំពីអភិបាលកិច្ចសាជីវកម្ម


២៦ អង្គការលេខ
២៧ សមាសភាពក្រុមប្រឹក្សាភិបាល
២៧ លេខាធិការក្រុមហ៊ុន៖


## ០៥

### ព័ត៌មានអំពីការជួញដូរមូលបត្រ និងភាគហ៊ុនិក របស់បុគ្គលចុះបញ្ជីលក់មូលបត្រ


២៨ ព័ត៌មានអំពីមូលបត្រ
២៨ ថ្លៃ និងបរិមាណការជួញដូរមូលបត្រ
២៨ ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់
២៨ ព័ត៌មានអំពីការបែងចែកភាគលាភក្នុងរយៈពល ៣ (បី) ឆ្នាំចុងក្រោយ


## ០៦

### ព័ត៌មានអំពីការជួញដូរមូលបត្រ និងភាគហ៊ុនិក របស់បុគ្គលចុះបញ្ជីលក់មូលបត្រ


២៩ របាយការណ៍សវនកម្មរបស់សវនករផ្ទៃក្នុងលើការត្រួតពិនិត្យផ្ទៃក្នុង


## ០៧

### របាយការណ៍ហិរញ្ញវត្ថុដែលត្រូវបានធ្វើសវនកម្ម ដោយសវនកឯករាជ្យ


៣០ របាយការណ៍សវនកម្មរបស់សវនករផ្ទៃក្នុងលើការត្រួតពិនិត្យផ្ទៃក្នុង


## ០៨

### ព័ត៌មានអំពីប្រតិបត្តិការភាគីដែលពាក់ព័ន្ធ និង ទំនាស់ផលប្រយោជន៍


១០២ ប្រតិបត្តិការសំខាន់ៗជាមួយភាគហ៊ុនិកដែលមានភាគហ៊ុនចាប់ពី ៥% ឡើងទៅ
១០២ ប្រតិបត្តិការសំខាន់ៗជាមួយអភិបាល និង បុគ្គលិកជាន់ខ្ពស់
១០២ ប្រតិបត្តិការជាមួយអភិបាល និងភាគហ៊ុនិកដែលពាក់ព័ន្ធនឹងការទិញ/លក់ទ្រព្យសកម្ម និងសេវាកម្ម
១០២ ប្រតិបត្តិការសំខាន់ៗជាមួយសមាជិកគ្រួសារផ្ទាល់របស់អភិបាល បុគ្គលិកជាន់ខ្ពស់ និងភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនយ៉ាងតិច ៥% ឡើងទៅ
១០២ ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលដែលមានទំនាក់ទំនងជាមួយអភិបាលរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ បុត្រសម្ព័ន្ធ ឬ ក្រុមហ៊ុនហូលឌីងរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ
១០២ ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលធ្លាប់ជាអភិបាល ឬបុគ្គលជាប់ពាក់ព័ន្ធនឹងបុគ្គលធ្លាប់ជាអភិបាល
១០២ ប្រតិបត្តិការសំខាន់ៗជាមួយអភិបាលដែលកាន់មុខតំណែងណាមួយនៅក្នុងសមាគម ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ឬនៅក្នុងក្រុមហ៊ុនណាមួយផ្សេងទៀត ក្រៅពីបុគ្គលចុះបញ្ជីលក់មូលបត្រ
១០២ ប្រតិបត្តិការសំខាន់ៗជាមួយអភិបាលដែលទទួលផលប្រយោជន៍ពីបុគ្គលចុះបញ្ជីលក់មូលបត្រ ទោះជា ហិរញ្ញវត្ថុ ឬមិនមែនហិរញ្ញវត្ថុ។

# មាតិកា





## ០៩

### ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង


១០៣ ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

១០៣ កត្តាសំខាន់ៗដែលជះឥទ្ធិពលលើផលចំណេញ

១០៤ ការប្រែប្រួលសំខាន់ៗនៅក្នុងការលក់ និងប្រាក់ចំណូល

១០៤ ផលប៉ះពាល់នៃអត្រាប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងតម្លៃទំនិញ

១០៤ ផលប៉ះពាល់នៃអតិផរណា

១០៤ គោលនយោបាយសេដ្ឋកិច្ច/សារពើពន្ធ/សាច់ប្រាក់របស់រាជរដ្ឋាភិបាល


## ១០

### ព័ត៌មានដែលចាំបាច់ផ្សេងទៀតសម្រាប់ការការពារវិនិយោគិន (ប្រសិនបើមាន)


១០៦ ហត្ថលេខារបស់អភិបាលក្រុមហ៊ុន

១០៨ ឧបសម្ព័ន្ធ៖ របាយការណ៍ស្តីពីអភិបាលកិច្ចសាជីវកម្មប្រចាំឆ្នាំដែលបានកំណត់ដោយអគ្គនាយកនៃ ន.ម.ក.។




# សេចក្ដីផ្ដើម



## ចក្ខុវិស័យ

### អ្វីដែលយើងចង់បាន

*ភាពបិតថេរប្រកបដោយសង្គតិភាព និងគុណសម្បត្តិបន្ថែម* ក្នុងភាពជាអ្នកស្ថាបនាហេដ្ឋារចនាចម្ព័ន្ធអគ្គិសនីប្រកបដោយចីរភាព

## បេសកកម្ម

### យើងជាអ្នកណា និងអ្វីដែលយើងធ្វើ

**ប្រសិទ្ធិភាព**

ក្នុងការបំពេញភារកិច្ច និងផ្ដល់សេវាកម្មនានាជូនអតិថិជនក្នុង និងក្រៅតំបន់

**ប្រសិទ្ធិផល**

ក្នុងការដឹកនាំការងារ និងសេវាកម្មដើម្បីទទួលបាននូវលទ្ធផលជាអតិបរមាក្នុងរយៈពេលដ៏ខ្លី

**ឧត្តមភាព**

ដែលផ្ដល់ជូនអតិថិជនលើសពីបរិមាណ និងគុណសម្បត្តិបន្ថែមដល់ការវិនិយោគរបស់ពួកគាត់

# ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| បរិយាយ | | ឆ្នាំ២០២១ (លានរៀល) | ឆ្នាំ២០២០ (លានរៀល) | ឆ្នាំ២០១៩ (លានរៀល) |
|---|---|---|---|---|
| **ស្ថានភាពហិរញ្ញវត្ថុ** | | | | |
| ទ្រព្យសកម្មសរុប | | ១ ១៦៦ ៨៨២ | ១ ០១៦ ១១២ | ៨៤២ ២៩០ |
| បំណុលសរុប | | ១ ០៧២ ៩៨៥ | ៩៤៦ ១៥៥ | ៧៨៥ ៦៧៩ |
| មូលធនសរុប | | ៩៣ ८៩៧ | ៦៩ ៩៥៧ | ៥៦ ៦១១ |
| **លទ្ធផលហិរញ្ញវត្ថុ** | | | | |
| ចំណូលសរុប | | ២៧៣ ៦២៨ | ២០៣ ០១៤ | ២៣១ ០៥៨ |
| ចំណេញមុនបង់ពន្ធ | | ១០ ០៨៨ | ៣៧ ៧៧៦ | ៩ ៥២៩ |
| ចំណេញសុទ្ធក្នុងការិយបរិច្ឆេទ | | ៥ ៩៨០ | ២៩ ៤៤៣ | ៧ ២១៨ |
| លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ | | ១១ ៦៦២ | ១៣ ៣២៥ | (១៩៩) |
| **លទ្ធផល** | | | | |
| អនុបាតសាធនភាព | | ២,៤០% | ៧,៤៣% | ០,៦៣% |
| អនុបាតសាធនភាព (កម្ចីទូទៅ) * | | ៤៩,៩៣% | ២០៣,៨៧% | ១៥,១០% |
| អនុបាតបំណុលធៀបនឹងមូលធន | | ១១,៤៣ | ១៣,៥២ | ១៣,៨៨ |
| អនុបាតបំណុលធៀបនឹងមូលធន (មិនរួមបញ្ចូលកម្ចីរយៈពេលវែង * * ) | | ០,២២ | ០,២៤ | ០,៣០ |
| អនុបាតសន្ទនីយភាព | អនុបាតចរន្ត | ០,៩០ | ០,២៨ | ០,៣៣ |
| | អនុបាតចរន្តលឿន | ០,៨៨ | ០,២៤ | ០,៣៣ |
| អនុបាតចំណេញភាព | អនុបាតចំណេញធៀបនឹងទ្រព្យសកម្ម | ០,៥១% | ២,៩០% | ០,៨៦% |
| | អនុបាតចំណេញធៀបនឹងមូលធន | ៦,៣៧% | ៤២,០៩% | ១២,៧៥% |
| | អនុបាតគម្លាតចំណេញភាព | ២,១៩% | ១៤,៥០% | ៣,១២% |
| | អនុបាតគម្លាតចំណេញដុល | ១៦,៣៤% | ៣៨,០២% | ១២,៤២% |
| | ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (រៀល) | ៧៥,៨៦ | ៤១៤,៨៦ | ១០១,៦៦ |
| អនុភាពលទ្ធភាពបង់ការប្រាក់ | | ១,២២ | ២,៣៩ | ១,៦៧ |

*កម្ចីទូទៅរាប់បញ្ចូលឥណទានសម្រាប់ទុនបង្វិល និងឥណទានវិបារូប៍ ដោយមិនរាប់បញ្ចូលលក្ខខណ្ឌកម្ចីរយៈពេលវែង ដែលបានធានាដោយដំណើរការនៃគម្រោងទូទាត់ពន្យាពេល ដែលមានកិច្ចព្រមព្រៀងទូទាត់ដោយផ្ទាល់ជាមួយអគ្គីសនីកម្ពុជា។

* *កម្ចីរយៈពេលវែងសំដៅលើកម្ចីដែលបានធានាដោយដំណើរការនៃគម្រោងទូទាត់ពន្យាពេល ដែលមានកិច្ចព្រមព្រៀងទូទាត់ដោយផ្ទាល់ជាមួយអគ្គីសនីកម្ពុជា។

# ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប

## ការរួមចំណែកនៃចំណូលសរុប និងចំណេញដុលសរុបតាមផ្នែក សម្រាប់ ឆ្នាំ២០២១




## ការរួមចំណែកចំណេញមុនបង់ការប្រាក់ និងពន្ធតាមផ្នែក សម្រាប់ ឆ្នាំ២០២១




## ការប្រមូលតាមផ្នែកសម្រាប់ ឆ្នាំ២០២១



# សមាសភាព ក្រុមប្រឹក្សាភិបាល



Paul
Lim Pay Chuan
ប្រធានក្រុមប្រឹក្សាភិបាល



Lim
Ah Hock
អភិបាល

PESTECH



Han Fatt Juan
អភិបាលប្រតិបត្តិ/
ប្រធាននាយកប្រតិបត្តិ



Charles Tan Pu Hooi
អភិបាល



ដាវ អានសាន
អភិបាលឯករាជ្យ

# សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាលប្រតិបត្តិ



# PAUL LIM PAY CHUAN

ប្រធានក្រុមប្រឹក្សាភិបាល

## ភាគហ៊ុនិក ជាទីរាប់អាន

សូមអរគុណដល់ភាហ៊ុនិកដែលបានចូលរួមជាមួយខ្ញុំក្នុងឆ្នាំហិរញ្ញវត្ថុទីពីររបស់ ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ម.ក (“ផថខ”) ជាក្រុមហ៊ុនដែលបានចុះបញ្ជីលក់មូលបត្រ នៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (“ផ.ម.ក”)។

## ផថខ បានបន្តផែនការរបស់ខ្លួនក្នុងការអភិវឌ្ឍន៍គម្រោងហេដ្ឋារចនាសម្ព័ន្ធថាមពល នៅក្នុងតំបន់ខណៈឥទ្ធិពល ពីជំងឺរាតត្បាតកូវីដ-១៩ យើងបានរាយការណ៍អំពីនិរន្តរភាព នៃឆ្នាំហិរញ្ញវត្ថុដែលបានកើតមានស្របពេលនៃការ ឆ្ពោះទៅរកកំណើនវិជ្ជមាន នៅឆ្នាំហិរញ្ញវត្ថុខាងមុខដោយការរិះរក នូវការគ្រប់គ្រងស្ថានភាពជំងឺរាតត្បាតនេះ។

យន្តការ **ផថខ** បានរៀបចំ និងត្រៀមជាស្រេចដែលកម្លាំងពលកម្មរបស់យើងស្ទើរតែ ១០០% នៅប្រទេសកម្ពុជា កំពុងទទួលបានការចាក់វ៉ាក់សាំងទាំងស្រុង។ ក្រុមការងារដែលបានខិតខំប្រឹងប្រែងនៅ ផថខ បានធានានូវដំណើរការរលូនជាប់ជានិច្ចដល់គម្រោងទាំងអស់ក្នុងប្រទេស។ ម៉្យាងវិញទៀត យើងមានមោទនភាពដែលក្នុងគ្រាដ៏លំបាកនេះ ក្រុមការងារបានទទួលនូវជំនាញ និងឯកទេសថ្មីៗដោយជោគជ័យក្នុងការអភិវឌ្ឍន៍ពេញលេញនៃរោងចក្រថាមពល ពន្លឺព្រះអាទិត្យខ្នាតធំ។ នៅពេលបញ្ចប់ការសាងសង់រោងចក្រថាមពលពន្លព្រះអាទិត្យ **ផថខ** នឹងមានអនុសាសន៍ដើម្បី អនុវត្តគម្រោងថាមពលកកើតឡើងវិញស្រដៀងគ្នានៅក្នុងតំបន់។

ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនបានព្យាករណ៍អំពី សក្ដានុពលការអភិវឌ្ឍន៍ជាបន្តបន្ទាប់នៃថាមពលកកើតឡើងវិញនៅឥណ្ឌូចិន ជាពិសេសនៅប្រទេសកម្ពុជា ស្របគ្នានឹងការពង្រីកដ៏ឆាប់រហ័សនៃសកម្មភាពបញ្ចេញសារធាតុកាបូននៅក្នុងតំបន់អាស៊ាន។ ដូច្នេះ ដោយភាពជឿជាក់ **ផថខ** នឹងវិវត្តទៅជាអ្នកបង្កើតថាមពលប្រកបដោយនិរន្តរភាពនៅទូទាំងតំបន់ ជាមួយនឹងសេវាកម្មដែលមានតម្លៃបន្ថែមដោយឈានដល់ការបញ្ចប់នូវដំណោះស្រាយពង្រឹងគុភាពថាមពលទំនើបសម្រាប់ការអនុវត្តតាមបណ្ដាញអគ្គិសនីឱ្យកាន់តែប្រសើរ និងមានប្រសិទ្ធភាពដល់ការផ្គត់ផ្គង់ថាមពលកកើតឡើងវិញតាមរយៈការរួមសហការយ៉ាងជិតស្និទ្ធជាមួយដៃគូរបស់យើង ភាគហ៊ុនិក និងក្រុមហ៊ុន Mas chinenfabrik Reinhausen ( “ MR” ) នៃប្រទេសអាល្លឺម៉ង់។

តាមរយៈកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយដៃគូបច្ចេកវិជ្ជាដូចជា MR **ផថខ** មានបំណងអភិវឌ្ឍន៍ចំណេះដឹង បច្ចេកទេសជាបណ្ដើរៗសម្រាប់ក្រុមវិស្វកររបស់ខ្លួននៅប្រទេសកម្ពុជាតាមរយៈការបណ្ដុះបណ្ដាលសមត្ថភាពបន្ថែមនឹងត្រូវបានលើកកម្ពស់ដើម្បីបម្រើទីផ្សារក្នុងតំបន់នៅឥណ្ឌូចិនឱ្យកាន់តែប្រសើរឡើង។ ជំហានបន្ទាប់ យើងនឹងខិតខំចូលរួមឱ្យច្រើនជាងនេះក្នុងការអភិវឌ្ឍន៍ព្រះរាជាណាចក្រកម្ពុជា ជាពិសេសលើវិស័យហេដ្ឋារចនាសម្ព័ន្ធថាមពល គំនិតផ្ដួចផ្ដើមទីក្រុងឆ្លាតវៃតាមរយៈការធ្វើសមាហរ័ណកម្មទំនាក់ទំនងខ្សែថាមពលបៃតង ( ដូចជា រោងចក្រថាមពលព្រះអាទិត្យ និងកាកសំណល់ឱ្យទៅជារោងចក្រថាមពល ) បន្ថែមលើបណ្ដុំផលិតផលថាមពល និងការនាំចេញ។

យើងខិតខំសហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរពាក់ព័ន្ធ ជាពិសេសក្រសួងរ៉ែ និងថាមពល អគ្គិសនីកម្ពុជា និយ័តករមូលបត្រកម្ពុជា និង **ផ.ម.ក** ដើម្បីឱ្យ **ផថខ** ក្លាយជាក្រុមហ៊ុនហេដ្ឋារចនាសម្ព័ន្ធថាមពលឈានមុខគេដែលបានចុះបញ្ជីលក់មូលបត្រនៅក្នុងទីផ្សារគោលរបស់ ផ.ម.ក និងបានត្រៀមខ្លួនរួចជាស្រេចដើម្បីបម្រើវិស័យឧស្សាហកម្មនៅក្នុងតំបន់។

ដើម្បីជារង្វាន់ដល់ភាគហ៊ុនិករបស់យើង ក្រុមប្រឹក្សាភិបាល **ផថខ** កាលពីថ្ងៃទី១២ ខែសីហា ឆ្នាំ២០២១ បានកំណត់ និងប្រកាសភាគលាភចំនួន ០.០០៦៥ ដុល្លារអាមេរិក ក្នុងមួយភាគហ៊ុន សម្រាប់ការិយបរិច្ឆេទគិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១។ ភាគលាភអាចនឹងមានការផ្លាស់ប្ដូរស្របតាមលទ្ធផលសវនកម្មរបស់សវនករឯករាជ្យ និងសេចក្ដីសម្រេចនៃកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក។

អរគុណ

Ir. Paul Lim Pay Chuan
**ប្រធានក្រុមប្រឹក្សាភិបាល**

កាលបរិច្ឆេទ៖ ២៣ កញ្ញា ២០២១

# សេចក្តីថ្លែង របស់នាយកប្រតិបត្តិ



ដោយមានការគាំទ្រពីក្រុមការងារដែលមានស្មារតីលះបង់ យើងគ្រោងនឹងកបញ្ចប់គម្រោងស្ថានីយបញ្ជូន-អូរខ្វាវដែលមានកម្លាំង ២៣០/១១ គីឡូវ៉ុល សម្រាប់គម្រោងរ៉ែមាស-អូរខ្វាវ មុនពេលកំណត់។

## HAN FATT JUAN

ប្រធាននាយកប្រតិបត្តិ

ភាគហ៊ុនិកជាទីរាប់អាន

ក្រុមហ៊ុន**ផេសថិក** (**ខេមបូឌា**) **ម.ក** (**“ផថខ”**) បានពុះពារការលំបាកជាច្រើន ប៉ុន្តែក៏ទទួលបាននូវផ្លែផ្កាសម្រាប់ឆ្នាំហិរញ្ញវត្ថុ ២០២១។

ក្នុងអំឡុងពេលនៃឆ្នាំហិរញ្ញវត្ថុនេះ ចំពេលមានការរំខានដែលបណ្តាលមកពីការរីករាលដាលនៃជំងឺកូវីដ-១៩ រាតត្បាតជាសកលដែលមិនធ្លាប់មានពីមុនមក **ផថខ** បានបន្តព្យាយាម និងរក្សាប្រតិបត្តិការរបស់ខ្លួនជាមួយនឹងនីតិវិធីប្រតិបត្តិការស្តង់ដារតឹងរឹង។

ដោយមានការគាំទ្រពីក្រុមការងារដែលមានស្មារតីលះបង់ យើងគ្រោងនឹងកបញ្ចប់គម្រោងស្ថានីយបញ្ជូន-អូរខ្វាវដែលមានកម្លាំង ២៣០/១១ គីឡូវ៉ុល សម្រាប់គម្រោងរ៉ែមាស-អូរខ្វាវ មុនពេលកំណត់។ គម្រោងរ៉ែមាស-អូរខ្វាវ ជាកម្មសិទ្ធិរបស់ក្រុមហ៊ុន Emerald Resources NL ជាក្រុមហ៊ុនរុករករ៉ែដែលមាន

# សេចក្ដីថ្លែង របស់នាយកប្រតិបត្តិ

មូលដ្ឋាននៅប្រទេសអូស្ត្រាលី និងជាក្រុមហ៊ុនដែលបានចុះបញ្ជីលក់មូលបត្រនៅផ្សារមូលបត្រអូស្ត្រាលី ដែលតាមរយៈ ក្រុមហ៊ុន រ៉ុនេសង់ មីនេរ៉ល (ខេមបូឌា) លីមីធីត ដែលជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន Emerald Resources NL បានចូលរួមអភិវឌ្ឍន៍ប្រាក់កម្ចីអូរខ្វារនៅខេត្តមណ្ឌលគិរី ភាគខាងកើតនៃប្រទេសកម្ពុជា។ ស្ថានីយនេះមានសារៈសំខាន់ណាស់ក្នុងការផ្គត់ផ្គង់តម្រូវការថាមពលដល់អណ្តូងរ៉ែមាសដើម្បីអាចដំណើរការគម្រោងឱបានឆាប់រហ័ស។

ពេញមួយការិយបរិច្ឆេទ **ផថខ** ក៏បានទិញគម្រោងខ្សែបញ្ជូនបន្ថែមនៅក្នុងប្រទេសកម្ពុជា ដើម្បីបង្កើនការបញ្ជាទិញ គម្រោងសម្រាប់និរន្តរភាព និងការពង្រីកអាជីវកម្ម។ បន្ថែមលើនេះ បច្ចុប្បន្នយើងកំពុងអនុវត្តគម្រោងសាងសង់រោងចក្រថាមពលពន្លឺព្រះអាទិត្យទំហំ ២០ មេហ្គាវ៉ាត់ (“PV”) សម្រាប់ក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់យើងគឺ ក្រុមហ៊ុន ហ្វ្រីន សឹស្តែនណេប៊ល វេនឈ័រ (ខេមបូឌា) ឯ.ក ដែលមានទីតាំងនៅក្រុងបាវិត ខេត្តស្វាយរៀង។ យើងរំពឹងថា រោងចក្រថាមពលនេះនឹងត្រូវបញ្ចប់ទាំងស្រុងមុនដំណាច់ឆ្នាំ២០២១។

ក្រុមហ៊ុនក៏កំពុងស្វែងយល់ពីការកែលម្អបច្ចេកវិទ្យាសំណង់ដែលអាចអនុវត្តបានចំពោះការកសាងហេដ្ឋារចនា សម្ព័ន្ធថាមពល ដូចជាអនុស្ថានីយ និងរោងចក្រថាមពលព្រះអាទិត្យ PV ដែលទាក់ទងនឹងការទទួលយកវិធីសាស្ត្រសាងសង់មុនពេលចាក់ពុម្ពដោយការប្រើដំណោះស្រាយ Mould & Die។ ភាពជឿនលឿននៃបច្ចេកទេសសាងសង់អាចជួយឱ្យមានស្តង់ដារកាន់តែប្រសើរ ការធានាគុណភាព ការពន្លឿនដល់ការអនុវត្ត និងការពង្រឹងសុវត្ថិភាព។ តាមភាពប្រយោល យើងក៏អាចពិនិត្យមើលការកែលម្អរចនាសម្ព័ន្ធចំណាយ ដោយសារភាពដូចគ្នានៃវត្ថុធាតុដើម និងកាត់បន្ថយការពឹងផ្អែកលើកម្លាំងពលកម្ម។ យើងសង្ឃឹមថានឹងអាចអនុវត្តយ៉ាងទូលំទូលាយនូវការប្រើប្រាស់វិធីសាស្ត្រសាងសង់នេះដើម្បីនាំមកនូវ ប្រសិទ្ធភាព និងភាពជឿជាក់ខ្ពស់ដល់គម្រោងរបស់យើង។

ម៉្យាងវិញទៀត ដោយសារមានការវិវឌ្ឍន៍ថ្មីនៅក្នុងប្រទេស មីយ៉ាន់ម៉ា ក្រុមហ៊ុន ផេសចិក (មីយ៉ាន់ម៉ា) លី មីតធីត ដែលជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ ផថខ នឹងត្រូវបោះបង់ការអភិវឌ្ឍន៍អាជីវកម្មរហូតដល់ស្ថានភាពទីផ្សារនៅក្នុងប្រទេសមានភាពប្រសើរឡើង ឬតាមភាពជាក់ស្តែង។ ទន្ទឹមនឹងនេះ យើងនឹងនៅតែផ្តោតលើឱកាសអភិវឌ្ឍន៍អាជីវកម្មនៅប្រទេសកម្ពុជា។

គណៈគ្រប់គ្រងរបស់ **ផថខ** ជឿជាក់យ៉ាងមុតមាំថា **ផថខ** នឹងរាយការណ៍អំពីលទ្ធផលវិជ្ជមានជានិច្ច និងផ្តល់នូវវឌ្ឍនៈភាពនៃការអនុវត្តគម្រោងលើកទឹកចិត្តដល់ភាគហ៊ុនិករបស់ខ្លួនសម្រាប់ឆ្នាំហិរញ្ញវត្ថុបន្ទាប់ ក្រៅពីការកើតឡើងវិញដោយការរំខាន ដែលបណ្តាលមកពីជំងឺរាតត្បាត។

យើងខ្ញុំសូមអរគុណចំពោះការគាំទ្រ និងជឿជាក់ជានិច្ចដល់ក្រុមហ៊ុន!

សូមអរគុណ



Han Fatt Juan
Chief Executive Officer

កាលបរិច្ឆេទ៖ ២៣ កញ្ញា ២០២១

# ព័ត៌មានទូទៅពាក់ព័ន្ធនឹង បុគ្គលចុះបញ្ជីលក់មូលបត្រ

## ក. អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ

| | |
|---|---|
| ឈ្មោះក្រុមហ៊ុនជាភាសាខ្មែរ | **ផេសថិក (ខេមបូឌា) ម.ក** |
| ជាអក្សរឡាតាំង | PESTECH (CAMBODIA) PLC |
| លេខកូដស្តង់ដារ | KH១០០០១៨០០០៩ |
| និមិត្តសញ្ញា | ផថខ |
| អាសយដ្ឋាន | ផ្ទះលេខ ៦ ផ្លូវលេខ ៥៨៨ សង្កាត់បឹងកក់ទី ॥ ខណ្ឌទួលគោក ភ្នំពេញ ប្រទេសកម្ពុជា |
| លេខទូរស័ព្ទ | +៨៥៥ ២៣ ៨៨២ ១០៥ |
| លេខទូរសារ | +៨៥៥ ២៣ ៨៨២ ១០៦ |
| គេហទំព័រ | www.pestech.com.kh |
| អ៊ីមែល៖ | info@pestech.com.my |
| លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម | ០០០០០៩៥៧ ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១០ ចេញដោយក្រសួងពាណិជ្ជកម្ម |
| លេខអាជ្ញាប័ណ្ណអាជីវកម្ម | ៣២៦ ប្រក.ជនស.អសណ ចេញដោយ ជនស ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ២០១៨ |
| សេចក្តីសម្រេចអនុញ្ញាត្ត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានលេខ | ១៧១/២០ គ.ម.គ/ស.ស.រ ចុះថ្ងៃទី ២២ ខែកក្កដា ឆ្នាំ២០២០ ចេញដោយ គណៈកម្មការមូលបត្រកម្ពុជា (បច្ចុប្បន្នជា និយ័តករមូលបត្រកម្ពុជា "នមក") |
| ឈ្មោះបុគ្គលតំណាងបុគ្គលចុះបញ្ជីលក់មូលបត្រ | លោក Lim Pay Chuan |

កាលពីមុន **ផថខ** ត្រូវបានគេស្គាល់ថាជាក្រុមហ៊ុនឈ្មោះ **ថាដវី-ផេសថិក ផេវី លីមីធីត** ដែលបានបង្កើតឡើងនៅថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១០ ជាក្រុមហ៊ុនឯកបុគ្គលទទួលខុសត្រូវមានកម្រិតនៅប្រទេសកម្ពុជា។ ផថខ បានចុះបញ្ជីនាមករណ៍បច្ចុប្បន្ននៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៣។

**ផថខ** បានប្តូរពីក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ទៅជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៨ ដែលអនុម័តដោយក្រសួងពាណិជ្ជកម្ម និងបានដាក់នាមករណ៍បច្ចុប្បន្នដើម្បីជួយសម្រួលដល់ការចុះបញ្ជីនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (ផ.ម.ក.)។

**ផថខ** គឺជាក្រុមហ៊ុនបច្ចេកវិទ្យាថាមពលអគ្គិសនីរួមបញ្ចូលគ្នា យើងបានចូលរួមយ៉ាងសំខាន់ក្នុងការផ្តល់នូវវិស្វកម្មប្រព័ន្ធថាមពលដ៏ទូលំទូលាយ និងដំណោះស្រាយបច្ចេកទេសសម្រាប់ ការរចនា លទ្ធកម្ម ការសាងសង់ ការតំឡើង ការដាក់ឱ្យដំណើរការអនុស្ថានីយ៍ HV និង EHV បណ្តាញបញ្ជូន HV និង EHV ព្រមទាំងប្រព័ន្ធខ្សែថាមពលក្រោមដីសម្រាប់បញ្ជូន ចែកចាយអគ្គិសនី ការជួញដូរគ្រឿងបន្លាស់ ឧបករណ៍ប្រព័ន្ធថាមពលដែលមានកម្មសិទ្ធិ និងមិនមានកម្មសិទ្ធិ។



# ព័ត៌មានទូទៅពាក់ព័ន្ធនឹង បុគ្គលចុះបញ្ជីលក់មូលបត្រ

ក្រុមហ៊ុនបុត្រសម្ព័ន្ធដែលមាននាមករណ៍ PESTECH (Myanmar) Limited ("PML") ត្រូវបានបង្កើតឡើងនៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៧ ជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតបង្កើតឡើងក្រោមច្បាប់ក្រុមហ៊ុនរបស់ប្រទេសមីយ៉ាន់ម៉ា។ សកម្មភាពចម្បងរបស់ PML គឺផ្តល់ជូននូវប្រព័ន្ធវិស្វកម្មសំណង់រចនា និងតំឡើងសេវាកម្មពាក់ព័ន្ធនឹងឧស្សាហកម្មថាមពល។

PESTECH Hinthar Corporation Limited ("PHC") ត្រូវបានបង្កើតឡើងនៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៩ ជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតក្រោមច្បាប់ក្រុមហ៊ុននៃប្រទេសមីយ៉ាន់ម៉ា និងជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន PESTECH (Myanmar)។ សកម្មភាពចម្បងរបស់ PHC គឺបង្កើតហេដ្ឋារចនាសម្ព័ន្ធនៃវិស័យថាមពល និងលើកកម្ពស់ផ្នែកថាមពលដូចជា ការផលិតថាមពល ការបញ្ជូនថាមពល និងការចែកចាយថាមពល។

ក្រុមហ៊ុន PESTECH Microgrid Corporation Limited ("PMC") ត្រូវបានបង្កើតឡើងនៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២០ ជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតក្រោមច្បាប់ក្រុមហ៊ុននៃ ប្រទេសមីយ៉ាន់ម៉ា និងជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន PHC។ សកម្មភាពចម្បងរបស់ PMC គឺផ្តល់ប្រព័ន្ធមីក្រូក្រាហ្វិច និងហេដ្ឋារចនាសម្ព័ន្ធថាមពលផ្សេងទៀតដល់តំបន់ជនបទក្នុងប្រទេសមីយ៉ាន់ម៉ា។

## ខ. ព្រឹត្តិការណ៍សំខាន់ៗប្រចាំឆ្នាំ

**ផថខ** បានចាប់ផ្តើមប្រតិបត្តិការពាណិជ្ជកម្មនៅ ឆ្នាំ២០១០ ពេលដែលយើងទទួលបានកិច្ចសន្យាពាក់ព័ន្ធនឹងការសាងសង់អនុស្ថានីយ៍ HV និងបណ្តាញបញ្ជូនHVរវាងបណ្តាញបញ្ជូនអគ្គិសនីភាគខាងជើងរាជធានីភ្នំពេញទៅខេត្តកំពង់ចាមនៅក្នុងព្រះរាជាណាចក្រកម្ពុជា (គម្រោងរាជធានីភ្នំពេញភាគខាងជើង-កំពង់ចាម) ពីក្រុមហ៊ុន ខេមបូឌាន ទ្រែនមីសិន លីមីធីត។ គម្រោងនេះរួមបញ្ចូលទាំងការគូសប្លង់ ការសាងសង់ ការសាកល្បង និងការដាក់ឱ្យប្រើប្រាស់ខ្សែបណ្តាញបញ្ជូនអគ្គិសនីប្រវែង ១១០ គីឡូម៉ែត្រ មានតង់ស្យុង ២៣០ គីឡូវ៉ុល ដែលមានខ្សែបញ្ជូននៃសៀគ្វីចំនួនពីរ ពីរាជធានីភ្នំពេញទៅខេត្តកំពង់ចាម រួមជាមួយនឹងបរិក្ខាសម្រាប់អនុស្ថានីយ៍ពីរ (០២) និងការធ្វើឱ្យដំណើរការកាន់តែប្រសើរឡើង។

**ផថខ** បានបញ្ចប់ និងប្រគល់គម្រោងរាជធានីភ្នំពេញភាគខាងជើង-ខេត្តកំពង់ចាមទៅឱ្យម្ចាស់គម្រោងគឺ ក្រុមហ៊ុន **ខេមបូឌាន ទ្រែនមីសិន លីមីធីត** ដោយជោគជ័យក្នុង ឆ្នាំ២០១៣។ គម្រោងនេះបានបង្ហាញពីព្រឹត្តិការណ៍សំខាន់មួយរបស់ **ផថខ** ដោយ **ផថខ** បានបញ្ចប់គម្រោងប្រាំបី (០៨) ខែមុនកាលកំណត់។





លើសពីនេះទៀត ក្នុងឆ្នាំ២០១២ ផថខ បានចុះកិច្ចសន្យាជាមួយនឹង EDC ពាក់ព័ន្ធនឹងការសាងសង់ខ្សែបណ្តាញបញ្ជូនដែលមានតង់ស្យុង ១១៥ គីឡូវ៉ុល ពីអនុស្ថានីយ របស់ក្រុមហ៊ុន Cambodia Power Grid Co., Ltd ("CPG") មានតង់ស្យុង ២៣០/១១៥ គីឡូវ៉ុល ទៅអនុស្ថានីយ៍ របស់ក្រុមហ៊ុន Transmission Lines Co. , Ltd (" CPTL") មានតង់ស្យុង ១១៥/២២ គីឡូវ៉ុល នៅខេត្តបាត់ដំបងដែលមានប្រវែង 0.៩៧ គីឡូម៉ែត្រ។ គម្រោងនេះពាក់ព័ន្ធនឹងការគូសប្លង់ វិស្វកម្ម លទ្ធកម្ម និងការតំឡើងបណ្តាញបញ្ជូនអគ្គិសនី។ ហើយគម្រោងនេះត្រូវបានបញ្ចប់ជាស្ថាពរនៅខែសីហា ឆ្នាំ២០១២។

នៅ ឆ្នាំ២០១៤ ផថខ បានចុះកិច្ចសន្យាជាមួយ ក្រុមហ៊ុន អាឡិច ឧបតើរេសិន ដែលជាក្រុមហ៊ុនផ្តល់សេវាកម្មច្រើនប្រភេទនៅកម្ពុជា។ កិច្ចសន្យានេះពាក់ព័ន្ធនឹង ការគូសប្លង់ វិស្វកម្ម ការតម្លើង ការសាកល្បង និងការដាក់ឱ្យប្រើប្រាស់នូវគម្រោងរាជធានីភ្នំពេញខាងលិច-ក្រុងព្រះសីហនុសម្រាប់៖

- ខ្សែបញ្ជូនរាជធានីភ្នំពេញខាងលិច-ក្រុងព្រះសីហនុ ដែលមានតង់ស្យុង ២៣០ គីឡូវ៉ុល និង
- គម្រោងពង្រីកអនុស្ថានីយ ២៣០/១១៥/២២គីឡូវ៉ុល។

# ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីលក់មូលបត្រ




គម្រោងនេះពាក់ព័ន្ធនឹងការសាងសង់ខ្សែបណ្តាញបញ្ជូនមួយមានប្រវែង ១៩៨ គីឡូម៉ែត្រ ដែលបញ្ជូនអគ្គិសនីពីរោងចក្រថាមពលក្នុងក្រុងព្រះសីហនុទៅរាជធានីភ្នំពេញ។ គម្រោងនេះពាក់ព័ន្ធនឹងការធ្វើឱ្យប្រសើរឡើងនូវអនុស្ថានីយ៍ ស្ទឹងហាវ ដែលមានស្រាប់ ជាមួយនឹងច្រកភ្ជាប់បណ្តាញថ្មីចំនួនពីរ (២) ដែលមានតង់ស្យុង ២៣០គីឡូវ៉ុល ដែលត្រូវតភ្ជាប់ទៅអនុស្ថានីយ៍រាជធានីភ្នំពេញខាងលិចនៅក្នុងរាជាធានីភ្នំពេញ តាមរយៈខ្សែបញ្ជូនថ្មី ដែលមានតង់ស្យុង ២៣០ គីឡូវ៉ុល ដែលនឹងត្រូវសាងសង់ក្រោមគម្រោងនេះ។

នៅឆ្នាំ២០១៥ ផថខ បានចុះកិច្ចសន្យាជាមួយ ក្រុមហ៊ុន ដាយអឹមិន ផៅវ័រ ដើម្បីអនុវត្តគម្រោងកំពង់ចាម-ក្រចេះ។ គម្រោងនេះពាក់ព័ន្ធនឹង ការគូសប្លង់ វិស្វកម្ម ការសាកល្បង ការតម្លើង និងការដាក់ឱ្យដំណើរការនូវកុងតាក់ ដែលមានតង់ស្យុង ២៣០ គីឡូវ៉ុល នៅអនុស្ថានីយ៍កំពង់ចាមដែលមានស្រាប់ និងអនុស្ថានីយ៍ថ្មីដែលមានតង់ស្យុង ២៣០/២២ គីឡូវ៉ុល នៅខេត្តក្រចេះ និងតភ្ជាប់បណ្តាញបញ្ជូន ១២៥ គីឡូម៉ែត្រ ពីអនុស្ថានីយ៍កំពង់ចាមទៅអនុស្ថានីយ៍ក្រចេះ។ ផថខ បានបញ្ចប់គម្រោងដោយជោគជ័យនៅក្នុង ខែតុលា ឆ្នាំ២០១៧។




បន្ថែមពីលើនេះ ក្នុងឆ្នាំដដែល ផថខ បានបញ្ចប់គម្រោងមួយនៅ Sarawak ប្រទេសម៉ាឡេស៊ី ដែល **ផថខ** បានផ្តល់សេវាកម្មគ្រប់គ្រងគម្រោង និងគ្រប់គ្រងសំណង់ស៊ីវិលសម្រាប់ការសាងសង់អនុស្ថានីដយ៍ដែលមានតង់ស្យុង ២៧៥/៣២ គីឡូវ៉ុល និង ១៣២/១១kv។

ក្រោយមកទៀត នៅថ្ងៃទី៨ ខែកុម្ភះ ឆ្នាំ២០១៧ ការធ្វើវិសោធនកម្មកិច្ចសន្យាដែលមានស្រាប់បានធ្វើជាមួយ ក្រុមហ៊ុន **អាឡិច ខបភើរេសិន** ដើម្បីធ្វើឱ្យប្រសើរឡើងនូវលក្ខណៈពិសេសនៃគម្រោងរាជធានីភ្នំពេញខាងលិច-ព្រះសីហនុ។ យោងតាមវិសោធនកម្មកិច្ចសន្យាដែលធ្វើឱ្យប្រសើរឡើងនេះរួមមាន ការគូសប្លង់ វិស្វកម្ម ការតំឡើង ការធ្វើតេស្ត និងការដាក់ឱ្យដំណើរការនូវ៖

- ខ្សែបញ្ជូនពីរខ្សែដែលមានតង់ស្យុង ២៣០ គីឡូវ៉ុល ប្រហែល ៥០ គីឡូម៉ែត្រ ពីអនុស្ថានីយ៍ស្ទឹងហាវ ទៅចំការហ្លួង និង
- ខ្សែបញ្ជូនពីរខ្សែដែលមានតង់ស្យុង ៥០០ គីឡូវ៉ុល ប្រមាណ ១៤០ គីឡូម៉ែត្រពីចំការហ្លួង ទៅអនុស្ថានីយ៍បែកចានដែលបានស្នើសុំថ្មី។

# ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីលក់មូលបត្រ

នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៧ **ផថខ** បានចុះកិច្ចសន្យាជាមួយ ក្រុមហ៊ុន **ស្នេថេក** សម្រាប់គម្រោងសៀមរាប-ឧត្តរមានជ័យ។ គម្រោងនេះពាក់ព័ន្ធនឹងការអភិវឌ្ឍន៍បណ្តាញបញ្ជូនដែលមានតង់ស្យុង ១១៥ គីឡូវ៉ុល ពីសៀមរាប ទៅឧត្តរមានជ័យ អនុស្ថានីយ៍ឧត្តរមានជ័យដែលមានតង់ស្យុង ១១៥/២២ គីឡូវ៉ុល និងអនុស្ថានីយ៍បែកចានដែលមានតង់ស្យុង ២៣០/២២ គីឡូវ៉ុល។ គម្រោងនេះត្រូវបានបញ្ចប់នៅ ខែមករា ឆ្នាំ២០២០។





ចំពេលដែលមានជំងឺរាតត្បាត ក្នុងឆ្នាំ២០២០ យើងអាចបញ្ចប់គម្រោងអនុស្ថានីយ៍បញ្ជូន-អូរខ្វាវដែលមានតង់ស្យុង ២៣០/១១ គីឡូវ៉ុល សម្រាប់គម្រោងរ៉ែមាស-អូរខ្វាវ បានមុនកាលកំណត់។ គម្រោងរ៉ែមាស-អូរខ្វាវដែលមានតង់ស្យុង ២៣០/១១ គីឡូវ៉ុល សម្រាប់គម្រោងរ៉ែមាស-អូរខ្វាវ បានមុនកាលកំណត់។ គម្រោងរ៉ែមាស-អូរខ្វាវ បានចូលរួមអភិវឌ្ឍន៍ប្រាក់កម្ចីអូរខ្វាវនៅខេត្តមណ្ឌលគិរីភាគខាងកើតនៃប្រទេសកម្ពុជា

បន្ទាប់ពីការបញ្ចប់ខ្សែបញ្ជូនរាជធានីភ្នំពេញខាងលិច-ក្រុងព្រះសីហនុដែលមានតង់ស្យុង ២៣០ គីឡូវ៉ុល **ផថខ** បានចូលរួមផ្តល់សេវាកម្មថែទាំបណ្តាញអនុស្ថានីយ៍ស្តឹងហាវចំនួនពី (០២) ខ្សែ និងខ្សែបញ្ជូនដែលមានតង់ស្យុង ៥០០ គីឡូវ៉ុល ក្រោមគម្រោងនេះផងដែរនៅឆ្នាំ២០២០។





## គម្រោងដែលកំពុងដំណើរការបច្ចុប្បន្ន

មកដល់បច្ចុប្បន្ន **ផថខ** បានចូលរួមក្នុងគម្រោងប្រព័ន្ធបញ្ជូនថាមពលស្ទឹងតាតៃ-រាជធានីភ្នំពេញ។ គម្រោងនេះពាក់ព័ន្ធនឹង៖

- ការគូសប្លង់ វិស្វកម្ម ការដំឡើង ការសាកល្បង និងការដាក់ឱ្យដំណើរការខ្សែបញ្ជូនដែលមានតង់ស្យុង ២៣០គីឡូវ៉ុល ដែលមានប្រវែងប្រហែល ២២០ គីឡូម៉ែត្រ ពីទំនប់វារីអគ្គិសនីស្ទឹងតាតៃ ទៅអនុស្ថានីយ៍បែកចានដែលបានស្នើសុំថ្មីនៅក្នុងរាជធានីក្រុងភ្នំពេញ។ និង
- ការផ្គត់ផ្គង់ ការតម្លើង និងការតភ្ជាប់បណ្តាញខ្សែភ្លើងដែលមានតង់ស្យុង ២៣០ គីឡូវ៉ុល ចំនួន ២ ខ្សែនៅចំណាតទំនប់វារីអគ្គិសនីស្ទឹងតាតៃ។

# ព័ត៌មានទូទៅពាក់ព័ន្ធនឹង បុគ្គលចុះបញ្ជីលក់មូលបត្រ

**ផថខ** ធានាបាននូវគម្រោងវិស្វកម្ម លទ្ធកម្ម ការសាងសង់ និងថាមពលព្រះអាទិត្យទ្រង់ទ្រាយធំដំបូងបង្អស់របស់ខ្លួននៅក្នុងប្រទេសកម្ពុជា នៅពេលក្រុមហ៊ុន PESTECH International Berhad កាន់កាប់ភាគហ៊ុន ៩៤% នៅក្នុង ក្រុមហ៊ុន **ហ្គ្រីន ស៊ីស្តែនណេបិល វេនឈ័រ (ខេមបូឌា) ឯ.ក** ("GSV") តាមរយៈក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួន។ GSV ទទួលបានកិច្ចព្រមព្រៀងទិញថាមពលសម្បទានរយៈពេល ២០ ឆ្នាំលើការអភិវឌ្ឍន៍រោងចក្រថាម ពលពន្លឺព្រះអាទិត្យខ្នាតធំ ២០ មេហ្គាវ៉ាត់ (ចរន្តផ្ទាល់ ២៤ មេហ្គាវ៉ាត់) នៅក្រុងបាវិតខេត្តស្វាយរៀង។ គម្រោងថាមពលពន្លឺព្រះអាទិត្យនៅក្រុងវាវិតនេះ គឺជាគម្រោងថាមពលពន្លឺព្រះអាទិត្យខ្នាតធំដំបូងបង្អស់ដែលធ្វើឡើងដោយ ផថខ នៅប្រទេសកម្ពុជា ហើយវាមានគោលបំណងដាក់ឱ្យដំណើរការនៅខែធ្នូ ឆ្នាំ២០២១។





គិតត្រឹមខែមិថុនា ឆ្នាំ២០២១ ផថខ មានភារកិច្ចគូសប្លង់ និងសាងសង់បណ្ដាញបញ្ជូនថាមពលដែលមាមប្រវែង ៦៨៨,៥ គីឡូម៉ែត្រ នៅផ្នែកផ្សេងៗគ្នានៃប្រទេសកម្ពុជា ដែលរួមចំណែកជាវិជ្ជមានដល់ការបន្តអភិវឌ្ឍន៍បណ្ដាញអគ្គិសនីរបស់កម្ពុជា។ **ផថខ** ប្ដេជ្ញាអភិវឌ្ឍន៍សមត្ថភាពរបស់ក្រុមការងារមូលដ្ឋានរបស់ខ្លួន ដើម្បីគាំទ្រដល់ការសាងសង់បណ្ដាញអគ្គិសនីនៅប្រទេសកម្ពុជាប្រកបដោយនិរន្តរភាព។

**ផថខ** ចូលរួមជានិច្ចក្នុងគំនិតផ្តួចផ្តើមថាមពលថ្មី ជាមួយភាគីពាក់ព័ន្ធផ្សេងៗ និងរក្សាកាច្នៃប្រឌិតលើការអភិវឌ្ឍន៍ដែលឥតឈប់ឈររបស់ខ្លួន។ បច្ចេកវិទ្យាថ្មី នឹងបង្កើនការប្រើប្រាស់ថាមពលកកើតឡើងវិញដូចជា ជីវមាស ថាមពលពន្លឺព្រះអាទិត្យ ថាមពលវារីអគ្គិសនីកំដៅក្នុងផែនដី និងថាមពលខ្យល់ នឹងណែនាំនូវប្រព័ន្ធចម្រុះជាច្រើនចូលទៅក្នុងបណ្ដាញថាមពលបន្ថែមលើរោងចក្រថាមពលខ្នាតធំ។ ការផ្លាស់ប្ដូរគំរូនេះ នឹងនាំមកនូវការលេចឡើងនូវបច្ចេកវិទ្យា និងគំនិតថ្មីៗដែលប្រសិទ្ធភាពថាមពល និងការសន្សំសំចៃអាចត្រូវបានដោះស្រាយបានល្អប្រសើរ ទោះបីជាបណ្ដាញចែកចាយរួមបញ្ចូលគ្នាក៏ដោយ។

ខណៈពេលដែល PESTECH នៅតែមានភាពរឹងមាំក្នុងការវាយលុកចូលទីផ្សារអាស៊ាននូវប្រព័ន្ធបណ្ដាញបញ្ជូន និងចែកចាយថាមពល **ផថខ** ក៏រក្សារការប្រុងប្រយ័ត្នក្នុងការពង្រីកខ្លួនឆ្ពោះផ្សារសកលសំដៅដល់ការបំបែកកាបូនឌីជីថល និងឌីជីថល ដែលជាមាគ៌ាឆ្ពោះទៅរកការរីកចម្រើនប្រកបដោយនិរន្តរភាពនាអនាគត។ ថាមពលកកើតឡើងវិញបានក្លាយជាកម្មវត្ថុនៃការផ្លាស់ប្តូរទៅជាប្រព័ន្ធថាមពលដែលមានកាបូនតិច និងមាននិរន្តរភាពជាងមុន។ ជាមួយនឹងការផ្លាស់ប្ដូរបន្តិចម្ដងៗជាបន្តបន្ទាប់នេះ ប្រតិបត្តិការរបស់ **ផថខ** ទាមទារឱ្យមានការផ្សារភ្ជាប់ ទទួលយក និងសម្របតាមគំនិតផ្តួចផ្តើមនៃថាមពលកកើតឡើងវិញ បញ្ចូលទៅក្នុងយុទ្ធសាស្ត្រអាជីវកម្មដើម្បីលើកកម្ពស់ការអភិវឌ្ឍន៍អាជីវកម្មប្រកបដោយនិរន្តរភាព និងការទទួលខុសត្រូវ។ សម្រាប់រយៈពេលជាច្រើនឆ្នាំមកនេះ **ផថខ** បានចាប់ផ្ដើមស្វែងយល់ពីទីផ្សារថាមពលកកើតឡើងវិញរួមជាមួយនឹងគំនិតផ្តួចផ្តើមបៃតងដូចខាងក្រោមៈ ៖



# ព័ត៌មានទូទៅពាក់ព័ន្ធនឹង បុគ្គលចុះបញ្ជីលក់មូលបត្រ

## គ. ស្ថានភាពទីផ្សារ

ការរីករាលដាលនៃជំងឺរាតត្បាតកូវីដ-១៩ បានជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់សេដ្ឋកិច្ចជាសាកល។ ចក្ខុវិស័យ លូតលាស់ រយៈពេលវែងសម្រាប់បណ្ដាប្រទេសអភិវឌ្ឍន៍មួយចំនួនមានភាពពុំច្បាស់លាស់ដោយមានមនុស្សភាគច្រើនប្រឈមមុខនឹងភាពមិនប្រាកដប្រជាអំពីនិរន្តរភាពលូតលាស់ និងការប្រឈមមុខនឹងផលប៉ះពាល់អវិជ្ជមាន នៃស្ថានភាពបច្ចុប្បន្នលើសុខុមាលភាពសេដ្ឋកិច្ចរបស់ពួកគេ។

ភាពគក់ស្លុតជាសកលដែលបង្កឡើងដោយជំងឺរាតត្បាតកូវីដ-១៩ បានជះឥទ្ធិពលដល់សេដ្ឋកិច្ចប្រទេសកម្ពុជានៅក្នុងឆ្នាំ២០២០ ដែលជាលទ្ធផលសេដ្ឋកិច្ចដែលបានកត់ត្រាកំណើនអវិជ្ជមាន ៣.១% ភាគរយប្រៀបធៀបទៅនឹង ៧.១% ភាគរយក្នុងឆ្នាំ២០១៩ ដែលជាឱនភាពខ្លាំងបំផុតនៅក្នុងប្រវត្តិសាស្រ្តចុងក្រោយនៃ ប្រទេសកម្ពុជា។(១)

យោងតាមទិន្នន័យផ្លូវការពីធនាគារពិភពលោក ផលិតផលក្នុងស្រុកសរុប ("GDP") របស់ប្រទេសកម្ពុជា ក្នុងឆ្នាំ២០១៩ មានចំនួន ២៧,០៩ ពាន់លាន ដុល្លារអាមេរិក ហើយបានធ្លាក់ចុះមកនៅត្រឹម ២៥,២៩ ពាន់លានដុល្លារអាមេរិក នៅក្នុងឆ្នាំ២០២០។ រលកនៃការទទួលរងឥទ្ធិពលអវិជ្ជមានកូវីដ-១៩ លើសេដ្ឋកិច្ចត្រូវបានគេរំពឹងថាអ្នកប្រើប្រាស់ដែលមានការចំណាយកំរិតខ្ពស់នឹងត្រូវចៀសផុតជាបណ្ដើរៗ ការវិនិយោគគឺមានកំរិតថេរ និងការ នាំចេញពីក្រោយយុទ្ធនាការចាក់វ៉ាក់សាំងជោគជ័យ។ បើទោះបីជាកម្មវិធីចាក់វ៉ាក់សាំងនៅតែបន្តដំណើរការ ដែលជាទូទៅគួរតែអនុញ្ញាតឱ្យមានការបន្ធូរបន្ថយនូវការរឹតបន្តឹង និងគាំទ្រដល់ការស្តារឡើងវិញនៅពាក់ កណ្តាលទីពីរនៃឆ្នាំ២០២១ ក៏ដោយ ប៉ុន្តែថ្មីៗនេះរដ្ឋាភិបាលប្រទេសកម្ពុជាបានទម្លាក់ការព្យាករណ៍កំណើន សេដ្ឋកិច្ចនៃប្រទេសមកត្រឹម ២,៥% នៅឆ្នាំ២០២១ ពីការព្យាករណ៍មុន ៤.១%។

ក្នុងចន្លោះឆ្នាំ២០១១ ដល់ឆ្នាំ២០១៥ កំណើនប្រចាំឆ្នាំនៃតម្រូវការអគ្គិសនីគិតជាមធ្យម ១៨%។ ជំហានបន្តបន្ទាប់ផែនការអភិវឌ្ឍន៍ថាមពលក្នុងឆ្នាំ២០១៥ នៅតាមមូលដ្ឋានគ្រោងនឹងកើនឡើងរហូតដល់ ៨,៨% នៃអត្រាកំណើនប្រចាំឆ្នាំនៃតម្រូវការអគ្គិសនី ដល់ឆ្នាំ២០៣០ ហើយតម្រូវការថាមពលរបស់ប្រទេសកម្ពុជាត្រូវបានព្យាករណ៍ថានឹងកើនឡើងរហូតដល់ ១៨,០០០ GWh នៅឆ្នាំ២០៣០ ដែលជាការកើនឡើងបីដង បើប្រៀបធៀប ទៅនឹងតម្រូវការក្នុងឆ្នាំ២០១៥។ ការបកស្រាយនេះគឺជាការព្យាករណ៍តម្រូវការកំរិតអតិបរិមា ៣.២៥៦ មេហ្គា វ៉ាត់នៅឆ្នាំ២០៣០ បើប្រៀបធៀបប្រមាណនឹង ១.០០០ មេហ្គាវ៉ាត់ នៃតម្រូវការកំរិតអតិបរិមាក្នុង ឆ្នាំ២០១៦។ ក្នុងចំណោមតម្រូវកម្រិតអតិបរិមាបច្ចុប្បន្នប្រហែល ៧០% ត្រូវបានប្រើប្រាស់នៅក្នុងរាជធានីភ្នំពេញដែលជារាជធានីមានប្រជាជនជាង ២ លាននាក់រស់នៅ និងការប្រកបអាជីវកម្មឧស្សាហកម្មបានប្រមូលផ្តុំ។(២)

រយៈកាលមុនប្រទេសកម្ពុជាពឹងផ្អែកទាំងស្រុងលើការផលិតថាមពលប្រេង និងការនាំចូលពីប្រទេសជិតខាង ប៉ុន្តែដោយសារការផលិតធ្យូងថ្ម និងវារីអគ្គិសនី បានកើនឡើងយ៉ាងឆាប់រហ័ស ដែលជាកត្តានាំអោយការនាំចូលអគ្គិសនីនាពេលបច្ចុប្បន្នបានធ្លាក់ចុះខ្លាំងបើប្រៀបធៀបទៅនឹងឆ្នាំ២០១០។ ផែនការថាមពលជាមូលដ្ឋានសម្រាប់កម្ពុជាក្រោមការត្រួតពិនិត្យរបស់ក្រសួងរ៉ែ និងថាមពលបានផ្តល់អនុសាសន៍លើគោលដៅផលិតថាមពល ជារួមនៅត្រឹមឆ្នាំ២០៣០ ជាធ្យូងថ្ម (៣៥%) អ៊ីដ្រូសែន (៥៥%) និងថាមពលកកើតឡើងវិញ (១០%) ដែលរួមមាន ជីវម៉ាសនិងសូឡា/ពន្លឺព្រះអាទិត្យ (PV) ដើម្បីរក្សាបាននូវថាមពលដែលមានតំលៃសម រម្យ និងសុខសុវត្ថិភាព។(៣)

ក្នុងរយៈពេល ១៥ ឆ្នាំកន្លងមកសមត្ថភាពប្រភពថាមពលបានកើនឡើង ១២ ដង ហើយថាមពលបញ្ជូនបាន កើនឡើងរហូតដល់ ១០,៣៩ ដង ដូចបង្ហាញជូនក្នុងតារាងខាងក្រោម៖(៤)




| | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| Power Sources Capacity (MW) | 325 | 419 | 490 | 579 | 584 | 793 | 825 | 1,088 | 1,359 | 1,986 | 2,115 | 2,322 | 2,635 | 2,999 | 3,897 |
| Energy Delivered (GWh) | 1,203 | 1,517 | 1,858 | 2,077 | 2,515 | 2,788 | 3,527 | 4,051 | 4,713 | 5,990 | 7,175 | 8,073 | 9,739 | 11,738 | 12,499 |
| Energy Increase (%) | 24.46 | 26.73 | 22.52 | 11.76 | 21.08 | 13.26 | 23.84 | 14.83 | 16.35 | 27.09 | 19.79 | 14.78 | 20.64 | 20.53 | 6.48 |

# ព័ត៌មានទូទៅពាក់ព័ន្ធនឹង បុគ្គលចុះបញ្ជីលក់មូលបត្រ

ប្រទេសកម្ពុជាមានអំណោយផលប្រភពថាមពលកកើតឡើងវិញជាច្រើនដូចជា វារីអគ្គិសនី ពន្លឺព្រះអាទិត្យជីវម៉ាស (រួមទាំងជីវឧស្ម័ន) និងខ្យល់។ ទោះជាយ៉ាងណា ធនធានថាមពលកកើតឡើងវិញទាំងនេះ ជាពិសេសថាមពលកកើតឡើងវិញដែលមិនមែនជាវារីអគ្គិសនី មិនទាន់ត្រូវបានគេប្រើប្រាស់ដើម្បីបំពេញតម្រូវការថាមពលនៅកម្ពុជានៅឡើយទេ។ ប្រទេសកម្ពុជាទទួលបានប្រភពថាមពលព្រះអាទិត្យខ្ពស់បំផុតនៅក្នុងអនុតំបន់ទន្លេមេគង្គ (GMS) ជាមួយនឹងការវាស់ពន្លឺព្រះអាទិត្យជាមធ្យម ១.៤០០-១.៨០០ គីឡូវ៉ាត់ម៉ោង (kWh) មួយម៉ែត្រការ៉េក្នុងមួយឆ្នាំ នៅទូទាំងប្រទេសសម្រាប់សក្តានុពលបច្ចេកទេសប្រមាណជាង ៨.០០០ មេហ្គាវ៉ាត់។ នៅចំកណ្តាលប្រទេសកម្ពុជារួមទាំងមជ្ឈមណ្ឌលផ្ទុកថាមពលរាជធានីភ្នំពេញដែលផ្ទុកថមពលប្រមាណ ៧០% នៃតម្រូវការអគ្គិសនីជាតិ ដែលជាប្រភពថាមពលពន្លឺព្រះអាទិត្យខ្ពស់បំផុតវាស់បានជាង ១៩០០ kWh មួយម៉ែត្រការ៉េ ក្នុងមួយឆ្នាំ។ [៥] ដូច្នេះ គេរំពឹងថាការបង្កើតថាមពលពីពន្លឺព្រះអាទិត្យនឹងកើនឡើងយ៉ាងខ្លាំងក្នុងរយៈពេលពីរបីឆ្នាំខាងមុខនេះ។

នៅថ្ងៃទី២៤ ខែកញ្ញាឆ្នាំ២០២១ ឯកឧត្តម **ស៊ុយ សែម** រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល បានថ្លែងនៅក្នុងកិច្ចប្រជុំ របស់អង្គការសហប្រជាជាតិពាក់ព័ន្ធនឹងថាមពលថា កម្ពុជាបានប្តេជ្ញាប្រើប្រាស់បច្ចេកវិទ្យាដែលកំពុងរីកចម្រើនដើម្បីបង្កើនសក្តានុពលថាមពលកកើតឡើងវិញ ដោយធានាថាជាថាមពលដែលអាចទទួលយកបាន មានទំនុកចិត្ត និងកាត់បន្ថយការបញ្ចេញកាបូន។ ឯកឧត្តម ស៊ុយ សែម បានលើកឡើងថា *"ដើម្បីសម្រេចគោលដៅនេះ យើងកំពុងបញ្ចូលគម្រោងថាមពលកកើតឡើងវិញទៅក្នុងផែនការអភិវឌ្ឍន៍របស់ក្រុមហ៊ុន និងបង្កើតប្រព័ន្ធផ្ទុកថាមពលថ្មខ្នាតធំ [BESS] ដើម្បីផ្គត់ផ្គង់គម្រោងថាមពលបន្ថែមទៀត និងអនុម័តគោលនយោបាយ និងផែនការសកម្មភាពដើម្បីបង្កើនប្រសិទ្ធភាពថាមពល"*។[២]

ប្រទេសកម្ពុជាកំពុងជួបប្រទះនូវកំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស និងការកើនឡើងនៃតម្រូវការថាមពល។ ប្រទេសកំពុងប្រឈមនឹងការរក្សាកំណើនតម្រូវការឆាប់រហ័សនេះខណៈកំពុងបន្តពង្រីកលទ្ធភាពចូលទៅកាន់តំបន់ដែលពុំមានតំបន់អភិរក្សពីមុនមក និងដោះស្រាយបញ្ហាសន្តិសុខថាមពលតម្លៃសមរម្យ និងនិរន្តរភាពបរិស្ថាន។ ការប្រើប្រាស់ថាមពលប្រកបដោយប្រសិទ្ធភាពគឺមានសារៈសំខាន់បំផុតចំពោះការអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ចនៃប្រទេសកម្ពុជា មិនតែប៉ុណ្ណោះក៏ដើម្បីការប្រកួតប្រជែងវិស័យឯកជនផងដែរ។

*(១) ប្រភពព័ត៌មាន៖ ធនាគារពិភពលោកប្រចាំនៅប្រទេសកម្ពុជា ទិន្នន័យចុងក្រោយ ១៤ មេសា ២០២១*
*(២) ប្រភពព័ត៌មាន៖ ការវាយតម្លៃយុទ្ធសាស្ត្រ និងផែនទីបង្ហាញផ្លូវវិស័យថាមពលនៅប្រទេសកម្ពុជា ធ្នូ ២០១៨*
*(៣) ប្រភពព័ត៌មាន៖ ផែនការថាមពលមូលដ្ឋានកម្ពុជាឆ្នាំ២០១៩*
*(៤) ប្រភពព័ត៌មាន៖ យការណ៍រួមនៃអាជ្ញាធរអគ្គិសនីកម្ពុជា*
*(៥) ប្រភពព័ត៌មាន៖ ការវាយតម្លៃយុទ្ធសាស្ត្រ និងផែនទីបង្ហាញផ្លូវវិស័យថាមពលនៅប្រទេសកម្ពុជា ធ្នូ ២០១៨*

## ឃ. ស្ថានភាពប្រកួតប្រជែង

**ផថខ** មានទីតាំងល្អដើម្បីទទួលបាននូវអត្ថប្រយោជន៍នៃការកើនឡើងនូវតម្រូវការអគ្គិសនីនៅកម្ពុជា។ ដែលមានជំនាញបច្ចេកទេសដ៏រឹងមាំខាងផ្នែកវិស្វកម្មប្រព័ន្ធថាមពល ផថខ កាន់កាប់គំរូអាជីវកម្មរួមមានផ្នែកបញ្ជូន និងចែកចាយ វិស្វកម្មប្រព័ន្ធថាមពល។ ការគ្រប់គ្រងប្រកបដោយបទពិសោធន៍ និងមានស្មារតីលះបង់ផ្តោតលើការរីកលូតលាស់ផ្នែកអាជីវកម្ម។ ចំណុចខ្លាំងគឺសង្កត់ធ្ងន់លើគុណភាពដែលជាគន្លឹះចាំបាច់ក្នុងការផ្តល់សេវាកម្មផ្សេងៗ។

កាលានុវត្តភាពនៃការអនុវត្តគម្រោងថាមពលព្រះអាទិត្យខ្នាតធំសម្រាប់កសិដ្ឋានថាមពលពន្លឺព្រះអាទិត្យបារិត ២០ មេហ្គាវ៉ាត់ នឹងផ្តល់លទ្ធភាពឱ្យ **ផថខ** មានអំនះអំនាងល្អដើម្បីចូលរួមក្នុងគម្រោងថាមពលកកើតឡើងវិញ ដែលជាយុទ្ធសាស្ត្ររបស់រដ្ឋាភិបាលកម្ពុជាក្នុងការស្វែងរកសក្តានុពលថាមពលកកើតឡើងវិញនៅក្នុងប្រទេស។

## ង. ផែនការអនាគត

**ផថខ** មានបំណងបន្តពង្រឹងជំហរទីផ្សាររបស់ខ្លួនលើផ្នែកបញ្ជូន និងចែកចាយថាមពលនៅប្រទេសកម្ពុជា និង បណ្តាប្រទេសនៅតំបន់ទន្លេមេគង្គដើម្បីបំពេញកំណើនតម្រូវការថាមពល។ ក្នុងពេលជាមួយគ្នានេះ ការធ្វើពិពិធកម្មវិស្វកម្មប្រព័ន្ធថាមពល និងដំណោះស្រាយបច្ចេកទេសរួមទាំង O&M នៃហេដ្ឋារចនាសម្ព័ន្ធថាមពលឱ្យល្អដើម្បី ផ្តល់ជូននូវដំណោះស្រាយថាមពលដ៏ទូលំទូលាយដល់អតិថិជន។

**ផថខ** ក៏មានបំណងបង្កើតរោងចក្រផលិតផលិតផលដើម្បីសម្រួលដល់សមាសធាតុប្រព័ន្ធថាមពលដើម្បីធ្វើ ពិពិធកម្មលំហូរចំណូលរបស់ខ្លួន។ មួយឆ្នាំបន្ទាប់ការចុះបញ្ជីលក់មូលបត្រជាសាធារណៈ **ផថខ** នឹងបន្តស្វែងយល់ឱកាសនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈបន្ថែមនៅផ្សារមូលបត្រប្រទេសថៃដើម្បីបង្កើនតម្លៃភាគហ៊ុនិករបស់ខ្លួន។

# ព័ត៌មានសាជីវកម្ម

**ផថខ** ខិតខំបញ្ចូលកម្មវិធីអភិវឌ្ឍន៍ប្រកបដោយចីរភាពផ្ដោតលើបរិបទសេដ្ឋកិច្ច បរិស្ថាន សង្គម និងអភិបាលកិច្ចក្នុងការអនុវត្តផែនការអាជីវកម្មនាពេលអនាគតរបស់ក្រុមហ៊ុន។ ការពង្រឹងនេះ គឺកើតចេញពីគំនិតច្នៃប្រឌិតថ្មី និងការស្រាវជ្រាវ និងអភិវឌ្ឍន៍ ដើម្បីនាំមកនូវថាមពលកកើតឡើងវិញដែលមានប្រសិទ្ធភាពតាមរយៈការបង្កើតកសិដ្ឋានថាមពលពន្លឺព្រះអាទិត្យ ប្រព័ន្ធផ្ទុកថាមពល និងប្រព័ន្ធមីក្រូក្រាហ្វ ដើម្បីបង្កើត RE ថ្មីសម្រាប់អ្នកប្រើប្រាស់ និងនាំមកនូវការផ្គត់ផ្គង់ថាមពលប្រកបដោយនិរន្តរភាពដល់តំបន់ដាច់ស្រយាលតាមតំបន់ទន្លេមេគង្គ។

## ជ. កត្តាហានិភ័យ

### ១. ហានិភ័យអត្រាការប្រាក់

ហានិភ័យអត្រាការប្រាក់សំដៅលើហានិភ័យ ពីការប្រែប្រួលនៃអត្រាការប្រាក់នាពេលអនាគតដែលអាចរងឥទ្ធិពលអាក្រក់ដល់ការចំណាយហិរញ្ញប្បទានដល់ក្រុមហ៊ុន។ **ផថខ** មានសមត្ថភាពក្នុងការពង្រីកប្រតិបត្តិការអាជីវកម្មគឺពឹងផ្អែកលើសមត្ថភាពរបស់ខ្លួនក្នុងការបង្កើនហិរញ្ញប្បទានឱ្យបានគ្រប់គ្រាន់ ក្នុងទម្រង់នៃការផ្ដល់ហិរញ្ញប្បទានបំណុលខាងក្រៅ ហិរញ្ញប្បទានមូលធន ឬលំហូរសាច់ប្រាក់ដែលបង្កើតឡើងពីខាងក្នុង។

ពុំមានផលប៉ះពាល់ជាសារវន្តដល់ការប្រែប្រួលអត្រាការប្រាក់ទៅលើប្រាក់ចំណេញរបស់ក្រុមហ៊ុនជាប្រវត្តិ សាស្ត្រឡើយ។ ទោះយ៉ាងណា **ផថខ** បានចុះកិច្ចសន្យាប្ដូរអត្រាការប្រាក់ដើម្បីការពារក្រុមហ៊ុនពីការប្រឈមនឹងហានិភ័យអត្រាការប្រាក់លើប្រាក់កម្ចីរបស់ខ្លួន។ កិច្ចសន្យាប្ដូរអត្រាការប្រាក់ដែលផ្ដល់លទ្ធភាពឱ្យក្រុមហ៊ុនបង្កើនប្រាក់កម្ចីក្នុងអត្រាអណ្ដែតទៅជាអត្រាថេរ។

គណៈគ្រប់គ្រងនឹងបន្តវាយតម្លៃហានិភ័យអត្រាការប្រាក់ដោយយកចិត្តទុកដាក់ និងកំណត់ពីតម្រូវការក្នុងការចុះកិច្ចសន្យាការពារអត្រាការប្រាក់នាពេលអនាគត។

### ២. ហានិភ័យអត្រាប្ដូរប្រាក់

ហានិភ័យនៃការប្ដូររូបិយប័ណ្ណរបស់ **ផថខ** កើតឡើងដោយសារប្រតិបត្តិការជារូបិយប័ណ្ណផ្សេងទៀតក្រៅពី ប្រាក់ដុល្លារអាមេរិក។ គណៈគ្រប់គ្រងមានបទពិសោធន៍ច្រើនក្នុងការទិញសំភារៈ និង/ឬឧបករណ៍ និងតាមដានជានិច្ចនូវនិន្នាការទី ផ្សារលើតម្លៃសម្ភារៈ និង/ឬឧបករណ៍ដើម្បីធានាថាការប្រឈមមុខនឹងហានិភ័យនៃការប្ដូរប្រាក់បរទេសត្រូវ បានរក្សាក្នុងកម្រិតតិចតួចបំផុត។

ទោះយ៉ាងណាក្ដីខាងលើនេះពុំមានការធានាថាការប្រែប្រួលអត្រាប្ដូរប្រាក់បរទេសនាពេលអនាគតនឹងមិនជះឥទ្ធិពលអាក្រក់ដល់ដំណើរការហិរញ្ញវត្ថុរបស់ក្រុមហ៊ុនឡើយ។

### ៣. ហានិភ័យផ្នែកឧស្សាហកម្ម ហានិភ័យដែលទាក់ទងនឹងការប្រែប្រួលនៅក្នុងបរិបទជាតិ និងអន្តរជាតិ និងការកែប្រែវិធាន និងបទប្បញ្ញត្តិនានា

#### i. ការពឹងផ្អែកលើតម្រូវការសម្រាប់ការផ្គត់ផ្គង់អគ្គិសនីដែលអាចជឿទុកចិត្តបាន មានសុវត្ថិភាព និងគ្រប់គ្រាន់

អតិថិជនរបស់ ផថខ ភាគច្រើនជាក្រុមហ៊ុនផ្ដល់សេវាកម្មសាធារណៈឧស្សាហកម្ម និងសម្បទានហេដ្ឋារចនាសម្ព័ន្ធថាមពលដែលផ្ដល់កិច្ចសន្យាការងារហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីពាក់ព័ន្ធ។ ដូច្នេះដំណើរការអាជីវកម្មត្រូវបានផ្សាភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងល្បឿននៃកំណើនសេដ្ឋកិច្ចសង្គមនៃតំបន់ដែលអាស្រ័យលើតម្រូវការរបស់ប្រជាជាតិនីមួយៗ

រាល់ឱនភាពនៃការពង្រីក ឬការធ្វើឱ្យហេដ្ឋារចនាសម្ព័ន្ធថាមពលមានភាពប្រសើរឡើងនៅក្នុងតំបន់ដែលបណ្ដាលមកពីកំណើនសេដ្ឋកិច្ច និងភាពអវិជ្ជមាននៃសង្គមនឹងរងឥទ្ធិពលដោយចំពោះដល់ប្រតិបត្តិការអាជីវកម្ម និងការរំពឹងទុករបស់ក្រុមហ៊ុន។

នៅបណ្ដាប្រទេសភាគច្រើន ជាពិសេសប្រទេសកំពុងអភិវឌ្ឍន៍នៅក្នុងតំបន់ ជាទូទៅនឹងមានតម្រូវការថាមពលជាមូលដ្ឋានស្របគ្នានឹងកំណើនសេដ្ឋកិច្ច និងសកម្មភាពកំណែទម្រង់លទ្ធភាពប្រើប្រាស់ថាមពលទូទៅ។

# ព័ត៌មានសាជីវកម្ម

នេះគឺជាបញ្ហាប្រឈមមួយសម្រាប់ប្រទេសមិនទាន់អភិវឌ្ឍន៍ និងកំពុងអភិវឌ្ឍជាច្រើន ក្នុងការបន្តវិនិយោគលើបណ្តាញអគ្គិសនី ដើម្បីផ្តល់នូវការផ្គត់ផ្គង់អគ្គិសនីដែលអាចទុកចិត្តបាន និងមានសុវត្ថិភាពដល់ប្រជាពលរដ្ឋ និងឧស្សាហកម្មរបស់ខ្លួន។

ជាមួយនឹងការបន្ធូរបន្ថយ **ផថខ** កំពុងខិតខំពង្រីកសេវាកម្មរបស់ក្រុមហ៊ុន ដល់អ្នកប្រើប្រាស់នៅទូទាំងតំបន់ និងបណ្តាប្រទេសដូចជាប៉ាពួញូហ្គីណេ មីយ៉ាន់ម៉ា និងកូតឌីវ័រ ដើម្បីធ្វើពិពិធកម្មមូលដ្ឋានអតិថិជនរបស់ក្រុមហ៊ុន។

### ii. បម្រែបម្រួលស្ថានភាពនយោបាយ សង្គម និងនិយ័តកម្មនៅក្នុងប្រទេសកម្ពុជា និងប្រទេសដទៃទៀត ដែលយើងអាចនឹងដំណើរការនៅទីនោះ

**ផថខ** ងាយនឹងទទួលយកនូវកំណែទម្រង់ស្ថានភាពនយោបាយ និងបទប្បញ្ញត្តិនៅក្នុងប្រទេសកម្ពុជា ក៏ដូចជាបណ្តាប្រទេសដទៃទៀតដែលយើងអាចនឹងដំណើរការនាពេលអនាគត។ ស្ថានភាពមិនល្អនៅក្នុងប្រទេសដែលអាចបណ្តាលឱ្យមានការរំខានជាខ្លាំងដល់សកម្មភាពអាជីវកម្ម ដូច្នេះ នឹងមានផលប៉ះពាល់ដល់ដំណើរការហិរញ្ញវត្ថុ និងប្រាក់ចំណេញ។ ស្ថានភាពទាំងនោះរួមមានជាអាទិ៍ បរិយាកាស សេដ្ឋកិច្ចទាំងក្នុងស្រុកនិងជាសាកលនាពេលបច្ចុប្បន្ន អតិផរណា លក្ខខណ្ឌឥណទាន ការដឹកនាំនយោបាយ បទបញ្ញានិងគោលនយោបាយរបស់រដ្ឋាភិបាល ហានិភ័យសង្គ្រាម វិធីសាស្ត្រហូតពន្ធជាតូបនីយកម្ម អស្សាមិករណ៍ និងការចរចាឡើងវិញ ឬការលុបចោលកិច្ចសន្យាដែលមានស្រាប់។

**ផថខ** បានប្រកាន់យកវិធីសាស្ត្រសកម្មនិយមក្នុងការតាមឱ្យទាន់ការអភិវឌ្ឍន៍សេដ្ឋកិច្ចនយោបាយ សង្គម និងបទប្បញ្ញត្តិនៅក្នុងប្រទេសកម្ពុជា ក៏ដូចជាប្រទេសដទៃទៀតដែលយើងអាចធ្វើប្រតិបត្តិការ នាពេលអនាគត។

ទោះយ៉ាងណាប្រភេទអាជីវកម្ម និងយុទ្ធសាស្ត្រមិនតម្រូវឱ្យ ផថខ ធ្វើការវិនិយោគទុនជាសារវន្តដើម្បី ចាត់ចែងអាជីវកម្មឡើយ។ ដោយ ផថខ បានរំពឹងថានឹងទទួលរងផលប៉ះពាល់ពីកត្តាអវិជ្ជមានតិចតួច ខាងផ្នែកនយោបាយ សេដ្ឋកិច្ចសង្គម និងបទប្បញ្ញត្តិដោយជឿជាក់ថានឹងអាចសម្របខ្លួនទៅនឹងភាពប្រែប្រួលដោយសារតម្រូវការដើមទុនអប្បបរិមា និងការធ្វើពិពិធកម្មភូមិសាស្ត្រ។

## ៤. ហានិភ័យផ្នែកប្រតិបត្តិការ

### i. ហានិភ័យផ្នែកប្រតិបត្តិការប្រចាំថ្ងៃ និងទំហំធានារ៉ាប់រង

ដោយ **ផថខ** បានចូលរួមក្នុងវិស័យឧស្សាហកម្មផ្គត់ផ្គង់អគ្គិសនី ដូច្នេះសកម្មភាពអាជីវកម្មងាយប្រឈមនឹងហានិភ័យប្រតិបត្តិការ។ ហានិភ័យក្នុងប្រតិបត្តិការប្រចាំថ្ងៃរួមមានហានិភ័យគ្រោះថ្នាក់ ភាពរអាក់រអួលក្នុងការផ្គត់ផ្គង់សមាសធាតុសំខាន់ៗ ការផ្គត់ផ្គង់ឧបករណ៍ប្រើប្រាស់ ក៏ដូចជាអគ្គីភ័យ ទឹកជំនន់ និង/ឬ គ្រោះធម្មជាតិ ផ្សេងទៀតដែលអាចបណ្តាលឱ្យមានការរំខាន ឬពន្យារពេលក្នុងការអនុវត្តគម្រោង ហើយក៏អាចបណ្តាលឱ្យខូចខាតដល់សម្ភារៈ និងឧបករណ៍ដែលអាចរំខានដល់ប្រតិបត្តិការអាជីវកម្មរបស់ខ្លួន។ ថែមពីលើនេះ ដោយសារគម្រោងពាក់ព័ន្ធនឹងការប្រើប្រាស់ឧបករណ៍ធុនធ្ងន់ និងគ្រឿងម៉ាស៊ីនដែល ផថខ អាចប្រឈមមុខនឹងឧបទ្ទវហេតុ ឬគ្រោះថ្នាក់នៅការដ្ឋានគម្រោង។

**ផថខ** ព្យាយាមដាក់កំហិតលើហានិភ័យមួយចំនួនដូចមានរៀងរាប់ខាងលើតាមរយៈវិធីសាស្ត្រគ្រប់គ្រងហានិភ័យដូចខាងក្រោម៖

- ជូនបុគ្គលិកគ្រប់រូបនូវប័ណ្ណសន្យាធានារ៉ាប់រងលើឧប្បទ្ទវហេតុផ្ទាល់ខ្លួន
- ការដ្ឋានគម្រោងត្រូវអនុលោមតាមលក្ខខណ្ឌតម្រូវផ្នែកសុវត្ថិភាពដែលមានចែងនៅក្នុងអាជ្ញាប័ណ្ណដែលបានចេញដោយអាជ្ញាធរពាក់ព័ន្ធ និងនីតិវិធីការងារផ្ទៃក្នុងដែលបានអនុម័ត។
- បង្កើតនីតិវិធីអនុវត្តគម្រោងផ្ទៃក្នុង និងការគ្រប់គ្រងខ្សែសង្វាក់ផ្គត់ផ្គង់ដើម្បីធានាបាននូវប្រតិបត្តិការ អាជីវកម្មប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។
- ការបណ្តុះបណ្តាលនៅខាងក្នុងក្រុមហ៊ុន និងការពន្យល់សង្ខេបអំពីភាពចាំបាច់ផ្នែកសុវត្ថិភាព និងការប្រើប្រាស់ឧបករណ៍យ៉ាងត្រឹមត្រូវបានធ្វើឡើងដើម្បីធានាថានិយោជិតទទួលបានការបណ្តុះបណ្តាលយ៉ាងសមស្របដើម្បីកាត់បន្ថយហានិភ័យនៃឧប្បទ្ទវហេតុនៅលើការដ្ឋានគម្រោងឱ្យដល់កម្រិតអប្បបរមា។ និង

# ព័ត៌មានសាជីវកម្ម

- ធានានូវសម្ភារៈផ្គត់ផ្គង់ពីសហគ្រិនស្របតាមប្រភេទគម្រោង និងសម្ភារៈទាំងនោះត្រូវបានទទួលការធានាគុណភាព។ គម្រោងទាំងអស់មានធានារ៉ាប់រងពេញលេញ ដើម្បីបង្ការការខូចខាត និងឧប្បទ្ទវហេតុជាសក្តានុពល។

## ii. ការបំពេញការងារតាមគម្រោង

ការបំពេញការងាររបស់ ផថខ គឺធ្វើឡើងតាមគម្រោង។ សមត្ថភាពនៅក្នុងការបង្កើនកិច្ចសន្យានាពេល អនាគតគឺអាស្រ័យលើ ក្នុងចំណោមស្ថានភាពដទៃទៀត ស្ថានភាពនយោបាយរបស់រដ្ឋាភិបាល និងសេដ្ឋកិច្ចទូទៅតម្រូវការក្នុងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធសម្រាប់ឧស្សាហកម្មផ្គត់ផ្គង់អគ្គិសនីនៅក្នុងតំបន់ និងបម្រែបម្រួលនៃលក្ខខណ្ឌធ្វើអាជីវកម្មទូទៅ និងលក្ខខណ្ឌឥណទានទាំងនៅក្នុងប្រទេស និងនៅក្រៅប្រទេស។

លើសពីនេះទៀត ការបំពេញការងាររបស់ **ផថខ** នៅក្នុងឆ្នាំហិរញ្ញវត្ថុជាក់លាក់មួយអាចពឹងផ្អែកខ្លាំងលើគម្រោងតែមួយគត់ និងដំណាក់កាលនៃការអនុវត្តគម្រោងរបស់ខ្លួន។

**ផថខ** ចាត់វិធានការចាំបាច់នានាដើម្បីបង្កើតមូលដ្ឋានអតិថិជនដ៏ទូលំទូលាយមួយនៅក្នុងតំបន់ដោយសារតែសេវាកម្ម និងផលិតផលរបស់យើងមានតម្រូវការប្រហាក់ប្រហែលគ្នានៅគ្រប់ប្រទេសទាំងអស់នៅក្នុងតំបន់។ យើងខិតខំប្រឹងប្រែងធានាឱ្យបាននូវសេចក្តីពេញចិត្តរបស់អតិថិជន ការថែរក្សាអតិថិជន និងការណែនាំបន្តឱ្យមានកម្រិតខ្ពស់៖

- ស្នើផ្តល់ដំណោះស្រាយ ឬសេវាកម្មដែលមានបន្ថែមគុណតម្លៃដល់អតិថិជនរបស់ខ្លួនតាមរយៈបរិក្ខារធ្វើតេស្តនៅក្នុងក្រុមហ៊ុនដែលមានភាពគ្រប់ជ្រុងជ្រោយសម្រាប់ការដាក់ឱ្យដំណើរការអនុស្ថានីយ៍ និង
- ផ្តល់ដំណោះស្រាយយ៉ាងសមស្របដល់អតិថិជនដែលមាននៅក្នុងដៃ និងធានាថាអតិថិជនពេញចិត្តនឹងគុណភាព សេវាកម្មគម្រោង និងការអនុវត្តទាន់ពេលវេលា។

## iii. ហានិភ័យផ្នែកគម្រោង

ប្រាក់ចំណូលរបស់ **ផថខ** ភាគច្រើនមានប្រភពចេញពីគម្រោងដែលបានអនុវត្តកិច្ចសន្យាដោយស្របតាមខចែង និងលក្ខខណ្ឌមួយចំនួន។ ប្រសិនបើគម្រោងរបស់ខ្លួនមានភាពយឺតយ៉ាវបណ្តាលមកពីកត្តាផ្សេងៗដែលយើង ត្រូវទទួលខុសត្រូវទៅតាមកិច្ចសន្យានោះ ជាពិសេសកត្តាដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រុមហ៊ុន នោះ **ផថខ** នឹងទទួលខុសត្រូវលើការទូទាត់សំណងព្រាងទុក និងសំណងខូចខាតដែលបានកំណត់មុនលើការបញ្ឈប់ ឬភាពយឺតយ៉ាវនោះ។ ដូច្នេះភាពយឺតយ៉ាវណាមួយអាចជះឥទ្ធិពលដល់លទ្ធភាពនៅក្នុងការបញ្ចប់គម្រោង និងសម្រេចគោលដៅប្រាក់ចំណូល និងផែនការអាជីវកម្មនៅក្នុងរយៈពេលជាក់លាក់មួយ។ ការលំបាកដែលត្រូវប្រឈមនៅក្នុងការអនុវត្តគម្រោងក៏អាចបណ្តាលឱ្យមានការចំណាយកើនឡើងកាន់តែខ្ពស់ផងដែរ។ ជាលទ្ធផលប្រភេទការអភិវឌ្ឍន៍ទាំងនេះអាចមានផលប៉ះពាល់ជាអវិជ្ជមានចំពោះអាជីវកម្ម ស្ថានភាពហិរញ្ញវត្ថុ និងលទ្ធផលប្រតិបត្តិការ។

ក្រៅពីការលើកឡើងដូចបានរៀបរាប់ខាងលើ គម្រោងរបស់យើងអាចប្រឈមនឹងការលុបចោល ការពន្យារពេល ឬការកែប្រែកាលវិភាគដែលអាចជះឥទ្ធិពលលើលទ្ធភាពក្នុងការទទួលបានប្រាក់ចំណេញដែលបានរំពឹងទុក។ លើសពីនេះទៀត ការបញ្ឈប់គម្រោងសំខាន់ៗណាមួយនឹងមានផលប៉ះពាល់ជាអវិជ្ជមានចំពោះប្រាក់ចំណូលនាពេលអនាគត។

ចំពោះស្ថានភាពដែលយើងមិនអាចគ្រប់គ្រងបានដូចជា អាកាសធាតុមិនអំណោយផល និង/ឬទឹកជំនន់ ការពន្យារពេលបែបនោះនឹងត្រូវបានប៉ះប៉ូវដោយអតិថិជនតាមរយៈការពន្យារពេលបញ្ចប់គម្រោង។ លើសពីនេះទៀត ស្របតាមលក្ខខណ្ឌនៃកិច្ចសន្យាជាមួយអតិថិជន ភាគច្រើនអតិថិជនអាចស្នើសុំឱ្យមានការកែប្រែព័ត៌មានលម្អិតនៃកិច្ចសន្យាដែលអាចបណ្តាលមកពីព្រឹត្តិការណ៍មិនបានរំពឹងទុកដែលជះឥទ្ធិពលដល់គម្រោងទាំងនោះ។ ជាទូទៅការទាមទារប្រាក់សម្រាប់ការងារដែលបានធ្វើមុនពេលលុបចោល ឬបញ្ឈប់ នឹងបានផ្តល់ជូនក្នុងកិច្ចសន្យា។

# ព័ត៌មានសាជីវកម្ម

គម្រោងទាំងអស់គឺផ្អែកលើកិច្ចព្រមព្រៀងតាមកិច្ចសន្យា។ ការលុបចោល និងការបញ្ឈប់គម្រោងណាមួយ នឹងត្រូវអនុវត្តតាមដោយយោងតាមលក្ខខណ្ឌដែលបានកំណត់ក្នុងកិច្ចសន្យា។ ជាទូទៅសំណងទាមទារសម្រាប់ការងារដែលបានធ្វើមុនពេលលុបចោល ឬបញ្ឈប់បែបនោះនឹងបានផ្តល់ជូននៅក្នុងកិច្ចសន្យា។

លើសពីនេះទៀត **ផថខ** នឹងស្នើសុំយោបល់ផ្នែកច្បាប់មុនពេលចុះកិច្ចសន្យាណាមួយដើម្បីធានាដល់កិច្ចការពារផលប្រយោជន៍របស់ក្រុមហ៊ុន។

## iv. ការពឹងផ្អែក និងអសមត្ថភាពក្នុងការក្សានាយកប្រតិបត្តិ និងបុគ្គលិកជាន់ខ្ពស់

**ផថខ** ជឿជាក់ថាភាពជោគជ័យជាបន្តបន្ទាប់របស់ក្រុមហ៊ុនមួយផ្នែកធំ គឺពឹងផ្អែកលើសមត្ថភាព ភាពអង់អាច និងកិច្ចខិតខំប្រឹងប្រែងជាបន្តបន្ទាប់របស់នាយកប្រតិបត្តិ និងបុគ្គលិកជាន់ខ្ពស់នៅក្នុងការធ្វើទីផ្សារសេវាកម្ម និងផលិតផល ដើម្បីធ្វើឱ្យអាជីវកម្ម មានភាពរីកចម្រើន។ ក្រុមហ៊ុនបានដឹកនាំដោយអភិបាលដែលមានបទពិសោធន៍ និងគ្រប់គ្រងដោយក្រុមបុគ្គលិកជាន់ខ្ពស់ដែលមានគុណវុឌ្ឍិ ចំណេះដឹង និងបទពិសោធន៍ដ៏ទូលំទូលាយខាងផ្នែកឧស្សាហកម្មនេះ។

ហេតុនេះ ការបាត់បង់អភិបាល និងបុគ្គលិកជាន់ខ្ពស់ណាម្នាក់អាចជះឥទ្ធិពលដល់សមត្ថភាពក្នុងការអនុវត្ត សកម្មភាពអាជីវកម្មប្រកបដោយប្រសិទ្ធភាព។

ក្រុមប្រឹក្សាភិបាលរបស់យើងទទួលស្គាល់អំពីសារសំខាន់នៃសមត្ថភាពរបស់ក្រុមហ៊ុនក្នុងការទាក់ទាញថែរក្សានាយកប្រតិបត្តិ និងបុគ្គលិកជាន់ខ្ពស់តាមរយៈការ អនុវត្តយុទ្ធសាស្ត្រផ្នែកធនធានមនុស្សដែលរួមបញ្ចូលកញ្ចប់ប្រាក់បំណាច់ដ៏សមរម្យ និងការចាប់ផ្តើមរៀបចំផែនការបន្តតំណែងសម្រាប់មុខតំណែងសំខាន់ៗ។

លើសពីនេះទៀត **ផថខ** បានអនុវត្តការគ្រប់គ្រងនិរន្តរភាពអាជីវកម្មដើម្បីធានាដល់ដំណើរការអាជីវកម្មដោយគ្មានការរាំងស្ទះ។

ទោះបីជាយ៉ាងណាក៏ដោយ មិនអាចមានការបញ្ជាក់ថាវិធីសាស្ត្រខាងលើនឹងទទួលបានជោគជ័យនៅក្នុងការទាក់ទាញ និងការថែរក្សានាយកប្រតិបត្តិ និងបុគ្គលិកជាន់ខ្ពស់របស់យើងនោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ ជឿជាក់ថា ការបាត់បង់នាយកប្រតិបត្តិ ឬបុគ្គលិកជាន់ខ្ពស់ណាម្នាក់នឹងមានផលប៉ះពាល់ដល់សកម្មភាពអាជីវកម្មក្នុងរយៈពេលខ្លីប៉ុណ្ណោះ។

ភាពពឹងផ្អែកលើក្រុមហ៊ុនពាក់ព័ន្ធនឹងសម្ព័ន្ធក្រុមហ៊ុន PESTECH International Berhad Group ( “PESTECH Group” )

**ផថខ** បានពង្រឹងសមត្ថភាព និងចំណេះដឹងពីបទពិសោធន៍ក្រុមហ៊ុនពាក់ព័ន្ធផ្សេងទៀតនៅក្នុងសម្ព័ន្ធ PESTECH។ ការណ៍នេះធ្វើឱ្យ **ផថខ** អាចជួយពន្លឿនការរីកចម្រើនរបស់ក្រុមហ៊ុនដោយមានការគាំទ្រពីសម្ព័ន្ធ PESTECH ដែលបង្កើតឱ្យ **ផថខ** ត្រូវពឹងផ្អែកតាមផ្នែកនៃជំនាញរបស់ក្រុមហ៊ុនពាក់ព័ន្ធផ្សេងទៀតដើម្បីផ្តល់សេវាកម្មរបស់ក្រុមហ៊ុនដល់អតិថិជន។

ទោះយ៉ាងណាក៏ដោយ ការពឹងផ្អែកនេះ គឺផ្តល់ផលប្រយោជន៍ដល់ ផថខ ក្នុងការពង្រីកវិសាលភាពសេវាកម្មរបស់ ផថខ ដល់អតិថិជនរបស់ក្រុមហ៊ុនដោយពង្រឹងសមត្ថភាព និងការយល់ដឹងពីក្រុមក្នុងស្រុក និងធ្វើឱ្យតម្លៃបន្ថែមដល់អតិថិជនរបស់ក្រុមហ៊ុន។

## v. ហានិភ័យនៃការប្រើប្រាស់បច្ចេកទេសរបស់ភាគីទីបី

នៅក្នុងដំណើរការនៃការអនុវត្តគម្រោង **ផថខ** ចាំបាច់ត្រូវប្រើប្រាស់បរិក្ខារ ឬផលិតផលរបស់ភាគីទីបី។ ប្រសិនបើបរិក្ខារ ឬផលិតផលទាំងនោះមានបញ្ហាគុណភាព **ផថខ** អាចចាំបាច់ត្រូវស្នើសុំជំនួយបច្ចេកទេសពីរោងចក្រដើមដើម្បីជួយដោះស្រាយបញ្ហាទាំងនោះ។ ទោះបីជា តាមធម្មតារោងចក្រមានក្រុមអ្នកជំនាញមួយក្រុមដែលត្រៀមជាស្រេចក្នុងការផ្តល់ជំនួយសម្រាប់កាលៈទេសៈទាំងនេះក៏ដោយ **ផថខ** មិនអាចធានាបានថាជំនួយនោះអាចទទួលបានទាន់ពេល និងប្រកបដោយប្រសិទ្ធិផលជានិច្ចឡើយ។

**ផថខ** ធានាថាសមាសធាតុ ឬបរិក្ខាររបស់ភាគីទីបី គឺមានម៉ាកសញ្ញាដែលមានកំណត់ត្រាតាមដានដែលជឿទុកចិត្តបានលើគុណភាពបរិក្ខារ ឬផលិតផលរបស់ពួកគេ ដើម្បីកាត់បន្ថយហានិភ័យលើបញ្ហាគុណភាពដែលកើតឡើង។ លើសពីនេះទៀត ការគ្រប់គ្រងខ្សែសង្វាក់ផ្គត់ផ្គង់របស់ក្រុមហ៊ុនតម្រូវឱ្យមានការចុះបញ្ជីអ្នកផ្គត់ផ្គង់ ការពិនិត្យតាមដានអំពីវឌ្ឍនភាព និងការត្រួតពិនិត្យដល់ទីកន្លែងរោងចក្រដើម្បីធានានូវគុណភាពផលិតផល និងការទទួលបានទាន់ពេលវេលា។

# ព័ត៌មានសាជីវកម្ម

### vi. ការពឹងផ្អែកលើអតិថិជនធំៗ

ដោយសារតែចំណូលទទួលបានជាចម្បងពីគម្រោង ផថខ អាចពឹងផ្អែកលើគម្រោងមួយចំនួន ដោយតាមរយៈអតិថិជនមួយចំនួននៅក្នុងអំឡុងពេលជាក់លាក់។

**ផថខ** មិនបានរំពឹងទុកថានឹងត្រូវពឹងផ្អែកលើអតិថិជនជាក់លាក់ណាម្នាក់ម្តងហើយម្តងទៀតនោះទេ វាគឺជាលក្ខណៈនៃអាជីវកម្មដែលអាចនឹងត្រូវពឹងផ្អែកលើអតិថិជនជាក់លាក់ណាម្នាក់នៅពេលណាមួយ នៅថ្ងៃអនាគត។ ការបាត់បង់អតិថិជនណាម្នាក់ក្នុងចំណោមអតិថិជនទាំងនេះ ប្រសិនបើពុំមានអតិថិជន ថ្មីចូលមកជំនួសទេនោះនឹងជះឥទ្ធិពលជាអវិជ្ជមានចំពោះស្ថានភាពហិរញ្ញវត្ថុ និងលទ្ធផលនៃដំណើរការ ទោះបីជាយ៉ាងណាក៏ដោយក្រុមប្រឹក្សាភិបាលមានទស្សនៈថាហានិភ័យទាំងនេះ នឹងត្រូវបានកាត់បន្ថយនូវកម្រិតជាក់លាក់មួយតាមរយៈវិធីសាស្ត្រដូចខាងក្រោម៖

- កំណត់ត្រាតាមដានអំពីការផ្តល់ដំណោះស្រាយដែលបន្ថែមគុណតម្លៃ និងសេវាដែលមានគុណភាព ល្អបានធានាចំពោះការថែរក្សាអតិថិជន និងការណែនាំបន្ត។ និង
- តាមរយៈការទទួលបានកិច្ចសន្យាកាន់តែច្រើនពីអតិថិជនខុសៗគ្នា ហើយតាមរយៈកិច្ចសន្យាទាំង នោះវាបំពេញបន្ថែមឱ្យការងារគម្រោង ហើយអាចកាត់បន្ថយការពឹងផ្អែកលើអតិថិជនណាម្នាក់ឱ្យដល់កម្រិតអប្បបរមានាថ្ងៃអនាគត។

លើសពីនេះទៀត ក្រុមហ៊ុនបានថែរក្សា និងខិតខំប្រឹងប្រែងបន្តទៀតដើម្បីបំពេញតាមការរំពឹងទុករបស់អតិថិជនតាមរយៈការធ្វើការងារស្របតាមលក្ខខណ្ឌតម្រូវរបស់ពួកគេដើម្បីធ្វើឱ្យគុណភាពសេវាមានភាពល្អប្រសើរឡើងបន្ថែមទៀត។ ទោះបីជាយើងខិតខំប្រឹងប្រែងពង្រីកមូលដ្ឋានអតិថិជនឱ្យកាន់តែទូលំទូលាយក៏ដោយ ក៏ពុំមានការធានាថាស្ថានភាពហិរញ្ញវត្ថុ និងប្រតិបត្តិការនានារបស់ក្រុមហ៊ុននឹងមិនទទួលរងផលប៉ះពាល់ជាអវិជ្ជមានពីការពឹងផ្អែកលើអតិថិជនធំៗនោះទេ។

### vii. ការពឹងផ្អែកលើអាជ្ញាប័ណ្ណលិខិតអនុញ្ញាត និងការអនុម័តពាក់ព័ន្ធផ្សេងទៀតចេញដោយអាជ្ញាធរ និយ័តកម្មផ្សេងៗក្នុងប្រទេសកម្ពុជា

**ផថខ** បានតម្រូវដោយអាជ្ញាធរនិយ័តកម្ម នៅក្នុងប្រទេសដែលយើងកំពុងតែដំណើរការអាជីវកម្មនៅទីនោះឱ្យកាន់កាប់អាជ្ញាប័ណ្ណលិខិតអនុញ្ញាត និងការអនុម័តផ្សេងទៀតដូចដែលត្រូវបានតម្រូវដើម្បី ដំណើរការអាជីវកម្ម។ ការកំណែទម្រង់ច្បាប់ បទប្បញ្ញត្តិ និងគោលនយោបាយរបស់រដ្ឋាភិបាលអាចជះ ឥទ្ធិពលដល់ដំណើរការ ជាពិសេសសេចក្តីសម្រេចដែលធ្វើឡើងដោយរដ្ឋាភិបាល ឬអាជ្ញាធរនិយ័តកម្ម ទាក់ទងនឹងការផ្តល់ ឬការបន្តអាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតអាចរំខានដល់ដំណើរការ និងមានផលប៉ះពាល់អវិជ្ជមានយ៉ាងខ្លាំងដល់អាជីវកម្ម និងស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។ ទោះបីជាទទួលបានអាជ្ញាប័ណ្ណ លិខិតអនុញ្ញាត និងការអនុម័តដែលបានតម្រូវរួចរាល់ហើយក៏ដោយ ក៏នៅតែត្រូវទទួលការត្រួតពិនិត្យឡើងវិញជានិច្ចស្របតាមច្បាប់ និងបទប្បញ្ញត្តិដែលពាក់ព័ន្ធដែលការអនុវត្តនោះអាចមានកំណែទម្រង់ពីមួយគ្រាទៅមួយគ្រា។

**ផថខ** នឹងបន្តអនុវត្តច្បាប់ និងបទប្បញ្ញត្តិនានានៅក្នុងប្រទេសដែលកំពុងដំណើរការអាជីវកម្មដោយធានាថានឹងទទួលការត្រួតពិនិត្យឡើងវិញលើបទប្បញ្ញត្តិ លក្ខខណ្ឌដែលត្រូវបានដាក់ជូន និងសេចក្តីណែនាំថ្មីៗជាបន្តបន្ទាប់។ ទោះបីជាយ៉ាងណាក៏ដោយពុំមានការធានាថាកិច្ចខិតខំប្រឹងប្រែងគឺគ្រប់គ្រាន់សម្រាប់កាត់បន្ថយហានិភ័យទាំងនោះទេ។

## ៥. ហានិភ័យនៃការមិនដំណើរការ

### i. ហានិភ័យផ្នែកហិរញ្ញវត្ថុរួមបញ្ចូលទាំងហានិភ័យសន្ទនីយភាព និងហានិភ័យឥណទាន ហានិភ័យ សន្ទនីយភាព

ហានិភ័យផ្នែកហិរញ្ញវត្ថុរួមបញ្ចូលទាំងហានិភ័យសន្ទនីយភាព (liquidity risk) និងហានិភ័យផ្នែកឥណទានហានិភ័យសន្ទនីយភាព (liquidity risk) គឺជាហានិភ័យដែលក្រុមហ៊ុននឹងជួបការលំបាកក្នុងការបង្កើនមូលនិធិដើម្បីបំពេញតាមការសន្យាទូទាត់ប្រាក់ក្នុងរយៈពេលខ្លី។

# ព័ត៌មានសាជីវកម្ម

**ផថឌ** ប្រឈមមុខនឹងហានិភ័យសន្ទនីយភាព ដោយទូទៅយើងពន្យារពេលផ្តល់ឥណទានជូនអតិថិជន និងនៅក្នុងករណីមួយចំនួននឹងទទួលបានការទូទាត់ប្រាក់នៅក្រោយពេលបញ្ចប់ការសាងសង់ប៉ុណ្ណោះ។ ជាលទ្ធផលអាចជាប្រឈមមុខនឹងហានិភ័យសន្ទនីយភាពប្រសិនបើមិនអាចផ្តល់មូលនិធិសម្រាប់ចំណាយលើការសាងសង់ និងការទិញគ្រឿងម៉ាស៊ីនបរិក្ខារសម្រាប់ប្រើប្រាស់នៅក្នុងគម្រោងបានទេនោះ។

**ផថឌ** ព្យាយាមរក្សាសាច់ប្រាក់ និងសមមូលនៃសាច់ប្រាក់ឲ្យបានគ្រប់គ្រាន់ដើម្បីបំពេញតាមតម្រូវការនៃទុនបង្វិលក្រោយពេល IPO និងក៏នឹងបន្តរក្សាទំនាក់ទំនងល្អជាមួយស្ថាប័នហិរញ្ញវត្ថុនានាផងដែរ។

គោលនយោបាយរបស់ក្រុមហ៊ុនគឺពិនិត្យតាមដានជាទៀងទាត់លើតម្រូវការសន្ទនីយភាពបច្ចុប្បន្ន និងដែលបានរំពឹងទុកដើម្បីធានាបន្តបម្រុងសាច់ប្រាក់បានគ្រប់គ្រាន់ដើម្បីបំពេញតាមតម្រូវការសន្ទនីយភាពនៅក្នុងរយៈពេលខ្លី និងរយៈពេលវែង។

ក្រុមហ៊ុនក៏នឹងខិតខំប្រឹងប្រែងធ្វើឱ្យគម្រោងការទូទាត់ប្រាក់មានរយៈពេលវែងមានតុល្យភាពនឹងគម្រោងទូទាត់ប្រាក់មានរយៈពេលខ្លី ដើម្បីសម្រាលបន្ទុកសន្ទនីយភាពដល់ក្រុមហ៊ុន។

### *ហានិភ័យផ្នែកឥណទាន*

**ផថឌ** ប្រឈមមុខនឹងហានិភ័យផ្នែកឥណទានដោយតាមធម្មតាការចេញវិក្កយបត្រជូនអតិថិជនតាមដំណាក់កាលនៃការបញ្ចប់គម្រោង ឬផ្អែកតាមលក្ខខណ្ឌទូទាត់ប្រាក់ដែលបានកំណត់នៅក្នុងកិច្ចសន្យាជាមួយអតិថិជន។ លក្ខខណ្ឌទូទាត់ប្រាក់ធម្មតាបានចរចាគ្នាជាមុនរវាងភាគីនៃកិច្ចសន្យា។

ការជះឥទ្ធិពលនៃស្ថានភាពសេដ្ឋកិច្ចអវិជ្ជមាន ឬភាពលំបាកផ្នែកហិរញ្ញវត្ថុរបស់អតិថិជនអាចកាត់បន្ថយលទ្ធភាពអតិថិជនក្នុងការទូទាត់ប្រាក់សម្រាប់សេវានានា ឬបំពេញកាតព្វកិច្ចនៃកិច្ចសន្យារបស់ពួកគេ ឬធ្វើឱ្យពួកគេពន្យារពេលទូទាត់ប្រាក់ ឬបំពេញកាតព្វកិច្ចទាំងនោះ។ **ផថឌ** ពឹងផ្អែកលើអតិថិជនក្នុងការផេរប្រាក់ឱ្យបានទៀងទាត់ពេលវេលា។

**ផថឌ** មានការយល់ឃើញថាវិធីសាស្រ្តក្នុងការចេញវិក្កយបត្រ គឺស្របតាមស្តង់ដានៃឧស្សាហកម្មនេះ។ អតិថិជន ឬអ្នកប្រើប្រាស់ចុងក្រោយភាគច្រើនគឺជាក្រុមហ៊ុនដែលកាន់កាប់ដោយរដ្ឋ ហើយកន្លងមកទទួលបានការទូទាត់ប្រាក់បានទាន់ពេលវេលា។

ជាទូទៅ **ផថឌ** ផ្តល់លក្ខខណ្ឌឥណទានរយៈពេលវែងសម្រាប់តែអតិថិជនប៉ុណ្ណោះនៅខណៈពេលដែលមានការព្រមព្រៀងទូទាត់ប្រាក់ដោយផ្ទាល់ជាមួយអ្នកប្រើប្រាស់ចុងក្រោយដែលជាទូទៅជាក្រុមហ៊ុនផ្តល់សេវាសាធារណៈដែលកាន់កាប់ដោយរដ្ឋ។

## ii. តម្រូវការដើមទុននាពេលអនាគត នឹងតម្រូវឱ្យមានការផ្តល់ហិរញ្ញប្បទានបន្ថែម

យើងអាចចាំបាច់ត្រូវបង្កើនសាច់ប្រាក់បន្ថែមទៀតនាពេលអនាគត តាមរយៈហិរញ្ញប្បទានសាធារណៈ ឬឯកជន ដើម្បីគាំទ្រដល់ភាពរីកចម្រើននៃក្រុមហ៊ុនដើម្បីអនុវត្តការទិញនានាដើម្បីឆ្លើយតបទៅនឹង សម្ពាធនៃការប្រកួតប្រជែង និង/ឬដើម្បីទិញអាជីវកម្ម និងបច្ចេកវិទ្យាបន្ថែមទៀត។ ពុំមានការធានាថា ការបញ្ចូលសាច់ប្រាក់បន្ថែម ប្រសិនបើចាំបាច់នឹងអាចស្វែងរកបានដោយមានលក្ខខណ្ឌអំណោយផល នោះទេ។ លើសពីនេះទៀត ហិរញ្ញប្បទានតាមរយៈបំណុលណាមួយ ប្រសិនបើអាចស្វែងរកបានអាច មានការយល់ព្រមដែលមានលក្ខណៈរឹតត្បិតដែលអាចដាក់កំហិតលើភាពបត់បែននៃដំណើរការរបស់ក្រុមហ៊ុន។ ប្រសិនបើសាច់ប្រាក់បន្ថែមនោះត្រូវបានបង្កើនតាមរយៈការចេញទ្រព្យម្ចាស់ ឬលិខិតូ បករណ៍ដែលមានទំនាក់ទំនងនឹងទ្រព្យម្ចាស់នោះ ប្រាក់ចំណូលរបស់ក្រុមហ៊ុនក្នុងមួយភាគហ៊ុននឹងត្រូវ ថយចុះហើយភាគហ៊ុនិកអាចជួបប្រទះការថយចុះនៃការកាន់កាប់ភាគហ៊ុននៃទ្រព្យម្ចាស់របស់ពួកគេនៅក្នុងក្រុមហ៊ុន។ លើសពីនេះទៀតទ្រព្យម្ចាស់ ឬលិខិតូបរណ៍ដែលមានទំនាក់ទំនងនឹងទ្រព្យម្ចាស់បែប នោះអាចមានសិទ្ធិ ភាពអនុគ្រោះ ឬឫព្វសិទ្ធិលើភាគហ៊ុនដែលមានស្រាប់ផងដែរ។ ការខកខានក្នុងការ ទទួលបានសាច់ប្រាក់គ្រប់គ្រាន់ ផ្អែកតាមលក្ខខណ្ឌដែលអាចទទួលយកបាននឹងជះឥទ្ធិពលអវិជ្ជមាន ខ្លាំងចំពោះអាជីវកម្មភាពប្រកួតប្រជែង និងស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

# ព័ត៌មានសាជីវកម្ម

ផថខ ថែរក្សាទំនាក់ទំនងល្អជាមួយស្ថាប័នហិរញ្ញវត្ថុ ហើយស្របតាមការយល់ឃើញរបស់ក្រុមប្រឹក្សាភិបាលមានសន្ទស្សន៍ដ៏ល្អនៅក្នុងការបង្កើតទំនាក់ទំនងផ្នែកធនាគារជាមួយពួកគេប្រសិនបើមានការចាំបាច់។ លើសពីនេះទៀត ផថខ រំពឹងទុកថាតម្រូវការនៃការបញ្ចូលសាច់ប្រាក់តាមរយៈបំណុលនាពេលអនាគត ភាគច្រើនពាក់ព័ន្ធនឹងគម្រោងដែលមានប្រភពនៃការសងប្រាក់យ៉ាងច្បាស់លាស់។

## ៦. ហានិភ័យផ្នែកបណ្ដឹងវិវាទ និងបំណុលអនិមិត្ត

### i. ហានិភ័យផ្នែកបណ្ដឹងវិវាទ

ផថខ ពុំជាប់ពាក់ព័ន្ធនឹងបណ្ដឹងវិវាទណាមួយនៅក្នុងប្រទេសកម្ពុជានោះទេ។ ទោះយ៉ាងណាក៏ដោយ ក្រុមហ៊ុនអាចមានហានិភ័យនៃបណ្ដឹងវិវាទ និងចំណាត់ការក្នុងការអនុវត្តនិយ័តកម្មនានានៅក្នុងដំណើរការធម្មតានៃអាជីវកម្ម ជាពិសេស ពាក់ព័ន្ធនឹងការបំពានលើការយល់ព្រមនៃកិច្ចសន្យាណាមួយលក្ខខណ្ឌតម្រូវផ្នែកបរិស្ថាន និងការសាងសង់ដែលទាក់ទងនឹងគម្រោងលក្ខខណ្ឌតម្រូវនៃច្បាប់ពន្ធដារ និងច្បាប់ការងារ។

បណ្ដឹងវិវាទ និងចំណាត់ការក្នុងការអនុវត្តនិយ័តកម្មណាមួយ អាចបង្កការខូចខាតជាសក្ដានុពលដល់កេរ្តិ៍ឈ្មោះ និងអាចធ្វើឱ្យក្រុមហ៊ុនត្រូវប្រឈមនឹងទំនួលខុសត្រូវផ្នែកហិរញ្ញវត្ថុបង្វែរចំណាប់អារម្មណ៍ផ្នែកធនធាន និងការគ្រប់គ្រងរបស់យើងចេញពីការធ្វើអាជីវកម្មប្រចាំថ្ងៃ និងជះឥទ្ធិពលអវិជ្ជមានលើកេរ្តិ៍ឈ្មោះក្រុមហ៊ុន និងស្ថានភាពហិរញ្ញវត្ថុ។

ផថខ នាពេលបច្ចុប្បន្នមិនបានប្រឈមមុខនឹងបណ្ដឹងវិវាទណាមួយដែលអាចជះឥទ្ធិពលអវិជ្ជមានយ៉ាងធ្ងន់ ធ្ងរលើស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននោះទេ។ ផថខ តែងតែខិតខំប្រឹងប្រែងដំណើរការអាជីវកម្មដើម្បីធានាចំពោះការអនុវត្តតាមច្បាប់ដែលពាក់ព័ន្ធទាំងអស់ និងទម្លាប់អនុវត្តល្អបំផុតនៅក្នុងឧស្សាហកម្មនេះ។

### ii. វិវាទសារពើពន្ធ

នៅឆ្នាំ២០១១ អគ្គនាយកដ្ឋានពន្ធដារបានចេញលិខិតជូនដំណឹងស្តីពីការវាយតម្លៃពន្ធឡើងវិញរបស់ក្រុមហ៊ុន ដោយទាមទារឱ្យបង់លើប្រាក់រំដោះពន្ធលើប្រាក់ចំណេញ និងអាករលើតម្លៃបន្ថែម ដែលសរុបជាប្រាក់ចំនួន ៥៤៦ ៩៧១ ដុល្លារអាមេរិក (២ ២២២ ៣៤៤ ០១១ រៀល) សម្រាប់រយៈពេលចាប់ពីថ្ងៃទី១ ខែឧសភា ឆ្នាំ២០១១ ដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១១។

នៅឆ្នាំ២០១៥ អគ្គនាយកដ្ឋានពន្ធដារបានចេញលិខិតជូនដំណឹងស្តីពីការវាយតម្លៃពន្ធឡើងវិញរបស់ក្រុមហ៊ុន ដោយទាមទារឱ្យបង់លើប្រាក់រំដោះពន្ធលើប្រាក់ចំណេញ និងអាករលើតម្លៃបន្ថែមដែលសរុបជាប្រាក់ចំនួន ៤៩០ ៩១២ ដុល្លារអាមេរិក (១ ៩៩៤ ៥៧៥ ៧៨៥ រៀល) សម្រាប់រយៈពេលចាប់ពីថ្ងៃទី ១០ ខែមករា ឆ្នាំ២០១៣ ដល់ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣។

នៅឆ្នាំ២០១៧ អគ្គនាយកដ្ឋានពន្ធដារបានចេញលិខិតជូនដំណឹងស្តីពីការវាយតម្លៃពន្ធឡើងវិញរបស់ក្រុមហ៊ុន ដោយទាមទារឱ្យបង់លើប្រាក់រំដោះពន្ធលើប្រាក់ចំណេញ អាករលើតម្លៃបន្ថែម និងពន្ធកាត់ទុកលើសេវាកម្ម ១៤% ដែលសរុបជាប្រាក់ចំនួន ២៦៧ ៩៥៦ ដុល្លារអាមេរិក (១ ០៨៨ ៧០៤ ៨៣៩ រៀល) សម្រាប់ ឆ្នាំជាប់ពន្ធ ២០១០ ។

ជាការឆ្លើយតប ក្រុមហ៊ុនបានដាក់លិខិតតវ៉ាទៅអគ្គនាយកដ្ឋានពន្ធដារដើម្បីជំទាស់នឹងការវាយតម្លៃមិនត្រឹមត្រូវទាំងនេះ។ គណៈគ្រប់គ្រងចាត់ទុកលិខិតវាយតម្លៃទាំងនេះថាគ្មានមូលដ្ឋាន និងមិនសមហេតុផល និងប្រហែលតម្រូវបញ្ចប់លើវាយតម្លៃឡើងវិញនូវបញ្ហាពន្ធនេះ។ លើសពីនេះទៀត ផថខ បានចុះបញ្ជីលក់មូលបត្រជោគជ័យនៅលើផ្សារមូលបត្រកម្ពុជា ដូចនេះក្រុមហ៊ុននឹងទទួលបានការលើកទឹកចិត្តពន្ធដែលរួមទាំងសិទ្ធិក្នុងការលើកលែងពន្ធដែលបានវាយតម្លៃឡើងវិញដែលបានរៀបរាប់ខាងលើ ស្របតាមអនុក្រឹត្យស្តីពីការលើកទឹកចិត្តពន្ធលើវិស័យមូលបត្រ។

នៅថ្ងៃទី ២៦ ខែសីហាឆ្នាំ២០២១ ក្រុមហ៊ុនបានទទួលលិខិតលេខ ១៤៣៣១ ចេញដោយអគ្គនាយកដ្ឋានពន្ធដារដើម្បីលើកលែងបំណុលពន្ធទាំងអស់សម្រាប់រយៈពេលចាប់ពីឆ្នាំ២០១០ ដល់ឆ្នាំ២០១៧ ។

# ព័ត៌មានអំពី លទ្ធផលនៃប្រតិបត្តិការធុរកិច្ច

## ក. លទ្ធផលនៃប្រតិបត្តិការអាជីវកម្មតាមផ្នែក

កិច្ចសន្យាលើ វិស្វកម្ម លទ្ធកម្ម ការសាងសង់ និងការដាក់អោយដំណើរការ ("EPCC") សម្រាប់បណ្តាញអគ្គីសនី និងអនុស្ថានីយ៍ គឺជាកត្តាចូលរួមសំខាន់ចំពោះចំណូលប្រចាំឆ្នាំដែលមានប្រាក់ចំនួន ២៦០ ៨៤៥ លាន រៀល (ឆ្នាំហិរញ្ញវត្ថុ ២០២០៖ ១៩៣ ៨៤៥ លានរៀល) ដែលស្មើនឹងប្រមាណ ៩៥,៣% (ឆ្នាំហិរញ្ញវត្ថុ ២០២០ ៖ ៩៥,៥%) នៃចំណូលសរុប។

ការបំពេញបន្ថែមលើសេវាកម្ម EPCC ដែលជាប្រតិបត្តិការ និងសេវាថែទាំ "O&M" ដែលមានទំហំទឹកប្រាក់ប្រមាណ ១២ ៧៨៣ លានរៀល ឬ ៤,៧% នៃចំណូលសរុប (ឆ្នាំហិរញ្ញវត្ថុ ២០២០៖ ៩ ១៦៩ លានរៀល ឬ ៤,៥% )។ ការកើនឡើងនៃចំណូលពីប្រតិបត្តិការ និងសេវាថែទាំ " O&M " បើប្រៀបធៀបនឹង ឆ្នាំហិរញ្ញវត្ថុ ២០២០ គឺ ភាគច្រើន បណ្តាលមកពីការចាប់ផ្តើមដំណើរការគម្រោងក្រុងព្រះសីហនុនៅខែមីនា ឆ្នាំ២០២០។

ក្នុងកំឡុងឆ្នាំនេះ ផថខ បានទទួលស្គាល់លើចំណូលហិរញ្ញវត្ថុដោយអនុលោមតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិកម្ពុជា (CIFRS) ១៥ ដែលចំណូលហិរញ្ញវត្ថុ គឺចំនួន ៤ ២៦៨ លានរៀល (ឆ្នាំហិរញ្ញវត្ថុ ២០២០៖ គ្មាន)។ ចំណូលហិរញ្ញវត្ថុបានមកពីគម្រោងមួយចំនួនតាមរយៈការអនុលោមតាម CIFRS ១៥ ហើយវាគឺជាផ្នែកមួយនៃចំណូលសរុបរបស់សម្ព័ន្ធក្រុមហ៊ុន។

## ខ. វចនាសម្ព័ន្ធចំណូល

| ល.រ. | ប្រភពចំណូល | ឆ្នាំហិរញ្ញវត្ថុ ២០២១ | | ឆ្នាំហិរញ្ញវត្ថុ ២០២០ | | ឆ្នាំហិរញ្ញវត្ថុ ២០១៩ | |
|---|---|---|---|---|---|---|---|
| | | លានរៀល | ភាគរយ | លានរៀល | ភាគរយ | លានរៀល | ភាគរយ |
| ១ | កិច្ចសន្យា វិស្វកម្ម លទ្ធកម្ម ការសាងសង់ និងការដាក់ឱ្យដំណើរការ ("EPCC) កិច្ចសន្យាសម្រាប់ បណ្តាញអគ្គីសនី និង អនុស្ថានីយ៍ | ២៦០ ៨៤៥ | ៩៥,៣ | ១៩៣ ៨៤៥ | ៩៥,៥ | ២២១ ២៧៥ | ៩៥,៨ |
| ២ | ប្រតិបត្តិការ និងសេវាថែទាំ | ១២ ៧៨៣ | ៤,៧ | ៩ ១៦៩ | ៤,៥ | ៩ ៨៧៣ | ៤,២ |
| | **ចំណូលសរុប** | **២៧៣ ៦២៨** | **១០០,០** | **២០៣ ០១៤** | **១០០,០** | **២៣១ ០៥៨** | **១០០,០** |
| ចំណូលហិរញ្ញវត្ថុអនុលោមតាម CIFRS ១៥ | | ៤ ២៦៨ | - | | - | - | - |
| | **ចំណូលសរុប** | **២៧៧ ៨៩៦** | - | **២០៣ ០១៤** | - | **២៣១ ០៥៨** | - |

# ព័ត៌មានអំពី អភិបាលកិច្ចសាជីវកម្ម

## ក. អង្គការលេខ



# ព័ត៌មានអំពី អភិបាលកិច្ចសាជីវកម្ម

## ខ. សមាសភាពក្រុមប្រឹក្សាភិបាល

| ល.រ. | ឈ្មោះ | មុខតំណែង | កាលបរិច្ឆេទ ចាប់ផ្តើមអាណត្តិ ជាអភិបាល | កាលបរិច្ឆេទ ផុតកំណត់អាណត្តិ ជាអភិបាល |
|---|---|---|---|---|
| ១ | Paul Lim Pay Chuan | ប្រធានក្រុមប្រឹក្សាភិបាល | ៥ កុម្ភៈ ២០១០ | មិនកំណត់ |
| ២ | Lim Ah Hock | អភិបាល | ៥ កុម្ភៈ ២០១០ | មិនកំណត់ |
| ៣ | Han Fatt Juan | អភិបាលប្រតិបត្តិ /ប្រធាននាយកប្រតិបត្តិ | ២៧ មិថុនា ២០១៨ | មិនកំណត់ |
| ៤ | Charles Tan Pu Hooi | អភិបាល | ២៧ មិថុនា ២០១៨ | មិនកំណត់ |
| ៥ | ដាវ់ អានសាន | អភិបាលឯករាជ្យ | ២៨ សីហា ២០១៨ | ២៨ សីហា ២០២៣ |

លេខាធិការក្រុមហ៊ុន៖

| ល.រ. | ឈ្មោះ | កាលបរិច្ឆេទតែងតាំង |
|---|---|---|
| ១ | វ៉ា សាមឿន | ៤ សីហា ២០២១ |
| ២ | Lynda Pan Seng Wee | ៤ សីហា ២០២១ |

# ព័ត៌មានអំពីការជួញដូរមូលបត្រ និង ភាគហ៊ុនិករបស់ផេសថិក (ខេមបូឌា) ម.ក

## ក. ព័ត៌មានអំពីមូលបត្រ

ព័ត៌មានអំពីមូលបត្រកម្មសិទ្ធិ (សម្រាប់បុគ្គលចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ)

- ឈ្មោះមូលបត្រកម្មសិទ្ធិ : ផេសថិក (ខេមបូឌា) ម.ក
- និមិត្តសញ្ញាមូលបត្រកម្មសិទ្ធិ : ផថខ
- ចំណាត់ថ្នាក់នៃមូលបត្រកម្មសិទ្ធិ : ភាគហ៊ុនធម្មតា
- តម្លៃចារឹកក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ : ០,១០ ដុល្លារអាមេរិក ឬ ៤០០ រៀល
- តម្លៃ IPO : ០,៧៦ ដុល្លារអាមេរិក ឬ ៣ ១២០ រៀល
- បរិមាណមូលបត្រកម្មសិទ្ធិសរុបទាំងអស់ដែលកំពុងចរាចរនៅលើទីផ្សារ : ៧៤ ៩៩៥ ០០០
- មូលធនូបនីយកម្មទីផ្សារ : ២៣៨ ៣២៥ ១០០ ០០០ រៀល (៣ ១៨០ រៀល ក្នុងមួយភាគហ៊ុន គិតត្រឹមថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២១)

- ឈ្មោះទីផ្សារមូលបត្រប្រតិស្រុត : ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
- កាលបរិច្ឆេទចុះបញ្ជី : ថ្ងៃទី១២ ខែសីហា ឆ្នាំ២០២០

## ខ. ថ្លៃ និងបរិមាណជួញដូរមូលបត្រ

| មូលបត្រ | | កក្កដា ២០ | សីហា ២០** | កញ្ញា ២០ | តុលា ២០ | វិច្ឆិកា ២០ | ធ្នូ ២០ | មករា ២១ | កុម្ភៈ ២១ | មីនា ២១ | មេសា ២១ | ឧសភា ២១ | មិថុនា ២១ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ថ្លៃជួញដូរ | អតិបរមា | | ៣ ៩៩០ | ៣ ៤០០ | ៣ ២៩០ | ៣ ២០០ | ៣ ២០០ | ៣ ០៤០ | ៣ ០២០ | ៣ ២៨០ | ៣ ០៩០ | ៣ ៣៩០ | ៣ ៣៨០ |
| | *ជាមធ្យម | | ៣ ៦៧០ | ៣ ២៩០ | ៣ ១៩០ | ៣ ០៥០ | ២ ៩៧៥ | ២ ៨៧៥ | ២ ៩២០ | ២ ៩៩០ | ៣ ០៥៥ | ៣ ២២០ | ៣ ១៦៥ |
| | អប្បបរមា | | ៣ ៣៥០ | ៣ ១៨០ | ៣ ០៩០ | ២ ៩០០ | ២ ៧៥០ | ២ ៧១០ | ២ ៨២០ | ២ ៧០០ | ៣ ០២០ | ៣ ០៥០ | ២ ៩៥០ |
| បរិមាណជួញដូរ | អតិបរមា | | ២២០ ២៣៦ | ២១ ៤៧១ | ៥ ០២៧ | ៦ ៧៨៦ | ៦ ៥៨៩ | ៤ ៤៧៩ | ៣ ៣៣៧ | ១២ ៦៣៩ | ៤ ០៧៥ | ៨ ៥០០ | ១០ ៤០៣ |
| | *ជាមធ្យម | | ១១១ ៩៨៥ | ១១ ០២៤.៥ | ២ ៥១៨.៥ | ៣ ៤២៥.៥ | ៣ ៣០០ | ២ ២៣៩.៥ | ២ ៩២០ | ៦ ៣៣៩ | ២ ២៦៧ | ៤ ៦២២ | ៥ ៣៦៦.៥ |
| | អប្បបរមា | | ៣ ៧៣៣ | ៣០៨ | ១០ | ៦៥ | ២០ | ០ | ០ | ៣៩ | ៤៥៩ | ៧៤៤ | ៣៣០ |

*ព័ត៌មានខាងលើត្រូវបានដកស្រង់ចេញពីគេហទំព័ររបស់ CSX ដោយផ្អែកតាមព័ត៌មាន គិតត្រឹមថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២១ ដែលត្រូវបានផ្សព្វផ្សាយ។*
**ជាកម្រិតមធ្យមរវាងអតិបរមា និងអប្បបរមា នៃថ្លៃ និងបរិមាណជួញដូរមូលបត្រ។*
***ផថខ បានចុះបញ្ជីលក់មូលបត្រនៅថ្ងៃទី១២ សីហា ឆ្នាំ២០២០ ហេតុនេះ ថ្លៃ និងបរិមាណជួញដូរមូលបត្រសម្រាប់ ខែសីហា ឆ្នាំ២០២១ ដែលបង្ហាញជូនគឺ ក្នុងអំឡុងពីថ្ងៃទី១២ ខែសីហា ឆ្នាំ២០២០ ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២០។*

## គ. ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ (ចាប់ពី៣០% ឡើងទៅ)

| ល.រ | ឈ្មោះ | សញ្ជាតិ | ចំនួនភាគកហ៊ុន | ភាគរយ |
|---|---|---|---|---|
| ១ | PESTECH International Berhad | ម៉ាឡេស៊ី | ៧១ ០០០ ០០០ | ៩៤,៧៤% |
| សរុប | | | ៧១ ០០០ ០០០ | ៩៤,៧៤% |

*ព័ត៌មានខាងលើត្រូវបានដកស្រង់ចេញពីគេហទំព័ររបស់ CSX ដោយផ្អែកតាមព័ត៌មាន គិតត្រឹមថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២០ ដែលត្រូវបានផ្សព្វផ្សាយ។*

## ឃ. ត៌មានអំពីការបែងចែកភាគលាភក្នុងរយៈពេល ៣ (បី) ឆ្នាំចុងក្រោយ (សម្រាប់បុគ្គលចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ)

ផថខ មិនបានបែងចែកភាគលាភសម្រាប់រយៈពេល ៣ (បី) ឆ្នាំចុងក្រោយនេះទេ ដោយសារ ផថខ ទើបបានចុះបញ្ជីលក់មូលបត្រនៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០២១។

នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២១ ក្រុមប្រឹក្សាភិបាលបានសម្រេចបែងចែកភាគលាភចំនួន ០,០០៦៥ ដុល្លារអាមេរិកក្នុងមួយភាគហ៊ុន សម្រាប់ឆ្នាំហិរញ្ញវត្ថុដែលបានបញ្ចប់នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១។ ការបែងចែកភាគលាភនេះ អាចមានការផ្លាស់ប្តូរផ្អែកលើរបាយការណ៍ហិរញ្ញវត្ថុដែលធ្វើសវនកម្មដោយសវនករឯករាជ្យ និងសេចក្តីសម្រេចរបស់កិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក។

HT&P Partners
Certified Public Accountants

Unit S13A02-01, Floor 13A
Diamond Twin Tower
Koh Pich, 120101
Phnom Penh, Cambodia

Tel: +855 23 231 236
info@htppartners.com
www.htppartners.com

**ក្រុមប្រឹក្សាភិបាល**
**ផេសចិក (ខេមបូឌា) ម.ក**
ផ្ទះលេខ៦ ផ្លូវលេខ៥៩៨ ភូមិ១១ សង្កាត់បឹងកក់ទី២
ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

យោង៖ HTP/HP/LUN

ថ្ងៃទី១១ ខែសីហា ឆ្នាំ២០២១

**ផេសចិក (ខេមបូឌា) ម.ក**
**របាយការណ៍សវនកម្មផ្ទៃក្នុងសម្រាប់ការិយបរិច្ឆេទចាប់ពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២០ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១**

យោងទៅតាមប្រធានបទខាងលើ យើងខ្ញុំសូមភ្ជាប់មកជាមួយនូវ របាយការណ៍សវនកម្មផ្ទៃក្នុងរបស់យើងខ្ញុំសម្រាប់លោកអ្នកពិនិត្យ និង វិនិច្ឆ័យ។ របាយការណ៍សវនកម្មផ្ទៃក្នុង ត្រូវបានពិភាក្សារួចហើយជាមួយអ្នកគ្រប់គ្រង ក្រុមហ៊ុន ផេសចិក (ខេមបូឌា) ម.ក ហៅកាត់ថា (“ក្រុមហ៊ុន”)។

យើងខ្ញុំបានធ្វើសវនកម្មផ្ទៃក្នុងលើដំណើរការលទ្ធកម្មនិងការគ្រប់គ្រងគម្រោង របស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទចាប់ពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២០ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១។ នៅក្នុងរបាយការណ៍ដែលបានភ្ជាប់មកជាមួយ យើងខ្ញុំបានបង្ហាញនូវបញ្ហាជាក់លាក់មួយចំនួន ដែលធ្វើឲ្យយើងខ្ញុំចាប់អារម្មណ៍ក្នុងអំឡុងពេលនៃការធ្វើសវនកម្មផ្ទៃក្នុង ហើយយើងខ្ញុំយល់ថាគួរតែត្រូវបានបង្ហាញជូនលោកអ្នក។

យើងខ្ញុំបានរៀបចំរបាយការណ៍នេះសម្រាប់ការប្រើប្រាស់របស់គណៈកម្មាធិការសវនកម្ម អ្នកគ្រប់គ្រង និងតបតាមកម្មវត្ថុនៃកិច្ចការសវនកម្មផ្ទៃក្នុងនេះ ។ ដូច្នេះយើងខ្ញុំជឿជាក់ថាវាមិនសមរម្យទេនៅពេលដែលរបាយការណ៍នេះត្រូវបានផ្តល់ជូនដល់ភាគីទីបី ប្រសិនបើភាគីទីបីនោះទទួលបានច្បាប់ចម្លងដោយគ្មានការដឹងឮជាលាយលក្ខណ៍អក្សរជាមុនអំពីយើងខ្ញុំ ហើយយើងខ្ញុំនឹងមិនទទួលខុសត្រូវលើការពឹងផ្អែកណាមួយដែលមានលើរបាយការណ៍នេះទេ។

យើងខ្ញុំបានដាក់បញ្ចូលនូវការឆ្លើយតបរបស់អ្នកគ្រប់គ្រងទៅនឹងបញ្ហាផ្សេងៗនៅក្នុងរបាយការណ៍ដែលបានភ្ជាប់មកជាមួយសម្រាប់ចំណាប់អារម្មណ៍របស់លោកអ្នក ។

ជាចុងក្រោយយើងខ្ញុំសូមអរគុណសម្រាប់កិច្ចសហការអំពីបុគ្គលិករបស់លោកអ្នក ក្នុងអំឡុងពេលនៃសវនកម្មផ្ទៃក្នុងនេះ។




**អេចធី & ភី ផាតនើរ ឯ.ក**
**គណនេយ្យករជំនាញ**

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

# របាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

និងរបាយការណ៍ហិរញ្ញវត្ថុ ដែលបានធ្វើសវនកម្មរួច

ក្រុមហ៊ុនផេសថិក (ខេមបូឌា) ម.ក និងក្រុមហ៊ុនបុត្រសម្ព័ន្ធ

ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១

# មាតិកា

ទំព័រ

| | |
|---|---|
| របាយការណ៍របស់ក្រុមប្រឹក្សាភិបាល | ៣២ |
| របាយការណ៍របស់សវនករឯករាជ្យ | ៣៦ |
| របាយការណ៍ស្ថានភាពហិរញ្ញវត្ថុរបស់សម្ព័ន្ធក្រុមហ៊ុន | ៤២ |
| របាយការណ៍ស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន | ៤៤ |
| របាយការណ៍ចំណេញ ឬខាត និងចំណូលពេញលេញផ្សេងៗរបស់សម្ព័ន្ធក្រុមហ៊ុន | ៤៦ |
| របាយការណ៍ចំណេញ ឬខាត និង ចំណូលពេញលេញផ្សេងៗរបស់ក្រុមហ៊ុន | ៤៨ |
| របាយការណ៍បម្រែបម្រួលមូលធនរបស់សម្ព័ន្ធក្រុមហ៊ុន | ៤៩ |
| របាយការណ៍បម្រែបម្រួលមូលធនរបស់ក្រុមហ៊ុន | ៥០ |
| របាយការណ៍លំហូរសាច់ប្រាក់របស់សម្ព័ន្ធក្រុមហ៊ុន | ៥១ |
| របាយការណ៍លំហូរសាច់ប្រាក់របស់ក្រុមហ៊ុន | ៥៣ |
| កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុនានា | ៥៥ |

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលសូមដាក់ជូននូវរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន ព្រមទាំងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចរបស់ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ម.ក ("ក្រុមហ៊ុន") និងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មហើយរបស់ក្រុមហ៊ុន និងក្រុមហ៊ុនបុត្រសម្ព័ន្ធ (រួមគ្នាហៅថា "សម្ព័ន្ធក្រុមហ៊ុន") សម្រាប់ការិយបរិច្ឆេទគិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ និងសម្រាប់ចុងការិយបរិច្ឆេទ។

## ព័ត៌មានអំពីក្រុមហ៊ុន

ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ម.ក បានប្រតិបត្តិការអាជីវកម្មនៅថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១០ ក្នុងនាមជាក្រុមហ៊ុនឯកជនទទួលខុសត្រូវបានកម្រិត ហើយវាជាក្រុមហ៊ុនបុត្រសម្ព័ន្ធ ១០០% របស់ក្រុមហ៊ុន PESTECH International Berhad ដែលជាក្រុមហ៊ុនចុះបញ្ជី និងមានអាស័យដ្ឋាននៅប្រទេសម៉ាឡេស៊ី និងបានចុះបញ្ជីនៅក្នុងទីផ្សារគោលនៃ Bursa Malaysia Securities Berhad ជាមួយនឹងដើមទុនដែលបានចុះបញ្ជី និងទូទាត់រួចរាល់ក្នុងចំនួនទឹកប្រាក់សរុប ៧.១០០.០០០ ដុល្លារអាមេរិក ដែលស្មើនឹង ៧១.០០០.០០០ ភាគហ៊ុន ដែលមានតម្លៃចារឹក ០.១០ដុល្លារអាមេរិកក្នុងមួយភាគហ៊ុន។ ក្រុមហ៊ុនបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម ("MOC") ក្រោមលេខចុះបញ្ជីពាណិជ្ជកម្ម ០០០០០៩៥៧។

នៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០២០ ក្រុមហ៊ុនបានចុះជាមួយផ្សារមូលបត្រកម្ពុជា ("CSX") ដោយជោគជ័យ។ ភាគហ៊ុនថ្មីដែលបានចេញផ្សាយមានចំនួន ៣.៩៤៥.០០០ ភាគហ៊ុនជាមួយតម្លៃចារឹក ៤០០ រៀល ឬ០.១០ដុល្លារអាមេរិកក្នុងមួយភាគហ៊ុននៅក្នុងតម្លៃបោះផ្សាយ ៣.១២០រៀល ឬ ០.៧៦ ដុល្លាអាមេរិកក្នុងមួយភាគហ៊ុន។ នាកាលបរិច្ឆេទនៃរបាយការណ៍លក្ខខន្តិកៈក្រុមហ៊ុនមិនទាន់បានកែប្រែនៅឡើយ និងរំពឹងទុកថានឹងត្រូវកែប្រែបន្ទាប់ពីអនុម័តដោយម្ចាស់ភាគហ៊ុននៅក្នុងមហាសន្និបាតប្រចាំឆ្នាំនៅក្នុងខែវិច្ឆិកា ឆ្នាំ២០២១ ខាងមុខនេះ។

សកម្មភាពចម្បងរបស់ក្រុមហ៊ុន គឺសាងសង់ស្ថានីយ៍អគ្គិសនីរង និងបណ្តាញបញ្ជូន។

ក្រុមហ៊ុន PESTECH (Myanmar) Limited (ហៅកាត់ថា "PML") បានធ្វើប្រតិបត្តិការអាជីវកម្មក្នុងនាមជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតដែលកម្មសិទ្ធិ ១០០% ជារបស់ក្រុមហ៊ុនក្រោមលេខចុះបញ្ជីពាណិជ្ជកម្ម ១១៧១ FC/២០១៦-២០១៧ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៧ ដែលបានចេញផ្សាយដោយ ក្រសួងផែនការ និងហិរញ្ញវត្ថុ នៃរដ្ឋាភិបាលរបស់សាធារណរដ្ឋសហភាពមីយ៉ាម៉ា។ ដើមទុនចុះបញ្ជីរបស់ក្រុមហ៊ុនមានទឹកប្រាក់ចំនួន ៥០.០០០ ដុល្លារអាមេរិក ដែលស្មើនឹង ៥០.០០០ភាគហ៊ុនធម្មតា។

សកម្មភាពអាជីវកមម្មចម្បងរបស់ PML គឺការផ្តល់សេវាកម្មគ្រប់គ្រងគម្រោង ស្ថានីយន៍អគ្គីសនី ការសាងសង់ និងតំឡើងបណ្តាញបញ្ជូន សេវាត្រួតពិនិត្យលើការធ្វើតេស្ត សេវាដាក់ឱ្យដំណើរការ និងការងារស៊ីវិល។

ក្រុមហ៊ុន PESTECH Hinthar Corporation Limited (ហៅកាត់ថា "PHC") ត្រូវបានចុះបញ្ជីជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតនៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ ២០១៩ ដែល ៦០% កាន់កាប់ដោយក្រុមហ៊ុន PML ក្រោមច្បាប់ក្រុមហ៊ុនមីយ៉ាន់ម៉ា២០១៧ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៩។ ដើមទុនដែលបានចុះបញ្ជីមានចំនួន ៥០.០០០ ដុល្លារអាមេរិកដែលស្មើនឹង ៥០.០០០ សន្លឹកហ៊ុន។

## ព័ត៌មានអំពីក្រុមហ៊ុន (ត)

សកម្មភាពអាជីវកម្មចម្បងរបស់ PHC គឺការបង្កើតហេដ្ឋារចនាសម្ព័ន្ធ ព្រមទាំងលើកកំពស់វិស័យថាមពល ដែលមានដូចជាការបង្កើតថាមពល ការបញ្ជូនថាមពល និងការចែកចាយថាមពលជាដើមនៅសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា។

ក្រុមហ៊ុន PESTECH Microgrid Company Limited (ហៅកាត់ថា "PMG") ត្រូវបានចុះបញ្ជីជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតដែល ៩០% កាន់កាប់ដោយក្រុមហ៊ុន PHC ក្រោមការគ្រប់គ្រងច្បាប់ក្រុមហ៊ុនមីយ៉ាន់ម៉ា២០១៧ ចុះទី១៤ ខែកុម្ភៈ ឆ្នាំ២០២០។ ដើមទុនដែលបានចុះបញ្ជីមានចំនួន ១០.០០០ ដុល្លារអាមេរិកដែលស្មើនឹង១០.០០០សន្លឹកហ៊ុន។

សកម្មភាពអាជីវកម្មចម្បងរបស់ PMG គឺការផ្តល់នូវប្រព័ន្ធមីក្រូក្រាដ និងហេដ្ឋារចនាសម្ព័ន្ធថាមពលផ្សេងៗជូនតំបន់ជនបទនៅក្នុងសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា។

ក្រុមហ៊ុនចាត់ទុកក្រុមហ៊ុន PHC និងក្រុមហ៊ុន PMG ជាក្រុមហ៊ុនបុត្រសម្ព័ន្ធដោយប្រយោល។

ការិយាល័យចុះបញ្ជីរបស់ក្រុមហ៊ុន គឺនៅផ្ទះលេខ៦ ផ្លូវលេខ៥៩៨ សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។ ការិយាល័យចុះបញ្ជីរបស់ក្រុមហ៊ុន PML និងក្រុមហ៊ុន PMG មានទីតាំងនៅ បន្ទប់លេខ០១-០៥ ជាន់ទី១០ អគារការិយាល័យទីក្រុងJunction កែងផ្លូវ២៧ និងផ្លូវBogyoke Aung San ទីក្រុងយ៉ានហ្គូន សាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា និងផ្លូវThapyaynyo លេខ៣អ៊ី Shinsawpu Ward Sannchaung ទីក្រុងយ៉ានហ្គូន នៃសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា។

ក្រុមហ៊ុនពុំមានការផ្លាស់ប្តូរជាសារវន្ត លើសកម្មភាពចម្បងរបស់ក្រុមហ៊ុន និងក្រុមហ៊ុនបុត្រសម្ព័ន្ធនៅក្នុងអំឡុងការិយបរិច្ឆេទនៃរបាយការណ៍នេះទេ។

## លទ្ធផលនៃប្រតិបត្តិការ

លទ្ធផលនៃប្រតិបត្តិការរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុននាចុងការិយបរិច្ឆេទថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ និងស្ថានភាពនៅការិយបរិច្ឆេទនេះត្រូវបានកំណត់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ។

ក្រុមប្រឹក្សាភិបាលបានធ្វើសេចក្តីណែនាំឱ្យមានការបែងចែកភាគលាភចុងក្រោយចំនួន ០.០០៦៥ ដុល្លារអាមេរិកក្នុងមួយភាគហ៊ុន ក្នុងកាលបរិច្ឆេទបច្ចុប្បន្នដោយមានការអនុម័តពីម្ចាស់ភាគហ៊ុននៅក្នុងមហាសន្និបាតប្រចាំឆ្នាំនាពេលខាងមុខនេះ។ របាយការណ៍ហិរញ្ញវត្ថុក្នុងកាលបរិច្ឆេទបច្ចុប្បន្នមិនបានបង្ហាញពីគោលបំណងក្នុងការប្រកាសភាគលាភឡើយ។ ភាគលាភទាំងនេះ ប្រសិនបើមានការការអនុម័តដោយម្ចាស់ភាគហ៊ុន នឹងត្រូវបានគិតចូលក្នុងគណនីមូលធន ក្នុងគោលបំណងក្នុងការរក្សាទុកប្រាក់ចំណេញសម្រាប់ចុងការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១។

## ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាលរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនអំឡុងការិយបរិច្ឆេទ និងកាលបរិច្ឆេទនៃរបាយការណ៍មានដូចខាងក្រោម៖

| ឈ្មោះ | មុខតំណែង | ថ្ងៃខែតែងតាំង |
|---|---|---|
| Mr.Lim Pay Chuan | ប្រធានក្រុមប្រឹក្សាភិបាល | ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១០ |
| Mr.Lim Ah Hock | អភិបាល | ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១០ |
| Mr.Tan Pu Hooi | អភិបាល | ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៨ |
| Mr.Han Fatt Juan | អភិបាលប្រតិបត្តិ | ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៨ |
| Mr.Dav Ansan | អភិបាលឯករាជ្យ | ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៨ |

## សវនករ

របាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនសម្រាប់ចុងការិយបរិច្ឆេទគិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ ត្រូវបានធ្វើសវនកម្មដោយក្រុមហ៊ុន ហ្គ្រេន សនថុន (ខេមបូឌា) លីមីធីត។

## អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

នៅក្នុងអំឡុង និងចុងការិយបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុនេះ មិនមានកិច្ចព្រមព្រៀងណាមួយដែលសម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនជាភាគីម្ខាង ដែលកម្មវត្ថុនៃកិច្ចព្រមព្រៀងនោះអាចផ្តល់លទ្ធភាព ដល់សមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់ឱ្យទទួលបាននូវអត្ថប្រយោជន៍តាមមធ្យោបាយផ្សេងៗ ដូចជាការទិញភាគហ៊ុន ឬប័ណ្ណបំណុលរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុននោះទេ។

ចាប់តាំងពីថ្ងៃចុងក្រោយនៃការិយបរិច្ឆេទនៃឆ្នាំកន្លងទៅ ពុំមានក្រុមប្រឹក្សាភិបាលណាម្នាក់បានទទួល ឬមានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយ តាមរយៈការចុះកិច្ចសន្យាដែលបានធ្វើឡើងដោយសម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន ឬជាមួយក្រុមហ៊ុនដែលក្រុមប្រឹក្សាភិបាលជាសមាជិក ឬក៏ជាមួយក្រុមហ៊ុនដែលក្រុមប្រឹក្សាភិបាលនោះមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុជាសារវន្តឡើយ លើកលែងតែអត្ថប្រយោជន៍ដទៃទៀតដែលអាចកើតឡើងពីប្រតិបត្តិការ ដែលបានបង្ហាញនៅក្នុងកំណត់សម្គាល់ទី២៧ នៃរបាយការណ៍ហិរញ្ញវត្ថុ។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាល មានទំនួលខុសត្រូវធានាថារបាយការណ៍ហិរញ្ញវត្ថុបានរៀបចំឡើង បានដើម្បីបង្ហាញទិដ្ឋភាពពិត និងត្រឹមត្រូវនូវស្ថានភាពហិរញ្ញវត្ថុរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនសម្រាប់កាលបរិច្ឆេទថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ ព្រមទាំងលទ្ធផលនៃប្រតិបត្តិការអាជីវកម្ម និងលំហូរសាច់ប្រាក់សម្រាប់ចុងការិយបរិច្ឆេទនេះ។ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ក្រុមប្រឹក្សាភិបាលក៏តម្រូវឱ្យ៖

i. អនុវត្តគោលនយោបាយគណនេយ្យដែលសមស្រប ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ស្មានសមហេតុផល និងប្រុងប្រយ័ត្ន ហើយបន្ទាប់មកធ្វើការអនុវត្តគោលនយោបាយទាំងនេះឱ្យមានសង្គតិភាព

ii. អនុលោមតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ហើយប្រសិនបើមានការប្រាសចាកណាមួយពីស្តង់ដារទាំងនេះក្នុងការបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវក្រុមប្រឹក្សាភិបាល ត្រូវប្រាកដថាការប្រាសចាកទាំងនេះត្រូវបានលាតត្រដាង ពន្យល់ និងកំណត់បរិមាណឱ្យបានត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ

iii. ធានាឱ្យបាននូវភាពគ្រប់គ្រាន់នៃការកត់ត្រាគណនេយ្យ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឱ្យមានប្រសិទ្ធិភាព

iv. រៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដោយផ្អែកលើមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម លុះត្រាតែករណីសន្មតយ៉ាងសមរម្យថាក្រុមហ៊ុននឹងបន្តធ្វើប្រតិបត្តិការអាជីវកម្ម នាពេលអនាគតដែលអាចរំពឹងទុកបាននិង

v. គ្រប់គ្រងនិងដឹកនាំ សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន ដោយផ្ទាល់អោយមានប្រសិទ្ធិភាពលើរាល់ការសំរេចចិត្តសំខាន់ៗដែលប៉ះពាល់ដល់ប្រតិបត្តិការ ហើយត្រូវប្រាកដថាសេចក្តីសម្រេច/ការណែនាំទាំងនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាល ក៏មានទំនួលខុសត្រូវក្នុងការថែរក្សាទ្រព្យសម្បត្តិរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនហើយក៏ត្រូវចាត់វិធានការឱ្យសមស្រប ដើម្បីទប់ស្កាត់ និងរកឱ្យឃើញការក្លែងបន្លំ និងភាពមិនប្រក្រតីផ្សេងៗ។

ក្រុមប្រឹក្សាភិបាលធានាអះអាងថា សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនបានអនុវត្តតាមរាល់តម្រូវការខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

## សេចក្តីថ្លែងការណ៍របស់ក្រុមប្រឹក្សាភិបាល

តាមមតិយោបល់របស់ក្រុមប្រឹក្សាភិបាល របាយការណ៍ហិរញ្ញវត្ថុ ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ របាយកាណ៍ចំណេញ ឬខាត និងចំណូលពេញលេញ របាយការណ៍បម្រែបម្រួលមូលធន របាយកាណ៍លំហូរសាច់ប្រាក់ ព្រមទាំងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវទៅតាមស្ថានភាពហិរញ្ញវត្ថុរបស់ សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន នាកាវិយបរិច្ឆេទថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ ព្រមទាំងលទ្ធផលប្រតិបត្តិការអាជីវកម្ម និងស្ថានភាពលំហូរសាច់ប្រាក់ សម្រាប់ដំណាច់ឆ្នាំ ត្រូវបានរៀបចំឡើង ដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុ អន្តរជាតិនៃកម្ពុជា។

ជំនួសឱ្យក្រុមប្រឹក្សាភិបាល



Lim Pay Chuan
ប្រធានក្រុមប្រឹក្សាភិបាល

ទីក្រុងកូឡាឡាំពួ ប្រទេសម៉ាឡេស៊ី
ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២១

# របាយការណ៍របស់សវនករឯករាជ្យ

**ហ្គ្រេន សនថុន (ខេមបូឌា) លីមីធីត**
ជាន់ទី២០ អាគារកាណាឌីយ៉ា
៣១៥ ផ្លូវព្រះអង្គឌួង
(កែងមហាវិថីព្រះមុនីវង្ស)
សង្កាត់វត្តភ្នំ. ខណ្ឌដូនពេញ
រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
**លេខទូរស័ព្ទ +៨៥៥ ២៣ ៩៦៦ ៥២០**
www.grantthornton.com.kh

**ជូនចំពោះភាគទុនិករបស់**
**ផេសចិក (ខេមបូឌា) ម.ក**

## មតិយោបល់

យើងបានធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនផេសចិក (ខេមបូឌា) ម.ក ("ក្រុមហ៊ុន") និងរបាយការណ៍ហិរញ្ញវត្ថុរួមរបស់ក្រុមហ៊ុន និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួន (ទាំងអស់រួមបញ្ចូលគ្នាហៅថា "សម្ព័ន្ធក្រុមហ៊ុន") ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនាកាលបរិច្ឆេទគិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ ព្រមទាំងរបាយការណ៍ចំណូលពេញលេញ របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់សម្រាប់ចុងការិយបរិច្ឆេទ និងកំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ និងសេចក្តីសង្ខេបគោលនយោបាយគណនេយ្យសំខាន់ៗ។

តាមមតិរបស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុបានបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុននាកាលបរិច្ឆេទថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ រួមបញ្ចូលលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់សម្រាប់ចុងការិយបរិច្ឆេទ ដោយអនុលោមទៅតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("CIFRSs")។

## មូលដ្ឋាននៃការបញ្ចេញមតិ

យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា("CISAs")។ ការទទួលខុសត្រូវរបស់យើងខ្ញុំស្ថិតក្រោមស្តង់ដារទាំងនោះ ត្រូវបានរៀបរាប់បន្ថែមទៀតនៅក្នុងផ្នែកការទទួលខុសត្រូវរបស់សវនករទៅលើការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ។ យើងមានឯករាជ្យភាព លើសម្ព័ន្ធក្រុមហ៊ុននិងក្រុមហ៊ុនហើយអនុលោម តាមស្តង់ដារនៃវិជ្ជាជីវៈគណនេយ្យអន្តរជាតិ ក្រមសីលធម៌ របស់គណនេយ្យករជំនាញ ("IESBA Code") រួមជាមួយ និងតម្រូវការក្រមសីលធម៌ ដែលពាក់ព័ន្ធទៅនឹងការធ្វើសវនកម្មរបស់យើងខ្ញុំ ទៅលើរបាយការណ៍ហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជា ហើយយើងបានបំពេញការទទួលខុសត្រូវទៅតាមតម្រូវការ និង ក្រមសីលធម៌ទាំងនោះ។ យើងខ្ញុំជឿជាក់ថាភស្តុតាងសវនកម្មទាំងឡាយដែលយើងទទួលបានគឺគ្រប់គ្រាន់ និងសមរម្យដើម្បីផ្តល់ជូនជាមូលដ្ឋានសម្រាប់ការបញ្ចេញមតិរបស់យើង។

## បញ្ហាសវនកម្មសំខាន់ៗ

បញ្ហាសវនកម្មសំខាន់ៗ គឺជាបញ្ហាទាំងឡាយដែល ការវិជ្ជាជីវៈវិនិច្ឆ័យសំខាន់ៗរបស់យើងខ្ញុំ មានសារៈសំខាន់បំផុតនៅក្នុងការធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនក្នុងការិយបរិច្ឆេទបច្ចុប្បន្ន។ បញ្ហាទាំងនេះត្រូវបានកំណត់នៅក្នុងបរិបទនៃការធ្វើសវនកម្មរបស់យើងខ្ញុំទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនជារួម ព្រមទាំងការបញ្ចេញមតិយោបល់របស់យើងខ្ញុំ ហើយយើងខ្ញុំមិនផ្តល់នូវមតិយោបល់ដាច់ដោយឡែកទៅលើបញ្ហាទាំងនេះឡើយ។

បញ្ហាសវនកម្មសំខាន់ៗខាងក្រោម ត្រូវបានកំណត់នៅក្នុងដំណើរការធ្វើសវនកម្មរបស់យើងខ្ញុំទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន៖

| បញ្ហាសវនកម្មសំខាន់ៗ | វិធីសាស្ត្រដែលសវនករយើងខ្ញុំកំណត់នូវបញ្ហាសវនកម្មសំខាន់ៗ |
|---|---|
| **ការទទួលស្គាល់ចំណូល និងថ្លៃដើមក្នុងកិច្ចសន្យាសាងសង់**<br><br>ការទទួលស្គាល់ចំណូល និងថ្លៃដើមទៅលើកិច្ចសន្យាសាងសង់ គឺត្រូវបានទទួលស្គាល់ដោយអនុលោមជាមួយគោលនយោបាយគណនេយ្យ និងការប៉ាន់ស្មានសំខាន់ៗ ការសន្មត់ និងការវិនិច្ឆ័យ ដូចដែលបានបកស្រាយនៅក្នុងកំណត់សម្គាល់ ៤.៤ និង៥ ទៅលើរបាយការណ៍ហិរញ្ញវត្ថុ។<br><br>យើងខ្ញុំផ្តោតសំខាន់ទៅលើការវិនិច្ឆ័យ និងការប៉ាន់ស្មានសំខាន់ៗរបស់គណៈគ្រប់គ្រងត្រូវបានរួមបញ្ចូលទៅក្នុងការកំណត់ដូចខាងក្រោម៖<br><br>(i) តម្លៃប្រតិបត្តិការលើកិច្ចសន្យាសាងសង់ដោយគិតបញ្ចូលទាំងសមាសធាតុហិរញ្ញវត្ថុសំខាន់ៗ<br>(ii) តម្លៃសមស្របក្នុងការផ្តល់សេវាកម្មដែលពាក់ព័ន្ធ និងបែងចែកលើសាច់ប្រាក់ដែលបានទទួល ឬត្រូវទទួលបាននៃសេវាកម្មនីមួយៗ<br>(iii) ដំណាក់កាលក្នុងការបំពេញកិច្ចការដោយប្រើប្រាស់វិធីសាស្ត្រធាតុចេញ ដោយផ្អែកលើដំណាក់កាលក្នុងការបញ្ចប់គម្រោងអភិវឌ្ឍន៍ដោយមានការបញ្ជាក់ពីវិស្វករជំនាញ ឬអ្នកប្រឹក្សាជំនាញ<br>(iv) វិសាលភាពនៃថ្លៃដើមនៃកិច្ចសន្យាដែលបានកើតឡើងរហូតដល់កាលបរិច្ឆេទបច្ចុប្បន្ន<br>(v) ថ្លៃដើមកិច្ចសន្យាសាងសង់សរុប និងថ្លៃដើមក្នុងការបញ្ចប់ការសាងសង់ និង<br>(vi) សំវិធានធនទៅលើការខូចខាតដែលបានបញ្ជាក់ | ក្នុងការដោះស្រាយបញ្ហាសំខាន់ៗទាំងនេះ យើងខ្ញុំបានអនុវត្តនូវនីតិវិធីផ្សេងៗដូចខាងក្រោម៖<br><br>- រយៈពេលប្រើប្រាស់ និងលក្ខខណ្ឌដែលបានកំណត់នៅក្នុងកិច្ចសន្យាជាមួយអតិថិជន និងអ្នកម៉ៅការបន្ត/អ្នកផ្គត់ផ្គង់ដើម្បីកំណត់នូវកិច្ចសន្យាសំខាន់ៗដាច់ដោយឡែក និងបានវាយតម្លៃទំនាក់ទំនងរវាងចំណូល និងថ្លៃដើមដែលបានទទួលស្គាល់<br>- បានវាយតម្លៃទៅលើចំណូលពីកិច្ចសន្យាសាងសង់សរុប តាមរយៈការការពិនិត្យមើលភស្តុតាង ដូចជាកិច្ចសន្យាសាងសង់ដែលបានអនុម័តក្នុងការបញ្ជាទិញ និងទំនាក់ទំនងជាមួយអតិថិជន និងការផ្ទៀងផ្ទាត់ទៅលើដំណើរការទូទាត់។ ក្នុងករណីដែលគម្រោងត្រូវបានពន្យាពេល បានធ្វើការវាយតម្លៃទៅលើភាពចាំបាច់ និងគ្រប់គ្រាន់លើសំវិធានធនលើការខូចខាតដែលបានបញ្ជាក់ដោយផ្អែកទៅលើប៉ាន់ស្មានរបស់គណៈគ្រប់គ្រង និងត្រូវបានត្រួតពិនិត្យទៅលើឯកសារយោងដែលមានដូចជាឯកសារទាក់ទងជាមួយអតិថិជន ឬអ្នកប្រឹក្សាយោបល់ ការពន្យាពេលទៅលើការអនុម័ត និងដំណើរការបង្កើតរបាយការណ៍ដែលបញ្ជាក់ពីហេតុផលនៃការពន្យាពេល<br>- បានវាយតម្លៃពីភាពសមស្រប និងភាពស្ថិតស្ថេរនៃការសន្មត់សំខាន់ៗដែលបានប្រើប្រាស់ដោយគណៈគ្រប់គ្រងដើម្បីកំណត់តម្លៃប្រតិបត្តិការនៃកិច្ចសន្យាសាងសង់ដោយរួមបញ្ចូលទាំងសមាសធាតុហិរញ្ញវត្ថុសំខាន់ៗ តម្លៃសមស្របនៃសេវាកម្មដែលត្រូវទទួលបាន និង/ឬត្រូវទទួលនៃសេវាកម្មនីមួយៗ<br>- បានតម្លៃលើលទ្ធភាព សមត្ថភាព និងគោលបំណងអ្នកប្រឹក្សាយោបល់វិស្វករឯករាជ្យ ឬវិស្វកររបស់ក្រុមហ៊ុន<br>- ពិនិត្យមើលដំណាក់កាលក្នុងការបំពេញកិច្ចសន្យាសាងសង់លើមូលដ្ឋានគំរូទៅលើការបំពេញរបាយការណ៍ដោយវិស្វករជំនាញ ឬអ្នកប្រឹក្សាយោបល់<br>- បានវាយតម្លៃលើមូលដ្ឋានដែលបានប្រើប្រាស់ក្នុងការកំណត់ចំណាយកិច្ចសន្យាគម្រោងថវិការ<br>- បានវាយតម្លៃលើចំណាយជាក់ស្តែងដែលបានកើតឡើង និងចំណាយបង្គរ ដោយពិនិត្យលើភស្តុតាងដែលមានដូចជាដំណើរការក្នុងការទាមទារសំណងរបស់អ្នកម៉ៅការ និងការចេញវិក័យបត្ររបស់អ្នកផ្គត់ផ្គង់ក្នុងអំឡុងឆ្នាំហិរញ្ញវត្ថុ និង/ឬឆ្នាំហិរញ្ញវត្ថុបន្ទាប់ |

| | |
|---|---|
| | - សម្ភាសអ្នកប្រឹក្សាយោបល់វិស្វករឯករាជ្យ ដើម្បីស្វែងយល់ពីមូលដ្ឋានដែលបានប្រើប្រាស់ក្នុងការផ្ទៀងផ្ទាត់ដំណាក់កាលក្នុងការបញ្ចប់ការសាងសង់ និង<br>- សម្ភាសក្រុមគណៈគ្រប់គ្រងគម្រោងលើការសម្រេចបាននូវគម្រោងចំណាយដែលបានព្យាករណ៍ទុកក្នុងការបញ្ចប់ការសាងសង់លើគម្រោងឯកជនដាច់ដោយឡែក។ |
| **លទ្ធភាពដែលអាចប្រមូលបានមកវិញនៃគណនីពាណិជ្ជត្រូវទទួល និងទ្រព្យសកម្មកិច្ចសន្យា**<br><br>CIFRS ៩ ណែនាំពីគំរូវឌិនភាពនៃការខាតបង់ឥណទានដែលបានរំពឹងទុក ("ECL") ដែលតម្រូវឱ្យមានការប្រើប្រាស់ការសន្មត់សំខាន់ៗអំពីលក្ខខណ្ឌសេដ្ឋកិច្ចនាពេលអនាគត ហើយហានិភ័យឥណទានរបស់អតិថិជនក្នុងការគណនាសំវិធានធនលើការខាតបង់។ សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនត្រូវបានវាយតម្លៃលើរយៈពេលនៃការខាតបង់ឥណទានរបស់ចំនួនទឹកប្រាក់នៃគណនីពាណិជ្ជត្រូវទទួល និងទ្រព្យសកម្មកិច្ចសន្យាដែលរំពឹងទុកដោយប្រើប្រាស់វិធីសាស្ត្រសាមញ្ញ។ ដូចដែលបានបង្ហាញក្នុងកំណត់សម្គាល់ ១០ និង ១១ លើរបាយការណ៍ហិរញ្ញវត្ថុ សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនមានទ្រព្យសកម្មកិច្ចសន្យា និងគណនីពាណិជ្ជត្រូវទទួលគិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ ហើយទាំងនេះជាកត្តាបង្កឱ្យមានហានិភ័យឥណទាន។ យើងខ្ញុំផ្តោតសំខាន់លើបញ្ហានេះ ព្រោះការវាយតម្លៃរបស់គណៈគ្រប់គ្រងលើ ECL តម្រូវឱ្យមានការវិនិច្ឆ័យសំខាន់ៗទៅលើអត្រាការខាតបង់ដែលបានរំពឹងទុក ព័ត៌មានយោងទៅមុខ និងការប៉ាន់ស្មានដែលអាចកើតមាន។ ព័ត៌មានលម្អិតនៃគោលនយោបាយគណនេយ្យបានប៉ាន់ស្មាន និងការសន្មត់សំខាន់ៗ ព្រមទាំងការគ្រប់គ្រងហានិភ័យឥណទានដែលបានប្រើប្រាស់ដោយសម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់៤.៨ ៥(ក) និង ៣១(ក)ទៅលើរបាយការណ៍ហិរញ្ញវត្ថុ។ | ក្នុងការដោះស្រាយបញ្ហាសំខាន់ៗទាំងនេះ យើងខ្ញុំបានអនុវត្តនូវនីតិវិធីមួយចំនួនដូចខាងក្រោម៖<br><br>- ស្វែងយល់ពីរបៀបដែលសម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនកំណត់អត្តសញ្ញាណ និងវាយតម្លៃលើECL សម្រាប់គណនីពាណិជ្ជដែលត្រូវទទួល និងទ្រព្យសកម្មកិច្ចសន្យា<br>- ត្រួតពិនិត្យឡើងវិញនូវប្រភពទិន្នន័យសំខាន់ៗ និងការសន្មត់លើទិន្នន័យដែលបានប្រើប្រាស់ក្នុងកំណត់អត្រាលំនាំដើម និងបច្ចុប្បន្ន និងការកែប្រែកត្តាយោងទៅមុខ<br>- ពិចារណាលើកាលកំណត់នៃបំណុល ក៏ដូចជានិន្នាការនៃប្រមូលផ្តុំដើម្បីវាយតម្លៃលើការប្រមូលផ្តុំហានិភ័យ<br>- ទទួលបានការបញ្ជាក់ពីកូនបំណុល និងត្រួតពិនិត្យលើលទ្ធភាពដែលអាចប្រមូលបានមកវិញ តាមរយៈរក្សាទុកនូវភស្តុតាងជាវិក័យបត្រពីកូនបំណុលលើមូលដ្ឋានឆ្នាំចាស់បន្ទាប់ចុងការិយបរិច្ឆេទ |

## ព័ត៌មានផ្សេងៗ

គណៈគ្រប់គ្រង មានភារៈទទួលខុសត្រូវលើព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗ ដែលបានទទួលត្រឹមកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះ គឺរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល ប៉ុន្តែមិនបានភ្ជាប់ក្នុងរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សវនកររបស់យើងទេ។

មតិរបស់យើងខ្ញុំ ទៅលើរបាយការណ៍ហិរញ្ញវត្ថុ មិនបានគ្របដណ្តប់លើព័ត៌មានផ្សេងៗឡើយ ហើយយើងខ្ញុំមិនធ្វើការផ្តល់នូវអំណះអំណាងធានាណាមួយទៅលើព័ត៌មាននេះទេ។

ពាក់ព័ន្ធនឹងការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុ ការទទួលខុសត្រូវរបស់យើងខ្ញុំគឺត្រូវអានព័ត៌មានផ្សេងៗ ហើយពិចារណាថាតើព័ត៌មានផ្សេងៗនោះ មានភាពមិនស្របគ្នាជាសារវន្តជាមួយរបាយការណ៍ហិរញ្ញវត្ថុ ឬការយល់ដឹងរបស់យើងខ្ញុំនៅក្នុងការធ្វើសវនកម្ម ឬមានបង្ហាញនូវកំហុសឆ្គងជាសារវន្ត។

ប្រសិនបើការអានព័ត៌មានផ្សេងៗនេះអាចឱ្យយើងខ្ញុំសន្និដ្ឋានថា មានកំហុសឆ្គងជាសារវន្តកើតឡើងលើព័ត៌មានផ្សេងៗនេះ យើងខ្ញុំត្រូវរាយការណ៍ទៅតាមស្ថានភាពជាក់ស្តែង។ យើងខ្ញុំពុំមានអ្វីដែលត្រូវរាយការណ៍ពាក់ព័ន្ធទៅនឹងព័ត៌មានផ្សេងៗនេះទេ។

នៅពេលដែលយើងខ្ញុំអានរបាយការណ៍ប្រចាំឆ្នាំ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាមានកំហុសឆ្គងជាសារវន្តណាមួយកើតមានឡើង យើងខ្ញុំត្រូវធ្វើការទាក់ទងជាមួយក្រុមប្រឹក្សាភិបាល និងឆ្លើយតបទៅលើបញ្ហាទាំងនេះដោយអនុលោមតាមការតម្រូវរបស់ CISA ៧២០ (បានធ្វើការកែតម្រូវ)។

## ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រងលើរបាយការណ៍ហិរញ្ញវត្ថុ

គណៈគ្រប់គ្រងនៃសម្ព័ន្ធក្រុមហ៊ុនទទួលខុសត្រូវក្នុងការរៀបចំ និងការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុទាំងនេះឱ្យបានត្រឹមត្រូវដោយអនុលោមទៅតាម ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា និងទទួលខុសត្រូវលើការត្រួតពិនិត្យផ្ទៃក្នុង ដែលក្រុមប្រឹក្សាភិបាលកំណត់ថាវាមានភាពចាំបាច់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ មិនឱ្យមានការរាយការណ៍ខុសជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ គណៈគ្រប់គ្រងរបស់សម្ព័ន្ធក្រុមហ៊ុនមានទំនួលខុសត្រូវចំពោះការវាយតម្លៃសមត្ថភាពរបស់ក្រុមហ៊ុន ក្នុងការបន្តប្រតិបត្តិការដោយផ្អែកលើមូលដ្ឋាននិរន្តរភាព ការលាតត្រដាង ប្រសិនជាមានការបញ្ហាទាក់ទងនឹងនិរន្តរភាព និងការប្រើប្រាស់និរន្តរភាពជាមូលដ្ឋានគណនេយ្យ លុះត្រាតែគណៈគ្រប់គ្រងមានគោលបំណងរំសាយក្រុមហ៊ុន ឬបញ្ឈប់ប្រតិបត្តិការ ឬក៏គ្មានជម្រើសផ្សេង ប៉ុន្តែចាំបាច់ត្រូវធ្វើ។

## ការទទួលខុសត្រូវរបស់សវនករនៅលើការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងខ្ញុំ គឺដើម្បីទទួលបាននូវការធានាអះអាងដ៏សមហេតុផល ទៅលើរបាយការណ៍ហិរញ្ញវត្ថុដោយពុំមានលក្ខណៈខុសឆ្គងជាសារវន្ត បណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គង ហើយនិងការបញ្ចេញមតិយោបល់លើរបាយការណ៍សវនកម្មរបស់យើងខ្ញុំ។ ការធានាអះអាងដែលសមហេតុផល គឺជាការធានាមួយដ៏ខ្ពស់ ប៉ុន្តែវាមិនបានធានាថា ការធ្វើសវនកម្មដោយផ្អែកទៅលើស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា នឹងតែងតែរកឃើញនូវការរាយការណ៍ខុសជាសារវន្តដែលមានឡើយ។ ការរាយការណ៍ខុសអាចកើតមានឡើងពីការក្លែងបន្លំ ឬកំហុសឆ្គងដែលអាចចាត់ទុកថាជាសារវន្ត នៅពេលដែលកំហុសមួយ ឬកំហុសរួមគ្នាបានធ្វើឱ្យប៉ះពាល់ដល់សេចក្តីសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុនេះ។

ជាផ្នែកមួយនៃការធ្វើសវនកម្មដោយយោងទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា យើងអនុវត្តនូវវិជ្ជាជីវៈវិនិច្ឆ័យ និង ការសង្ស័យដែលមានវិជ្ជាជីវៈទៅលើការធ្វើសវនកម្ម។ យើងខ្ញុំក៏បាន៖

- កំណត់អត្តសញ្ញាណ និងវាយតម្លៃនូវហានិភ័យនៃការរាយការណ៍ខុសជាសារវន្តនៃព័ត៌មានហិរញ្ញវត្ថុ ថាតើវាកើតឡើងដោយការក្លែងបន្លំ ឬកំហុសឆ្គង រៀបចំនិងអនុវត្តនីតិវិធីសវនកម្មដែលឆ្លើយតបទៅនឹងហានិភ័យទាំងនោះ រួមទាំងការប្រមូលយកភស្តុតាងសវនកម្មឱ្យបានគ្រប់គ្រាន់ និងសមស្រប ដើម្បីគាំទ្រជាមូលដ្ឋានសម្រាប់បញ្ចេញមតិយោបល់របស់យើង។ ហានិភ័យដែលមិនអាចរកឃើញដោយការរាយការណ៍ខុសជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ គឺធំជាងកំហុសឆ្គងដោយអចេតនា ដោយសារតែការក្លែងបន្លំរួមបញ្ចូលទាំងការរួមគំនិត ការក្លែងបន្លំដោយចេតនា ការលុបចោលដោយចេតនា ការបង្ហាញខុស ឬការលើសលប់ទៅលើការត្រួតពិនិត្យផ្ទៃក្នុង។

- ធ្វើការស្វែងយល់អំពីការគ្រប់គ្រងផ្ទៃក្នុង ដែលទាក់ទងទៅនឹងការធ្វើសវនកម្ម ដើម្បីបង្កើតនូវនីតិវិធីសវនកម្មដែលសមស្របទៅនឹងកាលៈទេសៈ ប៉ុន្តែមិនមែនជាគោលបំណងក្នុងការបង្ហាញនូវមតិយោបល់លើប្រសិទ្ធិភាពគ្រប់គ្រងផ្ទៃក្នុងរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន។

- ធ្វើការវាយតម្លៃភាពសមស្របលើគោលនយោបាយគណនេយ្យដែលបានប្រើប្រាស់ និងភាពសមហេតុផលនៃគណនេយ្យប៉ាន់ស្មាន ក៏ដូចជាការបង្ហាញនានាដែលធ្វើឡើងដោយគណៈគ្រប់គ្រង។

- សន្និដ្ឋានដ៏សមស្របមួយទៅលើការប្រើប្រាស់របស់គណៈគ្រប់គ្រង លើមូលដ្ឋាននិរន្តរភាពគណនេយ្យ ផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបាន ថាតើភាពមិនប្រាកដប្រជាជាសារវ័ន្តបានកើតឡើងទាក់ទិននឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលធ្វើឱ្យមានមន្ទិលសង្ស័យខ្លាំងទៅលើលទ្ធភាពក្នុងការបន្តនិរន្តរភាពរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន។ ប្រសិនបើយើងសន្និដ្ឋានថាភាពមិនប្រាកដប្រជា ជាសារវ័ន្តនឹងកើតមានឡើងយើងតម្រូវឱ្យធ្វើការលាតត្រដាងព័ត៌មានចាំបាច់ដើម្បីទាញការយកចិត្តទុកដាក់នៅក្នុងរបាយការណ៍សវនកម្មរបស់យើង ទៅនឹងការលាតត្រដាងនៅក្នុងព័ត៌មានហិរញ្ញវត្ថុ ឬក៏ប្រសិនបើការលាតត្រដាងនោះមិនគ្រប់គ្រាន់ នោះមតិយោបល់មិនត្រឹមត្រូវបានផ្តល់។ ការសន្និដ្ឋានរបស់ពួកយើង គឺផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបាន គិតត្រឹមកាលបរិច្ឆេទនៃការចេញរបាយការណ៍សវនកម្មរបស់យើង។ ក៏ប៉ុន្តែស្ថានភាព ឬក៏ព្រឹត្តិការណ៍នាពេលអនាគតអាចបណ្តាលឱ្យសម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនមិនអាចបន្តប្រតិបត្តិការជានិរន្តរភាពបាន។

- វាយតម្លៃការបង្ហាញទូទៅ ទម្រង់ និងអត្ថន័យរបស់ព័ត៌មានហិរញ្ញវត្ថុរួមបញ្ចូលទាំងការលាតត្រដាងនានាថាតើព័ត៌មានហិរញ្ញវត្ថុបង្ហាញនូវប្រតិបត្តិការ និងព្រឹត្តិការណ៍នានាដើម្បីបង្ហាញនូវភាពត្រឹមត្រូវសមស្របរបស់វា។

- ទទួលភស្តុតាងសវនកម្មចំពោះព័ត៌មានហិរញ្ញវត្ថុ ឬសកម្មភាពអាជីវកម្មរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនត្រឹមត្រូវ និងគ្រប់គ្រាន់ ដើម្បីបញ្ចេញមតិយោបល់ទៅលើ របាយការណ៍ហិរញ្ញវត្ថុ។ យើងខ្ញុំទទួលខុសត្រូវចំពោះការចាត់ចែង ការគ្រប់គ្រង និងការអនុវត្តសវនកម្ម។ យើងខ្ញុំទទួលខុសត្រូវតែទៅលើមតិយោបល់សវនកម្មរបស់យើងតែប៉ុណ្ណោះ។

យើងខ្ញុំប្រាស្រ័យទាក់ទងជាមួយនឹងគណៈគ្រប់គ្រងទៅលើបញ្ហាផ្សេងៗ ការរៀបចំដែនកំណត់ និងពេលវេលាក្នុងការធ្វើសវនកម្ម និងរបបគំហើញសវនកម្មសំខាន់ៗ រួមបញ្ចូលទាំងកង្វះខាតសំខាន់ៗមួយចំនួនទៅលើការគ្រប់គ្រងផ្ទៃក្នុងដែលពួកយើងខ្ញុំរកឃើញអំឡុងពេលធ្វើសវនកម្ម។

យើងខ្ញុំក៏ផ្តល់ជូនគណៈគ្រប់គ្រង នូវសេចក្តីថ្លែងការណ៍មួយដែលយើងខ្ញុំបានអនុវត្តទៅតាមតម្រូវការក្រមសីលធម៌ដែលទាក់ទងនឹងឯករាជ្យភាព ហើយយើងខ្ញុំធ្វើការប្រាស្រ័យទាក់ទងជាមួយនឹងគណៈគ្រប់គ្រងនូវបញ្ហាទាំងអស់ដែលនឹងគិតថាសមហេតុផលទៅលើឯករាជ្យភាពរបស់យើងខ្ញុំ និង ការការពារដែលអាចមាន។

ចំពោះបញ្ហាដែលបានទាក់ទងជាមួយក្រុមប្រឹក្សាភិបាល  យើងកំណត់បញ្ហាទាំងនោះដែលមានសារៈសំខាន់បំផុតនៅក្នុងការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទនាពេលបច្ចុប្បន្ន គឺជាបញ្ហាសវនកម្មសំខាន់ៗ។  យើងពិពណ៌នាអំពីបញ្ហាទាំងនេះនៅក្នុងរបាយការណ៍របស់សវនកររបស់យើងលុះត្រាតែច្បាប់ឬបទបញ្ញត្តិមិនរារាំងនូវការបង្ហាញជាសាធារណៈអំពីបញ្ហានេះឬនៅពេលណាដែលនៅក្នុងកាលៈទេសៈណាមួយយើងកំណត់ថាបញ្ហាណាមួយមិនត្រូវបានទាក់ទងនៅក្នុងរបាយការណ៍ពីព្រោះផលវិបាក  ឬអវិជ្ជមាននឹងត្រូវបានរំពឹងទុកដោយសមហេតុផល លើសពីទំនាក់ទំនងផលប្រយោជន៍ជាសាធារណៈ។

ព្រះរាជាណាចក្រកម្ពុជា
ហ្គ្រេន
សនថុន (ខេមបូឌា) លីមីធីត
GRANT THORNTON (CAMBODIA) LIMITED
រាជធានីភ្នំពេញ

Grant Thornton

ហ្គ្រេន សនថុន (ខេមបូឌា) លីមីធីត
គណនេយ្យករជំនាញ
សវនករប្រតិស្រុតចុះបញ្ជី

Ng Yee Zent
នាយកសវនករជំនាញ

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២១

គណនេយ្យករជំនាញ និងសវនករប្រតិស្រុត
សមាជិកភាពហ្គ្រេន សនថុន អន្តរជាតិ។ ហ្គ្រេន សនថុន អន្តរជាតិ និងសមាជិក គឺមិនមែនជាដៃគូរពាណិជ្ជកម្មទូទាំងសកលលោកទេ។
រាល់សេវាកម្មនានាត្រូវបានផ្តល់យ៉ាងឯករាជ្យដោយសមាជិកនីមួយៗ។

# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុរបស់សម្ព័ន្ធក្រុមហ៊ុន

| | សម្គាល់ | **ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ ពាន់ដុល្លារអាមេរិក** | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ ពាន់ដុល្លារអាមេរិក | **ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ លានរៀល (សម្គាល់ ៤.២)** | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ លានរៀល (សម្គាល់ ៤.២) |
|---|---|---|---|---|---|
| **ទ្រព្យសកម្ម** | | | | | |
| **ទ្រព្យសកម្មរយៈពេលវែង** | | | | | |
| ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | ៧ | **១៤.១៥០** | ១៥.៤០៤ | **៥៧.៦៦១** | ៦៣.០៤៩ |
| ទ្រព្យសកម្មអរូបិយ | | **៣** | ៥ | **១២** | ២០ |
| ទ្រព្យសកម្មកិច្ចសន្យា | ១០ | **១២២.១៦៧** | ១៩៨.២០០ | **៤៩៧.៨៣១** | ៨១១.២៣៣ |
| **ទ្រព្យសកម្មរយៈពេលវែងសរុប** | | **១៣៦.៣២០** | ២១៣.៦០៩ | **៥៥៥.៥០៤** | ៨៧៤.៣០២ |
| **ទ្រព្យសកម្មរយៈពេលខ្លី** | | | | | |
| សន្និធិ | ១១ | **៣.៥០៨** | ៤.៣៣៥ | **១៤.២៩៥** | ១៧.៧៤៣ |
| ទ្រព្យសកម្មកិច្ចសន្យា | ១០ | **១២២.៨៥១** | ១៨.៧៨៩ | **៥០០.៦១៨** | ៧៦.៩០៣ |
| គណនីពាណិជ្ជ និងគណនីត្រូវទទួលផ្សេងៗ | ១២ | **៦.៥០៣** | ៣.៦៦៧ | **២៦.៥០១** | ១៥.០០៩ |
| សមតុល្យត្រូវទទួលពីភាគីពាក់ព័ន្ធ | ២៦ | **២** | ២.៣៣២ | **៨** | ៩.៥៤៥ |
| សាច់ប្រាក់ និងសមតុល្យធនាគារ | ១៣ | **១៧.១៦៧** | ៥.៥២៤ | **៦៩.៩៥៦** | ២២.៦១០ |
| **ទ្រព្យសកម្មរយៈពេលខ្លីសរុប** | | **១៥០.០៣១** | ៣៤.៦៤៧ | **៦១១.៣៧៨** | ១៤១.៨១០ |
| **ទ្រព្យសកម្មសរុប** | | **២៨៦.៣៥១** | ២៤៨.២៥៦ | **១.១៦៦.៨៨២** | ១.០១៦.១១២ |

# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុរបស់សម្ព័ន្ធក្រុមហ៊ុន (ត)

| | សម្គាល់ | **ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ ពាន់ដុល្លារអាមេរិក** | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ ពាន់ដុល្លារអាមេរិក | **ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ លានរៀល (សម្គាល់ ៤.២)** | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ លានរៀល (សម្គាល់ ៤.២) |
|---|---|---|---|---|---|
| **មូលធន និងបំណុល** | | | | | |
| **មូលធន** | | | | | |
| ដើមទុន | ១៤ | **៧.៤៩៤** | ៧.១០០ | **៣០.៧២៥** | ២៨.៨៦៩ |
| ដើមទុនបុព្វលាភ | ១៥ | **២.៥៤១** | - | **១០.៤២២** | - |
| ប្រាក់បម្រុង | ១៦ | **(៤.២៦៩)** | (៥.៨១៥) | **(១៧.៤៣៥)** | (២៣.៧២៩) |
| ចំណេញរក្សាទុក | | **១៧.១៩០** | ១៥.៨០២ | **៧០.០៤០** | ៦៤.៣៩០ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | - | **(២០៦)** | ៤០៦ |
| **មូលធនសរុបទាក់ទងនឹងម្ចាស់ក្រុមហ៊ុន** | | **២២.៩៥៦** | ១៧.០៨៧ | **៩៣.៥៤៦** | ៦៩.៩៣៦ |
| ផលប្រយោជន៍ភាគតិច | | **៨៦** | ៥ | **៣៥១** | ២១ |
| **មូលធនសរុប** | | **២៣.០៤២** | ១៧.០៩២ | **៩៣.៨៩៧** | ៦៩.៩៥៧ |
| **បំណុល** | | | | | |
| **បំណុលរយៈពេលវែង** | | | | | |
| ប្រាក់កម្ចី | ១៨ | **៨៧.០២៥** | ១០០.០៧៧ | **៣៥៤.៦២៧** | ៤០៩.៦១៥ |
| បំណុលភតិសន្យា | ៨ | **១៤៨** | ២៣ | **៦០៣** | ៩៤ |
| បំណុលពន្ធពន្យា | ២៤ | **៧៧៧** | ៤៥៣ | **៣.១៦៦** | ១.៨៥៤ |
| ឧបករណ៍ហិរញ្ញវត្ថុនិទស្សន៍ | ១៩ | **៤.៣២១** | ៥.៨៦៧ | **១៧.៦០៨** | ២៤.០១៤ |
| **បំណុលរយៈពេលវែងសរុប** | | **៩២.២៧១** | ១០៦.៤២០ | **៣៧៦.០០៤** | ៤៣៥.៥៧៧ |
| **បំណុលរយៈពេលខ្លី** | | | | | |
| គណនីពាណិជ្ជ និងបំណុលផ្សេងៗ | ១៧ | **៣៣.៣៩៦** | ១០.៨៥៩ | **១៣៦.០៩៩** | ៤៤.៤៤៦ |
| សមតុល្យត្រូវសងទៅក្រុមហ៊ុនមេ | ២៦ | **២៧.០៥៤** | ៦២.៨៩២ | **១១០.២៤៥** | ២៥៧.៤១៧ |
| សមតុល្យត្រូវសងទៅភាគីពាក់ព័ន្ធ | ២៦ | **៩០.៦៦៨** | ៣៦.៦៦៧ | **៣៦៩.៤៧២** | ១៥០.០៧៨ |
| ប្រាក់កម្ចី | ១៨ | **១៣.៥៤៤** | ១២.៦១៤ | **៥៥.១៩២** | ៥១.៦២៩ |
| បំណុលភតិសន្យា | ៨ | **១៤** | ៧២ | **៥៨** | ២៩៥ |
| ពន្ធលើប្រាក់ចំណូលត្រូវបង់ | | **១.៨១២** | ១.៦៤០ | **៧.៣៨៤** | ៦.៧១៣ |
| **បំណុលរយៈពេលខ្លីសរុប** | | **១៦៦.៤៨៨** | ១២៤.៧៤៤ | **៦៧៨.៤៤០** | ៥១០.៥៧៨ |
| **បំណុលសរុប** | | **២៦៣.៣០៩** | ២៣១.១៦៤ | **១.០៧២.៩៨៥** | ៩៤៦.១៥៥ |
| **មូលធន និងបំណុលសរុប** | | **២៨៦.៣៥១** | ២៤៨.២៥៦ | **១.១៦៦.៨៨២** | ១.០១៦.១១២ |

# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន

| | សម្គាល់ | **ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ ពាន់ដុល្លារអាមេរិក** | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ ពាន់ដុល្លារអាមេរិក | **ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ លានរៀល (សម្គាល់ ៤.២)** | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ លានរៀល (សម្គាល់ ៤.២) |
|---|---|---|---|---|---|
| **ទ្រព្យសកម្ម** | | | | | |
| **ទ្រព្យសកម្មរយៈពេលវែង** | | | | | |
| វិនិយោគក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ | ៩ | **៥០** | ៣៥ | **២០៤** | ១៤៣ |
| ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | ៧ | **១៤.១៥០** | ១៥.៤០៤ | **៥៧.៦៦១** | ៦៣.០៤៩ |
| ទ្រព្យសកម្មអរូបិយ | | **៣** | ៥ | **១២** | ២០ |
| ទ្រព្យសកម្មកិច្ចសន្យា | ១០ | **១២២.១៦៧** | ១៩៨.២០០ | **៤៩៧.៨៣១** | ៨១១.២៣៣ |
| **ទ្រព្យសកម្មរយៈពេលវែងសរុប** | | **១៣៦.៣៧០** | ២១៣.៦៤៤ | **៥៥៥.៧០៨** | ៨៧៤.៤៤៥ |
| **ទ្រព្យសកម្មរយៈពេលខ្លី** | | | | | |
| សន្និធិ | ១១ | **៣.៥០៨** | ៤.៣៣៥ | **១៤.២៩៥** | ១៧.៧៤៣ |
| ទ្រព្យសកម្មកិច្ចសន្យា | ១០ | **១២២.៨៥១** | ១៨.៧៨៩ | **៥០០.៦១៨** | ៧៦.៩០៣ |
| គណនីពាណិជ្ជ និងគណនីត្រូវទទួលផ្សេងៗ | ១២ | **៦.៤៩៧** | ៣.៦៥២ | **២៦.៤៧៥** | ១៤.៩៤៨ |
| សមតុល្យត្រូវទទួលពីភាគីពាក់ព័ន្ធ | ២៦ | **២** | ២.៣៣២ | **៨** | ៩.៥៤៥ |
| សមតុល្យត្រូវទទួលពីក្រុមហ៊ុនបុត្រសម្ព័ន្ធ | ២៦ | **៧៩** | ៣៨ | **៣២២** | ១៥៦ |
| សាច់ប្រាក់ និងសមតុល្យធនាគារ | ១៣ | **១៧.១៥៤** | ៥.៥០០ | **៦៩.៩០៣** | ២២.៥១២ |
| **ទ្រព្យសកម្មរយៈពេលខ្លីសរុប** | | **១៥០.០៩១** | ៣៤.៦៤៦ | **៦១១.៦២១** | ១៤១.៨០៧ |
| **ទ្រព្យសកម្មសរុប** | | **២៨៦.៤៦១** | ២៤៨.២៩០ | **១.១៨៧.៣២៩** | ១.០១៦.២៥២ |

# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន(ត)

| | សម្គាល់ | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ ពាន់ដុល្លារអាមេរិក | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ ពាន់ដុល្លារអាមេរិក | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ លានរៀល (សម្គាល់ ៤.២) | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ លានរៀល (សម្គាល់ ៤.២) |
|---|---|---|---|---|---|
| **មូលធន និងបំណុល** | | | | | |
| **មូលធន** | | | | | |
| ដើមទុន | ១៤ | **៧.៤៩៤** | ៧.១០០ | **៣០.៧២៥** | ២៨.៨៦៩ |
| ដើមទុនបុព្វលាភ | ១៥ | **២.៥៤១** | - | **១០.៤២២** | - |
| ប្រាក់បម្រុង | ១៦ | **(៤.២៦៩)** | (៥.៨១៥) | **(១៧.៤៣៥)** | (២៣.៧២៩) |
| ចំណេញរក្សាទុក | | **១៧.៤០០** | ១៥.៨៤១ | **៧០.៩១២** | ៦៤.៥៦៦ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | - | **(២២៣)** | ៣៩១ |
| **មូលធនសរុប** | | **២៣.១៦៦** | ១៧.១២៦ | **៩៤.៤០១** | ៧០.០៩៧ |
| **បំណុល** | | | | | |
| **បំណុលរយៈពេលវែង** | | | | | |
| ប្រាក់កម្ចី | ១៨ | **៨៧.០២៥** | ១០០.០៧៧ | **៣៧៣.១៦៨** | ៤០៩.៦១៥ |
| បំណុលភតិសន្យា | ៨ | **១៤៨** | ២៣ | **៦០៣** | ៩៤ |
| បំណុលពន្ធពន្យា | ២៤ | **៧៧៧** | ៤៥៣ | **៣.១៦៦** | ១.៨៥៤ |
| ឧបករណ៍ហិរញ្ញវត្ថុនិទស្សន៍ | ១៩ | **៤.៣២១** | ៥.៨៦៧ | **១៧.៦០៨** | ២៤.០១៤ |
| **បំណុលរយៈពេលវែងសរុប** | | **៩៦.៨២១** | ១០៦.៤២០ | **៣៩៤.៥៤៥** | ៤៣៥.៥៧៧ |
| **បំណុលរយៈពេលខ្លី** | | | | | |
| គណនីពាណិជ្ជ និងគណនីត្រូវសងផ្សេងៗ | ១៧ | **៣៣.៣៨២** | ១០.៨៥៩ | **១៣៦.០៣២** | ៤៤.៤៤៦ |
| សមតុល្យត្រូវសងទៅក្រុមហ៊ុនមេ | ២៦ | **២៧.០៥៤** | ៦២.៨៩២ | **១១០.២៤៥** | ២៥៧.៤១៧ |
| សមតុល្យត្រូវសងទៅភាគីពាក់ព័ន្ធ | ២៦ | **៩០.៦៦៨** | ៣៦.៦៦៧ | **៣៦៩.៤៧២** | ១៥០.០៧៨ |
| ប្រាក់កម្ចី | ១៨ | **១៣.៥៤៤** | ១២.៦១៤ | **៥៥.១៩២** | ៥១.៦២៩ |
| បំណុលភតិសន្យា | ៨ | **១៤** | ៧២ | **៥៨** | ២៩៥ |
| ពន្ធលើប្រាក់ចំណូលត្រូវបង់ | | **១.៨១២** | ១.៦៤០ | **៧.៣៨៤** | ៦.៧១៣ |
| **បំណុលរយៈពេលខ្លី** | | **១៦៦.៤៧៤** | ១២៤.៧៤៤ | **៦៧៨.៣៨៣** | ៥១០.៥៧៨ |
| **បំណុលសរុប** | | **២៦៣.២៩៥** | ២៣១.១៦៤ | **១.០៧២.៩២៨** | ៩៤៦.១៥៥ |
| **មូលធន និងបំណុលសរុប** | | **២៨៦.៤៦១** | ២៤៨.២៩០ | **១.១៦៧.៣២៩** | ១.០១៦.២៥២ |

# របាយការណ៍ចំណេញ ឬខាត និងចំណូលពេញលេញផ្សេងៗរបស់សម្ព័ន្ធក្រុមហ៊ុន

| | សម្គាល់ | **សម្រាប់ចុងការិយបរិច្ឆេទ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ ពាន់ដុល្លារអាមេរិក** | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ ពាន់ដុល្លារអាមេរិក | **សម្រាប់ចុងការិយបរិច្ឆេទ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ លានរៀល (សម្គាល់ ៤.២)** | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ លានរៀល (សម្គាល់ ៤.២) |
|---|---|---|---|---|---|
| ចំណូល | ២០ | **៦៧.២១៤** | ៤៩.៦៧៣ | **២៧៣.៦២៨** | ២០៣.០១៤ |
| ចំណាយប្រតិបត្តិការ | ២១ | **(៥៩.៥៩៦)** | (៣៣.៨៣៤) | **(២៤២.៦១៥)** | (១៣៨.២៨១) |
| ចំណេញ/ខាតផ្សេងៗ | | **៥** | (១៣) | **២០** | (៥៣) |
| **ចំណេញប្រតិបត្តិការ** | | **៧.៦២៣** | ១៥.៨២៦ | **៣១.០៣៣** | ៦៤.៦៨០ |
| ចំណូលហិរញ្ញប្បទាន | | **១.០៩៨** | ២៩ | **៤.៤៧០** | ១១៩ |
| ចំណាយហិរញ្ញប្បទាន | ២២ | **(៦.២៤៣)** | (៦.៦១២) | **(២៥.៤១៥)** | (២៧.០២៣) |
| **ចំណេញមុនបង់ពន្ធលើប្រាក់ចំណូល** | | **២.៤៧៨** | ៩.២៤៣ | **១០.០៨៨** | ៣៧.៧៧៦ |
| ចំណាយពន្ធលើប្រាក់ចំណូល | ២៣ | **(១.០០៩)** | (២.០៣៩) | **(៤.១០៨)** | (៨.៣៣៣) |
| **ចំណេញក្នុងការិយបរិច្ឆេទ** | | **១.៤៦៩** | ៧.២០៤ | **៥.៩៨០** | ២៩.៤៤៣ |
| | | | | | |
| **ចំណេញក្នុងការិយបរិច្ឆេទទាក់ទងទៅនឹង៖** | | | | | |
| ម្ចាស់ក្រុមហ៊ុន | | **១.៣៨៨** | ៧.២០៧ | **៥.៦៥០** | ២៩.៤៥៥ |
| ផលប្រយោជន៍ភាគតិច | | **៨១** | (៣) | **៣៣០** | (១២) |
| | | **១.៤៦៩** | ៧.២០៤ | **៥.៩៨០** | ២៩.៤៤៣ |

ជូនភ្ជាប់កំណត់សម្គាល់ជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុ

# របាយការណ៍ចំណេញ ឬខាត និងចំណូលពេញលេញផ្សេងៗរបស់សម្ព័ន្ធក្រុមហ៊ុន (ត)

| | សម្គាល់ | សម្រាប់ចុងការិយបរិច្ឆេទ<br>ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១<br>ពាន់ដុល្លារអាមេរិក | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០<br>ពាន់ដុល្លារអាមេរិក | សម្រាប់ចុងការិយបរិច្ឆេទ<br>ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១<br>លានរៀល<br>(សម្គាល់ ៤.២) | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០<br>លានរៀល<br>(សម្គាល់ ៤.២) |
|---|---|---|---|---|---|
| **ចំណេញក្នុងការិយបរិច្ឆេទ** | | **១.៤៦៩** | ៧.២០៤ | **៥.៩៨០** | ២៩.៤៤៣ |
| ***ចំណូលពេញលេញផ្សេងៗ*** | | | | | |
| សមាសធាតុដែលត្រូវធ្វើចំណាត់ឡើងវិញ ក្នុងចំណេញ ឬខាត | | | | | |
| ចំណេញ/(ខាត) នៃតម្លៃសមស្របលើ លំហូរសាច់ប្រាក់ | | **១.៥៤៦** | (៤.០៤៣) | **៦.២៩៤** | (១៦.៥២៤) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | - | **(៦១២)** | ៤០៦ |
| **ចំណូលពេញលេញសរុបក្នុងការិយបរិច្ឆេទ** | | **៣.០១៥** | ៣.១៦១ | **១១.៦៦២** | ១៣.៣២៥ |
| **ចំណេញក្នុងការិយបរិច្ឆេទទាក់ទងទៅនឹង៖** | | | | | |
| ម្ចាស់ក្រុមហ៊ុន | | **២.៨៥៣** | ៣.១៦៤ | **១១.០០២** | ១៣.៣៣៧ |
| ផលប្រយោជន៍ភាគតិច | | **១៦២** | (៣) | **៦៦០** | (១២) |
| | | **៣.០១៥** | ៣.១៦១ | **១១.៦៦២** | ១៣.៣២៥ |

ចំណូលក្នុងមួយភាគហ៊ុនដែលជាកម្មសិទ្ធិរបស់ម្ចាស់ភាគហ៊ុនរបស់សម្ព័ន្ធក្រុមហ៊ុនក្នុងអំឡុងកាលបរិច្ឆេទមានដូចខាងក្រោម៖

| | | | | | |
|---|---|---|---|---|---|
| ចំណេញសុទ្ធក្នុងមួយភាគហ៊ុនគោល (សេន/រៀល) | ៣០ | **១,៨៦** | ១០,១៥ | **៧៥,៨៦** | ៤១៤,៨៦ |
| ចំណេញសុទ្ធក្នុងមួយភាគហ៊ុនថយចុះ (សេន/រៀល) | ៣០ | **១,៨៦** | ១០,១៥ | **៧៥,៨៦** | ៤១៤,៨៦ |

# របាយការណ៍ចំណេញ ឬខាត និងចំណូលពេញលេញផ្សេងៗរបស់សម្ព័ន្ធក្រុមហ៊ុន

| | សម្គាល់ | **សម្រាប់ចុងការិយបរិច្ឆេទ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ ពាន់ដុល្លារអាមេរិក** | សម្រាប់ចុងការិយបរិច្ឆេទ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ ពាន់ដុល្លារអាមេរិក | **សម្រាប់ចុងការិយបរិច្ឆេទ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ លានរៀល (សម្គាល់ ៤.២)** | សម្រាប់ចុងការិយបរិច្ឆេទ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ លានរៀល (សម្គាល់ ៤.២) |
|---|---|---|---|---|---|
| ចំណូល | ២០ | **៦៧.២១៤** | ៤៩.៦៧៣ | **២៧៣.៦២៨** | ២០៣.០១៤ |
| ចំណាយប្រតិបត្តិការ | ២១ | **(៥៩.៥១៧)** | (៣៣.៧៩៧) | **(២៤២.២៩៤)** | (១៣៨.១២៧) |
| ចំណេញ/ខាតផ្សេងៗ | | **១៦** | (២០) | **៦៥** | (៨២) |
| **ចំណេញប្រតិបត្តិការ** | | **៧.៧១៣** | ១៥.៨៥៦ | **៣១.៣៩៩** | ៦៤.៨០៥ |
| ចំណូលហិរញ្ញប្បទាន | | **១.០៩៨** | ២៩ | **៤.៤៧០** | ១១៩ |
| ចំណាយហិរញ្ញប្បទាន | ២២ | **(៦.២៤៣)** | (៦.៦១២) | **(២៥.៤១៥)** | (២៧.០២៣) |
| **ចំណេញមុនបង់ពន្ធលើប្រាក់ចំណូល** | | **២.៥៦៨** | ៩.២៧៣ | **១០.៤៥៤** | ៣៧.៩០១ |
| ចំណាយពន្ធលើប្រាក់ចំណូល | ២៣ | **(១.០០៩)** | (២.០៣៩) | **(៤.១០៨)** | (៨.៣៣៣) |
| **ចំណេញក្នុងការិយបរិច្ឆេទ** | | **១.៥៥៩** | ៧.២៣៤ | **៦.៣៤៦** | ២៩.៥៦៨ |
| **ចំណូល /(ខាត)ពេញលេញផ្សេងទៀត** | | | | | |
| សមាសធាតុដែលត្រូវធ្វើចំណាត់ឡើងវិញក្នុង ចំណេញ ឬខាត | | | | | |
| ចំណេញ/(ខាត) នៃតម្លៃសមស្របលើ លំហូរសាច់ប្រាក់ | | **១.៥៤៦** | (៤.០៤៣) | **៦.២៩៤** | (១៦.៥២៤) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | **-** | - | **(៦១៤)** | ៣៩១ |
| **ចំណូលពេញលេញសរុបក្នុងការិយបរិច្ឆេទ** | | **៣.១០៥** | ៣.១៩១ | **១២.០២៦** | ១៣.៤៣៥ |

# របាយការណ៍បម្រែបម្រួលមូលធនរបស់សម្ព័ន្ធក្រុមហ៊ុន

| | សម្គាល់ | កម្មសិទ្ធរបស់ម្ចាស់ភាគហ៊ុន | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | មិនអាចបែងចែក | | | អាចបែងចែក | | ផលប្រយោជន៍ភាគតិច | | |
| | | ដើមទុន ពាន់ដុល្លារអាមេរិក | បុព្វលាភដើមទុន ពាន់ដុល្លារអាមេរិក | ដើមទុនបម្រុងទុក ពាន់ដុល្លារអាមេរិក | ចំណេញរក្សាទុក ពាន់ដុល្លារអាមេរិក | សរុប ពាន់ដុល្លារអាមេរិក | ពាន់ដុល្លារអាមេរិក | ពាន់ដុល្លារអាមេរិក | មូលធនសរុប លានរៀល (សម្គាល់ ៤.២) |
| សមតុល្យគិតត្រឹមថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២០ | | ៧.១០០ | - | (៥.៨១៥) | ១៥.៨០២ | ១៧.០៨៧ | ៥ | ១៧.០៩២ | ៦៩.៩៥៧ |
| ភាគហ៊ុនដែលបានចេញផ្សាយ | ១៤ | ៣៩៤ | ២.៥៤១ | - | - | ២.៩៣៥ | - | ២.៩៣៥ | ១២.២៧៨ |
| ចំណេញក្នុងការិយបរិច្ឆេទ | | - | - | - | ១.៣៨៨ | ១.៣៨៨ | ៨១ | ១.៤៦៩ | ៥.៩៨០ |
| ចំណេញពីតម្លៃសមស្របនៃលំហូរសាច់ប្រាក់ | | - | - | ១.៥៤៦ | - | ១.៥៤៦ | - | ១.៥៤៦ | ៦.២៩៤ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | - | - | - | - | - | - | (៦១២) |
| **សមតុល្យគិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១** | | **៧.៤៩៤** | **២.៥៤១** | **(៤.២៦៩)** | **១៧.១៩០** | **២២.៩៥៦** | **៨៦** | **២៣.០៤២** | **៩៣.៨៩៧** |
| | | | | | | | | | |
| សមតុល្យគិតត្រឹមថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៩ | | ៧.១០០ | - | (១.៧៧២) | ៨.៥៩៥ | ១៣.៩២៣ | - | ១៣.៩២៣ | ៥៦.៦១១ |
| ចំណេញក្នុងការិយបរិច្ឆេទ | | - | - | - | ៧.២០៧ | ៧.២០៧ | (៣) | ៧.២០៤ | ២៩.៤៤៣ |
| បន្ថែមដើមទុនដោយ ផលប្រយោជន៍ភាគតិច ដោយក្រុមហ៊ុនបុត្រសម្ព័ន្ធ | | - | - | - | - | - | ៨ | ៨ | ៣៣ |
| ការខាតបង់ពីតម្លៃសមស្របនៃលំហូរសាច់ប្រាក់ | | - | - | (៤.០៤៣) | - | (៤.០៤៣) | - | (៤.០៤៣) | (១៦.៥២៤) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | - | - | - | - | - | - | ៣៩៤ |
| សមតុល្យគិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ | | ៧.១០០ | - | (៥.៨១៥) | ១៥.៨០២ | ១៧.០៨៧ | ៥ | ១៧.០៩២ | ៦៩.៩៥៧ |

# របាយការណ៍បម្រែបម្រួលមូលធនរបស់ក្រុមហ៊ុន

| | | ← មិនអាចបែងចែកបាន | | → | អាចបែងចែកបាន | | |
|---|---|---|---|---|---|---|---|
| | | ដើមទុន | បុព្វលាភដើមទុន | ដើមទុនបម្រុងទុក | ចំណេញរក្សាទុក | មូលធនសរុប | |
| | សម្គាល់ | ពាន់ដុល្លារអាមេរិក | ពាន់ដុល្លារអាមេរិក | ពាន់ដុល្លារអាមេរិក | ពាន់ដុល្លារអាមេរិក | ពាន់ដុល្លារអាមេរិក | លានរៀល (សម្គាល់ ៤.២) |
| សមតុល្យគិតត្រឹមថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២០ | | ៧.១០០ | - | (៥.៨១៥) | ១៥.៨៤១ | ១៧.១២៦ | ៧០.០៩៧ |
| ភាគហ៊ុនដែលបានចេញផ្សាយ | ១៤ | ៣៩៤ | ២.៥៤១ | - | - | ២.៩៣៥ | ១២.២៧៨ |
| ចំណេញក្នុងការិយបរិច្ឆេទ | | - | - | - | ១.៥៥៩ | ១.៥៥៩ | ៦.៣៤៦ |
| ចំណេញពីតម្លៃសមស្របនៃលំហូរសាច់ប្រាក់ | | - | - | ១.៥៤៦ | - | ១.៥៤៦ | ៦.២៩៤ |
| លម្អៀងពីការប្ដូររូបិយប័ណ្ណ | | - | - | - | - | - | (៦១៤) |
| **សមតុល្យគិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១** | | **៧.៤៩៤** | **២.៥៤១** | **(៤.២៦៩)** | **១៧.៤០០** | **២៣.១៦៦** | **៩៤.៤០១** |
| | | | | | | | |
| សមតុល្យគិតត្រឹមថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៩ | | ៧.១០០ | - | (១.៧៧២) | ៨.៦០៧ | ១៣.៩៣៥ | ៥៦.៦៦២ |
| ចំណេញក្នុងការិយបរិច្ឆេទ | | - | - | | ៧.២៣៤ | ៧.២៣៤ | ២៩.៥៦៨ |
| ខាតពីតម្លៃសមស្របនៃលំហូរសាច់ប្រាក់ | | - | - | (៤.០៤៣) | - | (៤.០៤៣) | (១៦.៥២៤) |
| លម្អៀងពីការប្ដូររូបិយប័ណ្ណ | | - | - | - | - | - | ៣៩១ |
| សមតុល្យគិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ | | ៧.១០០ | - | (៥.៨១៥) | ១៥.៨៤១ | ១៧.១២៦ | ៧០.០៩៧ |

ជូនភ្ជាប់កំណត់សម្គាល់ជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុ

# របាយការណ៍លំហូរសាច់ប្រាក់របស់សម្ព័ន្ធក្រុមហ៊ុន

| | | សម្រាប់ចុងការិយបរិច្ឆេទ | | សម្រាប់ចុងការិយបរិច្ឆេទ | |
|---|---|---|---|---|---|
| | សម្គាល់ | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ ពាន់ដុល្លារអាមេរិក | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ ពាន់ដុល្លារអាមេរិក | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ លានរៀល (សម្គាល់ ៤.២) | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ លានរៀល (សម្គាល់ ៤.២) |
| **សកម្មភាពប្រតិបត្តិការ** | | | | | |
| ចំណេញមុនបង់ពន្ធលើប្រាក់ចំណូល | | **២.៤៧៨** | ៩.២៤៣ | **១០.០៨៨** | ៣៧.៧៧៦ |
| **និយ័តកម្មសម្រាប់៖** | | | | | |
| រំលស់លើទ្រព្យសកម្មរូបិយ | ២១ | **១.០៥៩** | ១.១៧៨ | **៤.៣១១** | ៤.៨១៤ |
| រំលស់លើទ្រព្យសកម្មអរូបិយ | ២១ | **៣** | ២ | **១២** | ៨ |
| ចំណេញពីការលក់ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | | **-** | (៥) | **-** | (២០) |
| ចំណូលពីការប្រាក់ | | **(១.០៩៨)** | (២៩) | **(៤.៤៧០)** | (១១៩) |
| ចំណាយពីការប្រាក់ | ២២ | **៦.២៤៣** | ៦.៦១២ | **២៥.៤១៥** | ២៧.០២៣ |
| (ចំណេញ)/ខាតពីការប្តូររូបិយប័ណ្ណបរទេស | | **(១០)** | ១០ | **(៤១)** | ៤១ |
| **ចំណេញប្រតិបត្តិការមុនបម្រែបម្រួលទុនបង្វិល** | | **៨.៦៧៥** | ១៧.០១១ | **៣៥.៣១៥** | ៦៩.៥២៣ |
| **បម្រែបម្រួលដើមទុនបង្វិល** | | | | | |
| **បម្រែបម្រួលលើ៖** | | | | | |
| គណនីពាណិជ្ជ និងគណនីត្រូវទទួលផ្សេងៗ | | **(២.៦២៧)** | ៧.១៣៧ | **(១០.៦៩៥)** | ២៩.១៦៩ |
| ទ្រព្យសកម្មកិច្ចសន្យា | | **(២៨.០២៩)** | (៣៧.៨៨៨) | **(១១៤.១០៦)** | (១៥៤.៨៤៨) |
| សន្និធិ | | **៨២៧** | (៤.៣៣៥) | **៣.៣៦៧** | (១៧.៧១៧) |
| សមតុល្យត្រូវសងទៅក្រុមហ៊ុនមេ | | **(៣៥.៨៣៨)** | ៣.៣៣៤ | **(១៤៥.៨៩៦)** | ១៣.៦២៦ |
| សមតុល្យត្រូវទទួល/ត្រូវសងទៅភាគីពាក់ព័ន្ធ | | **៥៦.៣៤១** | ១៣.២៥៩ | **២២៩.៣៦៤** | ៥៤.១៩០ |
| គណនីពាណិជ្ជ និងគណនីត្រូវសងផ្សេងៗ | | **២២.៥០៣** | ១.៦៦៥ | **៩១.៦១០** | ៦.៨០៥ |
| **សាច់ប្រាក់ទទួលបានពីប្រតិបត្តិការ** | | **២១.៨៥២** | ១៨៣ | **៨៨.៩៥៩** | ៧៤៨ |
| ពន្ធលើប្រាក់ចំណូលដែលបានបង់ | | **(៥១៣)** | (៨៧៤) | **(២.០៨៨)** | (៣.៥៧២) |
| **សាច់ប្រាក់សុទ្ធបានពី/(ប្រើក្នុង) សកម្មភាពប្រតិបត្តិការ** | | ២១.៣៣៩ | (៦៩១) | **៨៦.៨៧១** | (២.៨២៤) |

# របាយការណ៍លំហូរសាច់ប្រាក់របស់សម្ព័ន្ធក្រុមហ៊ុន (ត)

| | សម្គាល់ | **សម្រាប់ចុងការិយបរិច្ឆេទ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ ពាន់ដុល្លារអាមេរិក** | សម្រាប់ចុងការិយបរិច្ឆេទ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ ពាន់ដុល្លារអាមេរិក | **ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ ២០២១ លានរៀល (សម្គាល់ ៤.២)** | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ លានរៀល (សម្គាល់ ៤.២) |
|---|---|---|---|---|---|
| **សកម្មភាពវិនិយោគ** | | | | | |
| ទិញទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | | **(២០២)** | (១៤.១៨៣) | **(៨២២)** | (៥៧.៩៦៦) |
| ទិញទ្រព្យសកម្មអរូបិយ | | **(១)** | (៤) | **(៤)** | (១៦) |
| ចំណេញពីការលក់ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | | **-** | ១៥ | **-** | ៦១ |
| ការប្រាក់ដែលបានទទួល | | **៥០** | ២៩ | **២០៤** | ១១៩ |
| **សាច់ប្រាក់សុទ្ធប្រើក្នុងសកម្មភាពវិនិយោគ** | | **(១៥៣)** | (១៤.១៤៣) | **(៦២២)** | (៥៧.៨០២) |
| **សកម្មភាពហិរញ្ញប្បទាន** | | | | | |
| ចំណូលពីប្រាក់កម្ចី | ២៥ | **៧.៩៩៧** | ២៥.៥៩៨ | **៣២.៥៥៦** | ១០៤.៦១៩ |
| ការទូទាត់ប្រាក់កម្ចី | ២៥ | **(១៥.៦១៣)** | (១២.២៩០) | **(៦៣.៥៦១)** | (៥០.២២៩) |
| ចេញផ្សាយដើមទុនបន្ថែម | ១៤ | **២.៩៣៥** | - | **១១.៩៤៨** | - |
| ការប្រាក់ដែលបានទូទាត់ | | **(៦.២០៩)** | (៥.៧៣៥) | **(២៥.២៧៧)** | (២៣.៤៣៩) |
| ការទូទាត់បំណុលភតិសន្យា | | **(១២៤)** | (៦៧) | **(៥០៥)** | (២៧៤) |
| ការដាក់ប្រាក់បញ្ញើមានកាលកំណត់ | | **(២០៤)** | (៤៨៧) | **(៨៣០)** | (១.៩៩០) |
| ការដាក់សាច់ប្រាក់នៅក្នុងគណនីធនាគារសន្យាខ្ចីប្រាក់ | | **(២.៤៦៣)** | (២.៧៥៣) | **(១០.០២៧)** | (១១.២៥២) |
| **សាច់ប្រាក់សុទ្ធបានពី/(ប្រើ)ក្នុងសកម្មភាពហិរញ្ញប្បទានសាច់ប្រាក់** | | **(១៣.៦៨១)** | ៤.២៦៦ | **(៥៥.៦៩៦)** | ១៧.៤៣៥ |
| **បម្រែបម្រួលសាច់ប្រាក់ និងសាច់ប្រាក់សមមូលសុទ្ធ** | | **៧,៥០៥** | (១០,៥៦៨) | **៣០,៥៤៣** | (៤៣.១៩១) |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលដើមគ្រា | | **(៩០៦)** | ៩.៦៦២ | **(៣.៧០៨)** | ៣៩.២៨៤ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | **-** | - | **៤៧** | ១៩៥ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលចុងគ្រា** | ១៣ | **៦.៥៩៩** | (៩០៦) | **២៦.៨៩២** | (៣.៧០៨) |

# របាយការណ៍លំហូរសាច់ប្រាក់របស់ក្រុមហ៊ុន

| | | សម្រាប់ចុងការិយបរិច្ឆេទ | | សម្រាប់ចុងការិយបរិច្ឆេទ | |
|---|---|---|---|---|---|
| | សម្គាល់ | **ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ ពាន់ដុល្លារអាមេរិក** | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ ពាន់ដុល្លារអាមេរិក | **ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ លានរៀល (សម្គាល់ ៤.២)** | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ លានរៀល (សម្គាល់ ៤.២) |
| **សកម្មភាពប្រតិបត្តិការ** | | | | | |
| ចំណេញមុនបង់ពន្ធលើប្រាក់ចំណូល | | **២.៥៦៨** | ៩.២៧៣ | **១០.៤៥៤** | ៣៧.៩០១ |
| **និយ័តកម្មសម្រាប់៖** | | | | | |
| រំលស់លើទ្រព្យសកម្មរូបិយ | ២១ | **១.០៥៩** | ១.១៧៨ | **៤.៣១១** | ៤.៨១៤ |
| រំលស់លើទ្រព្យសកម្មអរូបិយ | ២១ | **៣** | ២ | **១២** | ៨ |
| ចំណេញពីការលក់ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | | **-** | (៥) | **-** | (២០) |
| ចំណូលការប្រាក់ | | **(១.០៩៨)** | (២៩) | **(៤.៤៧០)** | (១១៩) |
| ចំណាយការប្រាក់ | ២២ | **៦.២៤៣** | ៦.៦១២ | **២៥.៤១៥** | ២៧.០២៣ |
| ចំណេញ/(ខាត)ពីការប្ដូររូបិយប័ណ្ណបរទេស | | **(១០)** | ១០ | **(៤១)** | ៤១ |
| **ចំណេញប្រតិបត្តិការមុនបម្រែបម្រួលទុនបង្វិល** | | **៨.៧៦៥** | ១៧.០៤១ | **៣៥.៦៨១** | ៦៩.៦៤៨ |
| **បម្រែបម្រួលទុនបង្វិល** | | | | | |
| **បម្រែបម្រួលក្នុង៖** | | | | | |
| គណនីពាណិជ្ជ និងគណនីត្រូវទទួលផ្សេងៗ | | **(២.៦៣៦)** | ៧.១៥២ | **(១០.៧៣១)** | ២៩.២៣០ |
| ទ្រព្យសកម្មកិច្ចសន្យា | | **(២៨.០២៩)** | (៣៧.៨៨៨) | **(១១៤.១០៦)** | (១៥៤.៨៤៨) |
| សន្និធិ | | **៨២៧** | (៤.៣៣៥) | **៣.៣៦៧** | (១៧.៧១៧) |
| សមតុល្យត្រូវសងទៅក្រុមហ៊ុនមេ | | **(៣៥.៨៣៨)** | ៣.៣៣៤ | **(១៤៥.៨៩៦)** | ១៣.៦២៦ |
| សមតុល្យត្រូវទទួល/ត្រូវសងទៅភាគីពាក់ព័ន្ធ | | **៥៦.៣៤១** | ១៣.២៥១ | **២២៩.៣៦៤** | ៥៤.១៥៧ |
| គណនីពាណិជ្ជ និងគណនីត្រូវសងផ្សេងៗ | | **២២.៤៨៩** | ១.៦៦៧ | **៩១.៥៥៣** | ៦.៨១៣ |
| សមតុល្យត្រូវសងទៅក្រុមហ៊ុនបុត្រសម្ព័ន្ធ | | **(៤១)** | (៣៧) | **(១៦៧)** | (១៥១) |
| **សាច់ប្រាក់ទទួលបានពីប្រតិបត្តិការ** | | **២១.៨៧៨** | ១៨៥ | **៨៩.០៦៥** | ៧៥៨ |
| ពន្ធលើប្រាក់ចំណូលដែលបានបង់ | | **(៥១៣)** | (៨៧៤) | **(២.០៨៨)** | (៣.៥៧២) |
| **សាច់ប្រាក់សុទ្ធបានពី/(ប្រើក្នុង)សកម្មភាពប្រតិបត្តិការ** | | **២១.៣៦៥** | (៦៨៩) | **៨៦.៩៧៧** | (២.៨១៤) |

# របាយការណ៍លំហូរសាច់ប្រាក់របស់ក្រុមហ៊ុន (ត)

| | សម្គាល់ | សម្រាប់ចុងការិយបរិច្ឆេទ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ ពាន់ដុល្លារអាមេរិក | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ ពាន់ដុល្លារអាមេរិក | សម្រាប់ចុងការិយបរិច្ឆេទ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ លានរៀល (សម្គាល់ ៤.២) | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ លានរៀល (សម្គាល់ ៤.២) |
|---|---|---|---|---|---|
| **សកម្មភាពវិនិយោគ** | | | | | |
| ទិញទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | | **(២០២)** | (១៤.១៨៣) | **(៨២២)** | (៥៧.៩៦៦) |
| ទិញទ្រព្យសកម្មអរូបិយ | | **(១)** | (៤) | **(៤)** | (១៦) |
| ចំណេញពីការលក់ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | | - | ១៥ | - | ៦១ |
| ការវិនិយោគក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ | | **(១៥)** | (១០) | **(៦១)** | (៤១) |
| ការប្រាក់ដែលបានទទួល | | **៥០** | ២៩ | **២០៤** | ១១៩ |
| **សាច់ប្រាក់សុទ្ធប្រើក្នុងសកម្មភាពវិនិយោគ** | | **(១៦៨)** | (១៤.១៥៣) | **(៦៨៣)** | (៥៧.៨៤៣) |
| **សកម្មភាពហិរញ្ញប្បទាន** | | | | | |
| ចំណូលពីប្រាក់កម្ចី | ២៥ | **៧.៩៩៧** | ២៥.៥៩៨ | **៣២.៥៥៦** | ១០៤.៦១៩ |
| ការទូទាត់ប្រាក់កម្ចី | ២៥ | **(១៥.៦១៣)** | (១២.២៩០) | **(៦៣.៥៦១)** | (៥០.២២៩) |
| ចេញផ្សាយដើមទុនបន្ថែម | ១៤ | **២.៩៣៥** | - | **១១.៩៤៨** | - |
| ការប្រាក់ដែលបានទូទាត់ | | **(៦.២០៩)** | (៥.៧៣៥) | **(២៥.២៧៧)** | (២៣.៤៣៩) |
| ការទូទាត់បំណុលភតិសន្យា | | **(១២៤)** | (៦៧) | **(៥០៥)** | (២៧៤) |
| ការដាក់ប្រាក់បញ្ញើរមានកាលកំណត់ | | **(២០៤)** | (៤៨៧) | **(៨៣០)** | (១.៩៩០) |
| ការដាក់សាច់ប្រាក់នៅក្នុងគណនី ធនាគារសន្យាខ្ចីប្រាក់ | | **(២.៤៦៣)** | (២.៧៥៣) | **(១០.០២៧)** | (១១.២៥២) |
| **សាច់ប្រាក់សុទ្ធបានពី/(ប្រើក្នុង)សកម្មភាព ហិរញ្ញប្បទាន** | | **(១៣.៦៨១)** | ៤.២៦៦ | **(៥៥.៦៩៦)** | ១៧.៤៣៥ |
| **បម្រែបម្រួលសាច់ប្រាក់ និងសាច់ប្រាក់ សមមូលសុទ្ធ** | | **៧.៥១៦** | (១០.៥៧៦) | **៣០.៥៩៨** | (៤៣.២២២) |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលដើមគ្រា | | **(៩៣០)** | ៩.៦៤៦ | **(៣.៨០៦)** | ៣៩.២៨៨ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | - | **៤៧** | ១២៨ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលចុងគ្រា** | ១៣ | **៦.៥៨៦** | (៩៣០) | **២៦.៨៣៩** | (៣.៨០៦) |

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុនានា

## ១ ព័ត៌មានអំពីក្រុមហ៊ុន

ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ម.ក បានប្រតិបត្តិការអាជីវកម្មនៅថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១០ ក្នុងនាមជាក្រុមហ៊ុនឯកជនទទួលខុសត្រូវបានកម្រិត ហើយវាជាក្រុមហ៊ុនបុត្រសម្ព័ន្ធ ១០០% របស់ក្រុមហ៊ុន PESTECH International Berhad ដែលជាក្រុមហ៊ុនចុះបញ្ជី និងមានអាស័យដ្ឋាននៅប្រទេសម៉ាឡេស៊ី និងបានចុះបញ្ជីនៅក្នុងទីផ្សារគោលនៃ Bursa Malaysia Securities Berhad ជាមួយនឹងដើមទុនដែលបានចុះបញ្ជី និងទូទាត់រួចរាល់ក្នុងចំនួនទឹកប្រាក់សរុប ៧.១០០.០០០ ដុល្លារអាមេរិក ដែលស្មើនឹង ៧១.០០០.០០០ ភាគហ៊ុនដែលមានតម្លៃចារឹក ០.១០ដុល្លារអាមេរិកក្នុងមួយភាគហ៊ុន។ ក្រុមហ៊ុនបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម ("MOC") ក្រោមលេខចុះបញ្ជីពាណិជ្ជកម្ម ០០០០០៩៥៧។

នៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០២០ ក្រុមហ៊ុនបានចុះជាមួយផ្សារមូលបត្រកម្ពុជា ("CSX") ដោយជោគជ័យ។ ភាគហ៊ុនថ្មីដែលបានចេញផ្សាយមានចំនួន ៣.៩៤៥.០០០ ភាគហ៊ុនជាមួយតម្លៃចារឹក ៤០០ រៀល ឬ០.១០ដុល្លារអាមេរិកក្នុងមួយភាគហ៊ុននៅក្នុងតម្លៃបោះផ្សាយ ៣.១២០រៀល ឬ០.៧៦ ដុល្លារអាមេរិកក្នុងមួយភាគហ៊ុន។ នាកាលបរិច្ឆេទនៃរបាយការណ៍លក្ខខន្តិកៈក្រុមហ៊ុនមិនទាន់បានកែប្រែនៅឡើយ និងរំពឹងទុកថានឹងត្រូវកែប្រែបន្ទាប់ពីអនុម័តដោយម្ចាស់ភាគហ៊ុននៅក្នុងមហាសន្និបាតប្រចាំឆ្នាំនៅក្នុងខែវិច្ឆិកា ឆ្នាំ២០២១ ខាងមុខនេះ។

សកម្មភាពចម្បងរបស់ក្រុមហ៊ុន គឺសាងសង់ស្ថានីយ៍អគ្គិសនីរង និងបណ្តាញបញ្ជូន។

ក្រុមហ៊ុន PESTECH (Myanmar) Limited (ហៅកាត់ថា "PML") បានធ្វើប្រតិបត្តិការអាជីវកម្មក្នុងនាមជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតដែលកម្មសិទ្ធិ ១០០% ជារបស់ក្រុមហ៊ុនក្រោមលេខចុះបញ្ជីពាណិជ្ជកម្ម ១១៧១ FC/២០១៦-២០១៧ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៧ ដែលបានចេញផ្សាយដោយ ក្រសួងផែនការ និងហិរញ្ញវត្ថុ នៃរដ្ឋាភិបាលរបស់សាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា។ ដើមទុនចុះបញ្ជីរបស់ក្រុមហ៊ុនមានទឹកប្រាក់ចំនួន ៥០.០០០ ដុល្លារអាមេរិក ដែលស្មើនឹង ៥០.០០០ភាគហ៊ុនធម្មតា។

សកម្មភាពអាជីវកម្មចម្បងរបស់ PML គឺការផ្តល់សេវាកម្មគ្រប់គ្រងគម្រោង ស្ថានីយ៍អគ្គិសនី ការសាងសង់ និងតំឡើងបណ្តាញបញ្ជូន សេវាត្រួតពិនិត្យលើការធ្វើតេស្ត សេវាដាក់ឱ្យដំណើរការ និងការងារស៊ីវិល។

ក្រុមហ៊ុន PESTECH Hinthar Corporation Limited (ហៅកាត់ថា "PHC") ត្រូវបានចុះបញ្ជីជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតនៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ ២០១៩ ដែល ៦០% កាន់កាប់ដោយក្រុមហ៊ុន PML ក្រោមច្បាប់ក្រុមហ៊ុនមីយ៉ាន់ម៉ា២០១៧ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៩។ ដើមទុនដែលបានចុះបញ្ជីមានចំនួន ៥០.០០០ ដុល្លារអាមេរិកដែលស្មើនឹង ៥០.០០០ សន្លឹកហ៊ុន។

សកម្មភាពអាជីវកម្មចម្បងរបស់ PHC គឺការបង្កើតហេដ្ឋារចនាសម្ព័ន្ធ ព្រមទាំងលើកកំពស់វិស័យថាមពល ដែលមានដូចជាការបង្កើតថាមពល ការបញ្ជូនថាមពល និងការចែកចាយថាមពលជាដើមនៅសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា។

ក្រុមហ៊ុន PESTECH Microgrid Company Limited (ហៅកាត់ថា "PMG") ត្រូវបានចុះបញ្ជីជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតដែល ៩០% កាន់កាប់ដោយក្រុមហ៊ុន PHC ក្រោមការគ្រប់គ្រងច្បាប់ក្រុមហ៊ុនមីយ៉ាន់ម៉ា២០១៧ ចុះទី១៤ ខែកុម្ភៈ ឆ្នាំ២០២០។ ដើមទុនដែលបានចុះបញ្ជីមានចំនួន ១០.០០០ ដុល្លារអាមេរិកដែលស្មើនឹង១០.០០០សន្លឹកហ៊ុន។

## ១ ព័ត៌មានអំពីក្រុមហ៊ុន (ត)

សកម្មភាពអាជីវកម្មចម្បងរបស់ PMG គឺការផ្តល់នូវប្រព័ន្ធមីក្រូក្រាដ និងហេដ្ឋារចនាសម្ព័ន្ធថាមពលផ្សេងៗជូនតំបន់ជនបទនៅក្នុងសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា។

ក្រុមហ៊ុនចាត់ទុកក្រុមហ៊ុន PHC និងក្រុមហ៊ុន PMG ជាក្រុមហ៊ុនបុត្រសម្ព័ន្ធដោយប្រយោល។

ការិយាល័យចុះបញ្ជីរបស់ក្រុមហ៊ុន គឺនៅផ្ទះលេខ៦ ផ្លូវលេខ៥៨៨ សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។ ការិយាល័យចុះបញ្ជីរបស់ក្រុមហ៊ុន PML និងក្រុមហ៊ុន PMG មានទីតាំងនៅ បន្ទប់លេខ០១-០៥ ជាន់ទី១០ អគារការិយាល័យទីក្រុងJunction កែងផ្លូវ២៧ និងផ្លូវBogyoke Aung San ទីក្រុងយ៉ានហ្គូន សាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា និងផ្លូវThapyaynyo លេខ៣អ៊ី Shinsawpu Ward Sannchaung ទីក្រុងយ៉ានហ្គូន នៃសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា។

ក្រុមហ៊ុនពុំមានការផ្លាស់ប្តូរជាសារវន្ត លើសកម្មភាពចម្បងរបស់ក្រុមហ៊ុន និងក្រុមហ៊ុនបុត្រសម្ព័ន្ធនៅក្នុងអំឡុងការិយបរិច្ឆេទនៃរបាយការណ៍នេះទេ។

### ការរីករាលដាលនៃជម្ងឺកូវីដ-១៩

វីរុសប្រភេទថ្មី កូរ៉ូណា ("កូវីដ-១៩") ត្រូវបានកំណត់ថាជាជម្ងឺរាតត្បាតជាសកល ដែលបានរីករាលដាលនៅក្នុងប្រទេសកម្ពុជាចាប់តាំងពីខែមករា ឆ្នាំ២០២០។ ចាប់តាំងពីពេលនោះមកប្រទេសកម្ពុជាប្រឈមមុខនឹងហានិភ័យនៃការរីករាលដាលបន្ថែមទៀតដែលបណ្តាលឱ្យមានការរំខានទៅដល់សកម្មភាពអាជីវកម្ម និងសេដ្ឋកិច្ចជាតិ។

នៅថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២១ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ឱ្យមាននូវបម្រាមគោចរនៅក្នុងប្រទេសកម្ពុជាចាប់ផ្តើមពីថ្ងៃទី១៥ ខែមេសា រហូតដល់ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២១ ដែលត្រូវបានពន្យាពេលបន្ថែមរហូតដល់ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២១ ដើម្បីទប់ស្កាត់នូវការរីករាលដាលនៃជម្ងឺកូវីដ-១៩ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ការរីករាលដាលនៃជម្ងឺកូវីដ-១៩ និងការបិទខ្ទប់បានបង្ករឱ្យមានការរំខានដល់អាជីវកម្ម និងកត្តាម៉ាក្រូសេដ្ឋកិច្ចទាំងសកល និងនៅក្នុងតំបន់នៃព្រះរាជាណាចក្រកម្ពុជា។

សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនបានធ្វើការវាយតម្លៃលើផលប៉ះពាល់ជារួមទៅលើស្ថានភាពបង្ហាញពីប្រតិបត្តិការរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន ប្រតិបត្តិការហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់ ហើយបានសន្និដ្ឋានថាមិនមានផលប៉ះពាល់ជាសារវន្តទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនគិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ និងសម្រាប់ចុងការិយបរិច្ឆេទ។ គណៈគ្រប់គ្រង ជឿជាក់ថាសម្ព័ន្ធក្រុមហ៊ុន និងសម្ព័ន្ធក្រុមហ៊ុន គឺជាស្ថានភាពដ៏ល្អក្នុងការទប់ស្កាត់ការធ្លាក់ចុះនៃសេដ្ឋកិច្ច។

កត្តាដែលចូលរួមចំណែកក្នុងការធ្វើឱ្យសម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនមានជំហររឹងមាំមានដូចខាងក្រោម៖

- មិនមានការលុបចោលនូវកិច្ចសន្យាសំខាន់ៗណាមួយឡើយ។ បន្ថែមពីនេះទៀត សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនក៏មានកិច្ចសន្យារយៈពេលវែងមួយចំនួនជាមួយអតិថិជនចាស់ និង
- អតិថិជនគោលរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនមិនមានប្រឈមនឹងការលំបាកផ្នែកហិរញ្ញវត្ថុឡើយ។ គុណភាពឥណទានរបស់គណនីពាណិជ្ជត្រូវទទួលគិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ត្រូវបានកំណត់ថាមានភាពល្អប្រសើរ។

គិតត្រឹមកាលបរិច្ឆេទនៃការចេញផ្សាយនៃរបាយការណ៍ហិរញ្ញវត្ថុ ការរីករាលដាលនៅក្នុងប្រទេសកម្ពុជានៅអាចគ្រប់គ្រងបានដោយសារមានការព្រៀងទុកដោយបន្តឱ្យមាននូវកម្មវិធីចាក់វ៉ាក់សាំង ហើយបានធ្វើអន្តរាគមន៍ទាន់ពេលវេលារបស់រដ្ឋាភិបាលតាមរយៈបទបញ្ជាបន្ថែម ក្នុងការទប់ស្កាត់នូវការរីករាលដាលវីរុសនេះនៅក្នុងប្រទេសកម្ពុជា។

គណៈគ្រប់គ្រងកំពុងបន្តការតាមដានយ៉ាងជិតដល់អំពីការវិវត្តនៃជម្ងឺរាតត្បាត រួមទាំងរបៀបវាប៉ះពាល់ដល់សេដ្ឋកិច្ចសម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន ព្រមទាំងប្រជាជនទូទៅ។ សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន ធានាថាបុគ្គលិកទាំងអស់ប្រកាន់ខ្ជាប់នូវវិធានការរបស់រាជរដ្ឋាភិបាលក្នុងការទប់ស្កាត់ការរីករាលដាលនៃជម្ងឺកូវីដ-១៩ ដែលរួមមានដូចជាការពាក់ម៉ាស ការរក្សាគម្លាតសង្គម និងការសម្លាប់មេរោគយ៉ាងទៀតទាត់។

## ២ របាយការណ៍អនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("CIFRSs")

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងសម្ព័ន្ធក្រុមហ៊ុនត្រូវបានរៀបចំឡើងដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("CIFRSs")។ CIFRSs គឺដូចគ្នានឹងស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិពេញលេញ ("IFRSs") ដែលបានអនុម័តដោយក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ ពីព្រោះ IFRSs បានអនុម័តដោយក្រុមប្រឹក្សាគណនេយ្យជាតិ ("NAC") ដោយមិនបានឆ្លងកាត់ការកែប្រែដូចជាស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាឡើយ("CIFRSs")។

## ៣. ស្តង់ដារថ្មី ឬវិសោធនកម្ម និងការបកស្រាយ

### ៣.១ ស្តង់ដារ វិសោធនកម្ម និងការបកស្រាយទៅនឹងស្តង់ដារមានស្រាប់ដែលមានប្រសិទ្ធភាព និងត្រូវបានអនុម័តដោយក្រុមហ៊ុន នាកាលបរិច្ឆេទថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២០

សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនបានអនុម័តទៅលើស្តង់ដារ និងការបកស្រាយគណនីទាំងអស់គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១។ ស្តង់ដារគណនេយ្យថ្មី និងស្តង់ដារគណនេយ្យដែលបានកែប្រែ ព្រមទាំងការបកស្រាយគណនេយ្យត្រូវបានវាយតម្លៃថាអាចអនុវត្តបានទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនមានដូចខាងក្រោម៖

- និយមន័យអាជីវកម្ម (បានកែប្រែទៅជា CIFRS ៣)
- និយមន័យភាពជាសារវន្ត (បានកែប្រែទៅជា CIAS ១ និង CIAS ៨)
- ក្របខណ្ឌទស្សទានសម្រាប់របាយការណ៍ហិរញ្ញវត្ថុ
- កំណែទម្រង់លើអត្រាការប្រាក់ (បានកែប្រែទៅជា CIFRS ៩. CAS ៣៩ និង CIFRS ៧)

គណៈគ្រប់គ្រងបានធ្វើការវាយតម្លៃថាការអនុម័តទៅលើស្តង់ដារគណនេយ្យទាំងនេះមិនមានផលប៉ះពាល់ជាសារវន្តទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន។

### ៣.២ ស្តង់ដារ វិសោធនកម្ម និងការបកស្រាយទៅនឹងស្តង់ដារមានស្រាប់ដែលមិនទាន់មានប្រសិទ្ធភាព និងមិនទាន់ត្រូវបានអនុវត្តដោយសម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន

នាកាលបរិច្ឆេទនៃការចេញផ្សាយនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ស្តង់ដារគណនីថ្មី និងស្តង់ដារគណនីដែលបានកែប្រែដែលបានចេញផ្សាយរួចរាល់ ប៉ុន្តែមិនទាន់មានប្រសិទ្ធិភាព និងមិនទាន់បានអនុវត្តជាមុនដោយសម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនមានដូចខាងក្រោម៖

- កិច្ចសន្យាធានារ៉ាប់រង CIFRS ១៧
- កំណែទម្រង់លើអត្រាការប្រាក់ — ដំណាក់កាល ២ (បានកែប្រែទៅជា CIFRS ៩ CAS ៣៩. CIFRS ៧ និង CIFRS ១៦)
- ឯកសារយោងចំពោះក្របខណ្ឌទស្សនទាន (បានកែប្រែទៅជា CIFRS ៣)
- ការធ្វើចំណាត់ថ្នាក់ឡើងវិញនៃបំណុលជាបំណុលរយៈពេលខ្លី ឬបំណុលរយៈពេលវែង — ពន្យាពេលចូលជាធរមាន (បានកែប្រែទៅជា CAS ១)
- ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ — ចំណូលដែលទទួលបានមុនពេលការប្រើប្រាស់ដែលបានគ្រោងទុក (បានកែប្រែទៅជា CAS ១៦)

## ៣. ស្តង់ដារថ្មី ឬវិសោធនកម្ម និងការបកស្រាយ (ត)

### ៣.២ ស្តង់ដារ វិសោធនកម្ម និងការបកស្រាយទៅនឹងស្តង់ដារមានស្រាប់ដែលមិនទាន់មានប្រសិទ្ធភាព និងមិនទាន់ត្រូវបានអនុវត្តដោយសម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន (ត)

- កិច្ចសន្យាស្មុគស្មាញ — ថ្លៃដើម្បីបំពេញកិច្ចសន្យា (បានកែប្រែទៅជា CAS ៣៧)
- ការកែតម្រូវប្រចាំឆ្នាំទៅលើស្តង់ដារ CIFRS ២០១៨–២០២០
- ការបង្ហាញពីគោលនយោបាយគណនេយ្យ (បានកែប្រែទៅជា CAS ១ និង របាយការណអនុវត្តលើ CIFRS ២)
- និយមន័យរបស់គណនេយ្យប៉ាន់ស្មាន (បានកែប្រែទៅជា CAS ៨)
- សម្បទានជួលដែលទាក់ទងនឹងជម្ងឺកូវីដ ១៩ (បានកែប្រែទៅជា CIFRS១៦)

គណៈគ្រប់គ្រងមិនរំពឹងទុកថា ការអនុវត្តស្តង់ដារគណនេយ្យដែលបានកត់ត្រាខាងលើនឹងមានផលប៉ះពាល់ជាសារវន្តទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុននាកាលបរិច្ឆេទពេលអនាគត។

## ៤ គោលនយោបាយគណនេយ្យសំខាន់ៗ

### ៤.១ មូលដ្ឋាននៃការរៀបចំ

របាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន ត្រូវបានបង្ហាញជាដុល្លារអាមេរិក("USD") ត្រូវបានរៀបចំក្រោមថ្លៃដើមជាប្រវត្តិសាស្រ្ត និងត្រូវបានរៀបចំដោយអនុលោមតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("CIFRSs")។

### ៤.២ រូបិយប័ណ្ណគោល និងរូបិយប័ណ្ណសម្រាប់បង្ហាញ

រូបិយប័ណ្ណជាតិនៃព្រះរាជាណាចក្រកម្ពុជា គឺខ្មែររៀល ("KHR")។ ក៏ប៉ុន្តែដោយសារសម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនមានប្រតិបត្តិការអាជីវកម្ម និងរក្សាកំណត់ត្រាគណនេយ្យបឋមជាដុល្លារអាមេរិក ("USD") ក្រុមប្រឹក្សាភិបាលបានកំណត់ USD ជារូបិយប័ណ្ណគោលរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនសម្រាប់គោលបំណងនៃការវាស់វែង និងបង្ហាញព្រោះវាបានឆ្លុះបញ្ចាំងពីខ្លឹមសារសេដ្ឋកិច្ចនៃព្រឹត្តិការណ៍ និងកាលៈទេសៈរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន។

ប្រតិបត្តិការជារូបិយប័ណ្ណបរទេស ក្រៅពីដុល្លារអាមេរិកត្រូវបានប្តូរទៅជាដុល្លារអាមេរិក ដោយប្រើប្រាស់អត្រាប្តូរប្រាក់ទូទៅនៅកាលបរិច្ឆេទនៃប្រតិបត្តិការនោះ។ ទ្រព្យសកម្ម និងបំណុលដែលជារូបិយប័ណ្ណផ្សេង ក្រៅពីដុល្លារអាមេរិក នៅកាលបរិច្ឆេទរបាយការណ៍ត្រូវបានប្តូរទៅជាដុល្លារអាមេរិក ដោយប្រើប្រាស់អត្រាប្តូរប្រាក់ទូទៅនាកាលបរិច្ឆេទនៃប្រតិបត្តិការ។ ភាពលម្អៀងពីការប្តូររូបិយប័ណ្ណបរទេសត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ចំណូលពេញលេញ។

ការប្តូរចំនួនទឹកប្រាក់ពីប្រាក់ដុល្លារអាមេរិក USD ទៅជាខ្មែររៀល KHR ដូចដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានដាក់បញ្ចូលទាំងស្រុងដោយអនុលោមតាមច្បាប់ស្តីពីគណនេយ្យ និងសវនកម្មនៃកម្ពុជា (ខែមេសា ឆ្នាំ២០១៦) និងត្រូវបានធ្វើឡើងដោយប្រើប្រាស់អត្រាប្តូរប្រាក់ជាផ្លូវការ ដែលបានបង្ហាញជាប្រាក់រៀលដោយយោងទៅតាមអត្រាប្តូរប្រាក់ក្នុង ១ដុល្លារអាមេរិកដែលបានប្រកាសដោយធនាគារជាតិនៃកម្ពុជា (អគ្គនាយកដ្ឋានពន្ធដារមុនថ្ងៃទី១ ខែមករា ឆ្នាំ២០២០)៖

| | **ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១** | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ |
|---|---|---|
| អត្រាប្តូរប្រាក់ជាមធ្យម* | **៤.០៧១** | ៤.០៨៧ |
| អត្រាប្តូរប្រាក់ចុងគ្រា | **៤.០៧៥** | ៤.០៩៣ |

*អត្រាប្តូរប្រាក់ជាមធ្យម គឺត្រូវបានគណនាដោយប្រើអត្រាប្តូរប្រាក់ប្រចាំថ្ងៃក្នុងអំឡុងកាលបរិច្ឆេទ

ការប្តូររូបិយប័ណ្ណទាំងនេះ គឺមិនត្រូវបានធ្វើសវនកម្មឡើយ និងមិនត្រូវបានបកស្រាយថាជាតំណាងនៃប្រាក់ដុល្លារអាមេរិក ដែលអាចនឹងត្រូវបាន ឬអាចប្តូរទៅជាប្រាក់រៀលនៅថ្ងៃអនាគតតាមអត្រាដែលបានបង្ហាញនេះ ឬអត្រាប្តូរប្រាក់ផ្សេងទៀតទេ។ ចំនួនទឹកប្រាក់ជា USD និង KHR គឺត្រូវបានបង្ហាញក្នុងចំនួនទឹកប្រាក់ខ្ទង់ពាន់ដុល្លារអាមេរិក និងលានរៀលដែលនៅជិតបំផុត លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ។

## ៤ គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ៤.៣ មូលដ្ឋាននៃការដាក់បញ្ចូលគ្នា

របាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធក្រុមហ៊ុន បានរួមបញ្ចូលទាំងរបាយការណ៍របស់ក្រុមហ៊ុនមេ និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់វា។ ក្រុមហ៊ុនទទួលបាន និងធ្វើការត្រួតពិនិត្យតាមរយៈការកាន់កាប់ច្រើនជាងពាក់កណ្តាលនៃសិទ្ធិបោះឆ្នោតក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ។

ការចំណេញ និងការខាតបង់មិនសមហេតុផលលើប្រតិបត្តិការរវាងសម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនត្រូវបានលុបចោល។ នៅពេលការខាតបង់មិនសមហេតុផល លើការលក់ទ្រព្យសម្បត្តិនៅក្នុងសម្ព័ន្ធក្រុមហ៊ុន ត្រូវបានលុបចោលសម្រាប់ការដាក់បញ្ចូលគ្នា ទ្រព្យសម្បត្តិមូលដ្ឋានក៏ត្រូវបានធ្វើការសាកល្បងសម្រាប់ឱនភាព។ ចំនួនទឹកប្រាក់ដែលបានរាយការណ៍នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធត្រូវបានកែតម្រូវនៅពេលចាំបាច់ ដើម្បីធានាឱ្យមានភាពស៊ីសង្វាក់ជាមួយគោលនយោបាយគណនេយ្យដែលបានអនុវត្តដោយសម្ព័ន្ធក្រុមហ៊ុន។

ប្រាក់ចំណេញ ឬការខាតបង់របស់ក្រុមហ៊ុនបុត្រសម្ព័ន្ធដែលបានទិញ ឬបោះចោលក្នុងអំឡុងពេលនេះត្រូវបានទទួលស្គាល់ពីកាលបរិច្ឆេទដែលមានសុពលភាពនៃការទិញ ឬរហូតដល់កាលបរិច្ឆេទដែលមានសុពលភាពនៃការលុបចោលតាមដែលអាចអនុវត្តបាន។

### ៤.៤ ការទទួលស្គាល់ចំណូល

ប្រាក់ចំណូលត្រូវបានទទួលស្គាល់នៅពេលដែល កាតព្វកិច្ចក្នុងកិច្ចសន្យាជាមួយអតិថិជនមានការពេញចិត្តពោលគឺនៅពេលដែល "សិទ្ធិក្នុងការគ្រប់គ្រង" ទំនិញ ឬសេវាកម្ម ដែលផ្អែកលើកាតព្វកិច្ចជាក់លាក់ដែលត្រូវបានផ្ទេរទៅឱ្យអតិថិជន។

កាតព្វកិច្ច គឺជាការសន្យាក្នុងការផ្ទេរទំនិញឬសេវាកម្មផ្សេងគ្នា (ទំនិញឬ សេវាកម្មដែលមានលក្ខណៈដូចគ្នានិង មានលំនាំនៃការផ្ទេរ) ទៅអតិថិជនដែលត្រូវបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងកិច្ចសន្យា និងបញ្ជាក់នៅក្នុងការអនុវត្តអាជីវកម្មតាមទំលាប់របស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន។

ប្រាក់ចំណូលត្រូវបានកំណត់ តាមការពិចារណាដែលសម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនជឿជាក់ថាមានសិទ្ធិក្នុងការផ្ទេរទំនិញ ឬសេវាកម្មដែលបានសន្យាជូនអតិថិជនដោយមិនរាប់បញ្ចូលចំនួនដែលប្រមូលបានពីតតិយជន ដូចជាពន្ធអាករលើផលចេញ ឬពន្ធលើទំនិញ និងសេវាកម្ម។

ប្រសិនបើការពិនិត្យពិច័យមានភាពខុសគ្នាដោយសារតែអប្បហារ ការបង្វិលសងប្រាក់វិញ បំណុល ប្រាក់លើកទឹកចិត្ត ប្រាក់ពិន័យឬភាពស្រដៀងគ្នាផ្សេងទៀតសម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនប៉ាន់ស្មានចំនួនទឹកប្រាក់ត្រូវទទួលដែលមានសិទ្ធិទទួលបាន ដោយផ្អែកលើតម្លៃដែលបានរំពឹងទុក ឬលទ្ធផលដែលសមស្របបំផុត។ ប្រសិនបើកិច្ចសន្យាជាមួយអតិថិជនលើសពីមួយអនុវត្តកាតព្វកិច្ច ចំនួនទឹកប្រាក់ត្រូវបានបែងចែកទៅតាមកាតព្វកិច្ចនីមួយៗ ដោយផ្អែកលើតម្លៃលក់ទំនិញ ឬសេវាកម្មដែលបានសន្យានៅក្នុងកិច្ចសន្យា។

ប្រាក់ចំណូលត្រូវបានគេទទួលស្គាល់ក្នុងកម្រិតមួយដែលវាអាចទៅរួចដែលថាការបញ្ច្រាសនូវបរិមាណប្រាក់ចំណូលដែលបានទទួលនឹងមិនកើតឡើងនៅពេលដែលការជាប់ទាក់ទងមិនច្បាស់លាស់ជាមួយនឹងការគិតពិចារណាត្រូវបានដោះស្រាយជាបន្តបន្ទាប់។

ការត្រួតពិនិត្យទំនិញឬសេវាកម្មដែលបានសន្យាអាចត្រូវបានផ្ទេរតាមពេលវេលាឬនៅពេលវេលា។ ប្រាក់ចំណូលសម្រាប់កាតព្វកិច្ចអនុវត្តដែលមិនតាមពេលវេលាត្រូវបានទទួលស្គាល់នៅពេលវេលាដែលអតិថិជនទទួលបានការត្រួតពិនិត្យទំនិញ ឬសេវាកម្មដែលបានសន្យា។

ការត្រួតពិនិត្យទំនិញ ឬសេវាកម្មត្រូវបានផ្ទេរតាមពេលវេលាហើយប្រាក់ចំណូលត្រូវបានទទួលស្គាល់តាមពេលវេលាប្រសិនបើ៖

- អតិថិជនក្នុងពេល ទទួលនិងប្រើប្រាស់អត្ថប្រយោជន៍ដែលបានផ្តល់ដោយសម្ព័ន្ធក្រុមហ៊ុននិងការអនុវត្តរបស់ក្រុមហ៊ុននៅពេលដែលសម្ព័ន្ធក្រុមហ៊ុននិងក្រុមហ៊ុនអនុវត្ត។

## ៤ គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ៤.៤ ការទទួលស្គាល់ចំណូល (ត)

- កាតព្វកិច្ចរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនឬបង្កើនទ្រព្យដែលអតិថិជនកាន់កាប់ជាទ្រព្យត្រូវបានបង្កើតឬកែលម្អ ឬ
- ការអនុវត្តរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនមិនបង្កើតទ្រព្យជាមួយនឹងការប្រើប្រាស់ជំនួសទេហើយសម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនមានសិទ្ធិបង្ខំក្នុងការទូទាត់សម្រាប់ប្រតិបត្តិការដែលបានបញ្ចប់រហូតមកដល់បច្ចុប្បន្ន។

ប្រាក់ចំណូលសម្រាប់កាតព្វកិច្ចអនុវត្តដែលមិនតម្រូវតាមពេលវេលា នឹងត្រូវបានទទួលស្គាល់នៅការិយបរិច្ឆេទណាមួយ។

សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនទទួលស្គាល់ប្រាក់ចំណូលពីការសាងសង់នាការិយបរិច្ឆេទកន្លងមក ប្រសិនបើវាបង្កើតទ្រព្យសម្បត្តិដោយគ្មានការប្រើប្រាស់ជំនួសហើយសម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនមានសិទ្ធិបង្ខំក្នុងការទូទាត់សងរហូតដលប្រតិបត្តិការសាងសងបានបញ្ចប់។ ប្រាក់ចំណូលត្រូវបានទទួលស្គាល់ក្នុងរយៈពេលកិច្ចសន្យាដោយយោងទៅលើវឌ្ឍនភាពឆ្ពោះទៅរកការពេញចិត្តពេញលេញនៃអនុវត្តកាតព្វកិច្ច។

ដំណើរការពេញលេញនៃកាតព្វកិច្ចការអនុវត្តត្រូវបានវាស់វែងផ្អែកលើការខិតខំប្រឹងប្រែងរបស់ក្រុមហ៊ុននិងការបញ្ចូលរបស់ក្រុមហ៊ុន និងភាពពេញចិត្តនៃកាតព្វកិច្ចនៃការអនុវត្ត (ឧទាហរណ៍ដោយយោងទៅការស្ទង់មតិនៃការងារដែលបានអនុវត្តឧទាហរណ៍ដំណាក់កាលនៃការបញ្ចប់) ។

ប្រាក់ចំណូលពីកិច្ចសន្យាសាងសង់និងប្រតិបត្តិការត្រូវបានទទួលស្គាល់លើភាគរយនៃវិធីសាស្ត្របញ្ចប់ដែលត្រូវបានវាយតម្លៃតាមរយៈការបូកបញ្ចូលគ្នានៃការវាយតម្លៃអ្នកជំនាញនិងតាមរយៈការពិចារណាលើថ្លៃដើមកិច្ចសន្យាដែលបានកើតឡើងបើប្រៀបធៀបទៅនឹងថ្លៃដើមប៉ាន់ស្មានសរុបដែលមិនមានភាពមិនច្បាស់លាស់ទាក់ទងនឹងការទទួលចុងក្រោយ នៃផលទុននិងថ្លៃដើមដែលទាក់ទងអាចត្រូវបានកំណត់សមរម្យ។

នៅពេលដែលលទ្ធផលនៃការអភិវឌ្ឍន៍មិនអាចត្រូវបានប៉ាន់ស្មានសមហេតុផលប្រាក់ចំណូលត្រូវបានទទួលស្គាល់ចំពោះទំហំនៃចំណាយសាងសង់ដែលអាចនឹងទទួលបានមកវិញហើយថ្លៃដើមនៃការសាងសង់ត្រូវបានទទួលស្គាល់ថាជាការចំណាយមួយក្នុងរយៈពេលដែលវាកើតឡើង។

នៅពេលដែលការប៉ាន់ស្មានថាការចំណាយសរុបនឹងលើសពីប្រាក់ចំណូលសរុប ការបាត់បង់ដែលអាចមើលឃើញជាមុនត្រូវបានគេទទួលស្គាល់ភ្លាមៗចំពោះប្រាក់ចំណេញឬការបាត់បង់ដោយមិនគិតពីថាតើការសាងសង់បានចាប់ផ្តើមឬអត់ ឬដំណាក់កាលនៃការបញ្ចប់សកម្មភាពសំណង់ឬចំនួនប្រាក់ចំណេញដែលរំពឹងទុក។ កើតឡើងលើកិច្ចសន្យាដែលមិនទាក់ទងផ្សេងទៀត។

ប្រាក់ចំណូលលើសដែលត្រូវបានទទួលស្គាល់នៅក្នុងប្រាក់ចំណេញឬខាតលើវិក័យប័ត្រដែលធ្វើជូនអតិថិជនកិច្ចសន្យាត្រូវបានទទួលស្គាល់ជាទ្រព្យសកម្មកិច្ចសន្យា។

វិក័យបត្រ ពីកិច្ចសន្យាដល់អតិថិជនលើប្រាក់ចំណេញដែលត្រូវបានទទួលស្គាល់ក្នុងប្រាក់ចំណេញឬខាតត្រូវបានទទួលស្គាល់ថាជាបំណុលកិច្ចសន្យា។

ប្រាក់ចំណូលផ្សេងទៀតដែលសម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនទទួលបានគឺតំណាងឱ្យប្រាក់ចំណូលការប្រាក់ដែលត្រូវបានទទួលស្គាល់តាមសមាមាត្រពេលវេលា។

## ៤ គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ៤.៤ ការទទួលស្គាល់ចំណូល (ត)

***កិច្ចសន្យាសាងសង់ និងការផ្តល់សេវាកម្ម***

ចំណូលដែលបានមកពីការផ្តល់សេវាវិស្វកម្ម ត្រូវបានទទួលស្គាល់នៅក្នុងគណនីចំណេញ ឬខាតនៅពេលដែលសេវាកម្មត្រូវបានបំពេញ។ ចំណូលដែលបានមកពីការលក់សម្ភារៈ ត្រូវបានទទួលស្គាល់នៅពេលដែលសម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន បានធ្វើការផ្ទេរទៅឱ្យអ្នកទិញនូវរាល់ហានិភ័យសំខាន់ៗ ដែលជាទូទៅនៅពេលដែលអតិថិជនបានទទួលយក ការដឹកជញ្ជូនសម្ភារៈដោយគ្មានជំលោះ។

ដើម្បីកំណត់ថាតើ ដើម្បីទទួលស្គាល់ប្រាក់ចំណូល សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនអនុវត្តតាមនីតិវិធី ៥ ជំហានដូចខាងក្រោម៖

១. កំណត់អត្តសញ្ញាណកិច្ចសន្យាជាមួយអតិថិជន
២. កំណត់ការអនុវត្តកាតព្វកិច្ច
៣. កំណត់តម្លៃប្រតិបត្តិការ
៤. ការបែងចែកតម្លៃប្រតិបត្តិការទៅនឹងការអនុវត្តកាតព្វកិច្ច
៥. ទទួលស្គាល់ចំណូលនៅពេល /កាតព្វកិច្ចបំពេញការងារត្រូវបានសម្រេច

***ប្រាក់ចំណូលគួរឱ្យកត់សម្គាល់លើការមិនបញ្ចុះតម្លៃ***

ប្រាក់ចំណេញគួរឱ្យកត់សម្គាល់លើការបង្រួបបង្រួមនៃការបញ្ចុះតម្លៃដែលទទួលបានពីសំណង់ត្រូវបានបង្គរតាមសមាមាត្រពេលវេលាដោយគិតគូរលើចំណូលដែលទទួលបាននិងអត្រាបញ្ចុះតម្លៃដែលមានប្រសិទ្ធិភាព។

ចំនួននេះបានមកពីភាពខុសគ្នានៃតម្លៃបច្ចុប្បន្ននៃប្រាក់ចំណូលនាពេលអនាគត និងប្រាក់ចំណូលដែលបានទទួលស្គាល់ក្នុងរយៈពេលសាងសង់។

### ៤.៥ ចំណាយប្រតិបត្តិការ

ចំណាយប្រតិបត្តិការ ត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ចំណូលពេញលេញ ក្នុងអំឡុងកាលបរិច្ឆេទដែលចំណាយបានកើតឡើង។

### ៤.៦ ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ

គ្រប់សមាសធាតុគណនីទាំងអស់នៃទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារត្រូវបានកំណត់ដំបូងតាមថ្លៃដើមនៃការទិញចូល ឬថ្លៃដើមក្នុងការផលិត រួមបញ្ចូលទាំងថ្លៃដើមទាំងឡាយដែលទាក់ទងដោយផ្ទាល់ក្នុងការនាំយកទ្រព្យសកម្មទៅកាន់ទីតាំង និងលក្ខខណ្ឌដែលសមស្របក្នុងប្រតិបត្តិការដែលបានគ្រោងទុកដោយគណៈគ្រប់គ្រង។ ថ្លៃដើមកើតឡើងជាបន្តបន្ទាប់ត្រូវបានបញ្ចូលក្នុងតម្លៃយោងរបស់ទ្រព្យសកម្ម ឬទទួលស្គាល់ជាទ្រព្យសកម្មដាច់ដោយឡែកតែនៅពេលណាដែលផលប្រយោជន៍សេដ្ឋកិច្ចដែលទាក់ទងនឹងសម្ភារៈនោះនឹងហូរចូលមកសម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន ហើយថ្លៃទាំងនោះអាចត្រូវបានវាស់វែងដោយជឿជាក់បាន។ រាល់ចំណាយលើការជួសជុល និងថែទាំត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ចំណេញ ឬខាតក្នុងអំឡុងការិយបរិច្ឆេទហិរញ្ញវត្ថុដែលវាបានកើតឡើង។

បន្ទាប់ពីការទទួលស្គាល់ដំបូង ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ ត្រូវបានកត់ត្រាតាមថ្លៃដើមដករំលស់បង្គរ និងរាល់ការខាតបង់លើឱនភាពនៃតម្លៃ។

***រំលស់***

រំលស់ត្រូវបានគណនា ដោយការប្រើប្រាស់វិធីរំលស់ថេរទៅតាមអត្រារំលស់ប្រចាំឆ្នាំដូចខាងក្រោម៖

| | **អត្រារំលស់** |
|---|---|
| បរិក្ខារ | ៤% - ១០% |
| ម៉ូតូ យានយន្ត | ២០% |
| កុំព្យូទ័រ | ៣០% |
| គ្រឿងសង្ហារឹម និងគ្រឿងបរិក្ខារ | ២០% |

## ៤ គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ៤.៦ ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ (ត)

តម្លៃសំណល់ អាយុកាលប្រើប្រាស់ និងវិធីការកាត់រំលោះត្រូវបានពិនិត្យឡើងវិញនៅការិយបរិច្ឆេទហិរញ្ញវត្ថុនីមួយៗ ដើម្បីធានាថាចំនួនទឹកប្រាក់វិធីសាស្រ្ត និងរយៈពេលនៃការរំលោះ គឺស្របទៅនឹងការប៉ាន់ស្មានពីមុន និងគំរូនៃការប្រើប្រាស់ផលប្រយោជន៍ផ្នែកសេដ្ឋកិច្ចនាពេលអនាគតដែលបានបញ្ចូលនៅក្នុងទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ។

ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារនឹងត្រូវឈប់កត់ត្រាក្នុងបញ្ជីគណនេយ្យនៅពេលដែលទ្រព្យសកម្មនោះត្រូវបានលក់ចេញ ឬក៏រំពឹងថានឹងមិនមានអត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគត គឺត្រូវបានរំពឹងទុកពីការប្រើប្រាស់ ឬការលក់ចេញ។ រាល់ចំណេញ ឬខាតដែលកើតឡើងពីការឈប់កត់ត្រាទ្រព្យសកម្ម គឺត្រូវបានដាក់បញ្ចូលទៅក្នុងគណនីចំណេញ ឬខាតនៅក្នុងកាលបរិច្ឆេទដែលទ្រព្យសកម្មត្រូវបានលក់ចេញ។ ចំណេញ និងខាតលើការលក់ចេញ ត្រូវបានកំណត់តាមរយៈការប្រៀបធៀបប្រាក់ចំណេញជាមួយចំនួនទឹកប្រាក់យោងនៃទ្រព្យសកម្មដែលបានលក់ចេញ។ ចំណេញ និងខាតគឺត្រូវបានដាក់បញ្ចូលទៅក្នុងគណនីចំណេញ ឬខាត។

### ៤.៧ ការធ្វើតេស្តឱនភាពតម្លៃនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

ដើម្បីធ្វើការវាយតម្លៃឱនភាព ទ្រព្យសកម្មត្រូវបានចាត់ជាក្រុមក្នុងកម្រិតទាបបំផុត ដែលមានលំហូរសាច់ប្រាក់ឯករាជ្យមួយផ្នែកធំ (ឯកតាបង្កើតសាច់ប្រាក់)។ ជាលទ្ធផលទ្រព្យសកម្មមួយចំនួនត្រូវបានវាយតម្លៃឱនភាពដាច់ដោយឡែក និងមួយចំនួនទៀតវាយតម្លៃជាកម្រិតឯកត្តាបង្កើតសាច់ប្រាក់។ ទ្រព្យសកម្មទាំងអស់ ជាកម្មវត្ថុក្នុងការធ្វើរលស់ ឬឯកតាបង្កើតសាច់ប្រាក់ គឺត្រូវបានធ្វើតេស្តលើឱនភាពនៃតម្លៃនៅពេលណាដែលមានព្រឹត្តិការណ៍ ឬការផ្លាស់ប្តូរកាលៈទេសៈដែលបង្ហាញថាចំនួនទឹកប្រាក់យោងប្រហែលជាមិនអាចប្រមូលមកវិញបាន។

ការខាតបង់លើឱនភាពតម្លៃ ត្រូវបានទទួលស្គាល់លើចំនួនដែលលើសរវាងទ្រព្យសកម្ម ឬតម្លៃយោងនៃឯកតាបង្កើតសាច់ប្រាក់ និងចំនួនដែលអាចប្រមូលមកវិញបាន ដែលជាតម្លៃខ្ពស់ជាងនៃតម្លៃសមស្របដកថ្លៃដើមក្នុងការលក់ និងតម្លៃក្នុងការប្រើប្រាស់។ ដើម្បីកំណត់តម្លៃប្រើប្រាស់ គណៈគ្រប់គ្រងប៉ាន់ស្មានលំហូរសាច់ប្រាក់នាពេលអនាគតដែលបានរំពឹងទុកពីឯកតាបង្កើតសាច់ប្រាក់នីមួយៗ ដោយកំណត់អត្រាការប្រាក់ដ៏សមរម្យដើម្បីគណនាតម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់ទាំងនោះ។ ទិន្នន័យប្រើប្រាស់ដើម្បីធ្វើការវាយតម្លៃឱនភាពមានការទាក់ទងដោយផ្ទាល់ទៅនឹងគម្រោងថវិការរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន ដែលបានអនុម័ត និងធ្វើនិយ័តកម្មប្រសិនបើចាំបាច់ដើម្បីដកផលប៉ះពាល់ពីការរៀបចំ និងធ្វើឱ្យប្រសើរឡើងវិញនៃទ្រព្យសកម្មនោះនាពេលអនាគត។ អត្រាអប្បហារ ត្រូវបានកំណត់ឡើងសម្រាប់ក្រុមទ្រព្យសកម្មនីមួយៗ ដើម្បីឆ្លុះបញ្ចាំងពីប្រវត្តិសង្ខេបនៃហានិភ័យរបស់ទ្រព្យសកម្មនីមួយៗដូចដែលបានវាយតម្លៃដោយគណៈគ្រប់គ្រង។

ការខាតបង់លើឱនភាពតម្លៃសម្រាប់ឯកតាបង្កើតសាច់ប្រាក់ដំបូង ត្រូវដកចេញពីតម្លៃយោងនៃទ្រព្យសកម្មអរូបិយនានានៅក្នុងឯកតាបង្កើតសាច់ប្រាក់នោះ។ ការខាតបង់ឱនភាពដែលនៅសល់ ត្រូវបានបែងចែកតាមសមាមាត្រនៃតម្លៃយោងនៃទ្រព្យសកម្មផ្សេងៗនៅក្នុងឯកតាបង្កើតសាច់ប្រាក់នោះ។ ទ្រព្យសកម្មទាំងអស់ត្រូវបានវាយតម្លៃឡើងវិញជាប្រចាំដើម្បីចង្អុលបង្ហាញថា ការខាតបង់លើឱនភាពតម្លៃដែលបានទទួលស្គាល់កន្លងមកប្រហែលមិនមានការកើតឡើងបន្តទៀត។ ឱនភាពតម្លៃប្រហែលត្រូវបានលុបចោល ប្រសិនបើតម្លៃឯកភាពបង្កើតសាច់ប្រាក់លើសពីតម្លៃយោងរបស់វា។

### ៤.៨. ឧបករណ៍ហិរញ្ញវត្ថុ

**ការទទួលស្គាល់ និងការឈប់ទទួលស្គាល់**

ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ត្រូវបានទទួលស្គាល់នៅពេលដែលសម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនក្លាយជាភាគីនៃកិច្ចសន្យាឧបករណ៍ហិរញ្ញវត្ថុ។

ទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានឈប់ទទួលស្គាល់ នៅពេលដែលសិទ្ធិទទួលបានសាច់ប្រាក់តាមកិច្ចសន្យានៃទ្រព្យសកម្មនោះផុតកំណត់ ឬនៅពេលហានិភ័យ និងតម្លៃតបស្នងពីកម្មសិទ្ធិភាពជាសារវន្តនៃទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានផ្ទេរ។ បំណុលហិរញ្ញវត្ថុនឹងឈប់ទទួលស្គាល់ នៅពេលដែលកិច្ចសន្យាបានបញ្ចប់ លុបចោល ឬផុតកាលកំណត់។

# ៤ គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

## ៤.៨. ឧបករណ៍ហិរញ្ញវត្ថុ (ត)

**ចំណាត់ថ្នាក់ និងការវាស់វែងជាបន្តបន្ទាប់ទ្រព្យសកម្មហិរញ្ញវត្ថុ**

លើកលែងតែអ្នកទទួលពាណិជ្ជកម្មដែលមិនមានសមាសភាពហិរញ្ញប្បទានដ៏សំខាន់ និងត្រូវវាស់វែងតម្លៃ ប្រតិបត្តិការដោយអនុលោមទៅតាម CIFRS១៥ ទ្រព្យសកម្មហិរញ្ញវត្ថុទាំងអស់ត្រូវបានវាស់វែងដំបូងតាមតម្លៃសមស្របដែលត្រូវបានកែតម្រូវសម្រាប់ថ្លៃប្រតិបត្តិការ ប្រសិនបើមាន។

ទ្រព្យសកម្មហិរញ្ញវត្ថុ ក្រៅពីការកំណត់និងមានប្រសិទ្ធភាពជាឧបករណ៍ការពារហានិភ័យត្រូវបានចាត់ថ្នាក់ជាប្រភេទដូចខាងក្រោម៖

- រំលស់ថ្លៃដើម
- តម្លៃទីផ្សារសមស្របតាមរយៈប្រាក់ចំណេញឬខាតបង់ (FVTPL)
- តម្លៃទីផ្សារសមស្របតាមរយៈចំណូលពេញលេញផ្សេងទៀត (FVOCI)

ការបែងចែកត្រូវបានកំណត់ដូចខាងក្រោម៖

- គំរូអាជីវកម្មរបស់ សម្ព័ន្ធក្រុមហ៊ុននិងក្រុមហ៊ុនសម្រាប់គ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ និង
- លក្ខណៈលំហូរសាច់ប្រាក់តាមកិច្ចសន្យារបស់ទ្រព្យសកម្មហិរញ្ញវត្ថុ។

ប្រាក់ចំណូល និងចំណាយទាំងអស់ដែលទាក់ទងនឹងទ្រព្យសកម្មហិរញ្ញវត្ថុដែលត្រូវបានគេទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាត ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ចំណេញ ឬខាត និងចំណូលពេលលេញផ្សេងៗ។

នាកាលបរិច្ឆេទនៃរបាយការណ៍ សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន យោងតែលើទ្រព្យសកម្មហិរញ្ញវត្ថុដែលត្រូវបានវាស់វែងបាតាមតម្លៃរំលស់លើរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុរបស់ខ្លួន។

**ទ្រព្យសកម្មហិរញ្ញវត្ថុ - ការវាស់វែងជាបន្តបន្ទាប់**

*ទ្រព្យសកម្មហិរញ្ញវត្ថុដោយរំលស់ថ្លៃដើម*

ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានវាស់វែងតាមតម្លៃរំលស់ប្រសិនបើទ្រព្យសកម្មមានលក្ខខ័ណ្ឌដូចខាងក្រោម (និងមិនត្រូវបានកំណត់ជា FVTPL)៖

- វាត្រូវបានធ្វើឡើងតាមគំរូអាជីវកម្មដែលមានគោលបំណងដើម្បីកាន់កាប់ទ្រព្យសម្បត្តិហិរញ្ញវត្ថុនិងប្រមូលលំហូរសាច់ប្រាក់តាមកិច្ចសន្យា និង
- លក្ខខ័ណ្ឌកិច្ចសន្យានៃទ្រព្យសកម្មហិរញ្ញវត្ថុផ្តល់នូវលំហូរសាច់ប្រាក់ជាការទូទាត់ប្រាក់ដើមនិងការប្រាក់ទៅលើចំនួនប្រាក់ដើមដែលនៅសល់

បន្ទាប់ពីការទទួលស្គាល់ដំបូងទ្រព្យសកម្មហិរញ្ញវត្ថុទាំងនេះត្រូវបានវាស់វែងតាមរយៈទ្រព្យសកម្មហិរញ្ញវត្ថុចំណាយរំលស់តាមរយៈវិធីសាស្ត្រអត្រាការប្រាក់ប្រសិទ្ធភាព។ ការធ្វើអប្បហារនិងមិនធ្វើត្រូវធ្វើឡើយប្រសិនបើផលប៉ះពាល់វាមិនមានលក្ខណៈជាសារវន្ត។ គណនីពាណិជ្ជកម្ម និងគណនីត្រូវទទួលផ្សេងទៀតរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន និងទឹកប្រាក់ដែលភាគីពាក់ព័ន្ធជំពាក់ និងសាច់ប្រាក់សមមូលត្រូវបានចាត់ថ្នាក់ជាឧបករណ៍ហិរញ្ញវត្ថុ។

***ការឈប់ទទួលស្គាល់***

ទ្រព្យសកម្មហិរញ្ញវត្ថុ ឬផ្នែកណាមួយរបស់វាត្រូវបានឈប់កត់ត្រានៅពេលដែលសិទ្ធិក្នុងកិច្ចសន្យាក្នុងការទទួលលំហូរទឹកប្រាក់ពីទ្រព្យសកម្មហិរញ្ញវត្ថុ ផុតកំណត់ ឬការផ្ទេរសិទ្ធិទទួលលំហូរទឹកប្រាក់តាមកិច្ចសន្យាក្នុងប្រតិបត្តិការ ដែលហានិភ័យទាំងអស់ និងភាពជាកម្មសិទ្ធិនៃ ទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានផ្ទេរ ឬក្នុងករណីដែលធនាគារមិនផ្ទេរ ឬមិនរក្សាទុកនូវរាល់ហានិភ័យ និងភាពជាកម្មសិទ្ធិហើយ វាមិនរក្សាការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ។

## ៤ គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ៤.៨. ឧបករណ៍ហិរញ្ញវត្ថុ (ត)

ក្នុងការឈប់កត់ត្រាទ្រព្យសកម្មហិរញ្ញវត្ថុ ភាពខុសគ្នារវាងទឹកប្រាក់យោងនិងផលបូកនៃការទទួលស្គាល់ពីមុនក្នុង របាយការណ៍ចំណេញ ឬខាតដែលត្រូវបានទទួលស្គាល់នៅក្នុងមូលធន និងត្រូវទទួលស្គាល់ក្នុងប្រាក់ចំណេញ ឬខាត។

**ទ្រព្យសកម្មហិរញ្ញវត្ថុ-ឱនភាព**

សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនពិចារណាលើព័ត៌មានទូលំទូលាយ នៅពេលវាយតម្លៃហានិភ័យឥណទាន និងការខាតបង់ឥណទានដែលរំពឹងទុករួមទាំងព្រឹត្តិការណ៍ពីមុន បច្ចុប្បន្ន និងការព្យាករណ៍ដ៏សមហេតុផល និងអាចជឿជាក់បាន ដែលប៉ះពាល់ដល់លទ្ធភាពនៃការប្រមូលនៃលំហូរសាច់ប្រាក់នាពេលអនាគតនៃឧបករណ៍ហិរញ្ញវត្ថុទាំងនោះ។

ដើម្បីអនុវត្តវិធីសាស្ត្រនេះ ការវែកញែកត្រូវបានធ្វើឡើងរវាង៖

- ឧបករណ៍ហិរញ្ញវត្ថុ ដែលមិនបានធ្លាក់ចុះយ៉ាងខ្លាំងនូវគុណភាពឥណទានចាប់តាំងពីការទទួលស្គាល់ដំបូង ឬដែលមាន ហានិភ័យឥណទានទាប (ដំណាក់កាលទី១) និង
- ឧបករណ៍ហិរញ្ញវត្ថុដែលបានធ្លាក់ចុះយ៉ាងខ្លាំងនូវគុណភាពឥណទានចាប់តាំងពីការទទួលស្គាល់ដំបូង និងពុំមានហានិភ័យឥណទានទាប (ដំណាក់កាលទី២)

ដំណាក់កាលទី៣ គ្របដណ្តប់ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលមានភស្តុតាងជាក់ស្តែងនៃឱនភាពនាកាលបរិច្ឆេទនៃរបាយការណ៍។

ឥណទានខាតបង់ដែលរំពឹងទុកសម្រាប់រយៈពេល១២ខែ ត្រូវបានគេទទួលស្គាល់សម្រាប់ប្រភេទទី១ ដែល "ឥណទានខាតបង់ដែលរំពឹងទុកសម្រាប់មួយអាយុកាល" ត្រូវបានទទួលស្គាល់សម្រាប់ប្រភេទទី២។

ការវាស់វែងលើការខាតបង់ឥណទានដែលរំពឹងទុក ត្រូវបានកំណត់ដោយការប៉ាន់ប្រមាណផលចំណេញសមស្រប នៃការខាតបង់ឥណទានលើវដ្តជីវិតនៃឧបករណ៍ហិរញ្ញវត្ថុដែលរំពឹងទុក។

*<u>គណនីពាណិជ្ជត្រូវទទួលផ្សេងទៀត និងទ្រព្យសកម្មកិច្ចសន្យា</u>*

សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនបានប្រើប្រាស់វិធីសាស្ត្រឱនភាពនៃទ្រព្យសកម្មហិរញ្ញវត្ថុសាមញ្ញ សម្រាប់គណនីពាណិជ្ជកម្ម និងគណនីទទួលផ្សេងទៀត ព្រមទាំងទ្រព្យសកម្មកិច្ចសន្យា និងកំណត់ត្រាសំវិធានធនដែលខាតបង់ ជាការខាតបង់ឥណទានពេញលេញ។ ទាំងនេះគឺជាកង្វះខាតដែលរំពឹងទុកនៅក្នុងលំហូរសាច់ប្រាក់តាមកិច្ចសន្យា ដោយគិតពីសក្តានុពលសម្រាប់ការមិនអនុវត្តកាតព្វកិច្ចនៅវេលាណាមួយ ក្នុងអំឡុងពេលនៃឧបករណ៍ហិរញ្ញវត្ថុ។ ក្នុងការគណនាក្រុមហ៊ុនបានប្រើបទពិសោធន៍ចាស់ៗ សន្ទស្សន៍ខាងក្រៅ និងព័ត៌មានពាក់ព័ន្ធខាងមុខដើម្បីគណនាការខាតបង់ឥណទានដែលបានរំពឹងទុកដោយប្រើវិធីសាស្ត្រកំណត់ខាងក្រៅ។

សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនវាយតម្លៃពីឱនភាពតម្លៃគណនីអតិថិជននិងទ្រព្យសម្បត្តិកិច្ចសន្យាជាសមូហភាពដោយសារអតិថិជនបានស្ថិតក្នុងប្រភេទឥណទានស្រដៀងគ្នា។ ការវិភាគលម្អិតនៃឱនភាពនៃទ្រព្យសកម្មហិរញ្ញវត្ថុទាក់ទង និងCIFRS៩ ត្រូវបានអនុវត្តនៅក្នុងកំណត់សម្គាល់ទី៣១ លើរបាយការណ៍ហិរញ្ញវត្ថុ។

**បំណុលហិរញ្ញវត្ថុ-ការធ្វើចំណាត់ថ្នាក់ និងការវាស់វែង**

បំណុលហិរញ្ញវត្ថុរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនរួមមានគណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងសមតុល្យត្រូវសងទៅក្រុមហ៊ុនមេ និងសមតុល្យត្រូវសងទៅភាគីភាគីពាក់ព័ន្ធ ប្រាក់កម្ចី និងឧបករណ៍ហិរញ្ញវត្ថុនិទស្សន៍។

បំណុលហិរញ្ញវត្ថុត្រូវបានវាស់វែងដំបូងតាមតម្លៃទីផ្សារសមរម្យដែលអាចអនុវត្តបានសម្រាប់តម្លៃប្រតិបត្តិការ លុះត្រាតែសម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនបានកំណត់បំណុលហិរញ្ញវត្ថុក្នុងតម្លៃជាក់ស្តែងតាមការរបាយការណ៍ចំណេញ ឬខាត។

# ៤ គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

## ៤.៨. ឧបករណ៍ហិរញ្ញវត្ថុ (ត)

**បំណុលហិរញ្ញវត្ថុ-ការធ្វើចំណាត់ថ្នាក់ និងការវាស់វែង (ត)**

បំណុលហិរញ្ញវត្ថុត្រូវបានវាស់វែងជាបន្តបន្ទាប់ ក្នុងតម្លៃរំលស់ដោយប្រើវិធីសាស្ត្រការប្រាក់ដែលមានប្រសិទ្ធភាពលើកលែងតែនិទស្សន៍ និងបំណុលហិរញ្ញវត្ថុដែលកំណត់តាមរយៈការចំណេញឬបាត់បង់ ដែលត្រូវបានធ្វើឡើងជាបន្តបន្ទាប់ក្នុងតម្លៃទីផ្សារសមរម្យ ជាមួយនឹងការចំណេញ ឬការខាតបង់ដែលបានទទួលស្គាល់នៅក្នុង របាយការណ៍ចំណូលពេញលេញ (ក្រៅពីឧបករណ៍ហិរញ្ញវត្ថុនិទស្សន៍ដែលត្រូវបានកំណត់និងមានប្រសិទ្ធភាពដូចជាឧបករណ៍ការពារហានិភ័យ)។

ចំណាយការប្រាក់ទាំងអស់ និងការផ្លាស់ប្តូរតម្លៃទីផ្សារសមស្របដែលរាយការណ៍នៅក្នុងរបាយការណ៍ចំណូលពេញលេញត្រូវបានរួមបញ្ចូលនៅក្នុងចំណាយ និងចំណូលហិរញ្ញប្បទាន។

**សកម្មភាពនិទស្សន៍ និងសកម្មភាពការពារហានិភ័យ**

និទស្សន៍ត្រូវបានទទួលស្គាល់ដំបូងដោយតម្លៃសមស្របនៅកាលបរិច្ឆេទដែលកិច្ចសន្យានិស្សន្ទវត្ថុត្រូវបានចូលនិងត្រូវបានវាយតម្លៃឡើងវិញនៅតម្លៃទីផ្សារសមរម្យរបស់ពួកគេនៅចុងបញ្ចប់នៃការិយបរិច្ឆេទនៃរបាយការណ៍នីមួយៗ។

គណនេយ្យសម្រាប់ការផ្លាស់ប្តូរជាបន្តបន្ទាប់នៃតម្លៃទីផ្សារសមរម្យអាស្រ័យលើថាតើនិទស្សន៍ត្រូវបានគេកំណត់ជាឧបករណ៍ការពារហានិភ័យរួមបញ្ចូលលក្ខណៈនៃវត្ថុដែលត្រូវបានគេការពារ។ សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនកំណត់ចំណាំឧបករណ៍ហិរញ្ញវត្ថុជាក់លាក់មួយចំនួនដូចជា៖

i. ធ្វើការការពារហានិភ័យទៅលើទ្រព្យឬបំណុលដែលបានទទួលស្គាល់ឬការសន្យាយ៉ាងច្បាស់លាស់ (ការការពារហានិភ័យតម្លៃសមស្រប)។
ii. ធ្វើការការពារហានិភ័យទៅលើ ហានិភ័យជាក់លាក់មួយដែលពាក់ព័ន្ធជាមួយនឹងទ្រព្យសកម្មឬបំណុលដែលត្រូវបានគេទទួលស្គាល់ ឬប្រតិបត្តិការព្យាករណ៍ដែលមានសក្តានុពលខ្ពស់ (ការការពារហានិភ័យលំហូរសាច់ប្រាក់) ឬ
iii. ធ្វើការការពារហានិភ័យទៅលើ ការវិនិយោគសុទ្ធនៅក្នុងប្រតិបត្តិការបរទេស (ការការពារហានិភ័យមូលនិធិវិនិយោគសុទ្ធ)។

នៅពេលចាប់ផ្តើមធ្វើការការពារហានិភ័យសម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនកត់ត្រាទំនាក់ទំនងសេដ្ឋកិច្ចរវាងឧបករណ៍ការពារហានិភ័យ និងខ្ទង់គណនីដែលមានហានិភ័យរួមទាំងថាតើការផ្លាស់ប្តូរលំហូរសាច់ប្រាក់នៃឧបករណ៍ការពារហានិភ័យត្រូវបានគេរំពឹងថានឹងទូទាត់ការផ្លាស់ប្តូរលំហូរសាច់ប្រាក់នៃខ្ទង់គណនីដែលត្រូវបានការពារ។ សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនកត់ត្រាគោលបំណង និងយុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យរបស់ខ្លួនសម្រាប់អនុវត្តប្រតិបត្តិការការពារហានិភ័យរបស់ខ្លួន។

តម្លៃទីផ្សារសមរម្យនៃឧបករណ៍និទស្សន៍ផ្សេងៗដែលត្រូវបានប្រើសម្រាប់គោលបំណងការពារហានិភ័យត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់២៨ ចំពោះរបាយការណ៍ហិរញ្ញវត្ថុ។ បម្រែបម្រួលលើទុនបម្រុងដែលបានធ្វើការការពារក្នុងចំណូលដែលមានលក្ខណៈទូលំទូលាយផ្សេងទៀតត្រូវបានបង្ហាញនៅក្នុង របាយការណ៍បម្រែបម្រួលមូលធន។ សមតុល្យនិទស្សន៍ពេញលេញ ត្រូវបានចាត់ថ្នាក់ជាទ្រព្យសកម្ម ឬបំណុលរយៈពេលវែងនៅពេលដែលអាយុកាលច្រើនជាង ១២ខែ នៅពេលដែលអាយុកាលទាបជាង ១២ខែវាត្រូវបានចាត់ថ្នាក់ជាទ្រព្យសកម្មឬបំណុលរយៈពេលខ្លី។ ការជួញដូរនិទស្សន៍ ត្រូវបានចាត់ថ្នាក់ជាទ្រព្យសកម្មឬបំណុលរយៈពេលខ្លី។

i. **ការការពារហានិភ័យតម្លៃទីផ្សារសមស្រប**

ការផ្លាស់ប្តូរតម្លៃទីផ្សានៃនិទស្សន៍ដែលត្រូវបានកំណត់និងមានលក្ខណៈគ្រប់គ្រាន់ដូចជាការការពារហានិភ័យតម្លៃទីផ្សារសមរម្យត្រូវបានកត់ត្រារបាយការណ៍ចំណេញ ឬខាតរួមជាមួយនឹងការផ្លាស់ប្តូរណាមួយនៃតម្លៃសមស្របនៃទ្រព្យសកម្ម ឬបំណុលដែលត្រូវបានកំណត់ដោយហានិភ័យ។ ការចំណេញឬខាតទាក់ទងនឹងចំណែកដ៏មានប្រសិទ្ធិភាពនៃអត្រាការប្រាក់ប្តូរអត្រាប្រាក់កម្ចីមានអត្រាថេរត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាតក្នុង "ចំណាយហិរញ្ញប្បទាន"។ ចំណេញឬខាតទាក់ទងនឹងចំណែកគ្មានប្រសិទ្ធភាពត្រូវបានទទួលស្គាល់នៅក្នុងប្រាក់ចំណេញឬខាតបង់ក្នុង "ចំណេញ/(ខាតបង់ផ្សេងៗ) សុទ្ធ"។ ការផ្លាស់ប្តូរតម្លៃសមស្របនៃការខ្ចីអត្រាការប្រាក់ថេរអត្រាហានិភ័យដែលត្រូវបានបង្កឡើងដោយហានិភ័យអត្រាការប្រាក់ត្រូវបានទទួលស្គាល់នៅក្នុងប្រាក់ចំណេញឬខាតបង់ក្នុង "ចំណាយហិរញ្ញប្បទាន"។

## ៤ គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ៤.៨. ឧបករណ៍ហិរញ្ញវត្ថុ (ត)

**i. ការការពារហានិភ័យតម្លៃទីផ្សារសមស្រប (ត)**

ប្រសិនបើការការពារហានិភ័យលែងមានលក្ខណៈវិនិច្ឆ័យសម្រាប់គណនេយ្យការការពារហានិភ័យការកែតម្រូវទៅនឹងតម្លៃយោងរបស់ធាតុដែលត្រូវបានវាស់វែងតាមវិធីសាស្ត្រការប្រាក់ដែលមានប្រសិទ្ធិភាពហើយត្រូវបានគេយកទៅរំលស់ហើយកត់ត្រាក្នុងរបាយការណ៍ចំណេញ ឬខាតក្នុងរយៈពេលដល់កាលកំណត់ដោយប្រើអត្រាការប្រាក់ដែលមានប្រសិទ្ធិភាពគណនាឡើងវិញ។

**ii. ការការពារហានិភ័យលំហូរសាច់ប្រាក់**

ចំណែកដ៏មានប្រសិទ្ធិភាពនៃការផ្លាស់ប្តូរតម្លៃត្រឹមត្រូវនៃនិស្សន្ទវត្ថុដែលត្រូវបានចាត់តាំងនិងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដូចជាមូលនិធិលំហូរសាច់ប្រាក់ត្រូវបានទទួលស្គាល់នៅក្នុងប្រាក់ចំណូលពេញលេញផ្សេងទៀតនិងប្រមូលផ្តុំជាទុនបម្រុងជាភាគលាភ។ ចំណេញឬខាតទាក់ទងនឹងចំណែកដែលគ្មានប្រសិទ្ធភាពត្រូវបានទទួលស្គាល់ភ្លាមៗនៅក្នុងប្រាក់ចំណេញ ឬខាតបង់ក្នុង" ចំណេញ/(ខាតបង់ផ្សេងៗ) សុទ្ធ"។ សម្ព័ន្ធក្រុមហ៊ុននិងក្រុមហ៊ុនមិនបញ្ចូលមូលដ្ឋានរូបិយប័ណ្ណបរទេស ជាឧបករណ៍ការពារហានិភ័យការផ្លាស់ប្តូរមូលដ្ឋានរូបិយប័ណ្ណបរទេសនៃឧបករណ៍ការពារហានិភ័យ ត្រូវបានទទួលស្គាល់នៅក្នុងប្រាក់ចំណូលពេញលេញផ្សេងទៀត និងបង្គរថ្លៃដើមនៃការការពារហានិភ័យក្នុងមូលធន។ សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនកំណត់ថ្លៃដើមនៃ ការពារហានិភ័យទាក់ទងនឹងមូលដ្ឋានរូបិយប័ណ្ណបរទេស ក្នុងការការពារហានិភ័យដោយគោលការណ៍ការពារហានិភ័យ។

ចំនួនទឹកប្រាក់ដែលបង្គរនៅក្នុងភាគហ៊ុន (រាប់បញ្ចូលទាំងថ្លៃដើមនៃការការពារហានិភ័យ) ត្រូវបានចាត់ថ្នាក់ឡើងវិញក្នុងចំណេញឬខាតក្នុងរយៈពេលដែលលំហូរសាច់ប្រាក់មានឥទ្ធិពលប៉ះពាល់ដល់ប្រាក់ចំណេញឬការបាត់បង់។ ចំណេញ ឬខាតដែលទាក់ទងនឹងចំណែកដ៏មានប្រសិទ្ធិភាពនៃអត្រាការប្រាក់បានផ្លាស់ប្តូរអត្រាការប្រាក់ខ្ចីអត្រាការប្រាក់ត្រូវបានទទួលស្គាល់នៅក្នុងប្រាក់ចំណេញឬខាតបង់នៅក្នុង "ចំណាយហិរញ្ញប្បទាន"។ ចំណេញឬខាតទាក់ទងនឹងចំណែកគ្មានប្រសិទ្ធភាពត្រូវបានទទួលស្គាល់នៅក្នុងប្រាក់ចំណេញឬខាតបង់ក្នុង "ចំណេញ/(ខាតបង់ផ្សេងៗ)សុទ្ធ"។

នៅពេលឧបករណ៍ការពារហានិភ័យហួសកំណត់ ឬលក់ ឬឧបករណ៍ការពារហានិភ័យលែងជួបនឹងលក្ខខណ្ឌការពារគណនេយ្យ ចំណេញ ឬខាតដែលបង្គរមាននៅក្នុងមូលធន នៅពេលនោះនឹងរក្សានៅក្នុងមូលធនដដែល និងទទួលស្គាល់នៅពេលការការពារហានិភ័យលំហូរសាច់ប្រាក់ប៉ះពាល់ដល់ចំណេញ ឬខាត។

**iii. ការការពារហានិភ័យមូលនិធិវិនិយោគសុទ្ធ**

ការការពារហានិភ័យលើការវិនិយោគសុទ្ធនៅក្នុងប្រតិបត្តិការបរទេសត្រូវបានគេរាប់បញ្ចូលក្នុងការការពារហានិភ័យលំហូរសាច់ប្រាក់។

ចំណេញឬខាតណាមួយនៅលើឧបករណ៍ការពារហានិភ័យដែលទាក់ទងនឹងចំណែកដ៏មានប្រសិទ្ធិភាពនៃការការពារហានិភ័យត្រូវបានទទួលស្គាល់នៅក្នុងប្រាក់ចំណូលពេញលេញផ្សេងទៀតនិង ទុនបម្រុងបង្គរក្នុងភាគហ៊ុន។ ចំណេញឬខាតទាក់ទងនឹងចំណែកដែលគ្មានប្រសិទ្ធភាពត្រូវបានទទួលស្គាល់ភ្លាមៗនៅក្នុងរបាយការណ៍ចំណេញឬខាតបង់ក្នុង "ចំណេញ/(ខាតបង់ផ្សេងៗ)សុទ្ធ"។

ចំណេញ និងការខាតបង់ដែលប្រមូលបាននៅក្នុងភាគហ៊ុនត្រូវបានរាប់បញ្ចូលទាំងប្រាក់ចំណេញ ឬខាតនៅពេលប្រតិបត្តិការបរទេសត្រូវបានគេបោះចោល ឬទុកចោលមួយចំណែក។

ការថយចុះនៃឧបករណ៍ហិរញ្ញវត្ថុមួយចំនួនមិនមានលក្ខណៈគ្រប់គ្រាន់សម្រាប់គណនេយ្យការការពារហានិភ័យទេ។ ការផ្លាស់ប្តូរតម្លៃត្រឹមត្រូវនៃឧបករណ៍និមិត្តរូបដែលមិនមានលក្ខណៈគ្រប់គ្រាន់សម្រាប់គណនេយ្យការការពារហានិភ័យត្រូវបានទទួលស្គាល់ភ្លាមៗ នៅក្នុងប្រាក់ចំណេញ ឬខាតហើយត្រូវបានរាប់បញ្ចូលក្នុង "ចំណេញ/(ខាតបង់ផ្សេងៗ)សុទ្ធ"។

## ៤ គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ៤.៩. សន្និធិ

សន្និធិត្រូវបានបង្ហាញនៅតម្លៃទាប និងតម្លៃជាក់ស្តែង។ តម្លៃនៃការទទួលបានសម្ភារៈសំណង់រួមទាំងថ្លៃដើមដែលកើតឡើងក្នុងការនាំរបស់របរនីមួយៗទៅទីតាំង និងស្ថានភាពបច្ចុប្បន្នរបស់ពួកគេត្រូវបានរាប់បញ្ចូលដោយប្រើវិធីសាស្រ្តចំណាយជាមធ្យម។ តម្លៃដែលអាចសម្រេចបានពិតប្រាកដគឺជាតម្លៃលក់ដែលបានប៉ាន់ស្មាននៅក្នុងដំណើរការអាជីវកម្មធម្មតាដែលចំណាយតិចជាងការប៉ាន់ស្មានក្នុងការលក់ ឬថ្លៃដើមជំនួសនៃទ្រព្យសកម្ម។

### ៤.១០. សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សាច់ប្រាក់ និងសាច់ប្រាក់សមមូលរួមមាន សាច់ប្រាក់ក្នុងដៃនិងប្រាក់បញ្ញើតាមតម្រូវការគណនីធនាគារ រួមទាំងការវិនិយោគក្នុងរយៈពេលខ្លី ដែលបំលែង ជាសាច់ប្រាក់បានឆាប់ ហើយនិងរួចរាល់ក្នុងការផ្លាស់ប្តូរទៅជាចំនួនទឹកប្រាក់ជាក់លាក់ណាមួយ និងមិនងាយរងហានិភ័យនៃការផ្លាស់ប្តូរតម្លៃ។

### ៤.១១ មូលធន ទុនបម្រុងទុក និងការទូទាត់ភាគលាភ

ដើមទុនតំណាងឱ្យតម្លៃចារឹកនៃតម្លៃដើមភាគហ៊ុនដែលបានបោះផ្សាយ។ ប្រាក់ចំណេញរក្សាទុក រួមមានប្រាក់ចំណេញរក្សានាពេលបច្ចុប្បន្ន និងប្រាក់ចំណេញរក្សាទុកពីឆ្នាំមុន។

ដើមទុនបម្រុងទុកតំណាងដោយតម្លៃសមស្របនៃភាគហ៊ុនដែលបានផ្តល់ក្រោមគម្រោងជំនួយភាគហ៊ុន។ វាជាភាគហ៊ុនអាស្រ័យលើគម្រោងទូទាត់ដែលបានផ្តល់ដោយក្រុមហ៊ុន Pestech International Berhad ទៅនិយោជិករបស់ក្រុមហ៊ុន។ តម្លៃសមស្របនៃភាគហ៊ុនដែលត្រូវបានផ្តល់ត្រូវបានវាស់វែងតាមតម្លៃសមស្របនៃកាលបរិច្ឆេទនៃការផ្តល់ និងត្រូវបានទទួលស្គាល់ជាការចំណាយលើអត្ថប្រយោជន៍និយោជិកជាមួយនឹងការកើនឡើងមូលធន។

ដើមទុនបម្រុង តំណាងឱ្យការប្រែប្រួលនៃតម្លៃសមស្របនៃអត្រាការប្រាក់នៃកិច្ចសន្យាប្តូរប្រាក់ដែលកំណត់ថាជាការពារហានិភ័យ ដែលត្រូវបានរួមបញ្ចូលក្នុងការពារហានិភ័យលើមូលធនបម្រុង និងបន្តដោះស្រាយចំណូល/ខាតពេញលេញផ្សេងៗរហូតដល់ការទូទាត់ប្រាក់កម្ចី ឬកាលកំណត់នៃកិច្ចសន្យាទៅតាមភាពជាក់ស្តែងមួយណាដែលលឿនជាង។ សម្រាប់កិច្ចសន្យាដែលមិនបានកំណត់ថាជាការការពារហានិភ័យ នោះការផ្លាស់ប្តូរតម្លៃសមស្របត្រូវបានទទួលស្គាល់នៅក្នុងគណនីចំណេញ ឬខាត។

### ៤.១២. សំវិធានធន បំណុលយថាហេតុ និងទ្រព្យសកម្មយថាហេតុ

សំវិធានធនត្រូវបានទទួលស្គាល់នៅពេលដែលសម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនមានកាតព្វកិច្ចស្របច្បាប់ ឬប្រយោល ដែលជាលទ្ធផលនៃព្រឹត្តិការណ៍កន្លងផុតទៅ ហើយមានលទ្ធភាពដែលតម្រូវឱ្យមានលំហូរចេញនូវអត្ថប្រយោជន៍សេដ្ឋកិច្ច ក្នុងការបំពេញនូវកាតព្វកិច្ចហើយតម្លៃនោះអាចប៉ាន់ស្មានដោយជាក់លាក់បាន។ ការកំណត់ពេលវេលា ឬចំនួនទឹកប្រាក់នៃលំហូរនៅតែអាចមានភាពមិនច្បាស់លាស់។ កាតព្វកិច្ចបច្ចុប្បន្នកើតឡើងពីកិច្ចសន្យាផ្លូវច្បាប់ ឬការទាមទារផ្សេងទៀតដែលកើតចេញពីព្រឹត្តិការណ៍កន្លងមក ជាឧទាហរណ៍ជម្លោះផ្លូវច្បាប់ ឬកិច្ចសន្យាជាច្រើន។

| | ពាន់ដុល្លារអាមេរិក | ពាន់ដុល្លារអាមេរិក | ពាន់ដុល្លារអាមេរិក | ពាន់ដុល្លារអាមេរិក | ពាន់ដុល្លារអាមេរិក | **ពាន់ដុល្លារអាមេរិក** | **លានរៀល (សម្គាល់ ៤.២)** |
| ឥណទានមានកាលកំណត់ | ៩៥.៤០៧ | - | - | ១៣.៩២៦ | (៧៥១) | **១០៨.៥៨២** | **៤៤៤.៤២៦** |
| ឥណទានបង្វិល | ១.៤៩៩ | - | - | ១១.៦៧២ | (១១.៥៣៩) | **១.៦៣២** | **៦.៦៨០** |
| បំណុលភតិសន្យា | ១៦២ | ៩ | - | - | (៧៦) | **៩៥** | **៣៨៩** |
| | ៩៧.០៦៨ | ៩ | - | ២៥.៥៩៨ | (១២.៣៦៦) | **១១០.៣០៩** | **៤៥១.៤៩៥** |

## ២៦. សមតុល្យ និងប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធ

ខាងក្រោម គឺជាសមតុល្យមិនទាន់ទូទាត់ជាមួយភាគីពាក់ព័ន្ធ៖

| ភាគីពាក់ព័ន្ធ | ទំនាក់ទំនង | ថ្ងៃទី៣០ ខែមិថុនាឆ្នាំ២០២១ ពាន់ដុល្លារអាមេរិក | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ ពាន់ដុល្លារអាមេរិក | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ លានរៀល (សម្គាល់ ៤.២) | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ លានរៀល (សម្គាល់ ៤.២) |
|---|---|---|---|---|---|
| **សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន** | | | | | |
| **សមតុល្យត្រូវទទួលពីភាគីពាក់ព័ន្ធ** | | | | | |
| Diamond Power Limited | ភាគីសម្ព័ន្ធញ្ញាតិ | **២** | ៣២ | **៨** | ១៣១ |
| Pestech Power Sdn Bhd | ភាគីសម្ព័ន្ធញ្ញាតិ | - | ២.៣០០ | - | ៩.៤១៤ |
| | | **២** | ២.៣៣២ | **៨** | ៩.៥៤៥ |
| **ទឹកប្រាក់ដែលជំពាក់ភាគីសម្ព័ន្ធញ្ញាតិ** | | | | | |
| PESTECH Sdn Bhd | ក្រុមហ៊ុនបុត្រសម្ព័ន្ធ | **១៦.៣០៨** | ៤.៧២៩ | **៦៦.៤៥៥** | ១៩.៣៥៦ |
| Enersol Co.. Ltd | ក្រុមហ៊ុនបុត្រសម្ព័ន្ធ | **៣៤.៨២៨** | ២៧.៩៩១ | **១៤១.៩២៤** | ១១៤.៥៦៧ |
| PESTECH Energy Sdn Bhd | ក្រុមហ៊ុនបុត្រសម្ព័ន្ធ | - | ៨៦២ | - | ៣.៥២៨ |
| ODM Power Line Co Ltd | ក្រុមហ៊ុនបុត្រសម្ព័ន្ធ | **២៧.០០៦** | - | **១១០.០៤៩** | - |
| PESTECH Transmission Sdn Bhd | ក្រុមហ៊ុនបុត្រសម្ព័ន្ធ | **៣.៥០០** | ៣.០៨៥ | **១៤.២៦៣** | ១២.៦២៧ |
| Green Sustainable Ventures Cambodia Co..Ltd | ក្រុមហ៊ុនបុត្រសម្ព័ន្ធ | **៩.០២៦** | - | **៣៦.៧៨១** | - |
| | | **៩០.៦៦៨** | ៣៦.៦៦៧ | **៣៦៩.៤៧២** | ១៥០.០៧៨ |
| | | | ៣៦.៦៦៧ | | ១៥០.០៧៨ |
| **ទឹកប្រាក់ដែលក្រុមហ៊ុនជំពាក់ទៅក្រុមហ៊ុនមេ** | | | | | |
| Pestech International Berhad | ក្រុមហ៊ុនមេ | **២៧.០៥៤** | ៦២.៩៩២ | **១១០.២៤៥** | ២៥៧.៤១៧ |
| **ក្រុមហ៊ុន** | | | | | |
| **ទឹកប្រាក់ដែលក្រុមហ៊ុនបុត្រសម្ព័ន្ធជំពាក់** | | | | | |
| Pestech (Myanmar) Limited | ក្រុមហ៊ុនបុត្រសម្ព័ន្ធ | **៧៩** | ៣៨ | **៣២២** | ១៥៦ |

## ២៦. សមតុល្យ និងប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធ (ត)

សមតុល្យត្រូវទទួលពី/ត្រូវសងទៅភាគីពាក់ព័ន្ធ គឺមិនមានទ្រព្យធានា គ្មានការប្រាក់ និងការទូទាត់តាមតម្រូវការ លើកលែងចំនួនទឹកប្រាក់ជាក់លាក់មួយចំនួនដែលត្រូវសងទៅក្រុមហ៊ុន PESTECH International Berhad និងក្រុមហ៊ុន PESTECH Sdn Bhd ដែលមានការប្រាក់ក្នុងអត្រា ៤.៥% និង ៥% ក្នុងមួយឆ្នាំ។

ក្នុងអំឡុងកាលបរិច្ឆេទ ខាងក្រោមជាប្រតិបត្តិការជាភាគីពាក់ព័ន្ធត្រូវបានកត់ត្រាដូចខាងក្រោម៖

**សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន**

| ភាគីពាក់ព័ន្ធ | ទំនាក់ទំនង | ប្រតិបត្តិការ | សម្រាប់ចុងការិយបរិច្ឆេទ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ ពាន់ដុល្លារអាមេរិក | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ ពាន់ដុល្លារអាមេរិក | សម្រាប់ចុងការិយបរិច្ឆេទ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ លានរៀល (សម្គាល់ ៤.២) | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ លានរៀល (សម្គាល់ ៤.២) |
|---|---|---|---|---|---|---|
| Diamond Power Limited | ក្រុមហ៊ុនបុត្រសម្ព័ន្ធ | សេវាប្រតិបត្តិការ និងសេវាថែទាំ | **១.២៨៩** | ១.២៤៥ | **៥.២៤៨** | ៥.០៩០ |
| PESTECH Sdn Bhd | ក្រុមហ៊ុនបុត្រសម្ព័ន្ធ | ថ្លៃដើមកិច្ចសន្យា | **២០.១៩៣** | ៧.២៥៥ | **៨២.២០៦** | ២៩.៦៥១ |
| | | ចំណាយការប្រាក់ | **៤២** | ៣៤ | **១៧១** | ១៣៩ |
| Enersol Co.. Ltd | ក្រុមហ៊ុនបុត្រសម្ព័ន្ធ | ថ្លៃដើមកិច្ចសន្យា (បញ្ច្រាស់)/កើតឡើង | **(៨៣)** | ១២.៦៣៥ | **(៣៣៨)** | ៥១.៦៣៩ |
| PESTECH Transmission Sdn Bhd | ក្រុមហ៊ុនបុត្រសម្ព័ន្ធ | ថ្លៃដើមកិច្ចសន្យា | **៧២៦** | ២.៦៤៥ | **២.៩៥៦** | ១០.៨១០ |
| | | សេវាគ្រប់គ្រងគម្រោង | **១៤២** | - | **៥៧៨** | - |
| ODM Power Line Co Ltd | ក្រុមហ៊ុនបុត្រសម្ព័ន្ធ | ថ្លៃដើមកិច្ចសន្យា | **១០.០០០** | - | **៤០.៧១០** | - |
| PESTECH International Berhad | ក្រុមហ៊ុនមេ | សេវាគ្រប់គ្រង | **៥៦៥** | ២៦០ | **២.៣០០** | ១.០៦៣ |
| | | ចំណាយការប្រាក់ | **៣៧១** | ៤៤ | **១.៥១០** | ១៨០ |
| Green Sustainable Ventures Cambodia Co., Ltd | ក្រុមហ៊ុនបុត្រសម្ព័ន្ធ | ថ្លៃដើមកិច្ចសន្យា | **២.៥៩២** | - | **១០.៥៥២** | - |

## ២៧. ប្រតិបត្តិការជាមួយគណៈគ្រប់គ្រងសំខាន់ៗ

គណៈគ្រប់គ្រងសំខាន់ៗ ត្រូវបានកំណត់ថាជាបុគ្គលទាំងឡាយណាដែលមានសិទ្ធិ និងទំនួលខុសត្រូវក្នុងការធ្វើផែនការ ដឹកនាំ និងគ្រប់គ្រងលើសកម្មភាពរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនមិនថាដោយផ្ទាល់ ឬដោយប្រយោល។ គណៈគ្រប់គ្រងសំខាន់ៗ រួមបញ្ចូលទាំងអភិបាលរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន។

| | សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន | | | |
|---|---|---|---|---|
| | **សម្រាប់ចុងការិយបរិច្ឆេទ** | | | សម្រាប់ចុងការិយបរិច្ឆេទ |
| | **ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១** | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ | **ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១** | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ |
| | **ពាន់ដុល្លារអាមេរិក** | ពាន់ដុល្លារអាមេរិក | **លានរៀល (សម្គាល់ ៤.២)** | លានរៀល (សម្គាល់ ៤.២) |
| ប្រាក់បៀវត្ស និងរង្វាន់ | **៣៩៤** | ៣៩៣ | **១.៦០៤** | ១.៤៤៣ |

## ២៨. តម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុ

តារាងខាងក្រោមបង្ហាញពីសមតុល្យយោង និងតម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ រួមបញ្ចូលទាំងកម្រិតនៃឋានានុក្រមនៃតម្លៃសមស្រប។ វាមិនរាប់បញ្ចូលទាំងព័ត៌មាននៃតម្លៃសមស្របសម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុដែលមិនបានវាស់វែងតាមតម្លៃសមស្រប ប្រសិនបើសមតុល្យយោងគឺជាការប៉ាន់ស្មានដ៏សមហេតុផលនៃតម្លៃសមស្រប។ សមតុល្យយោងនៃសាច់ប្រាក់ និងសមតុល្យធនាគារ សមតុល្យត្រូវសងទៅ/ទទួលពីភាគីពាក់ព័ន្ធ សមតុល្យត្រូវទទួលពីក្រុមហ៊ុនបុត្រសម្ព័ន្ធ សមតុល្យត្រូវសងទៅក្រុមហ៊ុនមេ គណនីពាណិជ្ជ និងគណនីត្រូវទទួលផ្សេងៗ គណនីពាណិជ្ជ និងគណនីត្រូវសងផ្សេងៗ ព្រមទាំងប្រាក់កម្ចី ជាការប៉ាន់ស្មានដ៏សមហេតុផលនៃតម្លៃសមស្រប ទោះបីជាដោយសារតែលក្ខណៈរយៈពេលខ្លីរបស់វា ឬដោយសារតែការកើនឡើងនៃអត្រាការប្រាក់នៃឧបករណ៍ហិរញ្ញវត្ថុដែលត្រូវបានកំណត់តម្លៃឡើងវិញក្នុងទីផ្សារអត្រាការប្រាក់ក្នុង ឬជិតដល់ចុងការិយបរិច្ឆេទនៃរបាយការណ៍។

កម្រិតខុសគ្នានៅក្នុងឋានានុក្រមនៃតម្លៃសមស្រប គឺមានដូចខាងក្រោម៖

- តម្លៃដែលបានដកស្រង (មិនបានកែប្រែ) ក្នុងទីផ្សារសកម្មសម្រាប់ទ្រព្យសកម្ម ឬបំណុលដែលអាចកំណត់អត្តសញ្ញាណបាន (កម្រិត ១)។
- ធាតុចូលផ្សេងទៀតក្រៅពីតម្លៃដែលបានដកស្រង បានរួមបញ្ចូលក្នុងកម្រិត ១ ដែលអាចអង្កេតបានសម្រាប់ទ្រព្យសកម្ម និងបំណុលមិនថាដោយផ្ទាល់ ឬដោយប្រយោល (កម្រិត ២)។
- ធាតុចូលនៃទ្រព្យសកម្ម ឬបំណុល ដែលមិនផ្អែកលើទិន្នន័យទីផ្សារដែលអាចអង្កេតបាន (កម្រិត ៣)។

| | សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន | | | |
|---|---|---|---|---|
| | **ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១** | | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ | |
| **បំណុលហិរញ្ញវត្ថុ** | **សមតុល្យយោង** | **កម្រិត ២** | សមតុល្យយោង | កម្រិត ២ |
| | **ពាន់ដុល្លារអាមេរិក** | **ពាន់ដុល្លារអាមេរិក** | ពាន់ដុល្លារអាមេរិក | ពាន់ដុល្លារអាមេរិក |
| សញ្ញាប័ណ្ណនៃឧបករណ៍ហិរញ្ញវត្ថុ | **៤.៣២១** | ៤.៣២១ | **៥.៨៦៧** | ៥.៨៦៧ |

តម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុបានធ្វើប្រតិបត្តិការជួញដូរ ក្នុងទីផ្សារសកម្ម គឺផ្អែកលើតម្លៃទីផ្សារដែលបានដកស្រង់នាកាលបរិច្ឆេទនៃរបាយការណ៍។ ទីផ្សារមួយដែលត្រូវបានគេចាត់ទុកជាទីផ្សារសកម្ម ប្រសិនបើតម្លៃដែលបានដកស្រង គឺបានកើតឡើង និងកើតឡើងជាទៀងទាត់ពីការផ្លាស់ប្តូរ អ្នកចែកចាយ ឈ្មួញកណ្តាល សម្ព័ន្ធសហគ្រាស តម្លៃសេវាកម្ម ឬភ្នាក់ងារនិយ័តកម្ម និងតម្លៃទាំងឡាយដែលតំណាងឱ្យប្រតិបត្តិការទីផ្សារជាក់ស្តែង និងកើតឡើងជាទៀងទាត់ដោយផ្អែកលើប្រតិបត្តិការជំហោងដៃ។ ឧបករណ៍ហិរញ្ញវត្ថុទាំងនេះ ត្រូវបានដាក់បញ្ចូលទៅក្នុងកម្រិត ១។

## ២៨. តម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុ (ត)

តម្លៃសមស្របរបស់ឧបករណ៍ហិរញ្ញវត្ថុដែលមិនបានធ្វើប្រតិបត្តិការនៅក្នុងទីផ្សារសកម្ម (ឧទាហរណ៍ សញ្ញាប័ណ្ណហួសការប៉ាន់ស្មាន) ត្រូវបានកំណត់ដោយប្រើប្រាស់បច្ចេកទេសវាយតម្លៃ។ បច្ចេកទេសវាយតម្លៃទាំងនេះ បង្កើនការប្រើប្រាស់នូវទិន្នន័យទីផ្សារដែលអាចអង្កេតបាន នៅពេលដែលវាកើតមាន និងពឹងផ្អែកលើភាពអាចទៅរួចនៃការប៉ាន់ស្មានជាក់លាក់របស់អង្គភាពតិចតួចបំផុត។

ប្រសិនបើរាល់ធាតុចូលសំខាន់ៗ តម្រូវដើម្បីឱ្យតម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុអាចអង្កេតបាន នោះឧបករណ៍ហិរញ្ញវត្ថុត្រូវបានរួមបញ្ចូលទៅក្នុងកម្រិត ២។ ប្រសិនបើធាតុចូលសំខាន់ៗមួយ ឬច្រើន គឺមិនផ្អែកលើភាពអាចអង្កេតមាននៃទិន្នន័យទីផ្សារ នោះឧបករណ៍ហិរញ្ញវត្ថុត្រូវបានរួមបញ្ចូលទៅក្នុងកម្រិត ៣។ តម្លៃសមស្របនៃអត្រាប្តូរប្រាក់ គឺត្រូវបានគណនាក្នុងនាមជាតម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់នាពេលអនាគតដែលបានប៉ាន់ស្មានទុក គឺផ្អែកលើខ្សែកោងទិន្នន័យដែលអាចអង្កេតបាន។

## ២៩. ចំណាត់ថ្នាក់នៃឧបករណ៍ហិរញ្ញវត្ថុ

តារាងខាងក្រោមបង្ហាញពីការវិភាគឧបករណ៍ហិរញ្ញវត្ថុក្នុងប្រភេទនីមួយៗ៖

| | សម្ព័ន្ធក្រុមហ៊ុន | | | |
|---|---|---|---|---|
| | **ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ ពាន់ដុល្លារអាមេរិក** | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ ពាន់ដុល្លារអាមេរិក | **ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ លានរៀល (សម្គាល់ ៤.២)** | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ លានរៀល (សម្គាល់ ៤.២) |
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | | | |
| **តាមថ្លៃដើមរំលស់** | | | | |
| សាច់ប្រាក់ និងសមតុល្យធនាគារ | **១៧.១៦៧** | ៥.៥២៤ | **៦៩.៩៥៦** | ២២.៦១០ |
| គណនីពាណិជ្ជ និងគណនីត្រូវទទួលផ្សេងៗ | **៣.២២១** | ១.៤៥២ | **១៣.១២៧** | ៥.៩៤៣ |
| សមតុល្យត្រូវទទួលពីភាគីពាក់ព័ន្ធ | **២** | ២.៣៣២ | **៨** | ៩.៥៤៥ |
| | **២០.៣៩០** | ៩.៣០៨ | **៨៣.០៩១** | ៣៨.០៩៨ |

| | ក្រុមហ៊ុន | | | |
|---|---|---|---|---|
| | **ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ ពាន់ដុល្លារអាមេរិក** | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ ពាន់ដុល្លារអាមេរិក | **ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ លានរៀល (សម្គាល់ ៤.២)** | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ លានរៀល (សម្គាល់ ៤.២) |
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | | | |
| **តាមថ្លៃដើមរំលស់** | | | | |
| សាច់ប្រាក់ និងសមតុល្យធនាគារ | **១៧.១៥៤** | ៥.៥០០ | **៦៩.៩០៣** | ២២.៥១២ |
| គណនីពាណិជ្ជ និងគណនីត្រូវទទួលផ្សេងៗ | **៣.២១៥** | ១.៤៣៧ | **១៣.១០១** | ៥.៨៨២ |
| សមតុល្យត្រូវទទួលពីក្រុមហ៊ុនបុត្រសម្ព័ន្ធ | **៧៩** | ៣៨ | **៣២២** | ១៥៦ |
| សមតុល្យត្រូវទទួលពីភាគីពាក់ព័ន្ធ | **២** | ២.៣៣២ | **៨** | ៩.៥៤៥ |
| | **២០.៤៥០** | ៩.៣០៧ | **៨៣.៣៣៤** | ៣៨.០៩៥ |

## ២៩. ចំណាត់ថ្នាក់នៃឧបករណ៍ហិរញ្ញវត្ថុ (ត)

| | សម្ព័ន្ធក្រុមហ៊ុន | | | |
|---|---|---|---|---|
| | **ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ ពាន់ដុល្លារអាមេរិក** | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ ពាន់ដុល្លារអាមេរិក | **ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ លានរៀល (សម្គាល់ ៤.២)** | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ លានរៀល (សម្គាល់ ៤.២) |
| **បំណុលហិរញ្ញវត្ថុ** | | | | |
| **តាមថ្លៃដើមរំលស់** | | | | |
| គណនីពាណិជ្ជ និងគណនីត្រូវសងផ្សេងៗ | **៣៣.២៧១** | ១០.៧៩៦ | **១៣៥.៥៨០** | ៤៤.១៥៨ |
| សមតុល្យត្រូវសងទៅក្រុមហ៊ុនមេ | **២៧.០៥៤** | ៦២.៨៩២ | **១១០.២៤៥** | ២៥៧.៤១៧ |
| សមតុល្យត្រូវសងទៅភាគីពាក់ព័ន្ធ | **៩០.៦៦៨** | ៣៦.៦៦៧ | **៣៦៩.៤៧២** | ១៥០.០៧៨ |
| ប្រាក់កម្ចី | **១០៥.១១៩** | ១១២.៦៩១ | **៤២៨.៣៦០** | ៤៦១.២៤៤ |
| **សញ្ញាប័ណ្ណដែលបានប្រើការពារហានិភ័យ** | | | | |
| សញ្ញាប័ណ្ណនៃឧបករណ៍ហិរញ្ញវត្ថុ | **៤.៣២១** | ៥.៨៦៧ | **១៧.៦០៨** | ២៤.០១៤ |
| | **២៦០.៤៣៣** | ២២៨.៩១៣ | **១.០៦១.២៦៥** | ៩៣៦.៩៤១ |

| | ក្រុមហ៊ុន | | | |
|---|---|---|---|---|
| | **ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ ពាន់ដុល្លារអាមេរិក** | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ ពាន់ដុល្លារអាមេរិក | **ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ លានរៀល (សម្គាល់ ៤.២)** | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ លានរៀល (សម្គាល់ ៤.២) |
| **បំណុលហិរញ្ញវត្ថុ** | | | | |
| **តាមថ្លៃដើមរំលស់** | | | | |
| គណនីពាណិជ្ជ និងគណនីត្រូវសងផ្សេងៗ | **៣៣.២៥៧** | ១០.៧៩៦ | **១៣៥.៥២៣** | ៤៤.១៥៨ |
| សមតុល្យត្រូវសងទៅក្រុមហ៊ុនមេ | **២៧.០៥៤** | ៦២.៨៩២ | **១១០.២៤៥** | ២៥៧.៤១៧ |
| សមតុល្យត្រូវសងទៅភាគីពាក់ព័ន្ធ | **៩០.៦៦៨** | ៣៦.៦៦៧ | **៣៦៩.៤៧២** | ១៥០.០៧៨ |
| ប្រាក់កម្ចី | **១០៥.១១៩** | ១១២.៦៩១ | **៤២៨.៣៦០** | ៤៦១.២៤៤ |
| **សញ្ញាប័ណ្ណដែលបានប្រើការពារហានិភ័យ** | | | | |
| សញ្ញាប័ណ្ណនៃឧបករណ៍ហិរញ្ញវត្ថុ | **៤.៣២១** | ៥.៨៦៧ | **១៧.៦០៨** | ២៤.០១៤ |
| | **២៦០.៤១៩** | ២២៨.៩១៣ | **១.០៦១.២០៨** | ៩៣៦.៩៤១ |

## ៣០. តម្លៃក្នុងមួយភាគហ៊ុន

កម្រៃក្នុងមួយភាគហ៊ុនជាមូលដ្ឋាន គឺត្រូវបានគណនាតាមរយៈការបែងចែកប្រាក់ចំណេញដែលទាក់ទងទៅនឹងអ្នកកាន់កាប់មូលធនរបស់ក្រុមហ៊ុនតាមចំនួនមធ្យមនៃភាគហ៊ុនធម្មតា ក្នុងការចេញផ្សាយភាគហ៊ុនក្នុងអំឡុងកាលបរិច្ឆេទដូចដែលបានបង្ហាញខាងក្រោម៖

| | សម្ព័ន្ធក្រុមហ៊ុន | | | |
|---|---|---|---|---|
| | **ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ ពាន់ដុល្លារអាមេរិក** | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ ពាន់ដុល្លារអាមេរិក | **ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ លានរៀល (សម្គាល់ ៤.២)** | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ លានរៀល (សម្គាល់ ៤.២) |
| ប្រាក់ចំណេញដែលទាក់ទងជាមួយម្ចាស់ក្រុមហ៊ុន | **១.៣៨៨** | ៧.២០៧ | **៥.៦៥០** | ២៩.៤៥៥ |
| ចំនួនភាគហ៊ុនជាមធ្យម | **៧៤.៤៨០.២៤៧** | ៧១.០០០.០០០ | **៧៤.៤៨០.២៤៧** | ៧១.០០០.០០០ |
| ចំណេញសុទ្ធក្នុងមួយភាគហ៊ុនគោល (សេន/រៀល) | **១.៨៦** | ១០.១៥ | **៧៥.៨៦** | ៤១៤.៨៦ |
| ចំណេញសុទ្ធក្នុងមួយភាគហ៊ុនថយចុះ (សេន/រៀល) | **១.៨៦** | ១០.១៥ | **៧៥.៨៦** | ៤១៤.៨៦ |

តម្លៃថយចុះក្នុងមួយភាគហ៊ុន គឺត្រូវបានគណនាតាមរយៈការកែប្រែចំនួនភាគហ៊ុនធម្មតាជាមធ្យមដែលនៅសល់ ដើម្បីសន្មត់ពីការកែប្រែទៅលើភាគហ៊ុនដែលសក្តានុពលទាំងអស់។

សម្ព័ន្ធក្រុមហ៊ុនមិនមានការកែប្រែទៅលើភាគហ៊ុនធម្មតាដែលមានសក្តានុពល គិតត្រឹមចុងកាលបរិច្ឆេទនីមួយៗ។ ដូចនេះ កម្រៃដែលបានចរចាក្នុងមួយភាគហ៊ុន គឺសមមូលទៅនឹងកម្រៃជាមូលដ្ឋានក្នុងមួយភាគហ៊ុន។

## ៣១. គោលបំណង និងគោលនយោបាយក្នុងការគ្រប់គ្រងហានិភ័យ

*ហានិភ័យហិរញ្ញវត្ថុ*

សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនត្រូវប្រឈមនឹងហានិភ័យហិរញ្ញវត្ថុដែលកើតឡើងពីប្រតិបត្តិការអាជីវកម្ម និងការប្រើប្រាស់ឧបករណ៍ហិរញ្ញវត្ថុ។ គោលនយោបាយគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុត្រូវបានបង្កើតឡើងដើម្បីធានាថាមានធនធានគ្រប់គ្រាន់សម្រាប់ការអភិវឌ្ឍន៍អាជីវកម្មរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនខណៈពេលដែលការគ្រប់គ្រងហានិភ័យឥណទាន និងហានិភ័យលទ្ធភាពទូទាត់សងបំណុល ហានិភ័យអត្រាការប្រាក់ និងហានិភ័យរូបិយប័ណ្ណបរទេស។ សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនដំណើរស្របតាមគោលនយោបាយ និងនីតិវិធីដែលបានកំណត់យ៉ាងច្បាស់ ត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាលដើម្បីធានាប្រសិទ្ធភាពនៃដំណើរការគ្រប់គ្រងហានិភ័យ។

ផ្នែកសំខាន់ៗនៃហានិភ័យហិរញ្ញវត្ថុដែលសម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនបានប្រឈមមុខ និងគោលនយោបាយនៃចំណុចសំខាន់នៃសកម្មភាពរតនាគារសំខាន់ៗត្រូវបានកំណត់ដូចខាងក្រោម៖

### (ក). ហានិភ័យឥណទាន

ហានិភ័យឥណទាន គឺជាហានិភ័យនៃការខាតបង់ផ្នែកហិរញ្ញវត្ថុរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនប្រសិនបើអតិថិជន ឬសមភាគីនៃឧបករណ៍ហិរញ្ញវត្ថុមិនអាចបំពេញតាមកាតព្វកិច្ចតាមកិច្ចសន្យារបស់ខ្លួនបាន។

វាគឺជាគោលនយោបាយរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនក្នុងការប្រើប្រាស់នូវឧបករណ៍ហិរញ្ញវត្ថុ ជាមួយសមភាគីដែលអាចជឿជាក់បាន។ សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនមិនរំពឹងទុកថា នឹងទទួលរងនូវការខាតបង់ឥណទានជាសារវន្ត លើទ្រព្យសកម្មហិរញ្ញវត្ថុ ឬឧបករណ៍ហិរញ្ញវត្ថុផ្សេងៗទៀត ។

ប្រភពនៃហានិភ័យឥណទាន កើតឡើងនៅពេលមានការប្រែប្រួលផ្នែកសេដ្ឋកិច្ច ឧស្សាហកម្ម និងកត្តាភូមិសាស្ត្រ ដែលធ្វើអោយប៉ះពាល់ដល់ក្រុមសមភាគី ដែលហានិភ័យឥណទានរបស់ខ្លួនជាផ្នែកដ៏សំខាន់ នៃហានិភ័យឥណទានទាំងអស់របស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន។ ប្រតិបត្តិការរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនត្រូវបានរួមបញ្ចូលជាមួយសមភាគីដែលអាចជឿជាក់បាន ដោយហេតុនេះវាអាចកាត់បន្ថយហានិភ័យឥណទានបាន។

## ៣១. គោលបំណង និងគោលនយោបាយក្នុងការគ្រប់គ្រងហានិភ័យ (ត)

### (ក). ហានិភ័យឥណទាន (ត)

កត្តាដែលបង្ករឱ្យសម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន ប្រឈមនឹងហានិភ័យឥណទានមានដូចខាងក្រោម៖

**គណនីត្រូវទទួល និងទ្រព្យសកម្មកិច្ចសន្យា**

តម្លៃដុលនៃគណនីត្រូវទទួល ត្រូវបានគិតពិចារណានូវការប៉ាន់ស្មានដែលសមហេតុផល នៃតម្លៃសមស្រប។

ក្នុងការវាស់វែងការខាតបង់ឥណទាន រំពឹងទុកពាណិជ្ជកម្មនិងគណនីត្រូវទទួលនិងទ្រព្យសកម្មកិច្ចសន្យាត្រូវបានវាយតម្លៃជាលក្ខណៈបុគ្គលដោយកំណត់លក្ខណៈហានិភ័យរបស់អតិថិជនចំពោះចំណាត់ថ្នាក់ខាងក្រៅដូចដែលបានផ្សព្វផ្សាយដោយទីភ្នាក់ងារវាយតម្លៃឥណទានអន្តរជាតិហើយ ECL ការខាតបង់ត្រូវបានប្រើដើម្បីគណនា ECL។

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ មិនមានហានិភ័យឥណទាននៃចំនួនទឹកប្រាក់របស់គណនីត្រូវទទួលនៅក្នុង របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

អតិថិជនត្រូវបានវាយតម្លៃ "AAA" ដោយក្រុមហ៊ុនមិនធ្លាប់ទទួលរងការខាតបង់ពីអតិថិជននេះពីមុនទេ ដូច្នេះអត្រា 0% ត្រូវបានប្រើ។ នាកាលបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ការខាតបង់ឥណទានដែលបានរំពឹងទុកមិនមាននោះទេ។

**សាច់ប្រាក់ និងសាច់ប្រាក់សមមូល**

ហានិភ័យឥណទានសម្រាប់សាច់ប្រាក់ និងសាច់ប្រាក់សមមូល ត្រូវបានចាត់ទុកថាតិចតួច ពីព្រោះសមភាគីជាធនាគារនៅក្នុងស្រុកដ៏ល្បី។

**ឧបករណ៍ហិរញ្ញវត្ថុប្រើក្នុងសកម្មភាពការពារហានិភ័យ**

សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនប្រឈមនឹងការខាតបង់ឥណទាន នៅក្នុងព្រឹត្តិការណ៍នៃមិនបានធ្វើប្រតិបត្តិការដោយសមភាគីនៃឧបករណ៍ហិរញ្ញវត្ថុ ប៉ុន្តែមិនមានការរំពឹងទុកថាមានសមភាគីណាមួយមិនអាចបំពេញកាតព្វកិច្ចរបស់ខ្លួនបាន។

### (ខ). ហានិភ័យលទ្ធភាពទូទាត់សងបំណុល

ហានិភ័យលទ្ធភាពទូទាត់សងបំណុល គឺជាហានិភ័យដែលសហគ្រាស ប្រឈមនឹងការលំបាកក្នុងការរៀបចំថវិកា ដើម្បីបំពេញតាមកិច្ចសន្យាដែលទាក់ទងជាមួយនឹងឧបករណ៍ហិរញ្ញវត្ថុ។

ហានិភ័យលទ្ធភាពទូទាត់សងបំណុល គឺជាលទ្ធផលនៃកង្វះលទ្ធភាពក្នុងការលក់ចេញនូវទ្រព្យសកម្មហិរញ្ញវត្ថុក្នុងតម្លៃសមស្របដែលនៅកៀកបំផុត។

គោលនយោបាយរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន គឺដើម្បីត្រួតពិនិត្យជាប្រចាំនូវតម្រូវការសាច់ប្រាក់បច្ចុប្បន្ន និងលទ្ធភាពទូទាត់សងបំណុលដែលបានរំពឹងទុក ដើម្បីធានាបានថាខ្លួនអាចរក្សាសាច់ប្រាក់បម្រុងបានគ្រប់គ្រាន់ក្នុងការបំពេញនូវតម្រូវការសាច់ប្រាក់រយៈពេលខ្លី និងរយៈពេលវែងរបស់ខ្លួនបាន។

ហានិភ័យលទ្ធភាពទូទាត់សងបំណុល ដែលកើតពីប្រាក់កម្ចីរបស់ពួកគេ គណនីពាណិជ្ជ និងគណនីត្រូវសងផ្សេងៗ និងគណនីត្រូវសងទៅភាគីពាក់ព័ន្ធ។

## ៣១. គោលបំណង និងគោលនយោបាយក្នុងការគ្រប់គ្រងហានិភ័យ (ត)

### (ខ). ហានិភ័យលទ្ធភាពទូទាត់សងបំណុល (ត)

***ការវិភាគទៅលើឧបករណ៍ហិរញ្ញវត្ថុតាមរយៈកាលកំណត់នៃកិច្ចសន្យា***

តារាងខាងក្រោម វិភាគអំពីទម្រង់នៃកាលកំណត់នៃបំណុលភតិសន្យារបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន ដោយផ្អែកលើលំហូរសាច់ប្រាក់កិច្ចសន្យាដែលមិនបានធ្វើអប្បហា ដែលអាចនឹងខុសគ្នាពីតម្លៃយោងនៃបំណុលនាកាលបរិច្ឆេទនៃរបាយការណ៍៖

**សម្ព័ន្ធក្រុមហ៊ុន**

| ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ | តាមតម្រូវការ ឬ ក្នុងពេល ១ឆ្នាំ | ១ឆ្នាំ ទៅ ៥ឆ្នាំ | ច្រើនជាង ៥ឆ្នាំ | លំហូរសាច់ប្រាក់កិច្ចសន្យាសរុប | |
|---|---|---|---|---|---|
| | ពាន់ដុល្លារអាមេរិក | ពាន់ដុល្លារអាមេរិក | ពាន់ដុល្លារអាមេរិក | ពាន់ដុល្លារអាមេរិក | លានរៀល (សម្គាល់ ៤.២) |
| គណនីពាណិជ្ជ និងគណនីត្រូវសងផ្សេងៗ | ៣៣.២៧១ | - | - | ៣៣.២៧១ | ១៣៥.៥៨០ |
| សមតុល្យត្រូវសងទៅក្រុមហ៊ុនមេ | ២៧.០៥៤ | - | - | ២៧.០៥៤ | ១១០.២៤៥ |
| សមតុល្យត្រូវសងទៅភាគីពាក់ព័ន្ធ | ៩០.៦៦៨ | - | - | ៩០.៦៦៨ | ៣៦៩.៤៧២ |
| បំណុលភតិសន្យា | ១៤ | ១៤៨ | - | ១៦២ | ៦៦១ |
| ប្រាក់កម្ចី | ១៨.៥០៧ | ១០១.៥៩៥ | - | ១២០.១០២ | ៤៨៩.៤១៦ |
| | ១៦៩.៥១៤ | ១០១.៧៤៣ | - | ២៧១.២៥៧ | ១.១០៥.៣៧៤ |

| ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ | តាមតម្រូវការ ឬ ក្នុងពេល ១ឆ្នាំ | ១ឆ្នាំ ទៅ ៥ឆ្នាំ | ច្រើនជាង ៥ឆ្នាំ | លំហូរសាច់ប្រាក់កិច្ចសន្យាសរុប | |
|---|---|---|---|---|---|
| | ពាន់ដុល្លារអាមេរិក | ពាន់ដុល្លារអាមេរិក | ពាន់ដុល្លារអាមេរិក | ពាន់ដុល្លារអាមេរិក | លានរៀល (សម្គាល់ ៤.២) |
| គណនីពាណិជ្ជ និងគណនីត្រូវសងផ្សេងៗ | ១០.៧៩៦ | - | - | ១០.៧៩៦ | ៤៤.១៨៨ |
| សមតុល្យត្រូវសងទៅក្រុមហ៊ុនមេ | ៦២.៨៩២ | - | - | ៦២.៨៩២ | ២៥៧.៤១៧ |
| សមតុល្យត្រូវសងទៅភាគីពាក់ព័ន្ធ | ៣៦.៦៦៧ | - | - | ៣៦.៦៦៧ | ១៥០.០៧៨ |
| បំណុលភតិសន្យា | ៧២ | ២៣ | - | ៩៥ | ៣៨៩ |
| ប្រាក់កម្ចី | ១៩.១៣៥ | ៩៤.៤០៣ | ២៧.០៩៩ | ១៤០.៦៣៧ | ៥៧៥.៦២៧ |
| | ១២៩.៥៦២ | ៩៤.៤២៦ | ២៧.០៩៩ | ២៥១.០៨៧ | ១.០២៧.៦៩៩ |

**ក្រុមហ៊ុន**

| ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ | តាមតម្រូវការ ឬ ក្នុងពេល ១ឆ្នាំ | ១ឆ្នាំ ទៅ ៥ឆ្នាំ | ច្រើនជាង ៥ឆ្នាំ | លំហូរសាច់ប្រាក់កិច្ចសន្យាសរុប | |
|---|---|---|---|---|---|
| | ពាន់ដុល្លារអាមេរិក | ពាន់ដុល្លារអាមេរិក | ពាន់ដុល្លារអាមេរិក | ពាន់ដុល្លារអាមេរិក | លានរៀល (សម្គាល់ ៤.២) |
| គណនីពាណិជ្ជ និងគណនីត្រូវសងផ្សេងៗ | ៣៣.២៥៧ | - | - | ៣៣.២៥៧ | ១៣៥.៥២៣ |
| សមតុល្យត្រូវសងទៅក្រុមហ៊ុនមេ | ២៧.០៥៤ | - | - | ២៧.០៥៤ | ១១០.២៤៥ |
| សមតុល្យត្រូវសងទៅភាគីពាក់ព័ន្ធ | ៩០.៦៦៨ | - | - | ៩០.៦៦៨ | ៣៦៩.៤៧២ |
| បំណុលភតិសន្យា | ១៤ | ១៤៨ | - | ១៦២ | ៦៦១ |
| ប្រាក់កម្ចី | ១៨.៥០៧ | ១០១.៥៩៥ | - | ១២០.១០២ | ៤៨៩.៤១៦ |
| | ១៦៩.៥០០ | ១០១.៧៤៣ | - | ២៧១.២៤៣ | ១.១០៥.៣៧៤ |

## ៣១. គោលបំណង និងគោលនយោបាយក្នុងការគ្រប់គ្រងហានិភ័យ (ត)

### (ខ). ហានិភ័យលទ្ធភាពទូទាត់សងបំណុល (ត)

ក្រុមហ៊ុន

| ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ | តាមតម្រូវការ ឬ ក្នុងពេល ១ឆ្នាំ ពាន់ដុល្លារអាមេរិក | ១ឆ្នាំ ទៅ ៥ឆ្នាំ ពាន់ដុល្លារអាមេរិក | ច្រើនជាង ៥ឆ្នាំ ពាន់ដុល្លារអាមេរិក | លំហូរសាច់ប្រាក់កិច្ចសន្យាសរុប ពាន់ដុល្លារអាមេរិក | លានរៀល (សម្គាល់ ៤.២) |
|---|---|---|---|---|---|
| គណនីពាណិជ្ជ និងគណនីត្រូវសងផ្សេងៗ | ១០.៧៩៦ | - | - | ១០.៧៩៦ | ៤៤.១៨៨ |
| សមតុល្យត្រូវសងទៅក្រុមហ៊ុនមេ | ៦២.៨៩២ | - | - | ៦២.៨៩២ | ២៥៧.៤១៧ |
| សមតុល្យត្រូវសងទៅភាគីពាក់ព័ន្ធ | ៣៦.៦៦៧ | - | - | ៣៦.៦៦៧ | ១៥០.០៧៨ |
| បំណុលភតិសន្យា | ៧២ | ២៣ | - | ៩៥ | ៣៨៩ |
| ប្រាក់កម្ចី | ១៩.១៣៥ | ៩៤.៤០៣ | ២៧.០៩៩ | ១៤០.៦៣៧ | ៥៧៥.៦២៧ |
| | ១២៩.៥៦២ | ៩៤.៤២៦ | ២៧.០៩៩ | ២៥១.០៨៧ | ១.០២៧.៦៩៩ |

### (គ). ហានិភ័យអត្រាការប្រាក់

ហានិភ័យអត្រាការប្រាក់ គឺជាហានិភ័យដែលតម្លៃសមស្របនៃលំហូរសាច់ប្រាក់នាពេលអនាគតនៃឧបករណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន នឹងប្រែប្រួលព្រោះតែការផ្លាស់ប្តូរក្នុងទីផ្សារអត្រាការប្រាក់។

*ការវិភាគលើហានិភ័យអត្រាការប្រាក់*

សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន ប្រឈមនឹងការប្រែប្រួលនៅក្នុងទីផ្សារអត្រាការប្រាក់តាមរយៈឥណទានធនាគារដែលមានអត្រាការប្រាក់អថេរ។ ខាងក្រោមនេះ គឺជាការបង្ហាញពីអត្រាការប្រាក់របស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុននៃឧបករណ៍ហិរញ្ញវត្ថុដែលមានការប្រាក់សំខាន់ៗ ដោយផ្អែកលើសមតុល្យយោងនាកាលបរិច្ឆេទនៃរបាយការណ៍៖

| | **សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន** | | | |
|---|---|---|---|---|
| | **ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ ពាន់ដុល្លារអាមេរិក** | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ ពាន់ដុល្លារអាមេរិក | **ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ លានរៀល (សម្គាល់ ៤.២)** | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ លានរៀល (សម្គាល់ ៤.២) |
| **ឧបករណ៍ហិរញ្ញវត្ថុតាមអត្រាកើនឡើង** | | | | |
| បំណុលហិរញ្ញវត្ថុ | | | | |
| ប្រាក់កម្ចី | **៥៧.៨៦៩** | ៦២.៦៩១ | **២៣៥.៨១៦** | ២៥៦.៥៩៤ |
| បំណុលហិរញ្ញវត្ថុសុទ្ធ | **៥៧.៨៦៩** | ៦២.៦៩១ | **២៣៥.៨១៦** | ២៥៦.៥៩៤ |

តារាងខាងក្រោមបង្ហាញពីភាពប្រែប្រួលនៃប្រាក់ចំណេញចំពោះការផ្លាស់ប្តូរអត្រាការប្រាក់សមរម្យ +/- ០.២៥% ។ ការផ្លាស់ប្តូរទាំងនេះត្រូវបានគេចាត់ទុកថាអាចធ្វើទៅបានដោយផ្អែកលើការសង្កេតលើលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន។ ការគណនា គឺផ្អែកលើការផ្លាស់ប្តូរទីផ្សារអត្រាការប្រាក់ជាមធ្យមសម្រាប់រយៈពេលនីមួយៗ និងឧបករណ៍ហិរញ្ញវត្ថុដែលបានធ្វើឡើងនៅកាលបរិច្ឆេទរបាយការណ៍នីមួយៗដែលងាយនឹងផ្លាស់ប្តូរអត្រាការប្រាក់។ អថេរផ្សេងទៀតទាំងអស់ត្រូវបានរក្សាថេរ។

## ៣១. គោលបំណង និងគោលនយោបាយក្នុងការគ្រប់គ្រងហានិភ័យ (ត)

### (គ). ហានិភ័យអត្រាការប្រាក់ (ត)

| | សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន ប្រាក់ចំណេញក្នុងការិយបរិច្ឆេទ | | | |
|---|---|---|---|---|
| | | +0.២៥% | | -0.២៥% |
| | ពាន់ដុល្លារអាមេរិក | លានរៀល (សម្គាល់ ៤.២) | ពាន់ដុល្លារអាមេរិក | លានរៀល (សម្គាល់ ៤.២) |
| **សម្រាប់ចុងការិយបរិច្ឆេទថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១** | **(១៤៥)** | **(៥៩១)** | **១៤៥** | **៥៩១** |
| សម្រាប់ចុងការិយបរិច្ឆេទថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ | (១៥៧) | (៦៤២) | ១៥៧ | ៦៤២ |

### (ឃ). ហានិភ័យរូបិយប័ណ្ណបរទេស

ហានិភ័យរូបិយប័ណ្ណបរទេស គឺជាហានិភ័យដែលតម្លៃសមស្រប ឬលំហូរសាច់ប្រាក់នាពេលអនាគតរបស់ឧបករណ៍ហិរញ្ញវត្ថុនឹងមានការប្រែប្រួល ពីព្រោះតែមានការផ្លាស់ប្តូរក្នុងអត្រាប្តូរប្រាក់បរទេស។

ហានិភ័យនៃការប្តូររូបិយប័ណ្ណបរទេសរបស់សម្ព័ន្ធក្រុមហ៊ុន កើតឡើងពីប្រតិបត្តិការជារូបិយប័ណ្ណបរទេស រីងហ្គីត ម៉ាឡេស៊ី ("RM")។

ការប្រឈមនឹងហានិភ័យរូបិយប័ណ្ណបរទេសរបស់សម្ព័ន្ធក្រុមហ៊ុន គឺអាស្រ័យលើសមតុល្យយោងគិតត្រឹមចុងការិយបរិច្ឆេទមាន៖

| បានធ្វើប្រតិបត្តិការក្នុងរូបិយប័ណ្ណ RM | **ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ ពាន់ដុល្លារអាមេរិក** | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ ពាន់ដុល្លារអាមេរិក | **ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ លានរៀល (សម្គាល់ ៤.២)** | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ លានរៀល (សម្គាល់ ៤.២) |
|---|---|---|---|---|
| សមតុល្យត្រូវសងទៅភាគីពាក់ព័ន្ធ | - | ៤១ | - | ១៦៨ |

***ការវិភាគលើហានិភ័យរូបិយប័ណ្ណបរទេស៖***

តារាងខាងក្រោម បង្ហាញពីហានិភ័យប្រាក់ចំណេញរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនក្នុងកាលបរិច្ឆេទក្នុង +/-៥% ការប្រែប្រួលនៅក្នុងរូបិយប័ណ្ណ RM គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍ដើម្បីទូទាត់ជាមួយរូបិយប័ណ្ណគោលរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន អថេរផ្សេងទៀតទាំងអស់ត្រូវបានរក្សាថេរ៖

| | សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន | | | |
|---|---|---|---|---|
| | **សម្រាប់ចុងការិយបរិច្ឆេទ** | | សម្រាប់ចុងការិយបរិច្ឆេទ | |
| | **ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ ពាន់ដុល្លារអាមេរិក** | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ ពាន់ដុល្លារអាមេរិក | **ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ លានរៀល (សម្គាល់ ៤.២)** | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ លានរៀល (សម្គាល់ ៤.២) |
| RM/ដុល្លារអាមេរិក | | | | |
| Strengthened | - | (២) | - | (៨) |
| Weakened | - | ២ | - | ៨ |

## ៣២. កិច្ចសន្យា

ក្រុមហ៊ុនមានកិច្ចសន្យាក្នុងការទិញធានារ៉ាប់រងលើហានិភ័យនយោបាយសម្រាប់រយៈពេល ១០ឆ្នាំ សម្រាប់ការសាងសង់គម្រោងប្រព័ន្ធបញ្ជូនថាមពលវារីអគ្គិសនី ស្ទឹងតាតែ ២៣០គីឡូវ៉ុល-ភ្នំពេញ ដែលមានចំនួនទឹកប្រាក់សរុបចំនួន ៤.៩៦៨.៦០០ដុល្លារអាមេរិក ដើម្បីធានាទៅលើប្រាក់កម្ចី ដូចដែលបានបង្ហាញនៅក្នុងកំណត់សម្គាល់ ១៨ គ.៣។ គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ ចំនួនទឹកប្រាក់ដែលមិនទាន់បានទូទាត់មានចំនួន ២.៧៦១.៧៣៣ ដុល្លារអាមេរិក (ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០៖ទឹកប្រាក់ចំនួន ៤.២១៦.៧៦២ ដុល្លារអាមេរិក)

លើសពីនេះទៀត ក្រុមហ៊ុនមានកិច្ចសន្យាក្នុងការទិញធានារ៉ាប់រងលើហានិភ័យនយោបាយសម្រាប់រយៈពេល ៧ឆ្នាំសម្រាប់ការសាងសង់គម្រោងប្រព័ន្ធបញ្ជូនសៀគ្វីភ្លោះ ២៣០គីឡូវ៉ុល និង ៥០០គីឡូវ៉ុល ពីភ្នំពេញទៅខេត្តព្រះសីហនុ ដែលមានចំនួនទឹកប្រាក់សរុប ៣.២២២.១២៥ ដុល្លារអាមេរិក ដើម្បីធានាទៅលើប្រាក់កម្ចី ដូចដែលបានបង្ហាញនៅក្នុងកំណត់សម្គាល់ ១៨ គ.៣។ គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ ចំនួនទឹកប្រាក់ដែលមិនទាន់បានទូទាត់មានចំនួន ២.៣២០.០០៥ ដុល្លារអាមេរិក (ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០៖គ្មាន)។

## ៣៣. យថាភាព

ក្នុងឆ្នាំ ២០១១ GDT បានចេញសេចក្តីជូនដំណឹងអំពីការវាយតំលៃពន្ធឡើងវិញដល់ក្រុមហ៊ុនដើម្បីទាមទារពន្ធលើប្រាក់ចំណេញដែលមិនបានប្រកាសជាមុននិងពន្ធលើតម្លៃបន្ថែមដែលមានទឹកប្រាក់ចំនួន ៥៤៦.៩៧១ ដុល្លារអាមេរិក (២.២២២.៣៤៤.០១១ ខ្មែររៀល) ក្នុងអំឡុងពេលចាប់ពីថ្ងៃទី១ ខែឧសភា ឆ្នាំ២០១១ ដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១១។

នៅឆ្នាំ២០១៥ GDT បានចេញសេចក្តីជូនដំណឹងស្តីពីការវាយតំលៃពន្ធឡើងវិញដល់ក្រុមហ៊ុនដើម្បីទាមទារពន្ធលើប្រាក់ចំណេញដែលមិនបានប្រកាសជាមុន និងអាករលើតម្លៃបន្ថែមដែលមានចំនួន ៤៩០.៩១២ ដុល្លារអាមេរិក (១.៩៩៤.៥៧៥.៧៨៥ ខ្មែររៀល) ដែលទាក់ទងនឹងរយៈពេលចាប់ពីថ្ងៃទី១០ ខែមករា ឆ្នាំ២០១៣ ដល់ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣។

នៅឆ្នាំ២០១៧ GDT បានចេញសេចក្តីជូនដំណឹងស្តីពីការវាយតំលៃពន្ធឡើងវិញដល់ក្រុមហ៊ុនដើម្បីទាមទារពន្ធលើប្រាក់ចំណេញដែលមិនបានប្រកាសអាករលើតម្លៃបន្ថែមនិងពន្ធកាត់ទុក ១៤%លើពន្ធសេវាកម្មចំនួន ២៦៧.៩៥៦ ដុល្លារអាមេរិក (១.០៨៨.៧០៤.៨៣៨ ខ្មែររៀល) សម្រាប់ការធ្វើសវនកម្មពន្ធពេញលេញប្រចាំឆ្នាំ២០១០។

ជាការឆ្លើយតប ក្រុមហ៊ុនបានបំពេញលិខិតស្នើរសុំទៅកាន់ GDT ដើម្បីជាការតវ៉ាលើការវាយតម្លៃខុសទាំងនេះ។ គណៈគ្រប់គ្រងបានកំណត់ថាលិខិតវាយតម្លៃទាំងនេះមិនមានមូលដ្ឋាន និងមិនសមស្រប ព្រមទាំងលទ្ធភាពដែលវាតម្រូវឱ្យទូទាត់ទៅលើការវាយតម្លៃពន្ធឡើងវិញដាច់ដោយឡែក។ បន្ថែមពីនេះទៀត ចាប់តាំងពីក្រុមហ៊ុនបានចុះបញ្ជីជាមួយផ្សារមូលបត្រកម្ពុជាដោយជោគជ័យ ក្រុមហ៊ុននឹងបានទទួលអត្ថប្រយោជន៍ពន្ធដោយរួមបញ្ចូលទាំងសិទ្ធិក្នុងការស្នើរសុំលើកលែងការវាយតម្លៃពន្ធឡើងវិញដែលបានរៀបរាប់ខាងលើ ដោយអនុលោមតាមអនុក្រឹតស្តីពីការលើកទឹកចិត្តផ្នែកពន្ធនៅក្នុងវិស័យមូលបត្រ។ គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមហ៊ុននៅកំពុងរងចាំការអនុម័តពី GDT ទៅលើការស្នើរសុំការលើកលែងលើលិខិតវាយតម្លៃពន្ធឡើងវិញ។

## ៣៤. ការគ្រប់គ្រងដើមទុន

គោលបំណងចម្បងនៃការគ្រប់គ្រងដើមទុនរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន គឺដើម្បីធានាឱ្យបានថា ក្រុមហ៊ុនរក្សាបាននូវសមាមាត្រដើមទុនគ្រប់គ្រាន់ដើម្បីគាំទ្រការធ្វើពាណិជ្ជកម្មរបស់ខ្លួន និងដើម្បីបង្កើនតម្លៃដល់ម្ចាស់ភាគហ៊ុន។

សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន គ្រប់គ្រងរចនាសម្ព័ន្ធដើមទុនរបស់ខ្លួន និងធ្វើនិយ័តកម្មដោយមើលឃើញពីការប្រែប្រួលនៃស្ថានភាពសេដ្ឋកិច្ច។ ដើម្បីរក្សាទុក ឬកែតម្រូវលើរចនាសម្ព័ន្ធដើមទុន សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនអាចធ្វើនិយ័តកម្មទៅលើការទូទាត់ភាគលាភទៅឱ្យម្ចាស់ភាគហ៊ុន ផ្ទេរភាគហ៊ុនទៅម្ចាស់ភាគហ៊ុនវិញ ឬការចេញផ្សាយភាគហ៊ុនថ្មី។ មិនមានការផ្លាស់ប្តូរទៅលើគោលបំណង គោលនយោបាយ ឬដំណើរការបានកើតមានឡើងសម្រាប់ចុងការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងឆ្នាំ២០២០នេះឡើយ។

## ៣៥. ព្រឹត្តិការណ៍ក្រោយកាលបរិច្ឆេទនៃរបាយការណ៍

លើកលែងតែផលប៉ះពាល់នៃជម្ងឺកូវីដ-១៩ទៅលើក្រុមហ៊ុនដូចដែលបានបង្ហាញនៅក្នុងសម្គាល់១ ទៅរបាយការណ៍ហិរញ្ញវត្ថុ មិនមានព្រឹត្តិការណ៍គួរឱ្យកត់សម្គាល់ផ្សេងទៀតបានកើតឡើងបន្ទាប់ពីចុងកាលបរិច្ឆេទនៃរបាយការណ៍ និងកាលបរិច្ឆេទនៃការអនុម័តទៅលើរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ដែលតម្រូវឱ្យមានការកែប្រែ ឬសេចក្តីបញ្ជាក់ដែលនឹងត្រូវធ្វើឡើងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

## ៣៦. សេចក្តីអនុម័តទៅលើរបាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនគិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ និងសម្រាប់ចុងការិយបរិច្ឆេទ គឺត្រូវបានអនុម័តឱ្យចេញផ្សាយដោយក្រុមប្រឹក្សាភិបាលនៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២១។

# ព័ត៌មានអំពីប្រតិបត្តិការជាមួយភាគី ជាប់ពាក់ព័ន្ធ និងទំនាស់ផលប្រយោជន៍

បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវបង្ហាញពីព័ត៌មានប្រតិបត្តិការសំខាន់ៗជាមួយភាគីជាប់ពាក់ព័ន្ធនៅក្នុងរយៈពេល ២ (ពីរ) ឆ្នាំចុងក្រោយ ដោយបញ្ជាក់ពីឈ្មោះ ទំនាក់ទំនងរវាងបុគ្គលចុះបញ្ជីលក់មូលបត្រ និងភាគីជាប់ពាក់ព័ន្ធ ទំហំនៃប្រតិបត្តិការ និងប្រភេទនៃផលប្រយោជន៍ដែលកើតចេញពីទំនាក់ទំនងនោះដូចខាងក្រោម៖

ក. ប្រតិបត្តិការសំខាន់ៗជាមួយភាគហ៊ុនិកមានភាគហ៊ុនចាប់ពី ៥% ឡើងទៅនៃមូលបត្រកម្មសិទ្ធិកំពុងធ្វើច រាចរលើទីផ្សារ។

| ក្រុមហ៊ុន | ទំនាក់ទំនង | ប្រតិបត្តិការ | ឆ្នាំបញ្ចប់ | | ឆ្នាំបញ្ចប់ | |
|---|---|---|---|---|---|---|
| | | | ៣០ មិថុនា ២០២១ | ៣០ មិថុនា ២០២០ | ៣០ មិថុនា ២០២១ | ៣០ មិថុនា ២០២០ |
| | | | 000 ដុល្លារអាមេរិក | 000 ដុល្លារអាមេរិក | លានរៀល | លានរៀល |
| PESTECH International Berhad | ក្រុមហ៊ុនហូលឌីង | ថ្លៃសេវាគ្រប់គ្រង | ៥៦៥ | ២៦០ | ២ ៣០០ | ១ ០៦៣ |
| PESTECH International Berhad | ក្រុមហ៊ុនហូលឌីង | ការប្រាក់ | ៣៧១ | ៤៤ | ១ ៥១០ | ១៨០ |

ខ. ប្រតិបត្តិការសំខាន់ៗជាមួយអភិបាល និងបុគ្គលិកជាន់ខ្ពស់

**ពុំមានប្រតិបត្តិការសំខាន់ៗជាមួយអភិបាល និងបុគ្គលិកជាន់ខ្ពស់ក្នុងរយៈពេល ២ (ពីរ) ឆ្នាំចុងក្រោយឡើយ។**

គ. ប្រតិបត្តិការពាក់ព័ន្ធនឹងអភិបាល និងភាគហ៊ុនិកពាក់ព័ន្ធនឹងការទិញ/លក់ទ្រព្យសកម្ម និងសេវាកម្ម

**ពុំមានប្រតិបត្តិការពាក់ព័ន្ធនឹងអភិបាល និងភាគហ៊ុនិកពាក់ព័ន្ធនឹងការទិញ/លក់ទ្រព្យសកម្ម និងសេវាកម្មក្នុងរយៈ ពេល ២ (ពីរ) ឆ្នាំចុងក្រោយឡើយ។**

ឃ. ប្រតិបត្តិការសំខាន់ៗជាមួយសមាជិកគ្រួសារផ្ទាល់របស់អភិបាល បុគ្គលិកជាន់ខ្ពស់ និងភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនចាប់ពី ៥% ឡើងទៅ

**ពុំមានប្រតិបត្តិការសំខាន់ៗជាមួយសមាជិកគ្រួសារផ្ទាល់របស់អភិបាល បុគ្គលិកជាន់ខ្ពស់ និងភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនចាប់ពី ៥% ឡើងទៅក្នុងរយៈពេល ២ (ពីរ) ឆ្នាំចុងក្រោយឡើយ។**

ង. ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលដែលមានទំនាក់ទំនងជាមួយអភិបាលរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនហូលឌីងរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ដែលទំនាក់ទំនងរបស់បុគ្គលទាំនោះ កើតមាននៅក្នុងប្រតិបត្តិការណាមួយ ឬការចាត់ចែងណាមួយដែលបានធ្វើឡើងដោយរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ

**ពុំមានប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលដែលមានទំនាក់ទំនងជាមួយអភិបាលរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនហូលឌីងរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ដែលទំនាក់ទំនងរបស់បុគ្គលទាំនោះ កើតមាននៅក្នុងប្រតិបត្តិការណាមួយ ឬការចាត់ចែងណាមួយដែលបានធ្វើឡើងដោយរបស់បុគ្គលចុះបញ្ជីលក់មូលបត្រឡើយ។**

ច. ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលធ្លាប់ជាអភិបាល ឬបុគ្គលជាប់ពាក់ព័ន្ធនឹងបុគ្គលធ្លាប់ជាអភិបាល

**ពុំមានប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលធ្លាប់ជាអភិបាល ឬបុគ្គលជាប់ពាក់ព័ន្ធនឹងបុគ្គលធ្លាប់ជាអភិបាលឡើយ។**

ឆ. ប្រតិបត្តិការសំខាន់ៗជាមួយអភិបាលដែលកាន់មុខតំណែងណាមួយនៅក្នុងសមាគម ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ឬនៅក្នុងក្រុមហ៊ុនណាមួយផ្សេងទៀតក្រៅពីបុគ្គលចុះបញ្ជីលក់មូលបត្រ

**ពុំមានប្រតិបត្តិការសំខាន់ៗជាមួយអភិបាលដែលកាន់មុខតំណែងណាមួយនៅក្នុងសមាគម ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ឬនៅក្នុងក្រុមហ៊ុនណាមួយផ្សេងទៀតក្រៅពីបុគ្គលចុះបញ្ជីលក់មូលបត្រឡើយ។**

ជ. ប្រតិបត្តិការសំខាន់ៗជាមួយអភិបាលដែលទទួលបានផលប្រយោជន៍ពីបុគ្គលចុះបញ្ជីលក់មូលបត្រទោះជាហិរញ្ញវត្ថុ ឬមិនមែនហិរញ្ញវត្ថុ

**ពុំមានប្រតិបត្តិការសំខាន់ៗជាមួយអភិបាលដែលទទួលបានផលប្រយោជន៍ពីបុគ្គលចុះបញ្ជីលក់មូលបត្រទោះជាហិរញ្ញវត្ថុ ឬមិនមែនហិរញ្ញវត្ថុឡើយ។**

# ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង ("MD & A")

## ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

### ១. ការវិភាគចំណូល

ចំណូលសម្រាប់ឆ្នាំហិរញ្ញវត្ថុ ២០២១ បានកត់ត្រាត្រឹម ២៧៣ ៦២៨ លានរៀល ដែលកើនឡើងចំនួន ៧០ ៦១៤ លានរៀល ឬ ៣៤,៨% បើធៀបទៅនឹងឆ្នាំហិរញ្ញវត្ថុ ២០២០ ដែលបានកត់ត្រាត្រឹម ២០៣ ០១៤ លានរៀល។ ការកើនឡើងនេះភាគច្រើនបណ្តាលមកពីការអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីនៅក្នុងប្រទេសកម្ពុជា និងប្រទេស PAPUA NEW GUINEA។

### ២. ការវិភាគចំណូលតាមផ្នែក

កិច្ចសន្យាវិស្វកម្ម លទ្ធកម្ម ការសាងសង់ និងការដាក់ឱ្យដំណើរការ ("EPCC") សម្រាប់បណ្តាញអគ្គិសនី និងអនុស្ថានីយ៍គឺជាកត្តាចូលរួមដ៏សំខាន់សម្រាប់ចំណូលប្រចាំឆ្នាំមានទឹកប្រាក់ចំនួន ២៦០ ៨៤៥ លានរៀល (ឆ្នាំហិរញ្ញវត្ថុ ២០២០៖ ១៩៣ ៨៤៥ លានរៀល) ដែលស្មើនឹងប្រមាណ ៩៥,៣ % (ឆ្នាំហិរញ្ញ វត្ថុ ២០២០៖ ៩៥,៥%) នៃចំណូលសរុប។

ការបំពេញបន្ថែមលើសេវាកម្ម EPCC ដែលជាប្រតិបត្តិការ និងសេវាថែទាំ ("O&M") ដែលស្មើនឹងប្រមាណ ១២ ៧៨៣ លានរៀល ឬ ៤,៧% នៃចំណូលសរុប (ឆ្នាំ២០២០៖ ៩.១៦៩ លានរៀលឬ ៤.៥%)។ ការកើនឡើងនៃប្រាក់ចំណេញដែលបានទទួលស្គាល់ពី O&M បើប្រៀបធៀបទៅនឹងឆ្នាំសារពើពន្ធ ២០២០ ភាគច្រើនផ្តើមចេញពីការអនុវត្តគម្រោងក្រុងព្រះសីហនុនៅ ខែមីនា ឆ្នាំ២០២០។

### ៣. ការវិភាគគម្លាតចំណេញដុល

ចំណេញដុលនៅក្នុងឆ្នាំហិរញ្ញវត្ថុ២០២១ត្រូវបានកត់ត្រាត្រឹម១៦,៣%បើធៀបទៅនឹង៣៨%នៅក្នុងឆ្នាំហិរញ្ញវត្ថុ២០២០ដែលថយចុះចំនួន២១,៧%។ កម្រិតគម្លាតនៃចំណេញដុលមានកម្រិតខ្ពស់ជាងនៅក្នុងឆ្នាំហិរញ្ញវត្ថុ ២០២០ ដោយសារតែការបញ្ចប់គម្រោងធំៗចំនួន ២។ គម្លាតចំណេញដុល គឺស្ថិតក្នុងការរំពឹងទុករបស់យើង។

### ៤. ការវិភាគចំណេញ/(ខាត)មុនបង់ពន្ធ

ចំណេញមុនបង់ពន្ធ ("PBT") សម្រាប់ឆ្នាំហិរញ្ញវត្ថុនេះត្រូវបានកត់ត្រាត្រឹម ១០ ០៨៨ លានរៀល ដែលថយចុះចំនួន ២៧ ៦៨៨ លានរៀល បើធៀបទៅនឹង PBT សម្រាប់ឆ្នាំហិរញ្ញវត្ថុ ២០២០ ដែលមានចំនួន ៣៧ ៧៧៦ លានរៀល ។ PBT សម្រាប់ឆ្នាំហិរញ្ញវត្ថុ ២០២០ មានកម្រិតខ្ពស់ ដោយសារកម្រិតខ្ពស់នៃគម្លាតចំណេញដែលបណ្តាលមកពីការបញ្ចប់គម្រោងធំៗចំនួន ២។

### ៥. ការវិភាគចំណេញក្នុងការិយបរិច្ឆេទ

ចំណេញក្រោយពេលបង់ពន្ធ ("PAT") ត្រូវបានកត់ត្រាត្រឹម ៥ ៩៨០ លានរៀល ដែលថយចុះចំនួន ២៣ ៤៦៣ លានរៀល បើធៀបទៅនឹង PAT សម្រាប់ឆ្នាំហិរញ្ញវត្ថុ ២០២០ ដែលមានចំនួន ២៩ ៤៤៣ លាន រៀល។ PAT សម្រាប់ឆ្នាំហិរញ្ញវត្ថុ ២០២០ មានកម្រិតខ្ពស់ ដោយសារកម្រិតខ្ពស់នៃគម្លាតចំណេញដែលបណ្តាលមកពីការបញ្ចប់គម្រោងធំៗចំនួន ២។

## ខ. កត្តាសំខាន់ដែលប៉ះពាល់លើផលចំណេញ

កត្តាសំខាន់ៗដែលជះឥទ្ធិពលលើប្រាក់ចំណេញភាគច្រើនទទួលបានការរួមចំណែកពីវដ្តនៃគម្រោងជាបន្ត បន្ទាប់ក្នុងអំឡុងពេលនៃឆ្នាំដែលស្ថិតនៅក្រោមការត្រួតពិនិត្យឡើងវិញ។ នេះរួមបញ្ចូលដំណាក់កាលខុសៗគ្នានៃគម្រោង ដូចជាដំណាក់កាលនៃការរចនាប្លង់ ការធ្វើផែនការសំណង់ស៊ីវិល ការប្រគល់ការដំឡើង និងការដាក់ឱ្យប្រើប្រាស់។ ដោយមានដំណើរការគម្រោងខុសៗគ្នានៅក្នុងពេលតែមួយផលប៉ះពាល់ទាំង នេះអាចត្រូវបានបន្ធូរបន្ថយតាមរយៈដំណាក់កាលខុសៗគ្នានៃគម្រោងនីមួយៗដែលធ្វើឱ្យកម្រិតលម្អៀង នៃប្រាក់ចំណេញដុលរបស់យើងស្ថិតនៅកម្រិតមធ្យម។

នៅថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២១ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវវិធានការបិទខ្ទប់ប្រទេសដែលចាប់ផ្តើមពីថ្ងៃទី១៥ ខែមេសា ដល់ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២១ ដែលត្រូវបានពន្យារពេលបន្ថែមទៀតរហូតដល់ ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២១ ដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ ១៩ នៅប្រទេសកម្ពុជា។ ការបិទខ្ទប់នេះ មិនបានជះឥទ្ធិពលខ្លាំងដល់សម្ព័ន្ធក្នុងអំឡុង ឆ្នាំ២០២១ ឡើយដោយសារគ្មានការលុបចោលកិច្ចសន្យា ហើយយើងក៏មិនបានជួបប្រទះបញ្ហាប្រឈមពាក់ព័ន្ធនឹងការប្រមូលប្រាក់ពីអតិថិជនធំៗរបស់សម្ព័ន្ធ។

# ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង ("MD & A")

ចំណាយលើបរិក្ខារ ឬវត្ថុធាតុដើមដែលត្រូវបានប្រើប្រាស់នៅក្នុងគម្រោង គឺអាស្រ័យលើការឡើងចុះនៃតម្លៃភាគរយរបស់វត្ថុធាតុដើម និងសម្ភារៈឧបភោគសម្រាប់ឆ្នាំដែលស្ថិតនៅក្រោមការត្រួតពិនិត្យឡើងវិញ នោះនឹងជះឥទ្ធិពលដល់លទ្ធភាពក្នុងការទទួលបានប្រាក់ចំណេញរបស់ក្រុមហ៊ុន។ នៅក្នុងឆ្នាំដែលស្ថិតនៅក្រោមការត្រួតពិនិត្យឡើងវិញ ចំណាយលើវត្ថុធាតុដើម និងសម្ភារៈឧបភោគធៀបនឹងចំណូលមានចំនួន ៧៨,៣% ដោយប្រៀបធៀបទៅនឹង ៨៧,៧% នៅក្នុងឆ្នាំហិរញ្ញវត្ថុ ២០២០។ ទោះបីជាយ៉ាងណាក៏ដោយ បរិក្ខារ និងវត្ថុធាតុដើមដែលពាក់ព័ន្ធនឹងការងារនីមួយៗត្រូវបានទទួលយក និងបានទទួលថវិកានៅក្នុងអំឡុងពេលដែលដំណាក់កាលនៃការដាក់សំណើត្រូវបានគិតប្រាក់ចំណាយសម្រាប់គម្រោងនីមួយៗទៅតាមនោះ។ ការឡើងចុះនៃតម្លៃវត្ថុធាតុដើមជាទូទៅត្រូវបានប្រគល់បន្តឱ្យរោងចក្រផលិតសមាសធាតុទាំងនោះប្រសិន អាចធ្វើទៅបាន។

ភាពយឺតយ៉ាវណាមួយនៅក្នុងការប្រគល់បរិក្ខាររបស់ភាគីទីបីដែលនៅបរទេសអាចធ្វើឱ្យការអនុវត្តគម្រោងមានភាពយឺតយ៉ាវដែរ និងបង្កើតចំណាយបន្ថែមដល់គម្រោងដោយពុំមានថវិកាត្រូវបានប្រគល់ជូនឡើយ។

## គ. បម្រែបម្រួលសំខាន់ៗលើការលក់ និងចំណូល

ចំណូលសម្រាប់ឆ្នាំហិរញ្ញវត្ថុ ២០២១ ត្រូវបានកត់ត្រាត្រឹម ២៧៣ ៦២៨ លានរៀល ដែលកើនឡើងចំនួន ៧០ ៦១៤ លានរៀល ឬ ៣៤,៨% បើធៀបទៅនឹងឆ្នាំហិរញ្ញវត្ថុ ២០២០ ត្រូវបានកត់ត្រាត្រឹម ២០៣ ០១៤ លានរៀល។ ការកើនឡើងនេះភាគច្រើនបណ្តាលមកពីការអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីនៅប្រទេសកម្ពុជា និងប្រទេស Papua New Guinea។

## ឃ. ផលប៉ះពាល់នៃអត្រាប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងតម្លៃទំនិញ

ចំណូលពីការលក់ និងការទិញរបស់យើង ភាគច្រើនត្រូវបានធ្វើឡើងជាដុល្លារអាមេរិក។ ដូច្នេះ យើងមិនទទួលរងផលប៉ះពាល់យ៉ាងខ្លាំងក្លាពីការឡើងចុះនៃអត្រាប្តូររូបិយប័ណ្ណបរទេសនៅក្នុងអំឡុងឆ្នាំហិរញ្ញវត្ថុ នេះទេ។ ការប្រឈមមុខនឹងអត្រាប្តូរបិយប័ណ្ណបរទេសភាគច្រើនបណ្តាលមកពីការរាយការណ៍។

សម្រាប់ហានិភ័យនៃអត្រាការប្រាក់ **ផថខ** ប្រឈមមុខនឹងបម្រែបម្រួលតាមរយៈលិខិតូបករណ៍នៃអត្រាការប្រាក់អណ្តែតពោលគឺការខ្ចីប្រាក់នៅក្នុងអត្រាអថេរ។ ពុំមានផលប៉ះពាល់ធ្ងន់ធ្ងរដែលបណ្តាលមកពីការឡើងចុះនៃតម្លៃទំនិញឡើយ។

## ង. ផលប៉ះពាល់នៃអតិផរណា

ការចំណាយសម្រាប់អាជីវកម្មគឺដោយសារផលប៉ះពាល់នៃអតិផរណាដែលមានចំនួនប្រហែល ១០% នៃចំណូល ទោះបីជាយ៉ាងណាក៏ដោយអតិផរណានៅក្នុងប្រទេសកម្ពុជាមានចំនួន ៤% (គិតត្រឹម ខែមិថុនា ឆ្នាំ២០២១) ដែលបានបង្កផលប៉ះពាល់ប្រហែល ០,៤២% តែប៉ុណ្ណោះចំពោះប្រាក់ចំណេញរបស់យើង។ រាល់ចំណាយប្រតិបត្តិការទាំងអស់មានតម្លៃថេរនៅក្នុងអំឡុងពេលនៃកិច្ចសន្យាទាំងមូល។ ក្រៅពីការលើកឡើងខាងលើពុំមានផលប៉ះពាល់សំខាន់ៗផ្សេងទៀតដែលបណ្តាលមកពីអតិផរណាឡើយ។

## ច. គោលនយោបាយសេដ្ឋកិច្ច/សារពើពន្ធ/សាច់ប្រាក់របស់រាជរដ្ឋាភិបាល

ពុំមានបម្រែបម្រួលសំខាន់ៗនៅក្នុងគោលនយោបាយសេដ្ឋកិច្ច/សារពើពន្ធ/សាច់ប្រាក់របស់រាជរដ្ឋាភិបាល ឬ កត្តានានាដែលមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរចំពោះលទ្ធផលហិរញ្ញវត្ថុនៅក្នុងអំឡុងឆ្នាំនេះនោះទេ។

# ព័ត៌មានចាំបាច់ផ្សេងទៀត សម្រាប់ការការពារវិនិយោគិន

លោក Charles Tan នាយកប្រតិបត្តិមានភារកិច្ចត្រួតពិនិត្យសកម្មភាពអភិវឌ្ឍន៍សាជីវកម្មដល់ ផថខ ដែលពាក់ព័ន្ធនឹងទំនាក់ទំនងវិនិយោគិន។ គាត់បានចូលរួមជានិច្ចជាមួយនឹងអ្នកវិភាគ អ្នកគ្រប់គ្រងមូលនិធិ និងអ្នកពាក់ព័ន្ធដទៃទៀតដើម្បីលើកកម្ពស់សក្តានុពលកំណើនសាជីវកម្មរបស់ ផថខ ព្រមទាំងធ្វើបច្ចុប្បន្នភាពជាប្រចាំជាមួយការអភិវឌ្ឍន៍ថ្មីៗរបស់ក្រុមហ៊ុន។

គេហទំព័រសាជីវកម្មរបស់ ផថខ www.pestech.com.kh ជាគន្លឹះសំខាន់សម្រាប់ភាគហ៊ុនិក វិនិយោគិន សមាជិកសាធារណជន និងអ្នកពាក់ព័ន្ធដទៃទៀតដើម្បីទទួលបាននូវព័ត៌មានថ្មីៗអំពីសកម្មភាពក្រុមហ៊ុន លទ្ធផលហិរញ្ញវត្ថុ ការអភិវឌ្ឍន៍យុទ្ធសាស្រ្តសំខាន់ៗ និងបញ្ហាផ្សេងៗទៀតដែលប៉ះពាល់ដល់ផលប្រយោជន៍នៃភាគីពាក់ព័ន្ធ។

## ហត្ថលេខារបស់អភិបាលនៃផេសចិក (ខេមបូឌា) ម.ក

កាលបរិច្ឆេទ៖ ២៣ កញ្ញា ២០២១
បានអាន និងឯកភាពដោយ៖



ហត្ថលេខា
ឈ្មោះ៖ Paul Lim Pay Chuan
មុខតំណែង៖ ប្រធានក្រុមប្រឹក្សាភិបាល

កាលបរិច្ឆេទ៖ ២៣ កញ្ញា ២០២១
បានអាន និងឯកភាពដោយ៖



ហត្ថលេខា
ឈ្មោះ៖ Lim Ah Hock
មុខតំណែង៖ អភិបាល

កាលបរិច្ឆេទ៖ ២៣ កញ្ញា ២០២១
បានអាន និងឯកភាពដោយ៖



ហត្ថលេខា
ឈ្មោះ៖ Han Fatt Juan
មុខតំណែង៖ អភិបាលប្រតិបត្តិ
/ប្រធាននាយកប្រតិបត្តិ

កាលបរិច្ឆេទ៖ ២៣ កញ្ញា ២០២១
បានអាន និងឯកភាពដោយ៖



ហត្ថលេខា
ឈ្មោះ៖ Charles Tan Pu Hooi
មុខតំណែង៖ អភិបាល

កាលបរិច្ឆេទ៖ ២៣ កញ្ញា ២០២១
បានអាន និងឯកភាពដោយ៖



ហត្ថលេខា
ឈ្មោះ៖ ដាវ់ អានសាន
មុខតំណែង៖ អភិបាលឯករាជ្យ

# របាយការណ៍អភិបាលកិច្ចប្រចាំឆ្នាំ

## ផ្នែកទី១- ភាគហ៊ុនិក

### ក. រចនាសម្ព័ន្ធភាគហ៊ុនិក

**១. ព័ត៌មានភាគហ៊ុនិក** (គិតត្រឹម ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២១)

| បរិយាយ | សញ្ជាតិ | ប្រភេទភាគហ៊ុនិក | ចំនួនភាគហ៊ុនិក | ចំនួនមូលបត្រ | ភាគរយ |
|---|---|---|---|---|---|
| តិចជាង ៥% | សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | ៨៨៨ | ៨៨៩ ១៨៥ | ១,១៩% |
| | | នីតិបុគ្គល | ០ | ០ | ០ |
| | មិនមែនសញ្ជាតិខ្មែរ | រូបវន្តបុគ្គល | ១០៦ | ៣ ០៥៥ ៨១៥ | ៤,០៧% |
| | | នីតិបុគ្គល | ១ | ០ | ០ |
| ចាប់ពី ៥% ដល់ ៣០% | សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | ០ | ០ | ០ |
| | | នីតិបុគ្គល | ០ | ០ | ០ |
| | មិនមែនសញ្ជាតិខ្មែរ | រូបវន្តបុគ្គល | ០ | ០ | ០ |
| | | នីតិបុគ្គល | ០ | ០ | ០ |
| ចាប់ពី ៣០% ឡើងទៅ | សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | ០ | ០ | ០ |
| | | នីតិបុគ្គល | ០ | ០ | ០ |
| | មិនមែនសញ្ជាតិខ្មែរ | រូបវន្តបុគ្គល | ០ | ០ | ០ |
| | | នីតិបុគ្គល | ១ | ៧១ ០០០ ០០០ | ៩៤,៧៤% |
| **សរុប** | | | ៤៨៧ | ៧៤ ៩៤៥ ០០០ | ១០០% |

១. ភាគហ៊ុនិកដែលជាអភិបាល និងនិយោជិតរបស់ក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រ (គិតត្រឹមថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២១)

| ភាគហ៊ុនិក | ចំនួនភាគហ៊ុនិក | ចំនួនមូលបត្រ | ភាគរយ |
|---|---|---|---|
| អភិបាល | ៥ | ១៨៥ ២៩៨ | ០,២៥ |
| និយោជិត | ៦១ | ៩២ ៨៣៤ | ០,១២ |
| សរុប | ៦៦ | ២៧៨ ១៣២ | ០,៣៧ |

# របាយការណ៍អភិបាលកិច្ចប្រចាំឆ្នាំ

## ផ្នែកទី១- ភាគហ៊ុនិក

### ខ. សិទ្ធិរបស់ភាគហ៊ុនិក និងការការពារសិទ្ធិរបស់ភាគហ៊ុនិក

ការការពារសិទ្ធិរបស់ភាគហ៊ុនិក និងសិទ្ធិរបស់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនភាគតិច និងការអនុវត្តរបស់ក្រុមហ៊ុនក្នុងការការពារសិទ្ធិរបស់ភាគហ៊ុនិក ដូចខាងក្រោម៖

ក) ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនធម្មតា មានសិទ្ធិបោះឆ្នោតពេញលេញដោយ ១ ភាគហ៊ុន ស្មើនឹង ១សំឡេង។

ខ) ករណីមានការរំលាយក្រុមហ៊ុន ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនធម្មតាមានសិទ្ធិទទួលបានទ្រព្យសកម្មសុទ្ធរបស់ក្រុមហ៊ុនបន្ទាប់ពីមានការរំលាយក្រុមហ៊ុនទៅតាមចំណែកភាគហ៊ុនដែលខ្លួនកាន់កាប់។

គ) ភាគហ៊ុនិកម្នាក់ៗមានសិទ្ធិៈ

- បោះឆ្នោត និងបញ្ចេញមតិក្នុងរាល់កិច្ចប្រជុំភាគហ៊ុនិករបស់ក្រុមហ៊ុន
- ទទួលបានភាគលាភដែលបានប្រកាសដោយក្រុមហ៊ុន
- ទទួលបានទ្រព្យសម្បត្តិដែលនៅសល់របស់ក្រុមហ៊ុនបន្ទាប់ពីការរំលាយក្រុមហ៊ុន
- ពិនិត្យបញ្ជីឈ្មោះរបស់ភាគហ៊ុនិកទាំងឡាយបាននៅទីស្នាក់ការចុះបញ្ជីរបស់ក្រុមហ៊ុន ឬ នៅកន្លែងរក្សាទុកបញ្ជីលក់មូលបត្រនោះនៅក្នុងម៉ោងធ្វើការ ឬពេលប្រជុំមហាសន្និបាតភាគហ៊ុ និកដែលបញ្ជីឈ្មោះត្រូវបានរៀបចំ និង
- អាចពិនិត្យរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ក្រុមហ៊ុនក្នុងម៉ោងធ្វើការ និងទទួលបានរបាយការណ៍នេះដោយឥតគិតថ្លៃយោងតាមមាត្រា២២៥ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម។

ពុំមានម្ចាស់ភាគហ៊ុនិកណាម្នាក់របស់ក្រុមហ៊ុនស្នើសុំព័ត៌មានពាក់ព័ន្ធនឹងក្រុមហ៊ុន ឬទទួលបានបណ្តឹង ចំពោះ ឆ្នាំហិរញ្ញវត្ថុដែលបានបញ្ចប់នៅថ្ងៃទី ៣០ ខែមិថុនាឆ្នាំ២០២១ ឡើយ។

### គ. មហាសន្និបាតភាគហ៊ុនិក

#### ១. នីតិវិធីនៃការរៀបចំមហាសន្និបាតភាគហ៊ុនិក និងការបោះឆ្នោត

ក) ភាគហ៊ុនិកអាចចូលរួមបោះឆ្នោតដោយផ្ទាល់ ឬដោយអាណត្តិគាហកៈ តាមរយៈលិខិតផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរ ដោយមានចុះហត្ថលេខាកាលបរិច្ឆេទ និងភ្ជាប់មកជាមួយនូវព័ត៌មានដូចខាងក្រោម៖

- ចំនួនភាគហ៊ុនដែលកាន់កាប់ដោយភាគហ៊ុនិក
- ឈ្មោះ និងអាសយដ្ឋានរបស់អាណត្តិគាហកៈ និង
- រយៈពេលនៃការតែងតាំងអាណត្តិគាហកៈ

ខ) ប្រសិនបើអាណត្តិគាហកៈស្នើសុំធ្វើការបោះឆ្នោតនៅក្នុងកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក នោះលិខិតផ្ទេរសិទ្ធិជាអាណត្តិគាហកៈត្រូវរក្សាទុកនៅប្រធានក្រុមប្រឹក្សាភិបាលនៅមុនពេល ឬនៅអំឡុង ពេលចាប់ផ្តើមកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក។

គ) រាល់កិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកគឺតំរូវអោយភាគហ៊ុនិកដែលមានឈ្មោះក្នុងបញ្ជីចូលរួមដោយផ្ទាល់ ឬអណត្តិគាហកៈ ភាគហ៊ុនទាំងអស់មានសិទ្ធិបោះឆ្នោតលើរបៀបវារៈណាមួយនឹងបង្កើតជាក្វ៉ូមសម្រាប់ក្រុមនោះ ហើយធ្វើការបោះឆ្នោតសម្រាប់ចំណាត់ការលើរបៀបវរៈនោះ។ នៅពេលភាគហ៊ុនរួមតែមួយត្រូវបានជាតំណាងនៅក្នុងកិច្ចប្រជុំក្រៅពីគោលបំណងរៀបចំកិច្ចប្រជុំឬធ្វើប្រតិបត្តិការអាជីវកម្មភាគហ៊ុននោះត្រូវបានចាត់ទុកថាមានវត្តមានសម្រាប់គោលបំណងក្វ៉ូមសម្រាប់ផ្នែកផ្សេងទៀតនៃកិច្ចប្រជុំ និងសម្រាប់ការលើកកិច្ចប្រជុំទៅកាលបរិច្ឆេទ ពេលវេលា ឬទីកន្លែងថ្មីលើកលែងតែកាលបរិច្ឆេទកំណត់ទុកថ្មីត្រូវបាន ឬដាច់ខាតត្រូវបានកំណត់សម្រាប់ការលើកពេលការប្រជុំ។

ឃ) ករណីគ្រប់ក្វ៉ូម របៀបវារៈមួយត្រូវបានអនុម័តដោយផ្អែកលើសំលេងភាគច្រើននៃអ្នកចូលរួមបោះឆ្នោតដែលមានន័យថា សំលេងអ្នកបោះឆ្នោតស្របត្រូវច្រើនជាងសំលេងអ្នកបោះឆ្នោតប្រឆាំង លើកលែងតែច្បាប់ និងបទប្បញ្ញត្តិ ឬលក្ខន្តិកៈរបស់ក្រុមហ៊ុនចែងផ្ទុយពីនេះ។

ង) ពេលអនុវត្តសិទ្ធិបោះឆ្នោតក្នុងកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកការបោះឆ្នោតគឺឈរលើគោលការណ៍មួយភាគហ៊ុនមួយសម្លេង។មានតែភាគហ៊ុនិកដែលបានចុះឈ្មោះត្រឹមត្រូវនិងបានទូទាត់ប្រាក់គ្រប់ចំនួនទៅឱ្យក្រុមហ៊ុនទើបមានសិទ្ធិបោះឆ្នោតដោយផ្ទាល់ឬដោយអាណត្តិគាហកៈនៅក្នុងមហាសន្និបាតភាគហ៊ុនិក។

ច) ការសម្រេចរបស់ភាគហ៊ុនិកដែលចងភ្ជាប់កាតព្វកិច្ចក្រុមហ៊ុន លុះត្រាតែធ្វើឡើងតាមរយៈសេចក្តីសម្រេចរបស់ភាគហ៊ុនិក។ សេចក្តីសម្រេចរបស់ភាគហ៊ុនិកតម្រូវឱ្យមានការបោះឆ្នោតគាំទ្រយ៉ាងហោចណាស់ដោយសំលេងភាគច្រើននៃភាគហ៊ុនមានសិទ្ធិបោះឆ្នោតដែលកាន់កាប់ដោយភាគហ៊ុនិក និងអាណត្តិគាហកៈនៅក្នុងកិច្ចប្រជុំ ក្នុងករណីសេចក្តីសម្រេចធម្មតា និងក្នុងករណីសេចក្តីសម្រេច ត្រូវធ្វើឡើងដោយសំលេងភាគច្រើនដាច់ខាត គឺមិនតិចជាង ២/៣ (ពីរភាគបី)។ សេចក្តីសម្រេចរបស់ ភាគហ៊ុនិកមិនអាចយកជាការបានឡើយប្រសិនបើមិនគោរពតាមលក្ខខណ្ឌនៃការអនុម័តនេះ។

## ២. ព័ត៌មានអំពីមហាសន្និបាតភាគហ៊ុនិក

មហាសន្និបាទភាគហ៊ុនិកបានធ្វើឡើងកាលពីថ្ងៃទី២៥ខែវិច្ឆិកាឆ្នាំ២០២០ដោយមានភាគហ៊ុននិកភាគច្រើនបានចូលរួម និងបានអនុម័តនូវសេចក្តីសម្រេចដូចខាងក្រោម៖

ក) ការទទួលបានលទ្ធផលអាជីវកម្មប្រចាំឆ្នាំសម្រាប់ឆ្នាំហិរញ្ញវត្ថុបានបញ្ចប់នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០

ខ) អនុម័តលើលាភការ របស់ក្រុមប្រឹក្សាភិបាល

គ) អនុម័តលើការតែងតាំង ក្រុមហ៊ុន ហ្គ្រេន សនថុន (ខេមបូឌា) លីមីធីត សារជាថ្មីជាសវនករបស់ ក្រុមហ៊ុន

ឃ) អនុម័តលើវិសោធនកម្មលក្ខន្តិកៈក្រុមហ៊ុនដោយលុបប្រការ ២៩ ចាស់ទាំងស្រុងនឹងជំនួស ប្រការ ២៩ ថ្មី។

# ឃ. ការបែងចែកភាគលាភ

## ១. គោលការណ៍បែងចែកភាគលាភ

ក្រុមហ៊ុនមានបំណងបែងចែកភាគលាភអប្បបរមាចំនួនសាមសិបភាគរយ (៣០%) នៃប្រាក់ចំណេញរបស់ខ្លួនបន្ទាប់ពីកាត់ពន្ធរួចដោយយោងទៅលើរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ របាយការណ៍សាច់ប្រាក់ ប្រាក់ចំណេញរក្សាទុកចំណាយមូលធន និងកត្តាផ្សេងទៀតដែលក្រុមប្រឹក្សាភិបាលគិតថាជាប់ពាក់ព័ន្ធ។

ក្រុមហ៊ុនអាចពិចារណាបែងចែកភាគលាភជាសាច់ប្រាក់ ជាភាគហ៊ុនសម្រាប់វិនិយោគនៅក្នុងក្រុមហ៊ុន ឬជម្រើស ទាំងពីរបញ្ចូលគ្នា។ នៅពេលមានជម្រើសភាគហ៊ុនិកអាចមានសិទ្ធិជ្រើសរើសយកកាបែងចែកភាគហ៊ុនជាសាច់ប្រាក់ជាភាគហ៊ុនឬជម្រើសទាំងពីរដោយគោរពទៅតាមច្បាប់និងបទប្បញ្ញត្តិតម្រូវនៃព្រះ រាជាណាចក្រកម្ពុជា។

## ២. ព័ត៌មានអំពីការបែងចែកភាគលាភក្នុងរយៈពេល៣ឆ្នាំចុងក្រោយ

ពុំមានការបែងចែកភាគលាភសម្រាប់រយៈពេលបី (៣) ឆ្នាំចុងក្រោយឡើយព្រោះ ផថខ ទើបតែបានចុះបញ្ជីលក់មូលបត្រនៅ ថ្ងៃទី១២ ខែសីហា ឆ្នាំ២០២០។

នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២១ ក្រុមប្រឹក្សាភិបាលបានកំណត់ និងប្រកាសបែងចែកភាគលាភចំនួន 0.00 ៦៥ ដុល្លារអាមេរិក ក្នុងមួយហ៊ុនសម្រាប់ការិយបរិច្ឆេទគិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១។ ភាគលាភអាចនឹងមានការផ្លាស់ប្តូរស្របតាមលទ្ធផលសវនកម្មរបស់សវនករឯករាជ្យ និងសេចក្តីសម្រេចនៃកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក។

# របាយការណ៍អភិបាលកិច្ចប្រចាំឆ្នាំ

## ផ្នែកទី ២- ក្រុមប្រឹក្សាភិបាល

### PAUL LIM PAY CHUAN

### ប្រធានក្រុមប្រឹក្សាភិបាល

| ល.រ. | ឈ្មោះ | មុខតំណែង | កាលបរិច្ឆេទចាប់ផ្តើម | កាលបរិច្ឆេទផុតកំណត់អាណត្តិជាអភិបាល |
|---|---|---|---|---|
| ១ | Paul Lim Pay Chuan | ប្រធានក្រុមប្រឹក្សាភិបាល | ៥ កុម្ភៈ ២០១០ | មិនកំណត់ |
| ២ | Lim Ah Hock | អភិបាល | ៥ កុម្ភៈ ២០១០ | មិនកំណត់ |
| ៣ | Han Fatt Juan | អភិបាលប្រតិបត្តិ /ប្រធាននាយកប្រតិបត្តិ | ២៧ មិថុនា ២០១៨ | មិនកំណត់ |
| ៤ | Charles Tan Pu Hooi | អភិបាល | ២៧ មិថុនា ២០១៨ | មិនកំណត់ |
| ៥ | ជាវ អានសាន | អភិបាលឯករាជ្យ | ២៩ សីហា ២០១៨ | ២៨ សីហា ២០២៣ |

លោក PAUL LIM PAY CHUAN មានសញ្ជាតិម៉ាឡេស៊ី អាយុ៥១ ឆ្នាំ ជាប្រធានក្រុមប្រឹក្សាភិបាលដែលបានតែងតាំងនៅថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១០។ គាត់បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រវិស្វកម្មអគ្គិសនី នៅសាកលវិទ្យាល័យ Mississippi សហ រដ្ឋអាមេរិក (Summa Cum Laude) នៅឆ្នាំ ១៩៩៣។ ក្រោយមកគាត់បានទទួលសញ្ញាបត្រថ្នាក់អនុ បណ្ឌិតវិស្វកម្ម (អគ្គិសនី) ពីសាកលវិទ្យាល័យ Cornell University សហរដ្ឋអាមេរិកក្នុង ឆ្នាំ១៩៩៤ ។ បច្ចុប្បន្នគាត់បានចុះឈ្មោះជាសមាជិកនៃវិទ្យាស្ថានវិស្វករម៉ាឡេស៊ី និងវិស្វករវិជ្ជាជីវៈជាមួយក្រុមប្រឹក្សាភិបាលវិស្វករ ម៉ាឡេស៊ីនៅ ឆ្នាំ២០០៧ ក្នុងវិស័យវិស្វកម្មអគ្គិសនី។ ចាប់តាំងពីឆ្នាំ២០១១ គាត់ក៏ជាអ្នកគ្រប់គ្រងគម្រោងវិជ្ជាជីវៈដែលមានបញ្ជាក់ពីវិទ្យាស្ថានគ្រប់គ្រងគម្រោងសមាគមវិជ្ជាជីវៈសកលដែលមានមូលដ្ឋាននៅសហ រដ្ឋអាមេរិកនិងមានការិយាល័យប្រចាំតំបន់ទូទាំងពិភពលោក។ គាត់បានចុះបញ្ជីជាវិស្វករជំនាញនៃធម្មនុញ្ញអាស៊ានចាប់តាំងពីឆ្នាំ២០១៦។ នៅឆ្នាំ ២០១៧ គាត់បានចុះបញ្ជីនៅក្រោមបញ្ជីឈ្មោះសហប្រតិបត្តិការ សេដ្ឋកិច្ចអាស៊ីប៉ាស៊ីហ្វិក និងបញ្ជីអន្តរជាតិនៃវិស្វករអេជីព និងវិស្វករអាស៊ាន។

នៅឆ្នាំ១៩៩៤ លោកបានចាប់ផ្តើមវិជ្ជាជីវៈជាមួយនឹងក្រុមហ៊ុន Motorola Malaysia Sdn Bhd ក្នុងនាមជាវិស្វករផលិតផលម្នាក់ បន្ទាប់មកនៅឆ្នាំ១៩៩៥ លោកបានចូលរួមជាមួយនឹងក្រុមហ៊ុន Toprank Corporation Sdn Bhd (បច្ចុប្បន្នដែលគេស្គាល់ថាជា ក្រុមហ៊ុន Toshiba Transmission & Distribution System Asia Sdn Bhd) ក្នុងនាមជាវិស្វករគម្រោង ដែលនៅទីនោះលោកត្រូវបានតម្លើងជាប្រធានគម្រោងនៅឆ្នាំ១៩៩៧ និង បន្តបន្ទាប់ក្លាយជាជំនួយការនាយកគ្រប់គ្រងទូទៅនៅឆ្នាំ១៩៩៨។ នៅឆ្នាំ២០០០ លោកបានចូលរួមជាមួយក្រុមហ៊ុនសម្ព័ន្ធផេសចិក ក្នុងតួនាទីជាប្រធានគ្រប់គ្រងទូទៅ និងបានតម្លើងជានាយកប្រតិបត្តិក្នុងឆ្នាំ២០០៨។

លោកបានដើរតួនាទីយ៉ាងសំខាន់ក្នុងដំណើរការរីកចម្រើន និងអភិវឌ្ឍន៍ របស់សម្ព័ន្ធក្រុមហ៊ុនផសចិក ដោយ ចាប់ផ្តើមពីក្រុមហ៊ុនខ្នាតតូចហួតក្លាយជាក្រុមហ៊ុនបច្ចេកវិទ្យាថាមពលអគ្គិសនីនៅក្នុងវិស័យអាជីវកម្ម ចែកចាយ និងបញ្ជូនថាមពល ជាមួយនឹងប្រតិបត្តិការនៅក្នុងប្រទេសម៉ាឡេស៊ី និងបណ្តាប្រទេសជាច្រើនទៀត ។ លោកបានដឹកនាំសម្ព័ន្ធក្រុមហ៊ុនផេសចិកឱ្យមានវត្តមាននៅលើទឹកដីនៃប្រទេស ប៊្រុយណេប៉ាពូហ្គីណេថ្មី ប្រទេសកម្ពុជា ប្រទេសចិន និងប្រទេសស្រីលង្កា និងបន្តយ៉ាងសកម្មក្នុងការរកផុរកិច្ចថ្មីទាំងនៅទីផ្សារក្នុងស្រុក និងបរទេស។

នៅឆ្នាំ២០១០ គាត់ទទួលបានពានរង្វាន់សហគ្រិនឆ្នើមប្រចាំឆ្នាំ២០១០ ដោយសហគ្រាសអាស៊ី ដោយសារការយកចិត្តទុកដាក់ និងភាពជាអ្នកដឹកនាំរបស់គាត់ក្នុងការដឹកនាំក្រុមដើម្បីក្លាយជាតួអង្គសំខាន់ក្នុងអាជីវកម្មបញ្ជូននិងចែកចាយថាមពលក្នុងនិងក្រៅប្រទេស។

# របាយការណ៍អភិបាលកិច្ចប្រចាំឆ្នាំ

## ផ្នែកទី ២- ក្រុមប្រឹក្សាភិបាល

មកដល់បច្ចុប្បន្នបញ្ជីឈ្មោះដឹកនាំដោយ PAUL LIM មានដូចខាងក្រោម៖-

| *បញ្ជីឈ្មោះក្រុមហ៊ុនដឹកនាំ* | | |
|---|---|---|
| *PESTECH International Berhad* | *PESTECH Power One Sdn Bhd* | *BETSOL (Sarawak) Sdn Bhd* |
| *Astoria Solar Farm Sdn Bhd* | *PESTECH REI Sdn Bhd* | *BETSOL International Sdn Bhd* |
| *CRSE Sdn Bhd* | *PESTECH Sdn Bhd* | *BETSOL Sdn Bhd* |
| *Diamond Power Ltd* | *PESTECH Solutions Sdn Bhd* | *Enlightyx Sdn Bhd* |
| *Enersol Co., Ltd* | *PESTECH System Siam Ltd* | *Fornix Biotech Sdn Bhd* |
| *Fornix Sdn Bhd* | *PESTECH Technology Sdn Bhd* | *Fornix Capital Sdn Bhd* |
| *Forward Metal Works Sdn Bhd* | *PESTECH Transmission Sdn Bhd* | *Fornix Foodstuffs Sdn Bhd* |
| *PESTECH (Brunei) Sdn Bhd* | *PESTECH Transmission Ltd* | *Imbiss Sdn Bhd* |
| *PESTECH (Myanmar) Limited* | *PESTECH Vietnam Company Limited* | *JAP Wylis Sdn Bhd* |
| *PESTECH (PNG) Ltd* | *PESTECH Hinthar Corporation Limited* | *Mercula Sdn Bhd* |
| *PESTECH (Sarawak) Sdn Bhd* | *PESTECH Microgrid Co. Ltd* | *PC Wylis Sdn Bhd* |
| *PESTECH Aerotrain Sdn Bhd (formerly known as Power Two Sdn Bhd)* | *PESTECH Power Sdn Bhd* | *Riviera Wylis Sdn Bhd* |
| *PESTECH Energy Sdn Bhd* | *PESTECH Corporation* | *Rock The City Entertainment Sdn Bhd* |
| *PESTECH GTI Sdn Bhd* | *Asiapac Builders Sdn Bhd* | *Wylis Corporation Sdn Bhd* |
| | *Asiapac Machineries Sdn Bhd* | *Wylis Sdn Bhd* |

### LIM AH HOCK

លោក Lim Ah Hock មានសញ្ជាតិម៉ាឡេស៊ី អាយុ៦៩ឆ្នាំ ជា អភិបាលក្រុមហ៊ុន។ លោកត្រូវបានតែងតាំងនៅថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១០។
នៅឆ្នាំ១៩៧៨ លោកបានទទួលបរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រជំនាញវិស្វកម្មមេកានិក (ជ័យលាភីលេខមួយ) ពីសាកលវិទ្យាល័យ Strathclyde ក្រុង Glasgow ប្រទេសអង់គ្លេស។ លោកជាសមាជិកនៃវិទ្យាស្ថានវិស្វករប្រទេសម៉ាឡេស៊ីចាប់តាំងពីឆ្នាំ១៩៨១។

នៅឆ្នាំ១៩៧៩ លោកបានចាប់ផ្តើមវិជ្ជាជីវៈជាសាស្ត្រាចារ្យនៅសាលាបច្ចេកទេស Ngee Ann នៅប្រទេស សិង្ហបុរី (នៅឆ្នាំ១៩៨២ ត្រូវបានប្តូរឈ្មោះជាសាលាពហុបច្ចេកទេស Ngee Ann) ដោយលោកបានទទួល បន្ទុកបង្រៀនមុខវិជ្ជាទែម៉ូឌីណាមិច និងមេកានិចរាវ (thermodynamics and fluid mechanics)។ នៅឆ្នាំ១៩៨០ លោកបានចូលរួមជាមួយក្រុមហ៊ុន Mechmar Kejuruteraan Sdn Bhd (“Mechmar") ក្នុងនាមជា វិស្វករសេវាកម្មដែលនៅទីនោះ លោកគ្រប់គ្រងលើផ្នែកសេវាកម្ម និងការផ្តល់សេវាកម្មក្រោយលក់ និងការជួសជុលម៉ាស៊ីនកម្តៅធំៗ។ បន្ទាប់មកទៀត លោកបានចាកចេញពីក្រុមហ៊ុន Mechmar នៅឆ្នាំ១៩៨៤ និងបានចូលរួមជាមួយនឹងក្រុមហ៊ុន Sing Mah Pressure Vessels Co. ក្នុងនាមជាប្រធានសាខាអំឡុងឆ្នាំ១៩៨៤ និង១៩៨៩ ដែលនៅទីនោះលោកទទួលបន្ទុកក្នុងការលក់ទាំងស្រុងនៅភាគខាងត្បូងរហូតដល់វិស័យឧស្សាហ កម្មចម្រាញ់ដូងប្រេង ចំណីអាហារ និងឧស្សាហកម្មឈើ ក៏ដូចជាឧស្សាហកម្មទាំងឡាយដែលមាននៅភាគខាងត្បូងឧបទ្វីប Sabah និង Sarawak។ នៅឆ្នាំ១៩៨៩ លោកបានក្លាយជាអភិបាលនៃក្រុមហ៊ុន VES- TECH Engineering Sdn Bhd ដល់បច្ចុប្បន្ន។

នៅឆ្នាំ១៩៩១ លោកបានបង្កើតក្រុមហ៊ុន PSB នៅ Johor Bahru ប្រទេសម៉ាឡេស៊ី។ មកទល់បច្ចុប្បន្ន តួនាទីរបស់លោកនៅក្នុងសម្ព័ន្ធក្រុមហ៊ុនផេសថិកគឺទទួលបន្ទុកផ្នែកផែនការអភិវឌ្ឍអាជីវកម្មធំៗតម្រង់ទិសដៅអភិវឌ្ឍម៉ាក្រូអាជីវកម្មជាមួយនាយកប្រតិបត្តិត្រួតពិនិត្យមើលស្ថានភាពហិរញ្ញវត្ថុ និងសកម្មភាពរបស់សម្ព័ន្ធ ក្រុមហ៊ុនផេសថិក ដែលរួមមានផ្តល់ការណែនាំក្នុងការគ្រប់គ្រង និងដឹកនាំបុគ្គលិក។

# របាយការណ៍អភិបាលកិច្ចប្រចាំឆ្នាំ

## ផ្នែកទី ២- ក្រុមប្រឹក្សាភិបាល

មកដល់បច្ចុប្បន្ននេះបញ្ជីឈ្មោះដឹកនាំដោយលោកលីមអាហុកមានដូចខាងក្រោម៖

| *បញ្ជីឈ្មោះក្រុមហ៊ុនដឹកនាំ* | | |
|---|---|---|
| *PESTECH International Berhad*<br>*Astoria Solar Farm Sdn Bhd*<br>*CRSE Sdn Bhd*<br>*Diamond Power Ltd*<br>*Enersol Co., Ltd*<br>*Fornix Sdn Bhd*<br>*Forward Metal Works Sdn Bhd*<br>*PESTECH (Sarawak) Sdn Bhd*<br>*PESTECH Aerotrain Sdn Bhd (formerly known as Power Two Sdn Bhd* | *PESTECH Energy Sdn Bhd*<br>*PESTECH Engineering Technology China Co., Ltd*<br>*PESTECH GTI Sdn Bhd*<br>*PESTECH Hinthar Corporation Limited*<br>*PESTECH Power Sdn Bhd*<br>*PESTECH Power One Sdn Bhd*<br>*PESTECH REI Sdn Bhd*<br>*PESTECH Sdn Bhd* | *PESTECH Solutions Sdn Bhd*<br>*PESTECH System Siam Ltd*<br>*PESTECH Technology Sdn Bhd*<br>*PESTECH Transmission Sdn Bhd*<br>*Asiapac Machineries Sdn Bhd*<br>*Fornix Biotech Sdn Bhd*<br>*Fornix Capital Sdn Bhd*<br>*Fornix Foodstuffs Sdn Bhd*<br>*Vestech Engineering Sdn Bhd* |

**HAN FATT JUAN**

លោក Han Fatt Juan មានសញ្ជាតិម៉ាឡេស៊ី អាយុ៥៦ ឆ្នាំ ជាអភិបាលប្រតិបត្តិ និងជានាយកប្រតិបត្តិរបស់ **ផថខ**។ លោកត្រូវបានតែងតាំងជាក្រុមប្រឹក្សាភិបាលនៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៨។

លោកទទួលបន្ទុកក្នុងការសម្រេចឱ្យបាននូវគោលដៅចំណូល និងចំណេញរបស់ក្រុមហ៊ុនឱ្យស្របតាមគម្រោងអាជីវកម្មរបស់ក្រុមហ៊ុន និងធានាឱ្យបានថាក្រុមហ៊ុនមានគោលដៅផែនការ និងថវិកាដែលតម្រូវដើម្បីសម្រេចគោលដៅហិរញ្ញវត្ថុ និងប្រតិបត្តិការរយៈពេលខ្លី និងរយៈពេលវែងដូចដែលបានកំណត់ទុកក្នុង ផែនការអាជីវកម្មក្រុមហ៊ុន។

នៅឆ្នាំ១៩៨៤ លោកបានចាប់ផ្តើមវិជ្ជាជីវៈជាអ្នកត្រួតពិនិត្យការដ្ឋាននៅក្រុមហ៊ុន Metral Villar Sdn Bhd ដោយទទួលបន្ទុកក្នុងការត្រួតពិនិត្យមើល និងសម្របសម្រួលសកម្មភាពរបស់កម្មករទាក់ទងនឹងការជីក និងការលាយស៊ីម៉ង់។ នៅឆ្នាំ១៩៨៨ លោកបានចាកចេញពីក្រុមហ៊ុនដើម្បីបន្តការសិក្សានៅសាកលវិទ្យាល័យ South Dakota State សហរដ្ឋអាមេរិក។ អំឡុងពេលសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នៅទីនោះ៖ លោកបាន បំពេញការងារជាជំនួយការបង្រៀននៅសាកលវិទ្យាល័យ South Dakota State សហរដ្ឋអាមេរិក។ នៅឆ្នាំ១៩៩២ លោកបានចូលរួមជាមួយក្រុមហ៊ុន Zafas_Sdn Bhd ក្នុងនាមជាវិស្វករការដ្ឋាន និងបានចំណាយពេលនៅទីនោះអស់រយៈពេល១៧ឆ្នាំ រហូតដល់ឆ្នាំ២០០៩ លោកត្រូវបានតម្លើងជានាយកគម្រោង។អំឡុង ពេលបំពេញការងារលោកបានចូលរួមគម្រោងជាច្រើនរួមមានការងារតម្លើងខ្សែកាបក្រោមដី និងខ្សែបណ្តាញបញ្ជូនថាមពលឆ្លងកាត់ប្រទេសម៉ាឡេស៊ី និងប្រទេសប្រ៊ុយណេ។

ក្នុងឆ្នាំ២០០៩ លោកបានចូលរួមជាមួយក្រុមហ៊ុនសម្ព័ន្ធផេសថិក ក្នុងតួនាទីជាប្រធានគម្រោង និង ត្រូវបាន តម្លើងជាប្រធានគ្រប់គ្រងទូទៅ(GM) ក្នុងគម្រោងយុទ្ធសាស្ត្រ (ការអភិវឌ្ឍន៍អាជីវកម្ម) នៅឆ្នាំ ២០១១ ក្រោយមកក្លាយជាប្រធានគ្រប់គ្រងទូទៅផ្នែកបណ្តាញថាមពល និងខ្សែកាបរបស់សម្ព័ន្ធក្រុមហ៊ុនផេសថិក។ ក្នុងនាមជាប្រធានគ្រប់គ្រងទូទៅផ្នែកបណ្តាញថាមពលនិងខ្សែកាបក្រុមរបស់លោកទទួលបន្ទុកការងារកិច្ច សន្យា EPCC ដែលគ្របដណ្តប់លើដំណើរការគ្រប់គ្រងគម្រោងការផ្គត់ផ្គង់គ្រឿងបរិក្ខារ ដំណើរការ ការដ្ឋានសំណង់ និងការតម្លើងបណ្តាញបញ្ជូនថាមពល និងខ្សែកាបក្រោមដី។

មកដល់បច្ចុប្បន្ន លោក Han Fatt Juan ដឹកនាំក្រុមហ៊ុន PESTECH (Myanmar) Ltd ក្រុមហ៊ុន PESTECH Hinthar Corporation Limited ក្រុមហ៊ុន PESTECH Transmission Ltd និងក្រុមហ៊ុន Imbiss Sdn Bhd.

# របាយការណ៍អភិបាលកិច្ចប្រចាំឆ្នាំ

## ផ្នែកទី ២- ក្រុមប្រឹក្សាភិបាល

**HAN FATT JUAN**

លោក Han Fatt Juan មានសញ្ជាតិម៉ាឡេស៊ី អាយុ៥៦ ឆ្នាំ ជាអភិបាលប្រតិបត្តិ និងជានាយកប្រតិបត្តិរបស់ **ផថខ**។ លោកត្រូវបានតែងតាំងជាក្រុមប្រឹក្សាភិបាលនៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៨។
លោកទទួលបន្ទុកក្នុងការសម្រេចឱ្យបាននូវគោលដៅ ចំណូល និងចំណេញរបស់ក្រុមហ៊ុនឱ្យស្របតាមគម្រោងអាជីវកម្មរបស់ក្រុមហ៊ុន និងធានាឱ្យបានថាក្រុមហ៊ុនមានគោលដៅផែនការ និងថវិកាដែលតម្រូវដើម្បីសម្រេចគោលដៅហិរញ្ញវត្ថុ និងប្រតិបត្តិការរយៈពេលខ្លី និងរយៈពេលវែងដូចដែលបានកំណត់ទុកក្នុង ផែនការអាជីវកម្មក្រុមហ៊ុន។

នៅឆ្នាំ១៩៨៤ លោកបានចាប់ផ្តើមវិជ្ជាជីវៈជាអ្នកត្រួតពិនិត្យការដ្ឋាននៅក្រុមហ៊ុន Metral Villar Sdn Bhd ដោយទទួលបន្ទុកក្នុងការត្រួតពិនិត្យមើល និងសម្របសម្រួលសកម្មភាពរបស់កម្មករទាក់ទងនឹងការដឹក និងការលាយស៊ីម៉ង់។ នៅឆ្នាំ១៩៨៨ លោកបានចាកចេញពីក្រុមហ៊ុនដើម្បីបន្តការសិក្សានៅសាកលវិទ្យាល័យ South Dakota State សហរដ្ឋអាមេរិក។ អំឡុងពេលសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នៅទីនោះ លោកបានបំពេញការងារជាជំនួយការបង្រៀននៅសាកលវិទ្យាល័យ South Dakota State សហរដ្ឋអាមេរិក។ នៅឆ្នាំ១៩៩២ លោកបានចូលរួមជាមួយក្រុមហ៊ុន Zafas_Sdn Bhd ក្នុងនាមជាវិស្វករការដ្ឋាន និងបានចំណាយ ពេលនៅទីនោះអស់រយៈពេល១៧ឆ្នាំ រហូតដល់ឆ្នាំ២០០៩ លោកត្រូវបានតម្លើងជានាយកគម្រោង។ អំឡុង ពេលបំពេញការងារ លោកបានចូលរួមគម្រោងជាច្រើនរួមមានការងារតម្លើងខ្សែកាបក្រោមដី និងខ្សែ បណ្តាញបញ្ជូនថាមពលឆ្លងកាត់ប្រទេសម៉ាឡេស៊ី និងប្រទេសប្រ៊ុយណេ។

ក្នុងឆ្នាំ២០០៩ លោកបានចូលរួមជាមួយក្រុមហ៊ុនសម្ព័ន្ធផេសថិក ក្នុងតួនាទីជាប្រធានគម្រោង និង ត្រូវបាន តម្លើងជាប្រធានគ្រប់គ្រងទូទៅ(GM) ក្នុងគម្រោងយុទ្ធសាស្ត្រ (ការអភិវឌ្ឍន៍អាជីវកម្ម) នៅឆ្នាំ២០១១ ក្រោយមកក្លាយជាប្រធានគ្រប់គ្រងទូទៅផ្នែកបណ្តាញថាមពល និងខ្សែកាបរបស់សម្ព័ន្ធក្រុមហ៊ុនផេសថិក។ ក្នុងនាមជាប្រធានគ្រប់គ្រងទូទៅផ្នែកបណ្តាញថាមពលនិងខ្សែកាបក្រុមរបស់លោកទទួលបន្ទុកការងារកិច្ច សន្យា EPCC ដែលគ្របដណ្តប់លើដំណើរការគ្រប់គ្រងគម្រោងការផ្គត់ផ្គង់គ្រឿងបរិក្ខារដំណើរការ ការដ្ឋាន សំណង់ និងការតម្លើងបណ្តាញបញ្ជូនថាមពល និងខ្សែកាបក្រោមដី។

មកដល់បច្ចុប្បន្ន លោក Han Fatt Juan ដឹកនាំក្រុមហ៊ុន PESTECH (Myanmar) Ltd ក្រុមហ៊ុន PESTECH Hinthar Corporation Limited ក្រុមហ៊ុន PESTECH Transmission Ltd និងក្រុមហ៊ុន Imbiss Sdn Bhd.

**CHARLES TAN PU HOOI**

Charles Tan សញ្ជាតិម៉ាឡេស៊ី អាយុ៥០ឆ្នាំ មានតួនាទីជាអភិបាលប្រតិបត្តិរបស់ ផថខ លោកបានតែងតាំងក្នុងក្រុមប្រឹក្សាភិបាលនៅថ្ងៃទី ២៧ ខែមិថុន ឆ្នាំ២០១៨។ លោកទទួលបន្ទុកផ្នែករៀបចំ និងអនុវត្តកិច្ច ការអាជីវកម្មផ្សេងៗមានដូចជា ការបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូងការបោះផ្សាយលក់មូលបត្របំណុល ការបំបែកមូលបត្រ(share split) ផែនការបែងចែកភាគហ៊ុន (share grant plant) ព្រម ទាំងការបង្កើតនិងការអនុវត្តនូវសកម្មភាពកៀរគរមូលធន។

ចាប់តាំងពីឆ្នាំ១៩៩៧ លោកមានបទពិសោធន៍លើផ្នែកហិរញ្ញវត្ថុសាជីវកម្មយ៉ាងទូលំទូលាយដោយលោកបានធ្វើការជាមួយនឹងធនាគារវិនិយោគនៅប្រទេសម៉ាឡេស៊ី និងជាសហស្ថាបនិកនៃក្រុមហ៊ុនប្រឹក្សាហិរញ្ញ វត្ថុសាជីវកម្មមួយដែលទទួលស្គាល់ដោយគណៈកម្មការមូលបត្រនៃប្រទេសម៉ាឡេស៊ី។

លោកទទួលបានគុណវុឌ្ឍផ្នែកហិរញ្ញវត្ថុសាជីវកម្មដែលទទួលស្គាល់ដោយវិទ្យាស្ថានគណនេយ្យករជំនាញ (Institute of Chartered Accountants) នៅប្រទេសអង់គ្លេស និងប្រទេសវ៉េល (ICAEW) និងជាសមាជិក សមាគមផែនការហិរញ្ញវត្ថុ (Financial Planning Association) នៃប្រទេសម៉ាឡេស៊ី (FPAN")។

មកដល់បច្ចុប្បន្ន លោកបានដឹកនាំក្រុមហ៊ុនមួយចំនួនដូចជា ក្រុមហ៊ុន ដាយអឹម៉ិន ផៅវ័រ លីមីធីត ក្រុមហ៊ុន PESTECH (PNG) Ltd. ក្រុមហ៊ុន PESTECH System Siam Ltd ក្រុមហ៊ុន Fornix Biotech Sdn Bhd ក្រុមហ៊ុន Fornix Foodstuffs Sdn Bhd និងក្រុមហ៊ុន PESTECH Corporation.

### ដាវ អានសាន

លោក ដាវ អានសាន មានសញ្ជាតិខ្មែរ អាយុ ៤២ ឆ្នាំ ជាអភិបាលឯករាជ្យដែលបានតែងតាំង ២៩ ខែសីហា ឆ្នាំ២០១៨។ លោកជាសារការី និងជាអនុប្រធានប្រចាំទីសារការី សេដ្ឋាវិទូ ចាប់ពីឆ្នាំ២០១៤។ លោក មានបទពិសោធន៍ការងារជាង ១០ ឆ្នាំក្នុងវិស័យច្បាប់ នយោបាយសង្គម និងសេដ្ឋកិច្ច។ លោកមានឯកទេសខាងគម្រោង និងហិរញ្ញវត្ថុសាជីវកម្ម។ មុនពេលចូលរួមជាមួយមន្ទីរសារការី សេដ្ឋាវិទូ លោកជាអ្នកអនុវត្ត ច្បាប់នៅការិយាល័យសហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ .ត.ក) ពី ឆ្នាំ២០០៩ ដល់ ២០១៣។ មុនពេលចូលរួមជាមួយ អ.វ.ត.ក ជាអ្នកផ្តល់ប្រឹក្សា និងអ្នកស្រាវជ្រាវនៅស្ថានទូតសាធារណរដ្ឋកូរ៉េប្រចាំប្រទេសកម្ពុជា និងនៅស្ថាប័នស្រាវជ្រាវសាធារណៈនៃរដ្ឋាភិបាលកម្ពុជាក្នុងវិ ស័យផ្នែកច្បាប់តស៊ូមតិ សេដ្ឋកិច្ចពាណិជ្ជកម្ម

# របាយការណ៍អភិបាលកិច្ចប្រចាំឆ្នាំ

## ផ្នែកទី ២- ក្រុមប្រឹក្សាភិបាល

ឆ្លងដែន និងផ្នែកអាជីវកម្ម ( Business Enabling Environm ent )។ លោកក៏ជាសាស្ត្រាចារ្យនៅសាកលវិទ្យាល័យរដ្ឋ និងឯកជនមួយចំនួនក្នុងរាជធានីភ្នំពេញ ផងដែរចាប់ ពី ឆ្នាំ២០០៣ ដល់ ឆ្នាំ២០១៣។

លោក ដាវ អានសាន ជាទីប្រឹក្សារបស់សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។ លោកក៏ជាសមាជិកនៃគណកម្មការកណ្តាលនៃសហភាពសហព័ន្ធកម្ពុជាដែលជាអង្គការមិនមែនរដ្ឋាភិបាល ដែលដឹកនាំដោយ ឯកឧត្តម ហ៊ុន ម៉ានី ដែលជាសមាជិកនៃរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

លោក ដាវ អានសាន ទទួលបានបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកសេដ្ឋកិច្ចនយោបាយពីសាកលវិទ្យាល័យ Williams College, Massachusetts សហរដ្ឋអាមេរិកក្នុងឆ្នាំ២០០៩ និងបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកអភិវឌ្ឍន៍សេដ្ឋកិច្ចពី រាជបណ្ឌិត្យសភាកម្ពុជាក្នុងឆ្នាំ២០០៣។

លោកនិយាយភាសាខ្មែរដែលជាភាសាកំណើត ភាសាអង់គ្លេសកម្រិតខ្ពស់ ហើយគាត់អាចទំនាក់ទំនងជាភាសាបារាំងផងដែរ។ មកដល់បច្ចុប្បន្ន លោក ដាវ អានសាន ក៏បានដឹកនាំមន្ទីរសារការី សេដ្ឋាវិទូ និង Propey Microfinance Plc ផងដែរ។

### តួនាទី ភារកិច្ច ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល និងការអនុវត្ត

ទំនួលខុសត្រូវចម្បងរបស់ក្រុមប្រឹក្សាភិបាលផ្អែកលើការវាយតម្លៃដែលបានកំណត់ជាមុនលើភាពពាក់ព័ន្ធនា នាដូចជា ការផ្តល់ទិសដៅយុទ្ធសាស្ត្រ ការកំណត់កត្តាហានិភ័យចម្បងៗ និងសូចនាករសំខាន់ៗ ប្រតិបត្តិការ ធុរៈកិច្ចរបស់ក្រុមហ៊ុន ការតាមដានការសម្រេចចិត្តលើការវិនិយោគ ការពិចារណាលើកិច្ចការហិរញ្ញវត្ថុសំ ខាន់ៗ និងការពិនិត្យឡើងវិញនូវលទ្ធផលការងាររបស់គណៈគ្រប់គ្រងទាក់ទងនឹងផែនការអាជីវកម្មថវិកា និងស្តង់ដាឧស្សាហកម្ម។

ក្រុមប្រឹក្សាភិបាលត្រូវទទួលខុសត្រូវឱ្យបានច្បាស់លាស់លើការងារគ្រប់គ្រងក្រុមហ៊ុន និងបំពេញកាតព្វកិច្ចរបស់ខ្លួនក្រុមប្រឹក្សាភិបាលត្រូវទទួលខុសត្រូវលើកិច្ចការដូចខាងក្រោម៖

( ក ) រក្សាគ្រប់គ្រងក្រុមហ៊ុនទាំងស្រុងប្រកបដោយប្រសិទ្ធភាព និងតាមដានគណៈ គ្រប់គ្រងក្នុងការអនុវត្ត ផែនការ និងយុទ្ធសាស្ត្ររបស់ក្រុមប្រឹក្សា
( ខ ) ធានាថាប្រព័ន្ធ គោលការណ៍និងនីតិវិធីគ្រប់ជ្រុងជ្រោយត្រូវបានដំណើរការ
( គ ) កំណត់ និងតាមដានការងារមិនមែនហិរញ្ញវត្ថុដែលទាក់ទងនឹងអាជីវកម្ម
( ឃ ) ត្រូវធានាថាមានក្រមសីលធម៌ អនុលោមទៅតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ ការធ្វើសវនកម្មគោល ការណ៍ និងគណនេយ្យ ការគ្រប់គ្រងឯកសារ និងក្រមសីលធម៌វិជ្ជាជីវៈរបស់ក្រុមហ៊ុន
( ង ) ខិតខំអនុវត្តសកម្មភាពខាងលើ និងឱ្យលើសពីតម្រូវការអប្បបរមា និងដើម្បីប្រកួតប្រជែងនឹងការអនុវត្តស្តង់ដាអន្តរជាតិ មិនត្រឹមតែការអនុវត្តទេ ប៉ុន្តែត្រូវធ្វើឱ្យបាន។
( ច ) កំណត់នូវកម្រិតនៃភាពជាសារ័ន្តដោយរក្សាអំណាចរបស់ក្រុមប្រឹក្សាភិបាលនិងធ្វើប្រតិភូកិច្ចការផ្សេងទៀតចាំបាច់ត្រូវមានលិខិតផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរទៅឱ្យគណៈគ្រប់គ្រង និងបង្កើតយន្តការប្រ កបដោយប្រសិទ្ធភាពដែលធានានូវទំនួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើការអនុវត្តមុខងាររបស់ខ្លួន
( ឆ ) ធ្វើសកម្មភាពប្រកបដោយការទទួលខុសត្រូវចំពោះភាគីពាក់ព័ន្ធនានារបស់ក្រុមហ៊ុន និង
( ជ ) យល់ដឹង និងប្តេជ្ញាចិត្តអនុវត្តឱ្យបាននូវគោលការណ៍សំខាន់ៗស្តីពីអភិបាលកិច្ចសាជីវកម្មល្អដែលអនុលោមតាមគោលការណ៍អភិបាលកិច្ចសាជីវកម្មក្រុមហ៊ុនដោយត្រូវត្រួតពិនិត្យឡើងវិញឱ្យបានទៀតទាត់

ក្រុមប្រឹក្សាភិបាលត្រូវចងចាំពីសារៈសំខាន់នៃការវាយតម្លៃលើប្រសិទ្ធភាពរបស់រាល់អភិបាលនីមួយៗទាំង ក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការរបស់ខ្លួន។ ក្រុមប្រឹក្សាភិបាលដោយមានជំនួយពីគណៈកម្មាធិការតែងតាំង និងលាភការត្រូវពិនិត្យ និងវាយតម្លៃលើការប្រតិបត្តិរបស់ក្រុមប្រឹក្សាភិបាលគណៈកម្មាធិការក្រុមប្រឹក្សាភិបាល និងអភិបាលនីមួយៗរួមទាំងការវាយតម្លៃលើអភិបាលឯករាជ្យជារៀងរាល់ឆ្នាំ។

### កិច្ចប្រជុំក្រុមប្រឹក្សាភិបាល

ចាប់ពីកាលបរិច្ឆេទចុះបញ្ជីលក់មូលបត្រថ្ងៃទី១២ ខែសីហា ឆ្នាំ២០២០ រហូតដល់ឆ្នាំហិរញ្ញវត្ថុបញ្ចប់នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ មានកិច្ចប្រជុំក្រុមប្រឹក្សាភិបាលចំនួនបី ( ៣ )

# របាយការណ៍អភិបាលកិច្ចប្រចាំឆ្នាំ

## ផ្នែកទី ២- ក្រុមប្រឹក្សាភិបាល

លើកដែលអភិបាលគ្រប់រូបបានចូលរួមជាគណៈ កម្មាធិការ និងកិច្ចប្រជុំក្រុមប្រឹក្សាដូចខាងក្រោម៖

| ល.រ | កាលបរិច្ឆេទ | ប្រភេទកិច្ចប្រជុំ |
|---|---|---|
| ១ | ២៥ វិច្ឆិកា ២០២០ | កិច្ចប្រជុំក្រុមប្រឹក្សាភិបាល<br>អភិបាលប្រតិបត្តិ /ប្រធាននាយកប្រតិបត្តិ<br>កិច្ចប្រជុំគណៈកម្មាធិការសវនកម្ម<br>កិច្ចប្រជុំគណៈកម្មាធិការគ្រប់គ្រងហានិភ័យ<br>កិច្ចប្រជុំគណៈកម្មាធិការតែងតាំង និងលាភការ |
| ២ | ៥ កុម្ភៈ ២០២១ | កិច្ចប្រជុំក្រុមប្រឹក្សាភិបាល<br>កិច្ចប្រជុំគណៈកម្មាធិការសវនកម្ម |
| ៣ | ១០ ឧសភា ២០២១ | កិច្ចប្រជុំក្រុមប្រឹក្សាភិបាល<br>កិច្ចប្រជុំគណៈកម្មាធិការសវនកម្ម<br>កិច្ចប្រជុំគណៈកម្មាធិការតែងតាំង និងលាភការ |

## គណៈកម្មាធិការក្រុមប្រឹក្សាភិបាល

គណៈកម្មាធិការសវនកម្ម

| ល.រ | ឈ្មោះ | តំណែង | កាលបរិច្ឆេទតែងតាំង | ចំនួននៃការចូលរួមកិច្ចប្រជុំ | ចំនួនកិច្ចប្រជុំសរុប |
|---|---|---|---|---|---|
| ១ | ដាវ់ អានសាន | អភិបាលឯករាជ្យ | ២៩ សីហា ២០១៨ | ៣ | ៣ |
| ២ | Han Fatt Juan | ប្រធានក្រុមប្រឹក្សាភិបាល | ២៩ សីហា ២០១៨ | ៣ | |
| ៣ | Charles Tan Pu Hooi | អភិបាល | ២៩ សីហា ២០១៨ | ៣ | |

តួនាទី និងភារកិច្ចរបស់ គណៈកម្មាធិការសវនកម្ម៖

I. ត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុ
II. ត្រួតពិនិត្យការគ្រប់គ្រងផ្ទៃក្នុង
III. ត្រួតពិនិត្យការធ្វើសវនកម្មផ្ទៃក្នុង
IV. ត្រួតពិនិត្យការធ្វើសវនកម្មខាងក្រៅ និង
V. រាយការណ៍ពីសកម្មភាពនៃគណៈកម្មាធិការជូនប្រធានក្រុមប្រឹក្សាភិបាល

គណៈកម្មាធិការតែងតាំង និងលាភការ

| ល.រ | ឈ្មោះ | តំណែង | កាលបរិច្ឆេទតែងតាំង | ចំនួននៃការចូលរួមកិច្ចប្រជុំ | ចំនួនកិច្ចប្រជុំសរុប |
|---|---|---|---|---|---|
| ១ | ដាវ់ អានសាន | អភិបាលឯករាជ្យ | ២៩ សីហា ២០១៨ | ១ | ១ |
| ២ | Lim Ah Hock | អភិបាល | ២៩ សីហា ២០១៨ | ១ | |
| ៣ | Charles Tan Pu Hooi | អភិបាល | ២៩ សីហា ២០១៨ | ១ | |

# របាយការណ៍អភិបាលកិច្ចប្រចាំឆ្នាំ

## ផ្នែកទី ២- ក្រុមប្រឹក្សាភិបាល

តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការតែងតាំង និងលាភការ

I. ត្រួតពិនិត្យ និងវាយតម្លៃលើគុណវុឌ្ឍិរបស់បេក្ខជនសម្រាប់តួនាទីជាអភិបាល ឬបុគ្គលិកជាន់ខ្ពស់ដែលត្រូវបានចាត់តាំងដោយប្រធានក្រុមប្រឹក្សាភិបាល
II. ពិនិត្យផ្តល់អនុសាសន៍លើប្រាក់បំណាច់ លាភការរបស់អភិបាល បុគ្គលិកជាន់ខ្ពស់ និង
III. ពិនិត្យធ្វើបច្ចុប្បន្នភាពយន្តការ វាយតម្លៃប្រសិទ្ធភាពនៃប្រធានក្រុមប្រឹក្សាភិបាល អភិបាល និងគណៈ កម្មាធិការនានាយ៉ាងតិច ១ ដងក្នុងមួយឆ្នាំ

### គណៈកម្មាធិការគ្រប់គ្រងហានិភ័យ

| ល.រ | ឈ្មោះ | តំណែង | កាលបរិច្ឆេទតែងតាំង | ចំនួននៃការចូលរួមកិច្ចប្រជុំ | ចំនួនកិច្ចប្រជុំសរុប |
|---|---|---|---|---|---|
| ១ | ដាវ អានសាន | អភិបាលឯករាជ្យ | ២៩ សីហា ២០១៨ | ២ | ២ |
| ២ | Paul Lim Pay Chuan | ប្រធានក្រុមប្រឹក្សាភិបាល | ២៩ សីហា ២០១៨ | ២ | |
| ៣ | Han Fatt Juan | អភិបាលប្រតិបត្តិ/ ប្រធាននាយកប្រតិបត្តិ | ២៩ សីហា ២០១៨ | ២ | |

តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការគ្រប់គ្រងហានិភ័យ

I. វិភាគហានិភ័យ រួមទាំងបរិយាយហានិភ័យ កំណត់ហានិភ័យ និងព្យាករណ៍ហានិភ័យ
II. វាយតម្លៃហានិភ័យ
III. រាយការណ៍ពីហានិភ័យ
IV. ដោះស្រាយហានិភ័យនិង
V. តាមដានត្រួតពិនិត្យហានិភ័យ

### លាភការ ឬ ប្រាក់បំណាច់

គោលនយោបាយសង្ខេបស្តីពីលាភការ ឬប្រាក់បំណាច់សម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់

(ក) ប្រធានក្រុមប្រឹក្សាភិបាលជាអ្នកស្នើនិងផ្តល់អនុសាសន៍អំពីទំហំនៃលាភការដែលត្រូវផ្តល់ឱ្យអភិបាល និងស្នើសុំការសម្រេចពីភាគហ៊ុនិកនៅក្នុងកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក។
(ខ) ទំហំ និងការប៉ះប៉ូវលាភការត្រូវតែមានចំនួនសមល្មម ដើម្បីទាក់ទាញ និងរក្សាសមាសភាពសមាជិកក្រុមប្រឹក្សាភិបាលដែលត្រូវការជាចាំបាច់ ក្នុងការដំណើរការក្រុមហ៊ុនឱ្យបានជោគជ័យ
(គ) អភិបាលមិនប្រតិបត្តិ ពុំទទួលបានភាគហ៊ុន ឬផលប្រយោជន៍ផ្សេងៗ ក្រៅពីប្រាក់កម្រៃជាអភិបាលមិនប្រតិបត្តិ និងប្រាក់ឧបត្ថម្ភ សម្រាប់កិច្ចប្រជុំដែលពួកគាត់បានចូលរួម។
(ឃ) សមាជិកប្រតិបត្តិ ពុំទទួលបានប្រាក់កម្រៃឡើយ ប៉ុន្តែទទួលបានប្រាក់បៀវត្សរ៍ក្នុងនាមជានិយោជិតរបស់ក្រុមហ៊ុនដោយយោងទៅតាមកិច្ចសន្យាការងាររបស់ពួកគេជាមួយនឹងក្រុមហ៊ុន។
(ង) គោលនយោ បាយលាភការ និងកញ្ចប់លាភការសម្រាប់សមាជិកក្រុមប្រឹក្សាភិបាលនីមួយៗ ត្រូវមាននីតិវិធីច្បាស់លាស់ និងប្រកបដោយតម្លាភាព។
(ច) អភិបាលមិនត្រូវជជែកវែកញែក និងបោះឆ្នោតទាក់ទងនឹងកញ្ចប់លាភការរបស់ខ្លួនក្នុងកិច្ចប្រជុំក្រុម ប្រឹក្សាភិបាល ឬកិច្ចប្រជុំគណៈកម្មាធិការឡើយ។

## បុគ្គលទទួលលាភការ ឬប្រាក់បំណាច់

| ល.រ | បុគ្គលទទួលបានលាភការ ឬប្រាក់បំណាច់ | ចំនួនលាភការ ឬប្រាក់បំណាច់ (គិតជាដុល្លារ) | ផ្សេងៗ |
|---|---|---|---|
| ១ | អភិបាល | ៣៩៤ ១១៩,៤១ | - |
| ២ | បុគ្គលិកដែលទទួលបានលាភការ ឬប្រាក់បំណាច់ខ្ពស់បំផុត ៥ រូប | ២៣៤ ៥៥៥,១៩ | - |

## ការវាយតម្លៃលទ្ធផលប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាភិបាលអភិបាល គណៈកម្មាធិការ និងនាយកប្រតិបត្តិ

| ល.រ | បរិយាយ | ដំណើរការនៃការវាយតម្លៃ | លក្ខណៈវិនិច្ឆ័យ |
|---|---|---|---|
| ១ | ក្រុមប្រឹក្សាភិបាល | ការវាយតម្លៃលើខ្លួនឯងបានធ្វើឡើងដោយយោងលើការវិនិច្ឆ័យ ឬ គូសធីក បាទ/ចាស ឬទេ ដូចខាងក្រោមៈ<br>១. ខ្សោយ<br>២. តម្រូវឱ្យមានការ ពង្រឹងបន្ថែម<br>៣. គ្រប់គ្រាន់<br>៤. ល្អសមរម្យ<br>៥. ខ្លាំង | ការអនុវត្តរបស់ក្រុមប្រឹក្សាភិបាល និងការវាយតម្លៃពីខ្លួនឯងបានអនុវត្តសម្រាប់ ឆ្នាំហិរញ្ញវត្ថុ ៣០ មិថុនា ២០២១ ដើម្បីវាយតម្លៃកម្រិតនៃ ការរួមចំណែកអន្តរ កម្ម គុណភាពនៃការចូលរួម យល់ដឹងអំពីតួនាទី របស់នាយក និងប្រធានក្រុមប្រឹក្សាភិបាល។ |
| ២ | អភិបាល | | ការអនុវត្តរបស់ក្រុមប្រឹក្សាភិបាល និងការវាយតម្លៃ ពីខ្លួនឯងបានអនុវត្តសម្រាប់ឆ្នាំហិរញ្ញវត្ថុ ៣០ មិថុនា ២០២១ ដើម្បីវាយតម្លៃកម្រិតនៃការរួមចំណែកអន្តរ កម្ម គុណភាពនៃការចូលរួម យល់ដឹងអំពីតួនាទី របស់នាយក និងប្រធានក្រុមប្រឹក្សាភិបាល។ |
| ៣ | គណៈកម្មាធិការ | | ការវាយតម្លៃរបស់គណៈកម្មាធិការសវនកម្មបានធ្វើឡើងសម្រាប់ឆ្នាំហិរញ្ញវត្ថុដែលបានបញ្ចប់នៅថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០២១ ដើម្បីវាយតម្លៃគុណភាព សមាសភាព ជំនាញ សមត្ថភាព ការប្រជុំរដ្ឋបាល ការប្រព្រឹត្ត ភារកិច្ច និងការទទួលខុសត្រូវ សវនកម្មខាងក្រៅ និងសវនកម្មផ្ទៃក្នុង |
| ៤ | នាយកប្រតិបត្តិ | | ការវាយតម្លៃសម្រាប់នាយកប្រតិបត្តិបានរួមបញ្ចូលនៅក្នុងការបំពេញតួនាទីរបស់ក្រុមប្រឹក្សាភិបាល និងការវាយតម្លៃពីខ្លួនឯងដែលការវាយតម្លៃបានធ្វើឡើងពាក់ព័ន្ធនឹងកម្រិតនៃការរួមចំណែកក្នុងអន្តរកម្ម គុណភាពនៃការចូលរួម យល់ដឹងអំពីតួនាទីរបស់ អភិបាល និងប្រធានក្រុមប្រឹក្សាភិបាល។ |

គណៈកម្មាធិការតែងតាំង និងលាភការបានសម្តែងការពេញចិត្តដល់ការបំពេញតួនាទីរបស់ក្រុមប្រឹក្សាភិបាល អភិបាល គណៈកម្មាធិការ និងនាយកប្រតិបត្តិ។

## ការបណ្តុះបណ្តាលសម្រាប់អភិបាល

ក្រុមប្រឹក្សាភិបាលដោយមានជំនួយពីគណៈកម្មាធិការតែងតាំង និងលាភការត្រូវកំណត់ពីវគ្គបណ្តុះ បណ្តាល ដែលចាំបាច់ដល់អភិបាលយោងតាមការវាយតម្លៃប្រចាំឆ្នាំនៃក្រុមប្រឹក្សាភិបាលគណៈកម្មាធិការក្រុមប្រឹក្សា ភិបាល និងអភិបាលម្នាក់ៗដើម្បីកំណត់ប្រភេទនៃការបណ្តុះបណ្តាលដែលតម្រូវសម្រាប់អភិបាលម្នាក់ៗ។ កម្មវិធីអប់រំបន្តនេះនឹងត្រូវទទួលរងបន្ទុកចំណាយដោយក្រុមហ៊ុន។

# របាយការណ៍អភិបាលកិច្ចប្រចាំឆ្នាំ

## ផ្នែកទី ២- ក្រុមប្រឹក្សាភិបាល

អំឡុងឆ្នាំហិរញ្ញវត្ថុ អភិបាល និងបុគ្គលិកជាន់ខ្ពស់បានចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាលដូចខាងក្រោម៖

| ល.រ | បរិយាយ | ដំណើរការនៃការវាយតម្លៃ | លក្ខណៈវិនិច្ឆ័យ |
|---|---|---|---|
| ១ | Paul Lim Pay Chuan | ប្រធានក្រុមប្រឹក្សាភិបាលប្រតិបត្តិ | • វគ្គបណ្តុះបណ្តាលបច្ចេកទេសពន្លឺព្រះអាទិត្យខ្នាតតូចតាមប្រព័ន្ធ online<br>• គោលនយោបាយប្រឆាំងអំពើសូកប៉ាន់ និងពុករលួយ វគ្គបណ្តុះបណ្តាល គោលការណ៍ណែនាំ និងនីតិវិធី<br>• ស៊េរីទស្សនវិស័យវិនិយោគ-ការវិភាគលើការបោះ ឆ្នោតនៅសហរដ្ឋអាមេរិក និងផលប៉ះពាល់ទីផ្សារ<br>• ស៊េរីទស្សនវិស័យវិនិយោគ-ការវិភាគលើការបោះឆ្នោតនៅសហរដ្ឋអាមេរិក និងផលប៉ះពាល់ទីផ្សារ<br>• ផ្តល់ថាមពលដល់អាជីវកម្មរបស់អ្នកជាមួយថាមពលនិ រន្តរភាពនៅប្រទេសម៉ាឡេស៊ី<br>• ការធ្វើបច្ចុប្បន្នភាពក្រុមហ៊ុន-សន្និសីទនៃទិវាសាជីវកម្ម ខ្នាតតូច<br>• ការធ្វើបច្ចុប្បន្នភាពលើការអនុវត្តរបស់ក្រុមហ៊ុន និងកិច្ចសង្ខេបខ្លីនៃបច្ចេកវិទ្យា<br>• វេទិកាថ្នាក់ខ្ពស់សម្រាប់ RCEP កិច្ចសហប្រតិបត្តិការ សេដ្ឋកិច្ច និងពាណិជ្ជកម្ម<br>• មហាសន្និបាទប្រចាំឆ្នាំ HSBC លើកទី៨ របស់ចិន៖ តម្រូវការបច្ចេកវិទ្យា និងបញ្ហាប្រឈមរបស់ចិន<br>• មហាសន្និបាទប្រចាំឆ្នាំ HSBC លើកទី៨ របស់ចិន៖ ស្តីពីប្រឆាំងភាពផ្តាច់មុខរបស់ចិន<br>• មហាសន្និបាទប្រចាំឆ្នាំ HSBC លើក ទី៨ របស់ចិន៖ ស្តីពីលោកខាងកើតប្រឆាំងនឹងលោកខាងលិច-ការចែករំលែកនៃគណៈវិនិយោគិន<br>• មហាសន្និបាទប្រចាំឆ្នាំ HSBC លើកទី៨ របស់ចិន៖<br>• មហាសន្និបាទប្រចាំឆ្នាំ HSBC លើកទី៨ របស់ចិន៖ C-Suite Dialogue: Symphony Communication CEO Regenerating Our Tomorrow៖ លើប្រធានបទការបង្កើតលោកនៃការផ្លាស់ប្តូរ<br>• ព័ត៌មានប្រចាំសប្តាហ៍នៃប្រទេសប្រចាំតំបន់អាស៊ាន ២០២១ នៃធនាគារមេយប៉ែង៖ យុទ្ធសាស្រ្តទីផ្សារ និងទស្សនវិស័យសេដ្ឋកិច្ចរៀតណាម ត្រៀមខ្លួនសម្រាប់ សង្គមជំនាន់ក្រោយ<br>• ក្រុមអភិបាលកិច្ចសាជីវកម្ម ប្រទេសម៉ាឡេស៊ី (“ MCCG” ) ការពិនិត្យឡើងវិញ ឆ្នាំ ២០២១៖ ប្រធានបទផលប៉ះពាល់សំខាន់ និងរបៀបផ្លាស់ប្តូរកាន់តែប្រសើរ |
| ២ | Lim Ah Hock | អភិបាល | • និរន្តរភាពវិនិយោគ និងការទទួលខុសត្រូវស៊េរី ២០២១ ភាគ ២៖ ការរួមបញ្ចូល Sri ការសម្រេចចិត្តវិនិយោគ<br>• គោលនយោបាយប្រឆាំងអំពើសូកប៉ាន់ និងពុករលួយ វគ្គបណ្តុះបណ្តាល គោលការណ៍ណែនាំ និងនីតិវិធី |
| ៣ | Han Fatt Juan | នាយកប្រតិបត្តិ | • គោលនយោបាយប្រឆាំងអំពើសូកប៉ាន់ និងពុករលួយ វគ្គបណ្តុះបណ្តាល គោលការណ៍ណែនាំ និងនីតិវិធី |
| ៤ | Charles Tan Pu Hooi | អភិបាល | • ផលប្រយោជន៍ ៤.០៖ ការប្រើប្រាស់បំលែងឌីជីថល<br>• គោលនយោបាយប្រឆាំងអំពើសូកប៉ាន់ និងពុករលួយ វគ្គបណ្តុះបណ្តាល គោលការណ៍ណែនាំ និងនីតិវិធី |
| ៥ | ដាវ អានសាន | អភិបាលឯករាជ្យ | • ការបំលែងឌីជីថល<br>• ការអភិវឌ្ឍន៍គោលនយោបាយវិទ្យាសាស្រ្តបច្ចេកវិទ្យានិងនវានុវត្តន៍ (“STI” )<br>• វិធីឆ្ពោះទៅរកការប្តូរបច្ចេកវិទ្យា<br>• សារៈសំខាន់នៃកាយរឹទ្ធិបច្ចេកវិទ្យា<br>• Alternative Binders to Portland Cement<br>• ទំនាក់ទំនងសាជីវកម្ម<br>• The Inevitably of Robotics AI<br>• ការស្រាវជ្រាវ និងអភិវឌ្ឍន៍ STI |

# របាយការណ៍អភិបាលកិច្ចប្រចាំឆ្នាំ

## ផ្នែកទី ៣- ការអនុវត្តក្រមសីលធម៌សម្រាប់ការអនុវត្តធុរកិច្ច

**ក. គោលនយោបាយពាក់ព័ន្ធនឹងក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ចរបស់អភិបាល និងបុគ្គលិកជាន់ខ្ពស់**

- ទំនាស់ផលប្រយោជន៍
- ការធ្វើធុរកិច្ច និងការ ប្រកួតប្រជែងដោយស្មោះត្រង់
- ការរក្សាការសម្ងាត់វិជ្ជាជីវៈក្នុងធុរកិច្ច
- ប្រើប្រាស់មូលធិនិ ទ្រព្យសកម្ម និងព័ត៌មានក្រុមហ៊ុន
- ច្បាប់ការងារ និងគោលនយោបាយពាក់ព័ន្ធនានា
- វិន័យការងារ និងបទបញ្ជាផ្ទៃក្នុង
- ការរាយការណ៍ពីកំហុសឆ្គងរបស់អភិបាល និងបុគ្គលិកជាន់ខ្ពស់ដោយនិយោជិត (Whistle Blower)
- ការដោះស្រាយជម្លោះ
- ផ្សេងទៀត

**ខ. ការផ្សព្វផ្សាយក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ច**

ក្រមសីលធម៌របស់ក្រុមហ៊ុន គឺត្រូវបានបង្ហាញ តាមរយៈគេហទំព័ររបស់ក្រុមហ៊ុនហូលឌីង **https://pestech-international.com/code-of-conduct-0.**

**គ. យន្តការ និងនីតិវិធីតាមដានអនុវត្តក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ច**

ការបម្រើអតិថិជន និងទំនាក់ទំនងជាមួយអ្នកផ្គត់ផ្គង់ អ្នកលក់ និងអ្នកម៉ៅការ ផេសថិក ព្យាយាមផ្តោតការយក ចិត្តទុកដាក់លើផលប្រយោជន៍របស់អតិថិជនជាចម្បងជាជាងផលប្រយោជន៍ផ្ទាល់ដើម្បីលើកតម្កើងកេរ្តិ៍ឈ្មោះ និងទំនុកចិត្តលើក្រុមហ៊ុន។ ផេសថិក ប្តេជ្ញាផ្តល់ជូននូវផលិតផល និងសេវាកម្មប្រកបដោយប្រសិទ្ធភាព និង ភាពឥតខ្ចោះតាមលក្ខណៈសមធម៌។

ផថខ ជឿជាក់ថាក្រមសីលធម៌គឺជាមូលដ្ឋានក្នុងចំណោមគុណតម្លៃរួមដូចខាងក្រោមដែលមានសារៈសំខាន់ សម្រាប់ភាពជាអ្នកដឹកនាំផ្ទាល់ និងជាបុគ្គលមួយ **ដែលដឹកនាំផ្តល់ជូន និងបម្រើអ្នកដទៃះ**

| | | |
|---|---|---|
| *ស្មោះត្រង់/សុចរិត* | ៖ | *យើងជឿជាក់ថាចរិតលក្ខណៈ និងបញ្ជាក់ពីភាពវិជ្ជមាន និងគុណធម៌ ផ្សេងទៀតដូចជាភាពស្មោះត្រង់ ការជឿជាក់ និងសុចរិតភាពដែលជា ផ្នែកសំខាន់នៃចរិតរបស់យើង។* |
| *ស្មោះត្រង់* | ៖ | *យើងជឿជាក់ថាការកំណត់ចំពោះទំនាក់ទំនងជាវង្វង់ និងអន្តរកម្មឥទ្ធិ ពលសង្គម (ជំនឿចិត្ត និងភាពជឿជាក់) ហេតុដូច្នេះភាពជាអ្នកដឹកនាំ-ការប្តេជ្ញាចិត្តក្នុងកិច្ចសន្យា* |
| *សុច្ចរិតភាព* | ៖ | *យើងជឿជាក់ថាការប្តេជ្ញាចិត្តមិនរុញ្ញា និងអាចទាយបានដើម្បីគោរព សីលធម៌ និងគោលការណ៍ គឺជាផ្នែកមួយដ៏ធំ-នៃចរិយាសម្បត្តិល្អ ធ្វើអំពើល្អ និងត្រឹមត្រូវទោះបីមិនមាននរណាមើលឃើញក៏ ដោយ។* |
| *សមធម៌* | ៖ | *យើងជឿជាក់ថាស្ថានភាព ឋានៈនិងល័ក្ខខ័ណ្ឌសម្រាប់ការអនុវត្តច្បាប់ បទបញ្ញត្តិនិងយុត្តិធម៌។* |
| *យុត្តិធម៌* | ៖ | *យើងជឿជាក់ថាការទទួលបាននូវសីលធម៌/ការកែតម្រូវសីលធម៌ សនិ ទានភាព ច្បាប់ សមធម៌ និងយុត្តិធម៌។* |
| *ភាពត្រឹមត្រូវ* | ៖ | *យើងជឿជាក់ថាការយល់ឃើញអំពីភាពសមស្របនៃការអនុវត្តទំនាក់ទំនង បុគ្គល ច្បាប់ និងនីតិវិធី។* |
| *យកចិត្តទុកដាក់ចំពោះអ្នកដទៃ* | ៖ | *យើងជឿជាក់ថាលទ្ធភាពពិចារណាចំពោះអ្នកដទៃមុនខ្លួនយើង និង ផ្តល់ជូន អ្នកដទៃតាមរបៀបដែលយើងចង់ទទួលបាននូវការគោរពដែលមិនមែនដើម្បីយកឈ្នះ ការបោកបញ្ឆោត និងការសងសឹកឡើយ។* |

**ឃ. ប្រតិបត្តិការភាគីជាប់ពាក់ព័ន្ធ**

១. គោលនយោបាយប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ

ក្នុងនាមជាក្រុមហ៊ុនហូលឌីងនៃ ផថខ ក្រុមហ៊ុន PESTECH International Berhad បានចុះបញ្ជីលក់មូល បត្រនៅលើផ្សារមូលបត្រនៃប្រទេសម៉ាឡេស៊ី Bursa Malaysia Securities Berhad ផថខ គឺជាកម្មវត្ថុដែលតម្រូវ ឱ្យអនុលោមតាមបទបញ្ញត្តិពាក់ព័ន្ធនៃទីផ្សារគោលរបស់គណៈកម្មការមូលបត្រ Bursa Malaysia Securities Berhad ដែលរួមមានប្រតិបត្តិការភាគីពាក់ព័ន្ធជាមួយក្រុមហ៊ុនហូលឌីង ក្រុមហ៊ុនចម្រុះរួមក្រុមហ៊ុន បុត្រសម្ព័ន្ធភាគហ៊ុនិកធំ និងភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ អភិបាល/បុគ្គលិក និងគ្រួសាររបស់ពួកគេ។

# របាយការណ៍អភិបាលកិច្ចប្រចាំឆ្នាំ

## ផ្នែកទី ៣- ការអនុវត្តក្រមសីលធម៌សម្រាប់ការអនុវត្តធុរកិច្ច

២. ប្រតិបត្តិការសំខាន់ៗជាមួយភាគីជាប់ពាក់ព័ន្ធ

| ល.រ | ភាគីជាប់ពាក់ព័ន្ធ | ប្រភេទទំនាក់ទំនង | ប្រភេទប្រតិបត្តិការ | ឆ្នាំហិរញ្ញវត្ថុ ៣០ មិថុនា ២០២១ (០០០ ដុល្លារ អាមេរិក) |
|---|---|---|---|---|
| ១ | ក្រុមហ៊ុន ដាយអឹម៉ិន ផៅវ័រ លីមីធីត | បុត្រសម្ព័ន្ធ | សេវាកម្មប្រតិបត្តិការ និងថែទាំ | ១ ២៨៩ |
| ២ | PESTECH Sdn Bhd | បុត្រសម្ព័ន្ធ | តម្លៃកិច្ចសន្យាជាប់ការប្រាក់ | ២០ ១៩៣ ៤២ |
| ៣ | ENERSOL Co., Ltd | បុត្រសម្ព័ន្ធ | តម្លៃកិច្ចសន្យា (បង្វិល) ជាប់ | (៨៣) |
| ៤ | PESTECH Transmission Sdn Bhd | បុត្រសម្ព័ន្ធ | តម្លៃកិច្ចសន្យាជាប់ថ្លៃគម្រោង គ្រប់គ្រង | ៧២៦ ១៩២ |
| ៥ | ក្រុមហ៊ុន អូឌីអិម ផៅវ័រ ឡាញ ឯ.ក | បុត្រសម្ព័ន្ធ | ដំណើរការបង់ប្រាក់ | ១០ ០០០ |
| ៦ | PESTECH International Berhad | បុត្រសម្ព័ន្ធ | ការប្រាក់ថ្លៃគ្រប់គ្រង | ៥៦៥ ៣៧១ |
| ៧ | ក្រុមហ៊ុន ហ្គ្រីន សឺស្តែន ណេបិល វេនឈ័រ (ខេមបូឌា) ឯ.ក | បុត្រសម្ព័ន្ធ | ដំណើរការបង់ប្រាក់ | ២ ៥៩២ |

# របាយការណ៍អភិបាលកិច្ចប្រចាំឆ្នាំ

## ផ្នែកទី ៤ - ការគ្រប់គ្រងហានិភ័យ ការត្រួតពិនិត្យផ្ទៃក្នុង និងការធ្វើសវនកម្ម

### ក. សង្ខេបអំពីប្រព័ន្ធគ្រប់គ្រងហានិភ័យ ឬគោលនយោបាយគ្រប់គ្រងហានិភ័យ

ក្របខណ្ឌគោលនយោបាយគ្រប់គ្រងហានិភ័យរបស់ក្រុមហ៊ុន គឺគ្រប់គ្រងដោយគោលនយោបាយគ្រប់គ្រងហានិភ័យនៃសម្ព័ន្ធ PESTEDH International Berhad Group (The Group) និងគោលការណ៍ណែនាំ ដែលធានាថាការគ្រប់គ្រងហានិភ័យគឺស្របតាមបទប្បញ្ញត្តិមានទំនួលខុសត្រូវ និងគណនេយ្យភាពហើយត្រូវបានបញ្ជាក់យ៉ាងច្បាស់គ្រប់លំដាប់ថ្នាក់។

ក្របខណ្ឌគោលនយោបាយគ្រប់គ្រងហានិភ័យរបស់សម្ព័ន្ធមានធាតុសំខាន់ៗចំនួន៦ (ប្រាំមួយ) ដូចខាងក្រោមហើយរាល់ហានិភ័យចម្បងឬចំណុចខ្សោយលើការគ្រប់គ្រងហានិភ័យត្រូវបានកំណត់ វាយតម្លៃ រាយការណ៍តាមដាន និងកែតម្រូវយ៉ាងត្រឹមត្រូវទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាព៖

- យុទ្ធសាស្ត្រហានិភ័យ និងកម្រិតទទួលយកហានិភ័យ (Risk Strategy & Appetite)
- អភិបាលកិច្ចហានិភ័យ
- វប្បធម៌ហានិភ័យ
- ការវាយតម្លៃហានិភ័យ និងវាស់វែង
- ការគ្រប់គ្រង និងតាមដានហានិភ័យ
- ការរាយការណ៍ពីហានិភ័យ

អំឡុងឆ្នាំហិរញ្ញវត្ថុគណៈកម្មាធិការគ្រប់គ្រងហានិភ័យបានទទួលរបាយការណ៍គ្រប់គ្រងហានិភ័យសម្រាប់ឆ្នាំហិរញ្ញវត្ថុបញ្ចប់នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១។ ហានិភ័យប្រតិបត្តិការគម្រោង និងហានិភ័យគម្រោង ហិរញ្ញវត្ថុត្រូវបានកំណត់ដូចខាងក្រោម៖

i) ហានិភ័យប្រតិបត្តិការគម្រោង
- វឌ្ឍនភាពគម្រោងពុំយោងតាមកាលវិភាគគម្រោងដែលបានអនុម័តផ្ទៃក្នុង និងការរំពឹងទុករបស់អ្នកគ្រប់គ្រងឡើយ (កាលវិភាគហានិភ័យ)

ii) ហានិភ័យគម្រោងហិរញ្ញវត្ថុ
- ភាពខុសគ្នានៃការចំណាយចំពោះថ្លៃដើមថវិកា (ហានិភ័យថ្លៃដើម)
- ការពន្យារពេលទូទាត់របស់អតិថិជន និងពុំយោងតាមពេលកិច្ចសន្យាឡើយ (ហានិភ័យឥណទាន)
- វិក្កយបត្រពន្យារពេល និងពុំយោងតាមកាលវិភាគក្នុងកាលវិភាគមេឡើយ (ហានិភ័យឥណទាន)

ជារួម ពុំមានចំណុចហានិភ័យខ្ពស់ដល់គម្រោង និងប្រតិបត្តិការដែលកំពុងដំណើរការរបស់ ផថខ ក្នុងអំឡុងឆ្នាំហិរញ្ញវត្ថុឡើយ។

### ខ. សង្ខេបពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង

ធាតុសំខាន់ៗនៃប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងរបស់ក្រុមហ៊ុន ត្រូវបានសង្ខេបដូចខាងក្រោម៖

- **ស្ថានភាពគ្រប់គ្រង**

  សារៈសំខាន់នៃស្ថានភាពគ្រប់គ្រងដែលមានលក្ខណៈត្រឹមត្រូវបានបញ្ជាក់ឱ្យដឹងទូទាំងក្រុមហ៊ុន។ការផ្តោតលើស្ថានភាពគ្រប់គ្រងដែលមានលក្ខណៈត្រឹមត្រូវនេះត្រូវបានសង្កត់ធ្ងន់ទៅលើការបង្កើនគុណភាព និងសមត្ថភាពរបស់បុគ្គលិកតាមរយៈការផ្តល់ការអប់រំ និងការបណ្តុះបណ្តាលបន្តបន្ទាប់ស្តីពីជំនាញបច្ចេកទេសទាំងរឹង និងទន់ដូចជាការគ្រប់គ្រងហានិភ័យវិជ្ជាជីវៈ និងសុចរិតភាពដែលអាចត្រូវបានរៀបចំឡើងយូរៗម្តងទៅតាមតម្រូវការ។

- **រចនាសម្ព័ន្ធនៃការគ្រប់គ្រង**

  ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងបានបង្កើតរចនាសម្ព័ន្ធក្រុមហ៊ុនដោយបានកំណត់យ៉ាងច្បាស់នូវគណនេយ្យភាព និងអំណាចនៃសិទ្ធិដែលផ្ទេរជូន។ រចនាសម្ព័ន្ធនេះរួមបញ្ចូលទាំងទំនួលខុសត្រូវរបស់គណៈកម្មាធិការក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងផ្សេងៗ រួមទាំងវិសាលភាពនៃសិទ្ធិសម្រេចនូវរាល់កិច្ចការធុរកិច្ចទាំងអស់។

  ធាតុសំខាន់ៗនៃរចនាសម្ព័ន្ធគ្រប់គ្រងផ្ទៃក្នុងរបស់ក្រុមហ៊ុន គ្របដណ្តប់លើគោលការណ៍និង នីតិវិធីផ្សេងៗដែលបានចងក្រងជាឯកសារក្នុងគោលបំណងគ្រប់គ្រងលើដំណើរការធុរកិច្ចសំខាន់ៗ។ គោល ការណ៍ និងនីតិវិធីទាំងនេះត្រូវបានប្រើប្រាស់សម្រាប់ការធ្វើលទ្ធកម្មបច្ចេកវិទ្យាព័ត៌មាន សុខភាព និងសុវត្ថិភាព មូលធនមនុស្ស ការថែទាំទ្រព្យសកម្ម និងទំនាក់ទំនងជាមួយភាគីជាប់ពាក់ព័ន្ធ។ ការធ្វើលទ្ធកម្ម ការគ្រប់គ្រងឥណទាន ការរៀបចំទំនិញបញ្ចូលឃ្លាំងការគ្រប់គ្រងសាច់ប្រាក់ និងប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធកំពុងត្រូវបានកែប្រែ/ពិនិត្យឡើងវិញដើម្បីពង្រឹងដំណើរការគ្រប់គ្រងផ្ទៃក្នុង និងនីតិវិធីបន្ថែមទៀត។

# របាយការណ៍អភិបាលកិច្ចប្រចាំឆ្នាំ

## ផ្នែកទី ៤ - ការគ្រប់គ្រងហានិភ័យ ការត្រួតពិនិត្យផ្ទៃក្នុង និងការធ្វើសវនកម្ម

- សវនកម្មផ្ទៃក្នុង
- ផថខ បានប្រើប្រាស់សេវាខាងក្រៅពីក្រុមហ៊ុន HT & P Partners Co. Ltd. ("HTP") ដើម្បីធ្វើសវនកម្ម ត្រួតពិនិត្យផ្ទៃក្នុងរបស់ ផថខ។ ការត្រួតពិនិត្យផ្ទៃក្នុងនេះ នឹងរាយការណ៍ផ្ទាល់ទៅគណៈ កម្មាធិការ សវនកម្ម ("AC") អំពីភាព ពេញលេញនៃការប្រព័ន្ធ ត្រួតពិនិត្យផ្ទៃក្នុងនៃអង្គភាពប្រតិបត្តិការ និងវិសាល ភាពអនុលោមតាមដំណើរការ គោលនយោបាយ និងនីតិវិធី ច្បាប់ និងបទបញ្ញត្តិ ជាធរមាន។
- អំឡុងឆ្នាំហិរញ្ញវត្ថុ HTP បានធ្វើសវនកម្មលើដំណើរការលទ្ធកម្ម ការគ្រប់គ្រងគម្រោង និងបានធ្វើបទបង្ហាញអំពីលទ្ធផលនៃការធ្វើសវនកម្មលើចំណុចមួយចំនួនដូចខាងក្រោមនេះទៅ AC៖
- កំណត់ត្រាវាយតម្លៃអ្នកផ្គត់ផ្គង់
- ការវាយតម្លៃអ្នកផ្គត់ផ្គង់/អ្នកម៉ៅការបន្ត
- ការប៉ាន់តម្លៃ
- គោលនយោបាយ និងនីតិវិធីសម្រាប់ការទិញពីភាគីពាក់ព័ន្ធ
- ទម្រង់ស្នើទិញ
- ជារួម ការធ្វើសវនកម្មលើលទ្ធកម្ម និងការគ្រប់គ្រងគម្រោង គឺជានីតិវិធីចម្បងចំណែកហានិភ័យពាក់ព័ន្ធគឺមានកម្រិតទាប។

កំហុសនិង/ឬភាពខ្វះចន្លោះធ្ងន់ធ្ងរលើការគ្រប់គ្រងដែលបានសម្គាល់ឃើញពីការត្រួតពិនិត្យឡើងវិញនឹងត្រូវចងក្រងទុកជាឯកសារ និងត្រូវរាយការណ៍ដល់គណៈគ្រប់គ្រងដើម្បីធ្វើការត្រួតពិនិត្យឡើងវិញ និងចាត់ ចំណាត់ការកែតម្រូវ។ សវនករផ្ទៃក្នុងត្រូវរាយការណ៍ជូន AC អំពីការពុំអនុលោមតាមបទប្បញ្ញត្តិ ចំណុចខ្សោយនៃការគ្រប់គ្រងផ្ទៃក្នុង និងចំណាត់ការដែលធ្វើឡើងដោយគណៈគ្រប់គ្រងដើម្បីដោះស្រាយបញ្ហាសវនកម្មដែលបានរកឃើញ។
សវនផ្ទៃក្នុងត្រូវទទួលខុសត្រូវលើការធ្វើផែនការអនុវត្ត និងរាយការណ៍អំពីគ្រោងការណ៍ សវនកម្មផ្ទៃក្នុង និងសកម្មភាពផ្សេងៗរបស់ក្រុមហ៊ុន។

គ. ការធ្វើសវនកម្ម

សវនកម្មផ្ទៃក្នុង
កាតព្វកិច្ច និងការទទួលខុសត្រូវរបស់សវនករផ្ទៃក្នុង
- អភិវឌ្ឍផែនការសវនកម្មផ្ទៃក្នុងសម្រាប់ឆ្នាំជាប់ពន្ធនីមួយៗដើម្បីស្នើសុំការអនុម័តពីគណៈកម្មាធិការសវនកម្ម/ប្រធានក្រុមប្រឹក្សាភិបាល
- រៀបចំផែនការ សម្របសម្រួល និងអនុវត្តការងារសវនកម្ម
- បែងចែកធនធានសវនកម្មផ្ទៃក្នុងឲ្យបានគ្រប់គ្រាន់ និងសមស្របដើម្បីបំពេញការងារសវនកម្មបានទាន់ពេលវេលាដែលបានគ្រោងទុក
- បង្ហាញភ្លាមៗជូនបុគ្គលតំណាងរបស់ PCL អំពីបញ្ហាប្រឈម និងបញ្ហាដែលត្រូវបានជួបប្រទះក្នុងពេលធ្វើសវនកម្មដែលអាចរារាំង/ប៉ះពាល់លើលទ្ធផលសវនកម្ម
- បង្ហាញពីបញ្ហាដែលបានរកឃើញអំពីការត្រួតពិនិត្យលើការគ្រប់គ្រងផ្ទៃក្នុងជូនគណៈគ្រប់គ្រងនៅក្នុងកិច្ចប្រជុំតាម ឬតាមការតម្រូវរបស់គណៈកម្មាធិការសវនកម្ម
- សម្របសម្រួល/អនុវត្តការងារពិនិត្យតាមដានស្ថានភាពផែនការចំណាត់ការគ្រប់គ្រងបន្ទាប់ពីធ្វើការត្រួតពិនិត្យលើការគ្រប់គ្រងផ្ទៃក្នុង (ប្រសិនចាំបាច់)

សវនករខាងក្រៅ

| ល.រ | ឈ្មោះ ក្រុមហ៊ុន | សេវាកម្ម | កាលបរិច្ឆេទចុះ កិច្ចព្រមព្រៀង | កម្រៃសវនកម្ម (គិតជាដុល្លារ) | កម្រៃពុំមែន សវនកម្ម |
|---|---|---|---|---|---|
| ១ | ក្រុមហ៊ុន ហ្គ្រេន សនថុន (ខេមបូឌា) លីមីធីត | ពិនិត្យឡើងវិញនូវរបាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាស និងធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំ ឆ្នាំហិរញ្ញវត្ថុ ២០២១ | ១៤ តុលា ២០២០ | ៣២ ៥០០ | - |
| | | ជំនួយក្នុងការទទួលបានវិញ្ញាបនប័ត្រស្នាក់នៅស្របតាមកិច្ចព្រមព្រៀងបង់ពន្ធទ្វេនិងស្នើសុំអត្រាពន្ធកាត់ទុកកំរិតតិច | ១០ មេសា ២០២១ | - | ៦០០ |

# របាយការណ៍អភិបាលកិច្ចប្រចាំឆ្នាំ

## ផ្នែកទី ៥- ភាគីពាក់ព័ន្ធ

**ផថខ** ផ្តល់អាទិភាពសំខាន់លើផ្នែកសុខភាពរបស់បុគ្គលិក។ ផថខ ប្តេជ្ញាការពារសុវត្ថិភាព និងសុខភាពរបស់បុគ្គលិក និងអ្នកពាក់ព័ន្ធនៅគ្រប់ទីកន្លែងដែលពួកគេធ្វើការ។ គោលនយោបាយ នីតិវិធីស្តីពីសុខភាព និង សុវត្ថិភាពការងារស្របតាម ISO 4500: 2018 ការគ្រប់គ្រងសុខភាព និងសុវត្ថិភាពការងារឆ្នាំ២០១៨ ត្រូវបានបង្កើតឡើងដើម្បីពិនិត្យតាមដានស្ថានភាពសុវត្ថិភាព និងសុខភាពនៅកន្លែងធ្វើការរបស់យើង។

សម្ព័ន្ធក្រុមហ៊ុន ផេសថិក អនុវត្តប្រតិបត្តិការប្រចាំថ្ងៃស្របតាមស្តង់ដារប្រកបដោយគុណភាពខ្ពស់ដែលផ្តោតលើសារៈសំខាន់នៃការតាមដានស្ថេរភាព និងជំនឿចិត្តសម្រាប់ក្រុមហ៊ុនទាំងមូល។

ផ្នែកមួយនៃលក្ខខណ្ឌសុវត្ថិភាព និងសុខភាព ការវាយតម្លៃហានិភ័យ ការកំណត់អត្តសញ្ញាណហានិភ័យនិង ដំណើរការត្រួតពិនិត្យត្រូវបានកំណត់នៅក្នុងប្រតិបត្តិការអាជីវកម្ម និងត្រូវដាក់ឱ្យអនុវត្តហើយកត់ត្រាជាប្រព័ន្ធ។ ដំណើរការនេះជួយកំណត់អត្តសញ្ញាណគ្រោះថ្នាក់ដែលអាចកើតមាននៅក្នុងមជ្ឈដ្ឋានការងារដើម្បីផ្តល់នូវវិធានការត្រួតពិនិត្យដែលសមស្រប។

យើងបង្កើតវប្បធម៌បង្ការការពារដ៏រឹងមាំ រួមទាំងសុវត្ថិភាព សុខភាព និងសុខុមាលភាពនៅកន្លែងធ្វើការ គុណ ភាពសុខសុវត្ថិភាព និងបរិស្ថាន (“QHSE”) របស់យើងរួមចំណែក និងអប់រំបុគ្គលិកជាប្រចាំ។ កម្មវិធីបណ្តុះ បណ្តាល និងចំណេះដឹងបានធ្វើឡើងដើម្បីផ្តល់ជូនដល់បុគ្គលិក និងអ្នកម៉ៅការ រម៉ៅការបន្ត (បើចាំបាច់) នូវ ព័ត៌មានពាក់ព័ន្ធនិងថ្មីៗដើម្បីបំពេញកាតព្វកិច្ចផ្នែកសុវត្ថិភាព និងសុខភាព។

### សុខុមាលភាពអតិថិជន និងការជ្រើសរើសអ្នកផ្គត់ផ្គង់ និងអ្នកម៉ៅការបន្ត

ម្យ៉ាងវិញទៀត ក្នុងនាមជាអ្នកម៉ៅការ EPCC ផថខ បានដាក់ចេញនូវគោលនយោបាយលទ្ធកម្ម របស់សម្ព័ន្ធក្រុមហ៊ុន ដើម្បីធានាដល់ការជ្រើសរើសអ្នកផ្គត់ផ្គង់ និងអ្នកម៉ៅការបន្តដែលត្រូវអនុវត្តដោយផ្អែកលើរយៈពេលកំណត់ដោយអនុលោមតាមច្បាប់ បទបញ្ញត្តិគ្រប់គ្រងពន្ធ និងប្រតិបត្តិការភាគីពាក់ព័ន្ធ។

### ការប្រឆាំងអំពើពុករលួយ

គោលនយោបាយប្រឆាំងអំពើពុករលួយ និងសូកប៉ាន់នៃសម្ព័ន្ធក្រុមហ៊ុនបានចែងថាពុំមានការអនុគ្រោះដែលឈានទៅរកអំពើសូកប៉ាន់ ឬពុករលួយឡើយ។ អំពើសូកប៉ាន់ និងពុករលួយគ្រប់ទម្រង់ដែលទាក់ទង នឹងសកម្មភាពអាជីវកម្មត្រូវបានហាមឃាត់យ៉ាងតឹងរ៉ឹង។ ដំណើរការអភិបាលកិច្ចសម្រាប់ប្រតិបត្តិការប្រចាំថ្ងៃ ក្នុងមុខងារអាជីវកម្មដែលមានការត្រួតពិនិត្យ និងតុល្យភាពគ្រប់គ្រាន់ដើម្បីបណ្តុះបណ្តាលសុច្ចរិតភាពការងារ ។ និយោជិតមិនត្រូវផ្តល់ដោយផ្ទាល់ ឬតាមរយៈភាគីខាងក្រៅនូវការសន្យា ការផ្តល់ សិទ្ធិអនុញ្ញាត សំណើ ឬទទួលយកផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុ ឬប្រយោជន៍ផ្សេងដ៏ទៃទៀតដើម្បីទទួលបានការរក្សាអជីវកម្ម ឬផល ប្រយោជន៍ផ្ទាល់ខ្លួនដែលប្រព្រឹត្តិមិនត្រឹមត្រូវដល់ការធ្វើអាជីវកម្មឡើយ។ ការឧស្សាហ៍ព្យាយាមសមស្រប នឹងត្រូវអនុវត្តនៅពេល ផថខ រួមចំណែកជាមួយភាគីទីបី ដូចជាភ្នាក់ងារ អ្នកចែកចាយ ឬដៃគូបណ្តាក់ទុន សម្រាប់ការរៀបចំអាជីវកម្មដើម្បីធានាបានថាពួកគេនឹងមិនប្រព្រឹត្តអំពើពុករលួយ និងតាមដានការអនុវត្តរបស់ ពួកគេជាប្រចាំដើម្បីធានាបាននូវការអនុលោមភាពបន្ត។ ផថខ នឹងប្តេជ្ញាអនុវត្តសកម្មភាពប្រកបដោយវិជ្ជាជីវៈ យុត្តិធម៌ សុច្ចរិតភាព និងសមធម៌នូវរាល់ទំនាក់ទំនងអាជីវកម្មគ្រប់ទីកន្លែងដែលយើងដំណើរការអនុវត្ត និង ពង្រឹងប្រព័ន្ធប្រកបដោយប្រសិទ្ធភាពដើម្បីការពារ ឬប្រឆាំងការសូកប៉ាន់ និងអំពើពុករលួយ។

### ការការពារបរិដ្ឋាន

ផថខ ប្តេជ្ញាការពារបរិស្ថាន និងគោរពតាមច្បាប់/បទបញ្ញត្តិបរិស្ថានជាធរមាន។ ដោយផ្អែកលើឯកសារយោងនៃសម្ព័ន្ធក្រុមហ៊ុន ផថខ បានអនុវត្តការកំណត់អត្តសញ្ញាណនិងការវាយតម្លៃផលប៉ះពាល់បរិស្ថាន (“EAIA”) ដោយផ្អែកលើប្រព័ន្ធគ្រប់គ្រងបរិស្ថានអន្តរជាតិ ISO 14001:2015 ដើម្បីកំណត់និងវាយ តម្លៃស្ថានភាព និងផលប៉ះពាល់បរិស្ថានទាក់ទងនឹងសកម្មភាពអង្គភាពផលិតផល និងសេវាកម្មរៀងៗខ្លួន។

អំឡុងពេលវាយតម្លៃនៃផលប៉ះពាល់គម្រោង ផថខ នឹងពិចារណាលើច្បាប់និងបទបញ្ញត្តិបរិស្ថាន ពាក់ព័ន្ធ ផលវិបាក បញ្ហាធ្ងន់ធ្ងរ និងលទ្ធភាពនៃការកកើតបញ្ហា។ ការវាយតម្លៃពីផលប៉ះពាល់សំខាន់ៗត្រូវបានវាយតម្លៃដោយផ្អែកលើលក្ខណៈវិនិច្ឆ័យបានកំណត់។ ជាឧទាហរណ៍ទំហំនៃភាពធ្ងន់ធ្ងរ/ហានិភ័យរយៈពេលប៉ះពាល់ លទ្ធភាពកកើត។ល។ លទ្ធផលនៃការវាយតម្លៃ ផថខ នឹងរៀបចំផែនការសកម្មភាព និងការត្រួតពិនិត្យឱ្យមានប្រសិទ្ធភាពដើម្បីកាត់បន្ថយផលប៉ះពាល់សំខាន់ៗនោះ។

### អន្តរកម្មសហគមន៍

ផថខ ជឿជាក់ថាការទទួលបាននូវបរិក្ខារអគ្គិសនីមានសារៈសំខាន់ណាស់ក្នុងការបំបែកវដ្តភាពក្រីក្រនៅប្រទេសកម្ពុជា។ ស្របតាមរដ្ឋាភិបាលកម្ពុជាកំពុងខិតខំប្រឹងប្រែងឥតឈប់ឈរដើម្បីបង្កើតហេដ្ឋារចនាសម្ព័ន្ធអគ្គិ សនីក្នុងការផ្តល់លទ្ធភាពប្រើប្រាស់អគ្គិសនីដល់សហគមន៍ជនបទ។ PESTECH បានដើរតួយ៉ាងសំខាន់ ក្នុងការនាំយកហេដ្ឋារចនាសម្ព័ន្ធថាមពលអគ្គិសនីមកកាន់សហគមន៍នៃប្រទេសកម្ពុជាចាប់តាំងពី ឆ្នាំ២០១២។

ច្រើនឆ្នាំមកនេះ ផថខបានបញ្ចប់គម្រោងសំខាន់ៗជាច្រើនដោយជោគជ័យរួមទាំងគម្រោងបញ្ជូន ភ្នំពេញ-កំពង់ចាម គម្រោងប្រព័ន្ធបញ្ជូន ២៣០kv កំពង់ចាម-ក្រចេះ និងគម្រោងប្រព័ន្ធបញ្ជូន ២៣០kv និង ៥០០ kv ភ្នំពេញ-ព្រះសីហនុ។

# របាយការណ៍អភិបាលកិច្ចប្រចាំឆ្នាំ

## ផ្នែកទី ៥- នាទីពាក់ព័ន្ធ

ការបញ្ចប់គម្រោងខាងលើនេះបានផ្តល់ឱ្យមានការតភ្ជាប់ចរន្តអគ្គិសនីទៅតាមតំបន់ជនបទដែលមានប្រជាជនរស់នៅ។ខណៈពេលដែលការបរិច្ចាគប្រាក់ត្រូវបានឱ្យតម្លៃយើងជឿថាស្នូលសំខាន់ពិតប្រាកដនៃការទទួលខុសត្រូវសង្គមគឺស្ថិតនៅពីក្រោយមូលហេតុដែលមានអត្ថន័យសម្រាប់ អាជីវកម្មរបស់យើង។ មតិយោបល់ដែលយើង ប្រមូលបានតាមរយៈការចូលរួមជាមួយអ្នកភូមិអំពីរបៀបតភ្ជាប់អគ្គិសនីបាននាំមកនូវការផ្លាស់ប្តូរយ៉ាងធំដល់ជីវិតរបស់ពួកគេគឺជាសេចក្តីប្រាថ្នា និងការលើកទឹកចិត្ត។ ផថខ សម្លឹងមើលការពង្រីកបុព្វហេតុ ល្អទៅកាន់សហគមន៍កាន់តែជាច្រើននៅជុំវិញតំបន់ខណៈពេលការធ្វើអាជីវកម្មរបស់យើងប្រកបដោយនិរន្តរភាព។

អំឡុងពេលនៃជំងឺរាតត្បាត ពុំបានបញ្ឈប់ ផថខ បន្តកម្មវិធី CSR របស់ខ្លួនដែលផ្តោតលើគោលការណ៍ (៤) យ៉ាងរួមមាន មូលដ្ឋានថែរក្សាសហគមន៍ ការអភិវឌ្ឍន៍ ការស្តារឡើងវិញ និងបរិស្ថានដូចខាងក្រោម៖

| ល.រ | អ្នកទទួលផលប្រយោជន៍ | ចំនួន | គោលបំណង CSR |
|---|---|---|---|
| ១ | កាកបាទក្រហមកម្ពុជា | ២៥ ០០០.០០ ដុល្លារអាមេរិក | **ឈ្មោះគម្រោង៖**<br>ជាមួយនឹង កាកបាទក្រហមកម្ពុជា ប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ -១៩ និងបង្កើតភាពសាំនៃសង្គមកម្ពុជា<br>**គោលបំណង៖**<br>បម្រើសេកម្មភាពសប្បុរសធម៌ក្នុងការជួយដល់ប្រជាពលរដ្ឋដែលកំពុងជួបគ្រោះធម្មជាតិ និងគ្រោះផ្សេងៗ។ |
| ២ | កងយោធពលខេមរភូមិន្ទ | ៦៨៥០ ដុល្លារអាមេរិក | **ឈ្មោះគម្រោង៖**<br>ប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ -១៩<br>**គោលបំណង៖**<br>គាំទ្រដល់កងកម្លាំងប្រដាប់អាវុធដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ -១៩ និងផ្តល់នូវគ្រែកម្រាលពូកពូកខ្នើយ និងភួយ ចំនួន ១០០ ឈុត។ |



# របាយការណ៍អភិបាលកិច្ចប្រចាំឆ្នាំ

## ផ្នែកទី ៦ - ការបង្ហាញព័ត៌មាន និងតម្លាភាព

ក. បង្ហាញអំពីព័ត៌មានក្នុងរបាយការណ៍ប្រចាំឆ្នាំដូចខាងក្រោម៖

| ល.រ | ព័ត៌មាន | មាន/គ្មានបង្ហាញ |
|---|---|---|
| ១ | ចក្ខុវិស័យ/ បេសកម្ម/ គោលដៅអាជីវកម្ម | មាន |
| ២ | សូចនាករហិរញ្ញវត្ថុ | មាន |
| ៣ | សូចនាករមិនមែនហិរញ្ញវត្ថុ | មាន |
| ៤ | កត្តាហានិភ័យសំខាន់ៗ | មាន |
| ៥ | គោលនយោបាយភាគលាភ | មាន |
| ៦ | ជីវប្រវត្តិរបស់អភិបាល | មាន |
| ៧ | ការបណ្តុះបណ្តាលសម្រាប់អភិបាល | មាន |
| ៨ | ចំនួនកិច្ចប្រជុំក្រុមប្រឹក្សាភិបាល | មាន |
| ៩ | វត្តមានរបស់អភិបាលក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល | មាន |
| ១០ | លាភការ ឬប្រាក់បំណាច់សម្រាប់អភិបាល និងបុគ្គ លិកជាន់ខ្ពស់ | មាន |

### ពិពណ៌នាអំពីយន្តការនៃការបង្ហាញព័ត៌មានដោយរៀបរាប់ពីមធ្យោបាយ នីតិវិធី និងបុគ្គលិកទទួលបន្ទុកផ្តល់ ព័ត៌មាន

**ក្រុមប្រឹក្សាភិបាលដែលមានជំនួយពីបុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មានត្រូវទទួលខុសត្រូវដូចខាងក្រោម៖**

ក) ត្រូវកំណត់ថាតើព័ត៌មានណាជាព័ត៌មានដែលមានលក្ខណៈជាសារវ័ន្ត យោងតាមច្បាប់ និងបទប្បញ្ញត្តិ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (ផ.ម.ក) និងនិយ័តករមូលបត្រកម្ពុជា (ន.ម.ក.)

ខ) ត្រូវធានាថាព័ត៌មានទាន់ពេលដែលមានលក្ខខណៈជាសារវ័ន្តគឺត្រូវបង្ហាញទាន់ពេលដល់វិនិយោគិនសា ធារណៈយោងតាមច្បាប់ និងបទប្បញ្ញត្តិ របស់ (ផ.ម.ក) និង (ន.ម.ក.)

គ) ត្រូវឆ្លើយតបទាន់ពេលពាក់ព័ន្ធនឹងពាក្យចចាមអារ៉ាម ឬការរាយការណ៍ និងសកម្មភាពទីផ្សារដែលខុសប្រក្រតី។

បន្ទាប់ពីបានការអនុញ្ញាតជាមុនពីក្រុមប្រឹក្សាភិបាលបុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មានអាចផ្តល់ព័ត៌មានទៅសារព័ត៌មាន សមាគមវិនិយោគិន និងបុគ្គលខាងក្រៅ រួមទាំងព័ត៌មានដែលត្រូវផ្សព្វផ្សាយនៅលើគេហទំព័ររបស់ក្រុម ហ៊ុននៅផ្នែកទំនាក់ទំនងវិនិយោគិន។

### ទំនាក់ទំនងវិនិយោគិន

នាយកប្រតិបត្តិ លោក Charles Tan មានភារកិច្ចត្រួតពិនិត្យសកម្មភាពអភិវឌ្ឍន៍សាជីវកម្មសម្រាប់ ផថខ ដែលពាក់ព័ន្ធនឹងទំនាក់ទំនងវិនិយោគិន។ លោក បានរួមចំណែកជានិច្ចជាមួយអ្នកវិភាគ អ្នកគ្រប់គ្រងមូលនិធិ និងអ្នកពាក់ព័ន្ធដទៃទៀតដើម្បីលើកកម្ពស់សក្តានុពលកំណើនសាជីវកម្មរបស់ ផថខ ព្រមទាំងធ្វើបច្ចុប្បន្ន ភាពជាប្រចាំជាមួយការអភិវឌ្ឍន៍ថ្មីៗរបស់ក្រុមហ៊ុន។

គេហទំព័រ PCL www.pestech.com.kh មានតួនាទីជាបណ្តាញទំនាក់ទំនងសំខាន់សម្រាប់ភាគហ៊ុនិក វិនិយោ គិនសាធារណៈ និងអ្នកពាក់ព័ន្ធផ្សេងទៀតក្នុងការទទួលបានព័ត៌មានដែលបានធ្វើបច្ចុប្បន្នភាពព័ត៌មានពាក់ព័ន្ធ នឹងសកម្មភាពរបស់ក្រុមហ៊ុន លទ្ធផលហិរញ្ញវត្ថុ ការអភិវឌ្ឍយុទ្ធសាស្ត្ររបស់ក្រុមហ៊ុន និងបញ្ហាផ្សេងទៀតដែលប៉ះពាល់ដល់ផលប្រយោជន៍របស់ភាគីពាក់ព័ន្ធ។

WWW.PESTECH.COM.KH


OFFICE ADDRESS:

No. 6, Street No. 588
Sangkat Boeung Kok 2,
Khan Toul Kork, Phnom Penh,
Kingdom of Cambodia.


OUR PROJECTS/PRODUCTS REACH:

• Australia • Brunei • Cambodia • China • Ghana • Indonesia • Iraq • Kyrgyzstan • Malaysia • Mali • Myanmar • Papua New Guinea • Philippines • Singapore • South Africa • Sri Lanka • Tanzania • Thailand • Vietnam